ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៩

លេខ ៨.៩. រួមគ្នា

ក្រសួងសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម




ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨០

គ. ស. ១៩៣៧

ក្រុមជំនុំទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


ទំព័រ

១ ខេមាខេមសរណកថា ( សំដែងពីវិធីដល់ព្រះត្រៃសរណគមន៍ ) ព្រះមហាពិទូរ-
ក្រសេម រៀបរៀង . . . . . . . . . . . . . . . . . . . . . ១៣៣

២ គាថាធម្មបទ ប្រែ . . . . . . . . . . . . . . . . . . . . . . ១៩១

៣ ច្បាប់ប្រដៅជនប្រុស-ស្រី របស់ក្រមង៉ុយ (ចប់) . . . . . . . . . . . ២០៥

៤ រឿងកុហក ៤ នាក់ . . . . . . . . . . . . . . . . . . . . . ២២១


# រូបក្រៅរឿង


១ រូបនាងដី ភូមា កំពុងចេញទៅគោចរបិណ្ឌបាត . . . . . . . . . . . ១៣១

២ លោកសង្ឃភូមា កំពុងមើលធម៌ក្នុងក្រាំង ដែលធ្វើដោយកំណាត់បីពរ ខ្ទុកម្រាក់ ២០៣

# TABLE DES MATIÈRES

I. Khemā-Khema Saraṇakathā ........................ 133

II. Gāthādhammapada traduit du Pali en Cambodgien ....... 151

III. Conseils aux hommes et femmes par Krom Ngoy........ 205

IV. Les quatre menteurs ............................ 221

## HORS TEXTE:

I. Bonzesse birmane s'en allant quêter Mandalay.......... 131

II. Bonze birman lisant le livre sacré fait à l'aide de vieux manteaux des bonzes ................ 203



នាងភិក្ខុនី (ឬយាយជី) ភូមា កំពុងចេញទៅគោចរបិណ្ឌបាត ។

ទំមាទំមសរណគាថា

ព្រះមហាពិទូរ ក្រសេម គន្ធរបនបណ្ឌិត

រៀបរៀង (ត)

ក៏ការដែលនឹងឈ្មោះថា "ដល់នូវលោកិយសរណគមន៍" មិនមែនសម្រេចដោយសំដីថា ដល់ៗប៉ុណ្ណោះទេ តោងប្រកបដោយអង្គ ៣ ប្រការ គឺ ១- សទ្ធា សេចក្ដីជឿជាក់ឥតលំអៀងក្នុងវត្ថុទាំង ៣ ប្រការ, ២- សម្មាទិដ្ឋិ បញ្ញាឃើញពិតឃើញប្រពៃក្នុងគុណនៃព្រះរតនត្រ័យ ហើយយឹតយកមកជាអារម្មណ៍, ៣- ជីវិតបរិច្ចាគ បរិច្ចាគជីវិតបំពោះព្រះរតនត្រ័យ សម្រេចដោយកាយនឹងវាចាគោរពប្រពៃ ដោយអាការឯណានីមួយមានអត្តសន្និយ្យាតនជាដើម, កាលប្រកបព្រមដោយអង្គ ៣ ប្រការនេះហើយ សូម្បីសមាទានកាន់យកតែម្ដង ក៏ឈ្មោះថាកាន់យកដោយប្រពៃ មិនបាច់សមាទានទៀតក៏បាន កាលបុគ្គលមកឃើញប្រយោជន៍ក្នុងការដល់នូវព្រះត្រ័យសរណគមន៍ គប្បីញ៉ាំងអង្គ ៣ ប្រការនេះឲ្យកើតឡើងបរិបូណ៌ក្នុងសន្តាន ហើយសមាទានកាន់យកនូវព្រះត្រៃសរណគមន៍ជាសរណទីពឹងឲ្យត្រឹមត្រូវតាមរបៀបដូចជានឹងថ្លែងតទៅនេះ ។

របៀបពាក្យដែលទេវតានឹងមនុស្សទាំងឡាយ មានព្រះពុទ្ធបសេនទិកោសលនឹងព្រះបាទអជាតសត្រូវជាដើម ថ្វាយ

ខ្ទនបំពោះព្រះភក្ត្រព្រះបរមសាស្តាក្នុងពុទ្ធសម័យ ដោយភាសាបាលីដូច្នេះ "ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច, ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ" ប្រែថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់នេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះដ៏មានព្រះភាគប្ញចាំទុកនូវខ្ញុំម្ចាស់ថា ជាឧបាសកដល់នូវព្រះរតនត្រ័យជាសរណៈស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើមទៅ ។ វេលានេះព្រះអង្គបរិនិព្វានទៅហើយ កាលបុគ្គលប្រាថ្នានឹងបូជាដោយឧបដិបត្តិ តាមពាក្យដែលមានមកក្នុងបាលីនោះក៏បាន គឺគប្បីចូលទៅកាន់ទីព្រះបដិមាករឬព្រះស្តូបចេតិយដែលបញ្ចុះព្រះសារីរិកធាតុជាដើម នឹករំឭកនូវពុទ្ធ-គុណដោយគោរព ហើយពោលពាក្យបាលីនោះចុះ ដោយគិតថា ក្រាបទូលដល់សម្តេចព្រះដ៏មានព្រះភាគក៏គួរ បានឈ្មោះថា សមាទាននូវសរណគមន៍ដោយពិត បើមិនធ្វើដូច្នេះសោត នឹងទៅពោលក្នុងសំណាក់ព្រះភិក្ខុសង្ឃតាំងពី ៤ អង្គឡើងទៅក្តី ក្នុងសំណាក់នៃគណៈ គឺភិក្ខុ ២ អង្គ ៣ អង្គក្តី

ឬក្នុងសំណាក់នៃបុគ្គល គឺភិក្ខុ ១ អង្គក្តីក៏គួរទាំងអស់ តែត្រូវផ្លាស់ពាក្យត្រង់កណ្តាល គឺ ភន្តេ ជាអាទិ ចេញ ឲ្យបញ្ចូលពាក្យដទៃជំនួសតាមសមគួរ គឺបើពោលក្នុងសំណាក់សង្ឃឲ្យដាក់ពាក្យថា សង្ឃោ ជាដើម ។ល។ បើពោលក្នុងសំណាក់គណៈថា អយ្យា ជាដើម ។ បើពោលក្នុងសំណាក់បុគ្គលថា អយ្យោ ជាដើម ហើយសូត្របំពេញតទៅទាល់តែចប់ ដូចពោលហើយខាងដើម មួយទៀត នឹងពោលក្នុងសំណាក់នៃវិញ្ញូជនដែលធ្លាតតិបក្តីច្រើនក្តីដោយមិនចំពោះ គប្បីផ្លាស់បទនោះជា ភោន្តោ ជាដើម ។ល។ ឬ តុម្ហេ ជាដើម ។ល។ ដូច្នេះក៏គួរ បើស្រ្តីនឹងធ្វើដូច្នេះផង គប្បីផ្លាស់បទគឺឧបាសកំនោះចេញ បញ្ចូលបទគឺ ឧបាសិកំ ជំនួសត្រង់នោះបុះ ពាក្យសមាទានជាបាលីបែបនេះ មានមកក្នុងព្រះសូត្រជាច្រើនអន្លើចំពោះជាពាក្យសមាទានរបស់គ្រហស្ថមួយពួក គ្រហស្ថកាលសមាទាននឹងពោលតែម្តង ឬនឹងពោលប្រែដែលដល់ទៅ ៣ ដងក៏គួរ តែគប្បីថែមក្នុងខាងដើមក្នុងវារៈទី ២ ថា ទុតិយម្បាហំ ភន្តេ ។ល។ វារៈទី ៣ ថា តតិយម្បាហំ ភន្តេ ។ល។

បំណែកឯព្រះអដ្ឋកថាចារ្យ សំដែងអាការដែលនឹងដល់នូវព្រះត្រៃសរណគមន៍ទុកក្នុងអដ្ឋកថានៃសាមញ្ញផលសូត្រ ភយភេរវសូត្រ នឹងគម្ពីរខុទ្ទកបាលី គម្ពីរសារសង្គហ ទាំង ៤ អន្លើនេះមានសេចក្ដីដូចគ្នា "តយិទំ ចតុធា វទ្ធតិ" លោកិយសរណគមន៍ គឺចេតនាដែលញាំងវាចាឲ្យបន្លឺឡើងនោះ រមែងសម្រេចដោយអាការ ៤ ប្រការឯណានីមួយ ក៏វាចាដែលបន្លឺចេញមកនោះនឹងដូចក្នុងបាលីក្ដី មិនដូចក្ដី មិនជាប្រមាណ កាលប្រកបដោយអាការ ៤ ឯណានីមួយហើយ ក៏ជាសរណគមន៍ដោយពិត ៗ ក៏ឯអាការទាំង ៤ នោះគឺ "អត្តសន្និយ្យាតនំ ច" ប្រគល់ថ្វាយខ្លួនដល់ព្រះរតនត្រ័យប្រការ ១ "តប្បរាយនតា ច" អធិដ្ឋានចំពោះព្រះរតនត្រ័យ ឲ្យប្រព្រឹត្តទៅខាងមុខប្រការ ១ "សិស្សភាវូបគមោ ច" ចូលទៅជិតដល់នូវភាវជាសិស្សស្ដាប់ឱវាទប្រការ ១ "បណិបាតោ ច" ប្រព្រឹត្តគោរពឱនលំទោនក្រែពេក ដោយអភិវាទកម្ម នឹងសាមីចិកម្មតាមសមគួរប្រការ ១ ៗ អាការទាំង ៤ នេះជាប្រមាណក្នុងការដល់សរណគមន៍ ហើយព្រះអដ្ឋកថាចារ្យសំដែងឧទាហរណ៍ដ៏សម

គួរដល់អាការទាំង ៤ នេះទុកថា បើបុគ្គលឯណាប្រកបដោយសទ្ធានឹងបញ្ញាដូចពោលហើយ ហើយថ្វាយខ្លួនដល់ព្រះរតនត្រ័យដោយពាក្យថា "អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ ពុទ្ធស្ស និយ្យាទេមិ ។ ល ។ ធម្មស្ស ។ ល ។ សង្ឃស្ស និយ្យាទេមិ" ដូច្នេះ អាការនៃបុគ្គលនោះឈ្មោះថា អត្តសន្និយ្យាតនាការ ប្រែថា "ខ្ញុំម្ចាស់ប្រគល់ថ្វាយនូវខ្លួន នូវជីវិតដល់ព្រះពុទ្ធជាម្ចាស់ ផ្ដើមនូវថ្ងៃនេះជាដើមទៅ" ក្នុងបទព្រះធម៌ ព្រះសង្ឃក៏ឲ្យប្រែដូចគ្នា ផ្លាស់តែនាមព្រះធម៌ ព្រះសង្ឃប៉ុណ្ណោះ ។ បទគឺ អត្តានំ ពោលសម្រាប់បុគ្គលខ្លៅមានបញ្ញាទន់ទាប ដែលសំគាល់ជីវិតថាជាខ្លួនតាមលោកវិស័យ មិនយល់ក្នុងធិវិសាសនយុត្តិ ។ បទគឺ ជីវិតំ ជាសេចក្ដីត្រង់នឹងសភាវធម៌ សមគួរដល់បុគ្គលមានបញ្ញាក្លាដឹងសាសនយុត្តិភាព កាលបើនឹងពោលដោយផ្លូវបរមត្ថ ពាក្យថា "អត្តសន្និយ្យាតន ប្រគល់ថ្វាយខ្លួន" នេះ បានឹងកិរិយាប្រគល់ថ្វាយជីវិតនេះឯង ទោះបីជីវិតនឹងស្លាប់បង់ក៏មិនលះបង់នូវព្រះរតនត្រ័យ នេះពោលសំដៅសេចក្ដីបំណងក្នុងខនេះ សូម្បីពាក្យដទៃ ៗ ដែលបុគ្គល

ពោលជាភាសាបាលីក្តី ភាសារបស់ខ្លួនក្តី ដែលសម្រេចនូវអត្ថដូច្នេះក៏ឈ្មោះថា អត្តសន្និយ្យាតនទាំងអស់ អាការនេះសមនឹងពាក្យដែលពោលក្នុងព្រះបាលី គឺ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។

ក្នុងតប្បរាយនតាការទី ២ នោះមានឧទាហរណ៍ថា "អជ្ជ អាទឹ កត្វា អហំ ពុទ្ធបរាយនោ ឥតិ មំ ធារេថ ។ល។ ធម្មបរាយនោ ។ល។ សង្ឃបរាយនោ ឥតិ មំ ធារេថ" ប្រែថា "ខ្ញុំម្ចាស់ជាអ្នកមានព្រះពុទ្ធជាទីទៅខាងមុខ ធ្វើនូវថ្ងៃនេះជាដើមទៅ, សូមលោកទាំងឡាយប្ដូរចាំទុកនូវខ្ញុំម្ចាស់ដូច្នេះ" ក្នុងបទព្រះធម៌ព្រះសង្ឃក៏ឡប្រែដូច្នេះ ទោះបីពាក្យដទៃៗ ដែលសំដែងនូវអត្ថថា ជាទីពឹង, ជាទីអាស្រ័យ, ជាទីរេះវាងភ័យក៏សង្គ្រោះចូលក្នុងអាការនេះទាំងអស់ អាការនេះសមនឹងព្រះបាលីគឺ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ។

ក្នុងសិស្សភាវូបគមនាការទី ៣ មានឧទាហរណ៍ថា "អជ្ជ អាទឹ កត្វា ពុទ្ធស្ស អន្តេវាសិកោ (ឬ ឧវាទការកោ) ឥតិ

មំ ធារេថ" ប្រែថា "ខ្ញុំម្ចាស់សូមជាសិស្សនៃព្រះពុទ្ធ ធ្វើនូវថ្ងៃនេះជាដើមទៅ, សូមលោកទាំងឡាយចូរចាំទុកនូវខ្ញុំម្ចាស់ដូច្នេះ" អាការនេះរួមនឹងបាលីថា "ឧបាសកំ មំ ភគវា ធារេថ" ពាក្យទាំង ៣ អន្លើដែលពោលមកហើយ ជាអាការដ៏មានកំលាំងក្លា ប្រព្រឹត្តទៅត្រង់ដល់ព្រះរតនត្រ័យ សំរេចនូវភាវជាឧបាសកដោយពោលអស់វារៈតែម្តងដោយពិត ។

ក្នុងបាណិបាតនាការទី ៤ គឺប្រព្រឹត្តឱនលំទោនសំរេចជាសរណាគមន៍នោះ ដោយអំណាចបុគ្គលមានចិត្តមូលមួយក្នុងព្រះរតនត្រ័យថាជាវត្ថុដ៏ប្រសើរវិសេស ហើយទើបធ្វើនូវអភិវាទកម្មក្រាបសំពះគោរពលំអុតឱនលំទោនដល់វត្ថុទាំង ៣ មិនគោរពវត្ថុដទៃឲ្យជាងនេះ កាលព្រមដោយកាយិកការស្មោះមែនៗ ហើយ វាចាក៏ពោលជាផ្លូវគោរពទំនងដូចគ្នានោះ ចិត្តក៏ជ្រះថ្លាទៅក្នុងផ្លូវនិព្វានគាមិនីបដិបត្តិ គឺឧបដិបត្តិដ៏ជាហេតុឲ្យបន្លុះព្រះនិព្វានដោយអាស្រ័យព្រះរតនត្រ័យហើយ ទើបសំរេចកើតជាសរណាគមន៍ ។ ពាក្យសមាទានវិធីដែលមកក្នុងបាលីនៃព្រះសូត្រនឹងអដ្ឋកថាដូចដែលសំដែងមកហើយ ខាងលើនេះ

ព្រះសង្គីតិកាចារ្យនឹងព្រះអដ្ឋកថាចារ្យលោកបង្គាប់ទុក ជាវិធីសម្រាប់ឧបាសកឧបាសិកា នឹងអ្នកចូលកាន់ព្រះពុទ្ធសាសន៍ ប្រើស្សូត្ររៀងរាបមកតាំងតែក្នុងពុទ្ធសម័យ ។

ក្នុងកាលឥឡូវនេះ ព្រះអាចារ្យក្នុងប្រទេសទាំងពួងឃើញថា វិធីនោះមិនគង់ទីបេះតែផ្លាស់ប្តូរបុះឡើង គឺហេតុអ្នកដែលមិនចេះអរិយកភាសា មិនអាចនឹងធ្វើឲ្យបរិបូណ៌បាន ទើបយកសរណគមនបាលិក្នុងព្រះវិន័យ ដែលសម្រាប់បំបួសសាមណេរ មកឲ្យឧបាសកឧបាសិកាប្រើស្សូត្រក្នុងវិធីដល់សរណៈ ឲ្យមានរបៀបដូចគ្នាទាំងអស់ គង់នៅជាបែបមួយមិនមានវេរុះ ព្រោះហេតុយល់ថា ដែលព្រះអដ្ឋកថាចារ្យទាំងឡាយអនុញ្ញាតទុកឲ្យប្រើបែបនេះ សឹងមានប្រាកដនៅក្នុងអដ្ឋកថាខុទ្ទកបាឋ នឹងសារត្ថសមុច្ច័យជាការសមគួរណាស់ អ្នកប្រាជ្ញទាំងឡាយកុំគាប្បីសន្និះថា លាយឡំទៅដោយបព្វជ្ជាវិធីឡើយ ព្រោះការបព្វជ្ជានៃសាមណេរមានទទួលសិក្ខាកាសារិពស្រ្តក្នុងដំបូង បំណែកឯឧបាសកឧបាសិកាគ្មានទទួលកាសារិពស្ត្រដូច្នេះ ។

ក៏សរណគមនបាលីនោះ  កាលដើមក្នុងបឋមពោធិសម័យ  សម្តេចព្រះបរមសាស្តាទ្រង់បញ្ជូនឲ្យព្រះអរហន្តទាំងពួងចេញទៅជួយប្រកាសពុទ្ធសាសនាក្នុងជនបទតូចធំទាំងឡាយ ទាំងទ្រង់ប្រទានអនុញ្ញាតឲ្យព្រះអរហន្តអម្បាលនោះបំបួសកុលបុត្រទាំងឡាយអ្នកត្រូវការបួស  ដោយឲ្យទទួលនូវបាឡីសរណគមន៍ គឺ ពុទ្ធំ សរណំ គច្ឆាមិ ។ល។ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ដោយហេតុមានប្រមាណប៉ុណ្ណេះ កុលបុត្រនោះក៏ជាភិក្ខុបរិបូណ៌ដោយចតុបារិសុទ្ធិសីល វិធីឧបសម្បទបែបនេះហៅថា សរណគមនូបសម្បទា  អំណើះតមកកាលព្រះសង្ឃមានចំនួនច្រើនឡើងហើយ ទ្រង់ឲ្យលើកលែងប្រើសរណគមនូបសម្បទានោះចេញ  ទ្រង់អនុញ្ញាតឲ្យព្រះសង្ឃបំបួសកុលបុត្រជាភិក្ខុដោយវិធីហៅថា  ញត្តិចតុត្ថកម្មវាចាជាជំនួស  ហើយទ្រង់អនុញ្ញាតឲ្យយកបាលីសរណគមន៍ទៅបំបួសកុលបុត្រជាសាមណេរវិញ  វេលាក្រោយព្រះថេរទាំងឡាយបានឲ្យគ្រហស្ថទាំងឡាយសមាទាននូវសរណគមនដោយសរណគមនបាលីនេះផងទៀត  ក្នុងគម្ពីរអដ្ឋកថាខុទ្ទកបាឋ  នឹងគម្ពីរសារត្ថសមុច្ចយ

ពោលថា សរណគមនបាលីទោះបីព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ជាវិន័យកម្មចំពោះការបព្វជ្ជាឧបសម្បទាក៏ពិត តែថាមានអានុភាពឲ្យសម្រេចនូវឱតារណកិច្ច គឺការយាងចុះកាន់ពុទ្ធ-សាសន៍ទាំងគ្រហស្ថទាំងបព្វជិត អធិប្បាយដោយសេចក្ដីគឺឲ្យសម្រេចប្រយោជន៍ក្នុងការយាងចុះកាន់ឧបាសកភូមិនៃមនុស្សនឹងទេវតាទាំងឡាយបានដោយពិត កាលមនុស្សនឹងទេវតាកើតជ្រះថ្លាជឿជាក់ក្នុងគុណព្រះរតនត្រ័យហើយ ពោលថ្វាយខ្លួនដល់ព្រះរតនត្រ័យ ដោយសរណគមនបាលីក្ដី ឬដោយភាសានៃខ្លួនក្ដី ក៏ឈ្មោះថាបានយាងចុះកាន់ពុទ្ធសាសន៍ជាឧបាសក ឧបាសិកាដោយពិត បណ្ឌិតគាប្បីជ្រាបថា សរណគមន៍មានអានុភាពធ្វើបុគ្គលឲ្យទៅជាឧបាសក ឧបា-សិកាដោយអត្ថ គឺ សម្រេចដោយសេចក្ដីជាធំ មិនបាច់ពោលជាភាសាបាលីក៏បាន សិងខុសគ្នានឹងវិធីបព្វជ្ជាឧបសម្បទា ៗ តោងពោលជាភាសាបាលី ហើយពោលឲ្យត្រឹមត្រូវតាមបទដែលបង្គាប់ទុកក្នុងអក្ខរវិធី ។

ខសំខាន់ក្នុងរឿងសរណគមន៍នេះ ក៏គឺតាំងប្រកបដោយអង្គ ៣ ដូចពោលហើយខាងដើម ទើបបានឈ្មោះថា វិវដ្ដគាមិនីកុសល ជាកុសលឲ្យដល់នូវព្រះនិព្វាន អ្នកប្រាជ្ញគប្បីជ្រាបថា សរណគមន៍នេះគ្មានសំរេចដោយហេតុដទៃក្រៅអំពីដែលពោលមកហើយ ត្រង់ដែលសត្វពួកខ្លះជារូបប្រមាណ គឺជាអ្នកចូលចិត្តខាងរូបល្អ កាលបានឃើញនូវព្រះសិរីរូបនៃសម្ដេចព្រះបរមសាស្ដាដ៏ប្រដាប់ដោយមហាបុរិសលក្ខណៈ នឹងអសីត្យានុព្យញ្ជនបរិសុទ្ធិផូរផង់ដោយឆព្វណ្ណរង្សី ជានយនាភិសេកនៃសត្វលោកក្ដី ឬបានឃើញព្រះបាដិហារ្យ គឺឥទ្ធិឫទ្ធិ៍ដែលព្រះអង្គនិរមិតឲ្យកើតជាអ្វីៗក្ដី ឬជ្រះថ្លាដោយបានស្ដាប់កិត្តិសព្ទសរសើរព្រះពុទ្ធឥស្សរិយយសមានប្រការផ្សេង ៗ អំពីសំណាក់នៃទេវតានឹងមនុស្សដទៃ ៗ ក្ដី ឬបានឮថាព្រះរតនត្រ័យជារបស់ប្រសើរអំពីសំណាក់បុព្វបុរសមានមាតាបិតាជាដើម ហើយកើតជ្រះថ្លាតាមចារិតនៃត្រកូល មិនបានជាអ្នកដឹងនូវគុណព្រះរតនត្រ័យដោយពិតក្ដី ឬបានឮព្រះសូរសៀងសម្ដេចព្រះបរមសាស្ដាដ៏ពិរោះក្រាងក្រអាវ បីដូច

ជាសម្លេងនៃមហាព្រហ្ម ហើយកើតជ្រះថ្លាក្តី ឬជាអ្នកល្អៗ ប្រមាណចូលចិត្តខាងឯរបស់ស្រអាប់ៗ (គឺមិនចូលចិត្តខាងឯរបស់ឆើតពេក) កាលបានឃើញព្រះសាក្យវង្សទ្រង់នូវបង្សុកូលចីវរ, នឹងសោយនូវបិណ្ឌបាតជារបស់សាយទ្បំ, គង់នៅក្នុងអរញ្ញិកសេនាសនៈជាដើម, នឹងពេញចិត្តត្រង់ដែលព្រះអង្គប្រព្រឹត្តមធ្យតតាមសិក្ខាបទក្តី នឹងគាប់ចិត្តត្រង់ដែលព្រះអង្គប្រើប្រាស់បរិក្ខារដែលសៅហ្មងក្តី ទោះបីនឹងលះជីវិតដល់ព្រះរតនត្រ័យដោយសេចក្តីជ្រះថ្លាតាមអាការអម្បាលនេះ ក៏នៅមិនទាន់រាប់ថាជា វិវដ្តគាមិនីកុសល គ្រាន់តែជាសេចក្តីជ្រះថ្លាជាន់បុព្វភាគ (ខាងដើម) ជាបច្ច័យប្រព្រឹត្តទៅដើម្បីដល់សរណគមន៍ ព្រោះមានតែសទ្ធាមួយយ៉ាង មិនបរិបូណ៌ដោយអង្គសម្បត្តិនៃសរណគមន៍ លុះតែកាលណាបុគ្គលនោះយករូបយកសំឡេង យកល្អគុណជាប្រុសគល់ហើយ ញ៉ាំងសម្មាទិដ្ឋិឲ្យបង្កើតឡើងបាន ដោយអនុមានថា ព្រះដ៏មានព្រះភាគអង្គឯណា ដែលប្រកបដោយព្រះរូបកាយដ៏បរិសុទ្ធផូរផង់ក្តី ប្រកបដោយបាដិហារ្យដ៏អស្ចារ្យក្តី ប្រកបដោយព្រះសូរសៀង

ដ៏ពីរោះក្តី កិត្តិសព្ទសរសើរព្រះគុណផ្ទិតផ្ទាបទូទៅក្នុងសកលលោកក្តី ឬទ្រង់លះចក្រពត្តិសិរីរាជសម្បត្តិចេញទ្រង់ផ្នួសកាន់ភេទដ៏សៅហ្មង់ក្តី ព្រះដ៏មានព្រះភាគអង្គនោះមិនមែនជាអ្នកទទេប្រាសចាកគុណសម្បត្តិ ជាអ្នកមិនចេះពិត មិនដឹងពិតក្នុងធម៌ទាំងពួងនោះជាមិនមែន សម្មាសម្ពុទ្ធោយេវ ព្រះអង្គគង់ជាអ្នកត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដែលមានក្នុងអតីតបច្ចុប្បន្ន អនាគត ដោយព្រះអង្គឯង គ្មានវិបរិតយៀងឃ្លាតខុះបន្លោះជាប្រាកដ, ស្វាក្ខាតោ ធម្មោ ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងនោះប្រាកដជាធម៌ល្អប្រពៃពិត មិនបានផ្តេសផ្តាសខុសចាកសភាវៈ ព្រោះថាធម៌នោះព្រះអង្គទ្រង់ជ្រើសរើសហើយដោយកំលាំងព្រះបញ្ញានាំយកមកសំដែង សុបដិបន្នោ សង្ឃោ ព្រះអរិយសង្ឃដ៏ជាសាវករបស់ព្រះដ៏មានព្រះភាគ គង់ជាអ្នកបដិបត្តិល្អ បដិបត្តិប្រពៃ មិនកន្លងបង់នូវមជ្ឈិមាបដិបទាដោយពិត, កាលបុគ្គលស្ទង់បញ្ញាចុះធ្លុះក្នុងគុណព្រះរតនត្រ័យដោយដ៏គួរតាមពិត ញាំងសេចក្តីជ្រះថ្លាឲ្យបង្កើតឡើងដូច្នេះហើយ ប្រគល់កាយថ្វាយជីវិតតាមដោយលក្ខណៈ

ដែលសំដែងមកហើយខាងដើម ដោយប្រាថ្នានូវព្រះនិព្វានជាគោលក្នុងចិត្ត ទើបបាត់ជាសរណគមន៍ដ៏ឧក្រិដ្ឋ ដោយការនៃសរណគមន៍នោះជាវិវដ្តគាមិនីកុសល ។

១ ទៀត ទោះបីបុគ្គលដែលកើតក្នុងត្រកូលឧបាសកដែលធ្លាប់រាប់អានព្រះរតនត្រ័យ ហើយក៏អនុវត្តរាប់អានទៅតាមចារិតនៃត្រកូលនោះ ញាំងបញ្ញាដ៏ជាសម្មាទិដ្ឋិឲ្យបង្កើតឡើងយ៉ាងនេះថា បុព្វបុរសទាំងឡាយរបស់យើងតៗ មកជាច្រើនដំណ តែងតែរាប់អានព្រះរតនត្រ័យយកជាសរណទីពឹង ព្រះរតនត្រ័យនេះ គង់មិនមែនជាវត្ថុថយថោក គង់ជាវត្ថុប្រសើរគួរជាអារម្មណ៍ ជាវិស័យនៃបញ្ញារបស់អ្នកប្រាជ្ញទាំងឡាយជាច្រើនដំណបុគ្គលមកហើយ លោកទើបរាប់អានដរាបដល់សព្វថ្ងៃនេះ កាលបុគ្គលមករឭកដូច្នេះហើយ ទើបតម្រង់បញ្ញាចុះពិចារណាក្នុងគុណព្រះរតនត្រ័យដោយន័យដែលពោលមកហើយ ទាល់តែកើតបញ្ញាចក្ខុឡើង ទើបជាសរណគមន៍ ទោះបីបុគ្គលកើតសេចក្តីជ្រះថ្លាក្នុងព្រះធម៌ព្រះសង្ឃ ដោយយ៉ាងទាប

បំផុតជ្រះថ្លាក្នុងភិក្ខុមួយអង្គក្តី ជាមូលហេតុ ហើយបាននូវសម្មា-ទិដ្ឋិគឺបញ្ញាឃើញគុណព្រះរតនត្រ័យ ក៏មានន័យដូចគ្នានោះដែរ លក្ខណសមាទានសរណគមន៍យ៉ាងឧក្រិដ្ឋដូចដែលពោលមកនេះ មានមកក្នុងសុត្តន្តកថាទាំងឡាយជាច្រើនអន្លើ ។

ក៏ការដែលដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណប៉ុណ្ណឹងហើយ ប្រហែលជានៅមិនល្មមការ គឺមិនរួចចាកទុក្ខបានទាំងអស់ ទើបក្នុងគាថាដែលឧទ្ទេសមកហើយខាងដើមសម្តេចព្រះបរមសាស្តាត្រាស់ថា តោងឃើញនូវអរិយសច្ច ៤ ដោយបញ្ញាដ៏ប្រពៃផង ទើបរួចចាកទុក្ខទាំងពួងគ្មានសេសសល់ ហេតុដូច្នោះអ្នកបដិបត្តិក្នុងព្រះពុទ្ធសាសនា មិនគួរនឹងពេញចិត្តតែត្រឹមសមាទានសរណគមន៍ប៉ុណ្ណោះ គួរជាបំពេញសម្មាបដិបត្តិក្នុងអរិយសច្ច ៤ នោះផង បើទោះបីបដិបត្តិមិនជិតដល់ មិនបានរួចចាកទុក្ខទាំងពួងតាមដែលអាងក្នុងជាតិនេះតែម្តង ក៏គង់ជាបានប្រសព្វសុខជាច្រើនប្រការ ហើយបានឈ្មោះថា បដិបត្តិត្រូវតាមផ្លូវកណ្តាល ដែលជាធម៌កំពូលក្នុង

ព្រះពុទ្ធសាសនា ក៏អរិយសច្ចៈ ៤ នោះបានសំដែងខាងដើមមកហើយដោយសង្ខេប អ្នកប្រាជ្ញាចង់ជ្រាបសេចក្ដីពិស្ដារគប្បីមើលក្នុងរឿងអរិយសច្ចក្នុងទីដទៃ អំពីនេះនឹងសំដែង១ បដិបត្តិក្នុងព្រះត្រៃសរណគមន៍ នឹងលក្ខណដែលដាច់ឬសៅហ្មងសរណគមន៍តទៅ ។

(មានតទៅទៀត)

គាថាធម្មបទ ប្រែ

របស់អាចារ្យ ហ៊ិម

ក្រុមជំនុំ ប្រែព្រះត្រៃបិដក

# ធម្មបទេ បញ្ចមោ ពាលវគ្គោ

សុមនមាលាការវត្ថុគាថា

(៩) តញ្ច កម្មំ កតំ សាធុ    យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ    វិបាកំ បដិសេវតិ ។

ឧប្បលវណ្ណាថេរីវត្ថុគាថា

(១០) មធុ វា មញ្ញតី ពាលោ    យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ    អថ ទុក្ខំ និគច្ឆតិ ។

ជម្ពុកត្ថេរវត្ថុគាថា

(១១) មាសេ មាសេ កុសគ្គេន    ពាលោ ភុញ្ជេថ[១] ភោជនំ
ន សោ សង្ខាតធម្មានំ    កលំ អគ្ឃតិ សោឡសឹ ។

---

១ ម. ភុញ្ជេយ្យ ។

## ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសុមនមាលាការ*

(៩) បុគ្គលធ្វើកម្មឯណាហើយ ឥតមានក្តៅក្រហាយជារឿយ (ឬ) បុគ្គលដែលមានបីតិនឹងសោមនស្សរីករាយ បាន សោយផលកម្មឯណា កម្មដែលបុគ្គលធ្វើហើយនោះ ឈ្មោះ ថាជាកម្មល្អប្រពៃពិត ។

*គាថាក្នុងរឿងឧប្បលវណ្ណាថេរី*

(១០) បាបមិនទាន់ឲ្យផលដរាបណា មនុស្សពាលតែង សំគាល់នូវបាបនោះថា មានរសផ្អែមដូចទឹកឃ្មុំដរាបនោះ លុះ តែបាបឲ្យផលកាលណា ទើបមនុស្សពាលនោះដល់សេចក្តី ទុក្ខលំបាក ក្នុងកាលនោះឯង ។

*គាថាក្នុងរឿងជម្ពុកត្ថេរ*

(១១) បុគ្គល (ឯណា) បរិភោគភោជន ប្រមាណប៉ុនចុង ស្លឹកស្បូវរាល់ៗខែ បុគ្គលពាលនោះមិនអាចដល់មួយចំណិត ដែលគេចែកជាចំណែកដប់ប្រាំមួយ ៗ ដង របស់បុគ្គលទាំង ឡាយដែលដឹងធម៌ពិតនោះឡើយ ។

## ធម្មបទេ បញ្ចមោ ពាលវគ្គោ

### អហិបេតវត្ថុគាថា

(១២) ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មច្ឆន្នោវ បាវកោ ។

### សដ្ឋីកូដបេតវត្ថុគាថា

(១៣) យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

### សុធម្មត្ថេរវត្ថុគាថា

(១៤) អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

# ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអហិបេត*

(១២) កម្មលាមកអាក្រក់ដែលបុគ្គលធ្វើហើយ មិនទាន់ឲ្យផលនៅឡើយនោះ ដូចទឹកដោះស្រស់ដែលគេរូតហើយ នៅមិនទាន់ក្លាយពីប្រក្រតីក៏ដូច្នោះឯង បាបកម្មដែលទៅតាមបុគ្គលពាលនាំឲ្យក្តៅក្រហាយនោះ ដូចភ្លើងដែលបិទបាំងដោយផេះ ។

*គាថាក្នុងរឿងសដ្ឋីកូដបេត*

(១៣) បំណោះវិជ្ជាមនុស្សពាលកើតឡើង ដើម្បីសេចក្តីវិនាសជាកំណត់ ជារបស់តែងបំផ្លាញខួរក្បាល គឺបញ្ញានឹងបំណែកនៃកុសលធម៌របស់មនុស្សពាលនោះឲ្យវិនាសបង់ ។

*គាថាក្នុងរឿងសុធម្មត្ថេរ*

(១៤) ភិក្ខុពាលតែងប្រាថ្នាឲ្យគេសរសើរគុណធម៌ ដែលមិនមានក្នុងខ្លួន ១ ប្រាថ្នាបរិវារក្នុងពួកភិក្ខុទាំងឡាយ ១ ប្រាថ្នាបង់ធ្វើធំជាងគេក្នុងអាវាស (វត្ត) ១ ប្រាថ្នាបង់បានគ្រឿងសក្ការបូជារបស់ត្រកូលទាំងឡាយដទៃ ១ ។

## ធម្មបទេ បញ្ចមោ ពាលវគ្គោ

មមេវ កតមញ្ញន្តុ គិហិ បព្វជិតា ឧភោ
មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិញ្ចិ ។
ឥតិ ពាលស្ស សង្កប្បោ ឥច្ឆា មានោ បវឌ្ឍតិ ។

តិស្សសាមណេរវត្ថុ ៥

(១៥) អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ ។
សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

ពាលវគ្គោ បញ្ចមោ សមត្តោ ។

## ពាលវគ្គទី ៥ ក្នុងព្រះធម្មបទ

ម្យ៉ាងទៀត សេចក្ដីត្រិះរិះកើតមានដល់ភិក្ខុពាលឯណាថា គ្រហស្ថនឹងអ្នកបួសទាំងពីរពួកប្ដូរដឹងចុះថា ការងារដែលជនធ្វើសម្រេចហើយព្រោះតែអាស្រ័យនូវអាត្មាអញនេះឯង ។ ម្យ៉ាងទៀត គ្រហស្ថបព្វជិតទាំងអស់ប្រព្រឹត្តក្នុងអំណាចសេចក្ដីបង្គាប់បញ្ជារបស់អាត្មាអញតែម្យ៉ាង ក្នុងកិច្ចតូចធំទាំងឡាយកិច្ចការឯណាមួយ សេចក្ដីប្រាថ្នា (តណ្ហា) នឹងមានះ (៥ ប្រការ) រមែងចំរើនដល់ភិក្ខុពាលនោះ ។

*គាថាក្នុងរឿងតិស្សសាមណេរ*

(១៥) បដិបទាជាហេតុញាំងលាភឲ្យកើតឡើងមានផ្សេង ៗ, ឯបដិបទាជាហេតុនាំងទៅកាន់ព្រះនិព្វានមានផ្សេង ៗ, ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ បើដឹងច្បាស់ហេតុទាំងពីរប្រការយ៉ាងនេះហើយ មិនគួរនឹងត្រេកអរចំពោះគ្រឿងសក្ការឡើយ គួរតែចំរើនវិវេកមានកាយវិវេកស្ងាត់កាយ គឺនៅក្នុងទីស្ងាត់ឯកឯងជាដើមវិញ ។

ពាលវគ្គ ទី ៥ ចប់ ។

# ធម្មបទេ ឆដ្ឋោ បណ្ឌិតវគ្គោ

## រាធត្ថេរវត្ថុគាថា

(១) និធីនំវ បវត្តារំ      យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ      តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស      សេយ្យោ ហោតិ ន បាបិយោ ។

## អស្សជិបុនព្វសុកវត្ថុគាថា

(២) ឱវទេយ្យានុសាសេយ្យ      អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ      អសតំ ហោតិ អប្បិយោ ។

# បណ្ឌិតវគ្គទី ៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងរាធត្ថេរ*

(១) បុគ្គលគួរសំឡឹងមើលលោកអ្នកប្រាជ្ញណា ដែលមានប្រាជ្ញាពោលសង្កត់សង្កិន បង្គួលប្រាប់ទោសឲ្យឃើញ ដូចមនុស្សដែលជាអ្នកបង្គួលបង្ហាញកំណប់ទ្រព្យ គួរសេពគប់នឹងលោកអ្នកប្រាជ្ញដូច្នោះចុះ ។ កាលបើបុគ្គលណាសេពគប់នឹងលោកអ្នកប្រាជ្ញយ៉ាងនោះហើយ បុគ្គលនោះតែងមានគុណសម្បត្តិដ៏ប្រសើរថ្លៃថ្លា ឥតមានបាបលាមកឡើយ ។

*គាថាក្នុងរឿងអស្សជិបុនព្វសុក*

(២) បណ្ឌិតណាពេះទូន្មានប្រៀនប្រដៅជនទាំងឡាយ ហាមឃាត់មិនឲ្យប្រព្រឹត្តធម៌របស់អសប្បុរស គឺអកុសលធម៌, បណ្ឌិតនោះតែងជាទីស្រឡាញ់របស់សប្បុរសដោយពិត មិនជាទីស្រឡាញ់នៃអសប្បុរសទាំងឡាយឡើយ ។

# ធម្មបទេ ឆដ្ឋោ បណ្ឌិតវគ្គោ

ឆន្នត្ថេរវត្ថុគាថា

(៣) ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

មហាកប្បិនត្ថេរវត្ថុគាថា

(៤) ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

បណ្ឌិតសាមណេរវត្ថុគាថា

(៥) ឧទកម្ហិ នយន្តិ នេត្តិកា ឧសុការា ទមយន្តិ[១] តេជនំ
ទារុំ ទមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា

១ នមយន្តីតិបិ បាឋោ ។

## បណ្ឌិតវគ្គទី ៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឆន្នត្ថេរ*

(៣) បុគ្គលមិនត្រូវសេពគប់មិត្តលាមកទាំងឡាយ មិនត្រូវសេពគប់បុរសដែលមានគំនិតថោកទាបទាំងឡាយ, ត្រូវសេពគប់តែកល្យាណមិត្តទាំងឡាយ ត្រូវសេពគប់តែបុរសឧត្តមទាំងឡាយវិញ ។

*គាថាក្នុងរឿងមហាកប្បិនត្ថេរ*

(៤) បណ្ឌិតជាអ្នកផឹកធម៌ គឺពាល់ត្រូវលោកុត្តរធម៌ដោយនាមកាយ ធ្វើឲ្យជាក់ច្បាស់ដោយអារម្មណ៍នឹងបាក់ធុះនូវអរិយសច្ច មានចិត្តជ្រះថ្លាហើយត្រេកអររាល់វេលា ក្នុងធម៌ដែលព្រះអរិយៈសំដែងហើយ តែងដេកនៅជាសុខ ។

*គាថាក្នុងរឿងបណ្ឌិតសាមណេរ*

(៥) ធម្មតាអ្នកនាំទឹកទាំងឡាយ តែងបង្ហូរទឹក (ទៅកាន់ទីប្រាថ្នារបស់ខ្លួន) បាន, ជាងអ្នកធ្វើសរទាំងឡាយ តែងពត់កូនសរឲ្យត្រង់បាន, ជាងបាំងឈើទាំងឡាយ តែងចាំងបំពត់ឈើឲ្យត្រង់ឬវៀចតាមសេចក្តីប្រាថ្នារបស់ខ្លួនបាន ឯបណ្ឌិតទាំងឡាយតែងទូន្មានខ្លួនឲ្យត្រង់ត្រឹមត្រូវល្អ ។

# ធម្មបទេ ឆដ្ឋោ បណ្ឌិតវគ្គោ

លកុណ្ដកភទ្ទិយត្ថេរវត្ថុគាថា

(៦) សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។

កាណមាតាវត្ថុគាថា

(៧) យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

បញ្ចសតភិក្ខុវត្ថុគាថា

(៨) សព្វត្ថ វេ សប្បុរិសា វជន្តិ
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុក្ខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

## បណ្ឌិតវគ្គទី ៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងលកុណ្ឌកភទ្ទិយ*

(៦) ថ្មតាន់មួយដុំរមែងមិនកំរើកញាប់ញ័រដោយខ្យល់យ៉ាងណាមិញ ឯបណ្ឌិតទាំងឡាយរមែងមិនរង្គើបញ្ជាប់ញ័រអំពីសេចក្ដីសរសើរនឹងសេចក្ដីនិន្ទា យ៉ាងនោះឯង ។

*គាថាក្នុងរឿងកាណមាតា*

(៧) អន្លង់ដែលជ្រៅមានទឹកថ្លាមិនល្អក់ យ៉ាងណាមិញ ឯបណ្ឌិតទាំងឡាយបើបានស្ដាប់ធម៌ទេសនាហើយ ក៏តែងជ្រះថ្លាដោយវិសេស យ៉ាងនោះឯង ។

*គាថាក្នុងរឿងបញ្ចសតភិក្ខុ*

(៨) បណ្ឌិតទាំងឡាយដែលជាសប្បុរស មានចិត្តស្ងប់រម្ងាប់ លះបង់ឆន្ទរាគៈក្នុងសភាវៈទាំងពួងមានបញ្ចក្ខន្ធជាដើម ហើយតែងមិនពោលពាក្យរាក់ទាក់ (នឹងអ្នកណាមួយ) ព្រោះតែសេចក្ដីប្រាថ្នាក្នុងកាមឡើយ បើសេចក្ដីសុខទុក្ខមកប៉ះពាល់ហើយ លោកក៏មិនសំដែងអាការខ្ពស់នឹងទាប គឺត្រេកអរឬតូចចិត្តឡើយ ។

# ធម្មបទេ ឆដ្ឋោ បណ្ឌិតវគ្គោ

## ធម្មិកត្ថេរវត្ថុគាថា

(៩) ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

## ធម្មស្សវនវត្ថុគាថា

(១០) អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

# បណ្ឌិតវគ្គទី ៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងធម្មិកត្ថេរ*

(៩) ជាតិបណ្ឌិតរមែងមិនធ្វើអំពើបាប ព្រោះហេតុតែខ្លួន ព្រោះហេតុតែអ្នកដទៃឡើយ លោកមិនដែលប្រាថ្នាកូនឬទ្រព្យសម្បត្តិ ឬដែន (ដោយអំពើបាបឡើយ) លោកមិនប្រាថ្នាសេចក្ដីសម្រេច (អ្វី) ដើម្បីខ្លួន ដោយអំពើដែលមិនប្រកបដោយធម៌ឡើយ បណ្ឌិតនោះឈ្មោះថា អ្នកមានសីល អ្នកមានបញ្ញា ជាអ្នកប្រកបដោយគន្លងធម៌ ។

*គាថាក្នុងរឿងធម្មស្សវន*

(១០) បណ្ដាមនុស្សច្រើនពួក ជនទាំងឡាយណាដែលឆ្លងទៅកាន់ត្រើយគឺព្រះនិព្វាន ជនទាំងនោះមានប្រមាណតិច ពួកសត្វក្រៅនេះតែងស្ទុះទៅកាន់ត្រើយគឺសក្កាយទិដ្ឋិជាច្រើន ។ មួយវិញទៀតពួកជនណាប្រព្រឹត្តតាមធម៌ចំពោះធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងមកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងតេភូមិកវដ្ដ ជាលំនៅនៃមច្ចុ (រាជ) ដែលគេឆ្លងបានដោយកម្រក្រៃពេក ហើយដល់នូវត្រើយគឺព្រះនិព្វានមិនខានឡើយ ។

# ធម្មបទេ ឆដ្ឋោ បណ្ឌិតវគ្គោ

បញ្ចសតអាគន្តុកភិក្ខុវត្ថុគាថា

(១១) កណ្ហំ ធម្មំ វិប្បហាយ　　សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម　　វិវេកេ យត្ថ ទូរមំ ។
តត្រាភិរតិមិច្ឆេយ្យ　　ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ　　ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ　　សម្មា ចិត្តំ សុភាវិតំ
អាទានប្បដិនិស្សគ្គេ　　អនុបាទាយ យេ រតា ។
ខីណាសវា ជុតិមន្តោ　　តេ លោកេ បរិនិព្វុតា ។

បណ្ឌិតវគ្គោ ឆដ្ឋោ សមត្តោ ។

## បណ្ឌិតវគ្គទី ៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបញ្ចសតអាគន្តុកភិក្ខុ*

(១១) អ្នកមានប្រាជ្ញាត្រូវចេញចាកទីអាល័យ ហើយអាស្រ័យនូវព្រះនិព្វានដែលមិនមានទីអាល័យ ហើយត្រូវលះបង់ធម៌ខ្មៅចេញហើយបំរើននូវធម៌ស ពួកសត្វរមែងត្រេកអរបានដោយកម្រក្នុងវិវេកគឺព្រះនិព្វានឯណា ។ ត្រូវលះបង់កាមទាំងឡាយ ជាអ្នកមិនមានកង្វល់ហើយប្រាថ្នាសេចក្តីត្រេកអរក្នុងវិវេកគឺព្រះនិព្វាននោះឯង ធម្មតាបណ្ឌិតគួរតែជម្រះខ្លួនឲ្យស្អាតផូរផង់ចាកនីវរណធម៌ជាគ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលបុគ្គលទាំងឡាយឯណាបានបំរើនដោយប្រពៃហើយក្នុងធម៌ជាអង្គនៃបុគ្គលជាអ្នកត្រាស់ដឹងទាំងឡាយ (ឬ) បុគ្គលទាំងឡាយឯណាមិនប្រកាន់មាំដោយឧបាទាន មានចិត្តត្រេកអរចំពោះកិរិយាលះបង់នូវកិលេសជាគ្រឿងធ្វើចិត្តឲ្យសៅហ្មង បុគ្គលទាំងឡាយនោះឈ្មោះថា មានកិលេសជាគ្រឿងត្រាំក្នុងសន្តានអស់ហើយ ឈ្មោះថាមានអានុភាពដ៏រុងរឿង ឈ្មោះថាមានកងទុក្ខរលត់អស់ហើយក្នុងលោក ។

បណ្ឌិតវគ្គ ទី ៦ ចប់ ។

# ធម្មបទេ សត្តមោ អរហន្តវគ្គោ

ជីវកបញ្ហាវត្ថុគាថា

(១) គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ

សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។

មហាកស្សបត្ថេរវត្ថុគាថា

(២) ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ

ហង្សាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

## អរហន្តវគ្គទី ៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងជីវកបញ្ហា*

(១) សេចក្ដីក្រវល់ក្រវាយ (ឬ) សេចក្ដីក្ដៅក្រហាយ រមែងមិនមានដល់ព្រះខីណាស្រព ដែលលោកមានដំណើរផ្លូវឆ្ងាយដើរទៅដល់ហើយ ឥតមានសេចក្ដីសោយសោក មានចិត្តស្រឡះហើយ ចាកសភាវៈទាំងពួងមានខន្ធជាដើម, មានកិលេសជាគ្រឿងចាក់ស្រែះទាំងពួងលះបង់អស់ហើយ ។

*គាថាក្នុងរឿងមហាកស្សបត្ថេរ*

(២) ព្រះខីណាស្រពទាំងឡាយនោះ មានស្មារតីតែងខ្វល់ខ្វាយ (ក្នុងឈានគឺងវិបស្សនាជាដើម) រមែងមិនត្រេកអរត្រង់ទីប្រកបដោយអាល័យ លោកបោះបង់ទីអាល័យទាំងពួងចោលស្រឡះ ដូចសត្វហង្សបោះបង់ស្រះដ៏បរិបូណ៌ដោយចំណីហើយហើរទៅរកទីគោចរផ្សេងទៀត យ៉ាងនោះឯង ។

# ធម្មបទេ សត្តមោ អរហន្តវគ្គោ

ពេឡដ្ឋសីសត្ថេរវត្ថុគាថា

(៣) យេសំ សន្និចយោ នត្ថិ   យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច   វិមោក្ខោ យេស គោចរោ ។
អាកាសេវ សកុណានំ[១]   គតិ តេសំ ទុរន្នយា ។

អនុរុទ្ធត្ថេរវត្ថុគាថា

(៤) យស្សាសវា បរិក្ខីណា   អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច   វិមោក្ខោ យស្ស គោចរោ ។
អាកាសេវ សកុណានំ   បទន្តស្ស ទុរន្នយំ ។

---

១ សកុន្តានន្តិបិ បាឋោ ។

## អរហន្តវគ្គទី ៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពេឡដ្ឋសីសត្ថេរ*

(៣) សេចក្តីសន្សំទុកមិនមានដល់ពួកជនណា (ឬ) ពួកជនណាមានភោជនបានកំណត់ដឹងហើយ; មួយវិញទៀត វិមោក្ខ ៣ យ៉ាងគឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ជាទីអារម្មណ៍របស់ជនពួកណា ៗ ដំណើររបស់ជនទាំងនោះឯងគេតែងដឹងបានដោយកម្រ ដូចដំណើរនៃសត្វស្លាបទាំងឡាយកំពុងហើរទៅ ឰដ៏អាកាសវេហាស៍ ដូច្នោះឯង ៗ

*គាថាក្នុងរឿងអនុរុទ្ធត្ថេរ*

(៤) អាសវៈទាំងឡាយរបស់បុគ្គលឯណាអស់រលីងហើយ បុគ្គលនោះមិនអាស្រ័យក្នុងអាហារ; ម្យ៉ាងទៀតវិមោក្ខទាំង ៣ យ៉ាង គឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ជាទីអារម្មណ៍របស់បុគ្គលណា, ស្នាមជើងរបស់បុគ្គលនោះឯងគេដឹង (គេឃើញ) បានដោយកម្រ ដូចស្នាមជើងសត្វស្លាបទាំងឡាយដែលហើរ ឰដ៏អាកាសប្រទេស ដូច្នោះឯង ៗ

# ធម្មបទេ សត្តមោ អរហន្តវគ្គោ

មហាកច្ចាយនត្ថេរវត្ថុគាថា

(៥) យស្សិន្ទ្រិយានិ សមថង្គតានិ
អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

សារីបុត្តត្ថេរវត្ថុគាថា

(៦) បឋវីសមោ នោ វិរុជ្ឈតិ ឥន្ទខីលូបមោ តាទិ សុព្វតោ
រហទោវ អបេតកទ្ទមោ សំសារា ន ភវន្តិ តាទិនោ ។

# អរហន្តវគ្គ ទី ៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមហាកច្ចាយនត្ថេរ*

(៥) ឥន្ទ្រិយទាំងឡាយ (៦) របស់ភិក្ខុណា ដល់ហើយនូវកិរិយាស្ងប់ម្ងាប់ គឺថាបានទូន្មានហើយ ដូចសេះដែលសាយសារថីហ្វឹកហ្វឺនរាបហើយ; ទេវតាទាំងឡាយក្តី មនុស្សទាំងឡាយក្តី តែងស្រឡាញ់រាប់អានភិក្ខុនោះដែលជាអ្នកមានមានះលះបង់ស្រឡះហើយ មិនមានអាសវៈជាគ្រឿងត្រាំក្នុងសន្តាន ជាបុគ្គលមិនញាប់ញ័រដោយលោកធម៌ ។

*គាថាក្នុងរឿងសារីបុត្តត្ថេរ*

(៦) ព្រះខីណាស្រពភិក្ខុឯណាមានហឫទ័យស្មើដោយផែនដី លោកមិនបេះទឹង មិនបេះញាប់ញ័រដោយលោកធម៌ប្រៀបដូចសសរគោល លោកមានវត្តល្អ មានភក់គឺកិលេសប្រាសហើយ ដូចអន្លង់ទឹកប្រាសចាកភក់ល្បាប់, កិរិយាអន្ទោលទៅក្នុងសុគតិនឹងទុគ្គតិ មិនមានដល់ព្រះខីណាស្រពភិក្ខុប្រាកដដូច្នោះឡើយ ។

## ធម្មបទេ សត្តមោ អរហន្តវគ្គោ

កោសម្ពិកតិស្សត្ថេរវត្ថុគាថា

(៧) សន្តន្តស្ស មនំ ហោតិ  សន្តា វាចា ច កម្ម ច
សម្មទញ្ញា វិមុត្តស្ស  ឧបសន្តស្ស តាទិនោ ។

សារីបុត្តត្ថេរវត្ថុគាថា

(៨) អស្សទ្ធោ អកតញ្ញូ ច  សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ  ស វេ ឧត្តមបោរិសោ ។

ខទិរវនិយរេវតត្ថេរវត្ថុគាថា

(៩) គាមេ វា យទិ វារញ្ញេ  និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ  តំ ភូមិរាមណេយ្យកំ ។

## អរហន្តវគ្គទី ៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកោសម្ពិកតិស្សត្ថេរ*

(៧) ចិត្តក្តីវាចាក្តីកាយកម្មក្តីរបស់ព្រះខីណាស្រពនោះ សុភាពរាបសាស្ងប់រម្ងាប់ហើយ លោកមានចិត្តរួចផុតស្រឡះ (ដោយវិមុត្តិទាំង ៥) ចូលទៅជិតស្ងប់ស្ងាត់ហើយចាករាគាទិក្កិលេស លោកមិនញាប់ញ័រដោយលោកធម៌ ព្រោះដឹងច្បាស់នូវធម៌ដោយប្រពៃ ។

*គាថាក្នុងរឿងសារីបុត្តត្ថេរ*

(៨) ជនណាមិនជឿតាមពាក្យគេផង ស្គាល់ព្រះនិព្វាន ដែលគេធ្វើមិនបានផង កាត់នូវទីតគឺវដ្ដសង្សារផង មានឱកាសជាទីកើតកំចាត់បង់ហើយ និងមានសេចក្តីប្រាថ្នាទាំងពួងខ្ជាក់ចោលហើយផង ជននោះឈ្មោះបុរសដ៏ឧត្តមខ្ពង់ខ្ពស់ ។

*គាថាក្នុងរឿងខទិរវនិយរេវតត្ថេរ*

(៩) ព្រះអរហន្តទាំងឡាយលោកគង់នៅក្នុងប្រទេសណា គឺស្រុកក្តីព្រៃក្តីទីទំនាបក្តីទីទួលក្តី ប្រទេសនោះឯង ជាទីនាំមកនូវសេចក្តីត្រេកអរដោយពិត ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

អញ្ញតរបិណ្ឌចារិកត្ថេរវត្ថុគាថា

(១០) រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ
វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។

អរហន្តវគ្គោ សត្តមោ សមត្តោ

តម្ពទាឋិកចោរឃាតកវត្ថុគាថា

(១) សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

# សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអញ្ញតរបរិព្វាជិក*

(១០) ជនអ្នកស្វែងរកកាម មិនត្រេកអរបំពោះព្រៃទាំងឡាយឯណា ព្រៃទាំងឡាយនោះឯង ជាកន្លែងគួរព្រះខីណាស្រពគប្បីត្រេកអរដោយពិត, ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ តែងនឹងត្រេកអរបំពោះព្រៃនោះ ព្រោះថាលោកមិនជាអ្នកស្វែងរកនូវកាមឡើយ ។

អរហន្តវគ្គ ទី ៧ ចប់

*គាថាក្នុងរឿងតម្ពទាឋិកចោរឃាតក*

(១) បើពាក្យសំដីដែលពោលទៅហើយ សូម្បីដល់មួយពាន់ជាកំណត់ តែថាជាសំដីមិនប្រកបដោយបទដែលប្រយោជន៍ បុគ្គលស្តាប់បទណាដែលមានប្រយោជន៍ ហើយរម្ងាប់នូវរាគាទិក្កិលេសបាន បទជាប្រយោជន៍នោះ សូម្បីតែមួយបទក៏ប្រសើរជាងសំដីនោះ ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

ពាហិយទារុចីរិយត្ថេរគាថា

(២) សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

កុណ្ឌលកេសិត្ថេរីគាថា

(៣) យោ ច គាថាសតំ ភាសេ អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ

## សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពាហិយទារុចីរិយ*

(២) បើគាថា សូម្បីដល់មួយពាន់ដែលជាគាថាមិនប្រកបដោយបទដែលមានប្រយោជន៍ បុគ្គលស្តាប់នូវគាថាណា ហើយរម្ងាប់នូវរាគាទិក្កិលេសបាន, គាថានោះសូម្បីតែមួយបទ ក៏ប្រសើរជាងគាថាទាំងនោះ ។

*គាថាក្នុងរឿងកុណ្ឌលកេសីថេរី*

(៣) បើបុគ្គលណាពោលគាថាទាំងឡាយមួយរយ ដែលជាគាថាមិនប្រកបដោយបទដែលមានប្រយោជន៍ បុគ្គលបានស្តាប់បទធម៌ណាហើយរម្ងាប់នូវរាគាទិក្កិលេសបាន បទធម៌នោះសូម្បីតែមួយបទក៏ប្រសើរជាងគាថាទាំងនោះ ។ យោធាណាឈ្នះមនុស្សទាំងឡាយបំនួនមួយពាន់បានមួយពាន់ដងក្នុងសង្គ្រាម យោធានោះឯងឈ្មោះថាខ្ពង់ខ្ពស់ដោយកិរិយាឈ្នះនូវសង្គ្រាមនោះក៏ទេ ក្រែងតែបុគ្គលណាមួយឈ្នះនូវខ្លួនដោយកិរិយាឈ្នះនូវកិលេសមានលោភជាដើម បុគ្គលនោះទើបឈ្មោះថា បុរសដ៏ខ្ពង់ខ្ពស់ក្នុងសង្គ្រាមគឺកិលេសដោយពិត ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

### អនត្ថបុច្ឆកព្រាហ្មណវត្ថុគាថា

(៤) អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ ។
នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

### សារីបុត្តត្ថេរស្ស មាតុលព្រាហ្មណវត្ថុគាថា

(៥) មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ ។
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

## សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអនត្ថបុច្ឆកព្រាហ្មណ៍*

(៤) ខ្លួនឯងឈ្នះខ្លួនឯងដោយការឈ្នះនូវរាគាទិក្កិលេស ឈ្មោះថាប្រសើរ ពួកសត្វដ៏សេសឯណាគេរមែងឈ្នះដោយបាស្កាជាដើម ឈ្នះនោះមិនប្រសើរទេ សត្វដែលមានខ្លួនទូន្មានហើយប្រព្រឹត្តសង្រួមមិនដាច់ ។ ទេវតាគន្ធព្វនឹងមារព្រមទាំងព្រហ្ម មិនអាចធ្វើនូវជ័យជំនះរបស់សត្វដែលមានភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

*គាថាក្នុងរឿងសារីបុត្តត្ថេរស្រមាតុលព្រាហ្មណ៍*

(៥) បុគ្គលណាបូជាដល់លោកិយមហាជន ដោយពាន់នៃកហាបណៈក្នុង ១ ខែៗ អស់មួយរយឆ្នាំក្តី បុគ្គលណាបូជាដល់បុគ្គលមានខ្លួនបំរើនហើយ សូម្បីតែមួយរំពេច(ម្រមួង) ការបូជានោះឯងប្រសើរដោយវិសេស ក៏ឯបូជាអស់មួយរយឆ្នាំនោះមិនប្រសើរដោយវិសេសឡើយ ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

សារីបុត្តត្ថេរស្ស មាតុលព្រាហ្មណវត្ថុ គាថា

(៦) យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ ។
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

សារីបុត្តត្ថេរស្ស សហាយកព្រាហ្មណវត្ថុ គាថា

(៧) យំកិញ្ចិ យិដ្ឋញ្ច ហុតញ្ច(១) លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជុគតេសុ សេយ្យោ ។

---

១ យិដ្ឋំ វ ហុតំ វ ឥតិបិ បាឋោ ។

# សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងព្រាហ្មណ៍ជាក្មួយនៃព្រះសារីបុត្តត្ថេរ*

(៦) សត្វណាបំរើភ្លើងក្នុងព្រៃអស់មួយរយឆ្នាំក្តី បុគ្គលបូជាលោកណាមួយដែលមានខ្លួនបំរើនហើយ សូម្បីតែមួងការបូជានោះឯងប្រសើរដោយវិសេស ឯការបូជាភ្លើងសូម្បីមួយរយឆ្នាំនោះ ក៏មិនប្រសើរដោយវិសេសឡើយ ។

*គាថាក្នុងរឿងព្រាហ្មណ៍ជាសំឡាញ់នៃព្រះសារីបុត្តត្ថេរ*

(៧) បុគ្គលប្រាថ្នានូវបុណ្យហើយ បូជាគ្រឿងសក្ការៈធំក្តី តូចក្តីឯណានីមួយ ដល់លោកិយមហាជន ក្នុងមួយឆ្នាំរាល់ ៗ ថ្ងៃ មិនមានបន្លោះ ក៏ឯកិរិយាបូជាទាំងអស់នោះ ក៏មិនស្មើនឹងចំណែកជាគំរប់ ៤ នៃកុសលចេតនារបស់បុគ្គលដែលថ្វាយបង្គំចំពោះលោកដែលដំកល់ខ្លួនត្រង់ឡើយ កិរិយាថ្វាយបង្គំចំពោះលោកដែលដំកល់ខ្លួនត្រង់នោះប្រសើរជាងវិសេសជាង ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

អាយុវឌ្ឍនកុមារវត្ថុគាថា

(៨) អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

សំកិច្ចសាមណេរវត្ថុគាថា

(៩) យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

ខាណុកោណ្ឌញ្ញត្ថេរវត្ថុគាថា

(១០) យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ

# សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអាយុវឌ្ឍនកុមារ*

(៨) ធម៌ទាំងឡាយ ៤ ប្រការគឺ អាយុ ១ ពណ៌សម្បុរ ១ សេចក្ដីសុខ ១ កម្លាំង ១ តែងចំរើនដល់បុគ្គលមានកិរិយាអភិវាទជាប្រក្រតី នឹងមានប្រក្រតីកោតក្រែងដល់បុគ្គលដែលចំរើនអស់កាលជានិច្ច ។

*គាថាក្នុងរឿងសំកិច្ចសាមណេរ*

(៩) បុគ្គលណាទ្រុស្ដសីល មានចិត្តមិនបានដំកល់ខ្ជាប់ ក្នុងកុសលធម៌គឺឈាន ហើយរស់នៅអស់មួយរយឆ្នាំក្តី កិរិយារស់នៅសូម្បីតែ ១ ថ្ងៃនៃបុគ្គលដែលមានសីលនឹងឈានក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅ អស់ ១ រយឆ្នាំនៃបុគ្គលដែលទ្រុស្ដសីលនោះ ។

*គាថាក្នុងរឿងខាណុកោណ្ឌញ្ញត្ថេរ*

(១០) បុគ្គលណាមួយគ្មានប្រាជ្ញា មានចិត្តមិនបានដំកល់មាំក្នុងកុសលធម៌គឺឈាន ហើយរស់នៅអស់មួយរយឆ្នាំ

ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

សប្បទាសត្ថេរវត្ថុគាថា

(១១) យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ

ឯកាហំ ជីវិតំ សេយ្យោ វីរិយារព្ភតោ ទឡ្ហំ ។

បដាចារាថេរីវត្ថុគាថា

(១២) យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ

ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

កិរិយារស់នៅសូម្បីតែមួយថ្ងៃ នៃបុគ្គលដែលមានបញ្ញានិងឈាន ក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅអស់មួយរយឆ្នាំ នៃបុគ្គលដែលគ្មានប្រាជ្ញានោះឯង ។

*គាថាក្នុងរឿងសប្បទាសត្ថេរ*

(១១) បុគ្គលឯណាខ្ជិលច្រអូសមានព្យាយាមថយថោក រស់នៅអស់មួយរយឆ្នាំ កិរិយារស់នៅសូម្បីតែមួយថ្ងៃនៃបុគ្គលអ្នកប្រារព្ធនូវព្យាយាមដ៏មាំមួន ក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅអស់មួយរយឆ្នាំ នៃបុគ្គលដែលខ្ជិលច្រអូសនោះឯង។

*គាថាក្នុងរឿងបដាចារីថេរី*

(១២) បុគ្គលណាមួយមិនដែលឃើញច្បាស់នូវកិរិយាកើតឡើងនិងវិនាសទៅវិញ (នៃបញ្ចក្ខន្ធ) រស់នៅអស់មួយរយឆ្នាំ កិរិយារស់នៅសូម្បីតែមួយថ្ងៃនៃបុគ្គលអ្នកឃើញច្បាស់នូវកិរិយាកើតឡើងនិងវិនាសទៅវិញ ក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅអស់មួយរយឆ្នាំ នៃបុគ្គលដែលមិនឃើញច្បាស់នូវកិរិយាកើតឡើងនិងវិនាសទៅវិញនោះឯង ។

# ធម្មបទេ អដ្ឋមោ សហស្សវគ្គោ

កិសាគោតមីវត្ថុគាថា

(១៣)យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

ពហុបុត្តិកាថេរីវត្ថុគាថា

(១៤)យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

សហស្សវគ្គោ អដ្ឋមោ សមត្តោ

# សហស្សវគ្គទី ៨ ក្នុងព្រះធម្មបទ

## គាថាក្នុងរឿងកិសាគោតមី

(១៣) បុគ្គលណាមួយមិនដែលឃើញច្បាស់ នូវឧបាយជាគ្រឿងដល់នូវអមតនិព្វាន រស់នៅអស់មួយរយឆ្នាំ កិរិយារស់នៅសូម្បីតែមួយថ្ងៃ នៃបុគ្គលអ្នកឃើញច្បាស់នូវឧបាយជាគ្រឿងដល់នូវអមតនិព្វាន ក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅមួយរយឆ្នាំ នៃបុគ្គលដែលមិនឃើញច្បាស់នូវឧបាយជាគ្រឿងដល់នូវព្រះនិព្វាននោះឯង ។

## គាថាក្នុងរឿងពហុបុត្តិកាថេរី

(១៤) បុគ្គលណាមួយមិនដែលឃើញច្បាស់នូវធម៌ដ៏ខ្ពង់ខ្ពស់គឺលោកុត្តរធម៌ រស់នៅអស់មួយរយឆ្នាំ កិរិយារស់នៅសូម្បីតែមួយថ្ងៃ នៃបុគ្គលអ្នកឃើញច្បាស់នូវធម៌ដ៏ខ្ពង់ខ្ពស់ក៏ប្រសើរដោយវិសេសជាងកិរិយារស់នៅអស់មួយរយឆ្នាំ នៃបុគ្គលដែលមិនបានឃើញច្បាស់នូវធម៌ដ៏ខ្ពង់ខ្ពស់នោះឯង ។

សហស្សវគ្គ ទី ៨ ចប់

# ធម្មបទេ នវមោ បាបវគ្គោ

ចូឡេកសាដកវត្ថុគាថា

(១) អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ
ទន្ធំ ហិ ករោតោ បុញ្ញំ បាបស្មឹ រមតី មនោ ។

សេយ្យសកត្ថេរវត្ថុគាថា

(២) បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។

លាជទេវធីតាវត្ថុគាថា

(៣) បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។

## បាបវគ្គទី ៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចូឡេកសាដកព្រាហ្មណ៍*

(១) បុគ្គលគួរធ្វើកុសលទាំងឡាយឲ្យរហ័សរួសរាន់ ម្យ៉ាងទៀតគួរឃាត់ចិត្តចាកបាបលាមក ព្រោះថាកាលបុគ្គលធ្វើបុណ្យដោយយឺតយូរ ចិត្តតែងត្រេកអរចំពោះបាបលាមក (នោះឯង) ។

*គាថាក្នុងរឿងសេយ្យសកត្ថេរ*

(២) បើបុរសធ្វើបាប មិនត្រូវធ្វើបាបនោះរឿយៗឡើយ មិនត្រូវធ្វើសេចក្ដីប្រាថ្នាចំពោះបាបនោះ ការសន្សំបាបតែងនាំនូវសេចក្ដីទុក្ខមកឲ្យមិនខាន ។

*គាថាក្នុងរឿងលាជទេវធីតា*

(៣) បើបុរសធ្វើបុណ្យ ត្រូវធ្វើបុណ្យនោះឲ្យរឿយ ៗ ត្រូវធ្វើសេចក្ដីប្រាថ្នាក្នុងបុណ្យនោះ ការសន្សំបុណ្យតែងនាំនូវសេចក្ដីសុខមកឲ្យដោយពិត ។

# ធម្មបទេ នវមោ បាបវគ្គោ

អនាថបិណ្ឌិកសេដ្ឋីវត្ថុគាថា

(៤) បាបោបិ បស្សតិ ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ អថ (បាបោ) បាបានិ បស្សតិ ។
ភទ្រោបិ បស្សតិ បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតិ ភទ្រំ អថ ភទ្រានិ បស្សតិ ។

អសញ្ញតបរិក្ខារវត្ថុគាថា

(៥) មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ ។
បូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

## បាបវគ្គទី ៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអនាថបិណ្ឌិកសេដ្ឋី*

(៤) បាបមិនទាន់ឲ្យផលដរាបណា បុគ្គលបាបតែងឃើញតែសេចក្តីចំរើនដរាបនោះ លុះតែបាបឲ្យផលក្នុងកាលណា បុគ្គលបាបទើបឃើញបាបលាមកក្នុងកាលនោះ ។

កម្មដ៏ល្អមិនទាន់ឲ្យផលដរាបណា បុគ្គលអ្នកធ្វើកម្មដ៏ល្អតែងឃើញបាបលាមកដរាបនោះ លុះតែកម្មដ៏ល្អឲ្យផលក្នុងកាលណា អ្នកធ្វើកម្មដ៏ល្អទើបឃើញនូវសេចក្តីចំរើនក្នុងកាលនោះ ។

*គាថាក្នុងរឿងអសញ្ញតបរិក្ខារ*

(៥) បុគ្គលមិនត្រូវមើលងាយបាបថា បាបមានប្រមាណតិច នឹងមិនមកគឺថាមិនឲ្យផលឡើយ សូម្បីក្អមសម្រាប់ដាក់ទឹកម្តេចគង់ពេញដោយដំណក់ទឹក ដែលស្រក់ចុះមកមិនដាច់បាន ឯបុគ្គលពាលសន្សំនូវបាប សូម្បីបន្តិចម្តង ៗ ក៏គង់តែពេញដោយបាបមិនខាន ។

## ធម្មបទេ នវមោ បាបវគ្គោ

ពិឡាលបទកសេដ្ឋីវត្ថុគាថា

(៦) មាវមញ្ញេថ បុញ្ញស្ស ន មត្តំ(១) អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

មហាធនវាណិជវត្ថុគាថា

(៧) វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

កុក្កុដមិត្តនេសាទវត្ថុគាថា

(៨) បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

---

១ បរិស្សាតិបិ បាឋោ ។

## បាបវគ្គទី ៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពិឡាលបទកសេដ្ឋី*

(៦) បុគ្គលមិនត្រូវមើលងាយបុណ្យថា បុណ្យមានប្រមាណតិច នឹងមិនមកគឺថាមិនឲ្យផលឡើយ សូម្បីក្អមសម្រាប់ដាក់ទឹក ម្តេចគង់ពេញដោយដំណក់ទឹកដែលស្រក់ចុះមកមិនដាច់បាន ។ អ្នកមានប្រាជ្ញាកាលសន្សំនូវបុណ្យ សូម្បីបន្តិចម្តង ៗ ក៏គង់ពេញដោយបុណ្យមិនខាន ។

*គាថាក្នុងរឿងមហាធនវាណិជ*

(៧) ភិក្ខុវៀរចាកបាបទាំងឡាយ ដូចពាណិជដែលមានគ្នាតិចហើយមានទ្រព្យច្រើន វៀរចាកផ្លូវដែលគេត្រូវខ្លាច ពុំនោះសោតដូចបុរសមានប្រាជ្ញាដើម្បីរស់នៅវៀរចាកថ្នាំពិស ។

*គាថាក្នុងរឿងកុក្កុដមិត្តនេសាទ*

(៨) បើដំបៅមិនមានត្រង់បាតដៃទេ បុគ្គលគប្បីនាំទៅគឺថាគប្បីចាប់កាន់ថ្នាំពិសដោយដៃបាន ថ្នាំពិសមិនជ្រាបជ្រាប់ទៅតាមបាតដៃដែលគ្មានដំបៅនោះបានឡើយ បាបតែងមិនមានដល់បុគ្គលដែលមិនធ្វើបាប ។

# ធម្មបទេ នវមោ បាបវគ្គោ

កោកសុនខលុទ្ធកវត្ថុ គាថា

(៩) យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំ វ ខិត្តោ ។

មណិការកុលុបកតិស្សត្ថេរវត្ថុ គាថា

(១០) គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

តយោជនវត្ថុ គាថា

(១១) ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស

## បាបវគ្គទី ៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកោកសុនខលុទ្ទកៈ*

(៩) បុគ្គលពាលណាប្រទុស្តដល់សត្វ ដែលគេមិនមានប្រទុស្តហើយជាសត្វស្អាតមិនមានទីទួលពោលគឺកិលេស បាបនឹងត្រឡប់មកកាន់បុគ្គលពាលនោះវិញមិនខាន ដូចធូលីដ៏ល្អិតដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។

*គាថាក្នុងរឿងកុលុបគតិស្សត្ថេរ*

(១០) សត្វទាំងឡាយពួកមួយរមែងកើតក្នុងគភ៌ សត្វទាំងឡាយពួកមួយដែលធ្វើអំពើបាបលាមកជាប្រក្រតីរមែងទៅកើតក្នុងនរក សត្វទាំងឡាយពួកមួយទៀតដែលមានគតិល្អគឺអំពើល្អជាប្រក្រតី រមែងទៅកាន់ស្ថានសួគ៌ ឯព្រះអរិយបុគ្គលទាំងឡាយដែលមិនមានអាសវៈរមែងបរិនិព្វាន ។

*គាថាក្នុងរឿងតយោជន*

(១១) បុគ្គលធ្វើបាបកម្មហើយ ទោះទៅនៅក្នុងកណ្តាលអាកាសក្តី ក្នុងកណ្តាលសមុទ្រក្តី ចូលទៅកាន់បន្លោះភ្នំទាំងឡាយក្តី ក៏គង់មិនរួចអំពីបាបកម្មឡើយ ។

## ធម្មបទេ ទសមោ ទណ្ឌវគ្គោ

ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្ថដ្ឋិតោ មុញ្ចេយ្យ បាបកម្មា ។

### សុប្បពុទ្ធសក្យវត្ថុ

(១២) ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ ។

បាបវគ្គោ នវមោ សមត្តោ ។

### ឆព្វគ្គិយភិក្ខុវត្ថុ

(១) សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

ម្យ៉ាងទៀត បុគ្គលស្ថិតនៅក្នុងប្រទេសនៃផែនដីឯណាហើយ គប្បីរួចអំពីបាបកម្ម ប្រទេសនៃផែនដីនោះមិនមានឡើយ ។

*គាថាក្នុងរឿងសុប្បពុទ្ធសក្យ*

(១២) បុគ្គលធ្វើបាបកម្មហើយ ទោះស្ថិតនៅក្នុងកណ្ដាលអាកាសក្ដី ក្នុងកណ្ដាលសមុទ្រក្ដី ចូលទៅកាន់ចន្លោះភ្នំទាំងឡាយក្ដី ក៏គង់មិនរួចអំពីបាបកម្មឡើយ ម្យ៉ាងទៀត មច្ចុគឺសេចក្ដីស្លាប់ មិនគប្បីគ្របសង្កត់បាននូវបុគ្គលដែលស្ថិតនៅក្នុងប្រទេសនៃផែនដីឯណា ប្រទេសនៃផែនដីនោះមិនមានឡើយ ។

បាបវគ្គ ទី ៩ ចប់

*គាថាក្នុងរឿងឆព្វគ្គិយភិក្ខុ*

(១) សត្វទាំងអស់តែងតក់ស្លុតអំពីដំបង សត្វទាំងអស់តែងភិតភ័យអំពីសេចក្ដីស្លាប់ បុគ្គលគួរធ្វើខ្លួនជាឧបមាថា (អាត្មាអញតក់ស្លុតភិតភ័យយ៉ាងណា សត្វទាំងអស់ក៏តក់ស្លុតភិតភ័យយ៉ាងនោះដែរ) ហើយកុំគប្បីសម្លាប់ដោយខ្លួនឯង និងកុំគប្បីប្រើគេឲ្យសម្លាប់សត្វដទៃឡើយ ។

# ធម្មបទេ ទសមោ ទណ្ឌវគ្គោ

### ឆព្វគ្គិយវត្ថុគាថា

(២) សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

### សម្ពហុលកុមារវត្ថុគាថា

(៣) សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។

## ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឆព្វគ្គិយ*

(២) សត្វទាំងអស់តែងតក់ស្លុតអំពីដំបង. ជីវិតជាទីស្រឡាញ់របស់សត្វទាំងអស់ បុគ្គលគួរធ្វើខ្លួនជាឧបមាថា (អាត្មាអញតក់ស្លុតអំពីដំបង មានជីវិតជាទីស្រឡាញ់យ៉ាងណា សត្វទាំងអស់តក់ស្លុតអំពីដំបង មានជីវិតជាទីស្រឡាញ់យ៉ាងនោះដែរ) ហើយកុំគប្បីសម្លាប់ដោយខ្លួនឯង នឹងកុំគប្បីប្រើគេឲ្យសម្លាប់នូវសត្វដទៃឡើយ ។

*គាថាក្នុងរឿងសម្ពហុលកុមារ*

(៣) អ្នកណាជាអ្នកស្វែងរកសេចក្ដីសុខ ដើម្បីខ្លួនឯង ហើយបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខដែរដោយដំបង អ្នកនោះលុះទៅកាន់បរលោកនាយ នឹងមិនបានសេចក្ដីសុខឡើយ ។ អ្នកណាជាអ្នកស្វែងរកសេចក្ដីសុខដើម្បីខ្លួនឯង ហើយមិនបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខដែរ ដោយដំបង អ្នកនោះលុះទៅកាន់បរលោកនាយ តែងបានសេចក្ដីសុខគ្រប់ប្រការដោយពិត ។



លោកសង្ឃភូមា កំពុងមើលធម៌ក្នុងក្រាំង ដែលធ្វើដោយកំណាត់ចីពរខ្មុកម្រាក់ ។

# ច្បាប់ប្រដៅ ៨៣

# ប្រុស-ស្រី

របស់ក្រុម ង៉ុយ

# ច្បាប់ប្រដៅ

អ្នកព្រះភិរម្យភាសាអ៊ូ ជាគ្រូបង្រៀនក្នុងស្រុកខ្មែរ ប្រដៅ
ពួកក្មេងកូនអ្នកស្រែ គិតកែជាពាក្យប្រាំពីរពិត ។ ប្រដៅកូន
ចៅទាំងប្រុសស្រី កើតមកលើដីឲ្យបេះគិត ខ្លះមានកំណើត
ផតគំនិត ខ្លះមានជីវិតផតប្រាជ្ញា ។ ប្រញាប់ប្ដូរច្បាប់នេះឲ្យបេះ
ដឹង ឲ្យប្រិតខំប្រឹងពិចារណា បំណាច់កើតមកមានពង្សា
កុំឲ្យគេថាអាក្រក់បាន ។ កិច្ចការគួរសមគិតឲ្យអស់ កុំឲ្យ
បន្ថោះនៅសល់ខាន របស់ខុសត្រូវទាំងប៉ុន្មាន ប្រិតប្រុងក្នុង
ប្រាណទើបបានប្រាជ្ញ ។ រៀនច្បាប់ឲ្យឆ្អិនកុំឲ្យឆៅ បេះល្អិត
ក្នុងត្រៀអ្នកខ្លៀវខ្លាប មនុស្សមានបំណេះមានអំណាប បង់ឈ្មោះ
មនុស្សកាបកុំស្ដីភោង ។ ស្ដីការមុខក្រោយកុំឲ្យភ្លាត់ កុំអាង
តែមាត់មានប្របោង បើមនុស្សព្រហើនហួសទំនង កុំតោង
តទល់កើតល្វល់ទាស់ ។ អាដែងមនុស្សពាលពោលមិន
ពិត កុំយកធ្វើមិត្តខាតរបស់ មនុស្សណាសុចរិតចិត្តសប្បុរស
ស្រឡាញ់ឲ្យស្មោះចិត្តឲ្យស្មើ ។ កើតមកជាមនុស្សកុំល្ងង់ពេក

រៀនស៊ីរៀនដេកហើយរៀនដើរ រៀនបេះប្រសប់គាប់ប្រសើរ កុំគ្នាងារក្លើអ្នកមានសក្តិ ។ កុំមានតែរូបនឹងជង្ហើម រៀនដេកជាដើមដេកឆាប់ភ្ញាក់ ពូថៅដាវវែងលំពែងផ្គាក់ ទុកដាក់កុំឲ្យឃ្លាតពីខ្លួន ។ ទុកហើយស្ទៀមស្ទាត់កុំមាត់ក ក្រែងមនុស្សមិនល្អភាលបព្ធួន បច្ឆិមយាមម៉ោង ៣ ឬម៉ោង ៤ ភ្ញាក់ឡើងដឹងខ្លួនកុំដេកវិញ ។ បើកភ្នែកស្រឡះរហ័សក្រោក ទឹកផ្តិលត្រឡោកលុបមុខចេញ ជក់ថ្នាំស៊ីស្លាគិតលក់ទិញ ទោះខាតបំណេញគិតឲ្យស្រេច ។ ទំនិញអ្វីៗទោះថ្លៃថោក លៃលកលក់ដាច់លក់មិនដាច់ ផ្លែឈើទុំខ្ចីឬត្រីសាច់ ទាត់ក្បាប់វាយលេខបែកឲ្យត្រូវ ។ រកស៊ីលក់ដូរកុំបោលស្រែ របស់កេរ្តិ៍ម៉ែនឹងកេរ្តិ៍ឪ រវាងដប់ពីរខែបីរដូវ កុំឲ្យស្រែកស្រូវពីជង្រុក ។ ទ្រព្យស្រូវនេះឯងជាដើមទុន ខែមាឃផល្គុនប្រមូលទុក គ្រឿងស៊ីជាដើមអម្បិលប្រហុក ឲ្យមានគ្រប់មុខកុំសុំគេ ។ នៅអ្នូលបងប្អូនកូនប្រពន្ធ ចូបចិត្តឲ្យធ្ងន់កុំវាយជេរ បើឃើញខ្លះខ្ជិលនៅទំនេរ កុំស្ទៀមទទេដាស់តឿនទៅ ។ កុំជេរបន្ទោសដាក់មុខភ្ញៀវ ក្រែងក្មេងឈាមរវាមិននៅ ក្មេងស្រីកុំស្ដី

អស្សុគ្រាមជ្រៅ ក្រែងខឹងឃោរឃៅទៅជាខូច ។ និយាយ ឲ្យមើលឫកមារយាទ មើលមុខមើលមាត្រទោះធំតូច កុំងាយ តែមាត់ភ្លាត់ប៉ផ្លូច ក្រែងវាប្រដូចលើឫកខ្លួន ។ បើម៉ែនឹង បេះប្រដៅ;គ យើងគួរគំនិតគិតបែបប្លូន បើឯងមិនខំឲ្យម៉ាំ មួន ក្រែងប្អូនវាឆ្លងឆ្លើយកើតឈ្លោះ ។ បើទុកជាខ្លួនតូចទាប ពិត ប្រុងម្យាទគំនិតឲ្យបានខ្ពស់ ឲ្យខ្ពើមពាក្យក្មេងស្តីបញ្ចោះ រក្សាកេរ្តិ៍ឈ្មោះឲ្យបានល្អ ។ កុំរៀនមាត់ល្អិលស្តីជ្រុលស ប្រ-ពន្ធខឹងហួសកុំឆ្លើយត មនុស្សឈ្មោះនឹងស្រីរកស៊ីក្រ បាន បាយសំឡក្តីទិញហោក ។ គ្រឿងស៊ីគ្រឿងដេកទិញឲ្យថ្លៃ ក្រែងពេលយប់ថ្ងៃមានភ្ញៀវមក ធ្វើផ្ទះធំស្តុកស្រណុកជ្រក ផ្ទះ បាយស្មែកស្មោកឆាប់រុះរើ ។ កុំខ្ជិលព្រឹកអពមង្គល កុំអាង បីល្វល់មិនបានធ្វើ ខាងក្រោមបាក់ខ្ទេចលេចខាងលើ អ្នក ផងគេមើលគេមាក់ងាយ ។ បងប្អូនរាប់អានដោយរលឹក រៀបបាយរៀបទឹកគួរសរីករាយ គេឃើញបាយឆ្ងាញ់ផ្ទះទូលាយ គេទៅនិយាយយើងល្អឈ្មោះ ។ រៀនស៊ីកុំឲ្យស៊ីឆ្អែតជ្រុល ដូចគេបំពុលបាយតឹងពោះ ដេកលង់វិញ្ញាណលោមានគ្រោះ

ប្អូទមនុស្សពោរខ្លាំងមកកំហែង ។ ភ្ញាក់ឡើងម៉ឹងម៉ង់ទ្រង់មមើ បើកភ្នែកភ្លើ ៗ បេះតែផ្សែង កាំបិតពូថៅដាវលំពែង ប្រឡី កន្លែងរកមិនទាន់ ។ ឯងដៃទទេគ្មានប្រដាប់ ពោរវាយបាក់ កាប់ស្លាប់ព្រោះស្លន់ វាយកមាសប្រាក់អស់រយពាន់ ខ្លះគ្រាន់ តែល្បួសទៅដេកពេទ្យ ។ រៀនសុីឲ្យល្មមកុំពមល្មោភ កុំ លេបរំលោភឬកដូចប្រែត តែសុីច្រើនពោកច្រើនកើតហេតុ សុី ហួសពីផ្អែតខានធ្វើការ ។ ចូលរកដំណោកទាស់ទំនួល ដេក ផ្អៀងមិនស្រួលល្ហួលដេកផ្ងារ ដង្ហើមឡេះឡះអន្ទះសា ក្រោក ដើរទៅណាហែលហាល់ហត់ ។ ដើរលេងផ្ទះគេទោះជិតឆ្ងាយ គេហៅសុីបាយឲ្យខំអត់ អង្ករគេប្រាកដឹងកំណត់ ឲ្យល្មមតែ មាត់កូនចៅគេ ។ ឯងចូលទៅផងប្អូនលោខ្វះ មិនផ្អែតអ្នក ផ្ទះគេខ្សឹបដេរ គេហៅយកគួរជាងទំនេរ បើឯងថាទេគេមិន ខឹង ។ សាប់សាលោហិតទោះជិតឆ្ងាយ ទៅមុនពេលបាយ គេបានដឹង គេដាំស្លលើសហើយម្តងហ្នឹង គេប្រឹងគួរសមកុំ ប្រកែក ។ ប្រការមួយទៀតឲ្យឈ្វេងយល់ មើលពេលគេ រវល់រៀបទូលរែក កុំប្អែមគគូធកកិលប្អែក កុំភរដដែកគេមិន

ស្តាប់ ។ អង្គុយយូរពេកគេកើតម្ទេញ គេបង់បណ្តោញឲ្យបុះ
ធាប់ គេធ្វើជាតៀនកូនប្រើប្រាប់ ឲ្យបុះប្រញាប់ទៅធ្វើការ ។
វេរង់ចាំស្អែកគេកើតស្អប់ គេធុញគេថប់គេមិនថា បើគេបន្ទយ
ប្រអប់ស្លា ប្រាជ្ញាគេតៀនឲ្យទៅផ្ទះ ។ បើពេលព្រលប់ជាង
ទំនេរ ទៅលេងនឹងគេគេជិះ សួររឿងសាស្ត្រាអវតារព្រះ បើ
ខ្លួនចាំច្បាស់គួរសម្តែង ។ មើលមុខគេស្មួតមាត់គេស្ងាប ខ្លះ
ទ្រាលខ្លះក្រាបពែនកន្ទែង បើទុកជារឿងទោះនៅវែង សង្ខេប
លើកលែងលាគេទៅ ។ ម្យ៉ាងទៀតផ្ទះគេទើបការប្ដី ប្រពន្ធ
នឹងប្ដីចាស់មិននៅ កុំនាំជជែកដល់យប់ជ្រៅ ដ្បិតគេមិនត្រូវ
ការបង់ស្តាប់ ។ គេអរតែស្ងាត់គេនឹងដេក កុំនៅយូរពេកបុះ
ឲ្យធាប់ គេស្ងាបញយ ៗ ហ្នឹងគេប្រាប់ បេះប្បាប់ឲ្យស្គាល់
អធ្យាស្រ័យ ។ ម្យ៉ាងទៀតផ្ទះគេមានក្រមុំ កំឡោះជួបជុំទាំង
យប់ថ្ងៃ យើងវាងឲ្យផុតកុំសង្ស័យ ក្រែងគ្រោះបង្រៃជាបដល់
ខ្លួន ។ ចិត្តឯងទៅមកថាត្រង់ស្មោះ អាពួកកំឡោះវាគុំគួន
ក្រែងគ្រោះអកុសលមកផ្តល់ប្អូន វាពួនសំងំចាំសំឡាប់ ។
បើរស់ក៏របួសអន្ទការ មិនដឹងឈ្មោះណាវាលបកាប់ បើឯង

សង្ស័យប្ដឹងប្រាប់ ទាស់ច្បាប់ឯងគ្មានអាងសាក្សី ។ ហេតុ
នេះបើដើរមានធុរៈ រកម្នាក់ពីរនាក់បានជាបី ក្រែងមានគេ
បាត់របស់អ្វី ប្រកាន់កើតក្ដីយើងមានគ្នា ។ កុំដើរតែឯងក្រែង
មានគ្រោះ វិលមុខបុកពោះគ្រុនរងា ជួយចាប់ជួយជាន់គ្រាន់
បើជា សង្គ្រោះកាលគ្រាមានធុរៈ ។ ដើរជិតផ្ទះគេពេលគេ
ដេក កុំក្អេងក្អាងពេកគេផ្អើលភ្ញាក់ និយាយឲ្យល្មមគេស្ដាប់
ជាក់ កុំខ្សឹបលបលាក់គេសង្ស័យ ។ ដើរកាន់រំពាត់ប្រយ័ត្ន
គ្រោះ ក្រែងក្អែបខ្មួយពស់គោះទាត់វៃ កុំកាន់បៀកផ្គាក់ឲ្យហៅ
ដៃ គេម៉ែថាយើងរកកាប់គេ ។ បើមានខឹងឈ្លោះនឹងឈ្មោះ
ណា កុំដើរបរហារបញ្ជោរជេរ អ្នកផងនឹកស្អៀសមិនល្អទេ បើ
គេប្រកាន់រវល់ប្រកែក ។ ប្រការមួយទៀតមានទោសខឹង ថ្ងៃ
នេះបង់ប្ដឹងឲ្យបាំស្អែក ស្អប់ជ្រុលកុំអាលឲ្យលែក រលង់ទឹក
ភ្អែករលត់ខឹង ។ រលោះរលាយរលីងស្អាត គិតឃើញខ្លាច
ខាតលោខានប្ដឹង កុំស្អប់ថ្ងៃណាថាថ្ងៃណឹង ឲ្យប្រឹងខំអត់កុំ
អាលស្ដី ។ បើឮគេឈ្លោះកុំចង់ស្ដាប់ ក្រែងគេប្រាប់ធ្វើសាក្សី

ស័ក្តិសិទ្ធិប្រាកដស្បថមិនថ្វី  អ្នកម្ខាងបាញ់ក្តីវាកើតក្តៅ ។
រកស៊ីទូកក្តារពឹងក្តោង សត្វក្តាមពពងប្រតោងស្មៅ អ្នករកស៊ី
ជ្លូញអាងជង្ហៅ  រៀបចំកូនចៅអាងប្រពន្ធ ។ រៀបរែករែក
ពាក់កណ្តាល  កុំដាក់ម្ខាងស្រាលផ្លុកម្ខាងធ្ងន់  ផ្គាប់ចិត្តអ្នក
ស្រុកគង់ទ្រព្យធន  ផ្គាប់អ្នកមានបុណ្យគង់កេរ្តិ៍កោះ ។ កើត
កាលវាលគុម្ពពីព្រោះស្រី  កិច្ចការអ្វីៗ ស្តីឱ្យស្មោះ  ប្រពន្ធ
ចិត្តស្មើកុំញ៉េះញ៉ោះ  លលេងឡេះឡោះវាឡើងដៃ ។ ឡើង
ដូចមេម៉ាយក្មេងស្លៀកស  រូបរាងស្អាតល្អស្រស់ប៉ប្រៃ  ប្រព្រឹត្ត
ស្មាទានសីលសព្វថ្ងៃ  បង់ដាប់និស្ស័យនឹងលោកសង្ឃ ។
លោកសូត្រធម៌អាប់បេះបាំស្ងាត់  ទ្រស្តីសំលល្អិលមាត់ចិត្តមិន
ត្រង់  ត្រេកឃើញមេម៉ាយស្រស់កំប្លង់  សោសិកបាកបង់
សិក្ខាបទ ។ ជំណ្តាំងសិស្សឯងតែងរៀបការ  បង្ហាញធម៌អាប់
បកសង្កត់  គាស់គុម្ពសង្កែមិនឲ្យហាត់  រកស៊ីខ្លាចខ្សត់ភ្លាត់
សីលទាន ។  កាលនៅជាសង្ឃធ្វើជាគ្រូ  បរិស្លាម្ចូពោរ
ជើងពាន សឹកមកធ្វើប្តីស្រីចង់មាន ពេលណាវាឃ្លានវាហ៊ាន
ប្រើ ។ ពីដើមលុតក្រាបថ្វាយបង្គំ ឆ្លើយទានប្រោសខ្ញុំគ្រូគ្រាន់

បើ សិកធ្វើជាប្តីស្រីចិត្តស្មើ អញអុយអឺអើវ៉ាលែងខ្លាច ។
កាលនៅជាសង្ឃមានបុណ្យថ្កើង សំរួមឫកឆ្មើងឡើងអំណាច
សិកមកធ្វើប្តីស្រីតាំងកាច តាំងគៀងអ្នកប្រាជ្ញបុះរណ្តៅ ។
ពីព្រោះស្រាលបុណ្យធ្ងន់ខាងបាប មានគេលុតក្រាបតែសិស្ស
ក្រៅ ដល់កើតកូនខ្ចីស្រីហ៊ានហៅ ប្រើដាំទឹកក្តៅឲ្យវាងូត ។
វាងើកឲ្យហុចត្រឡោកផ្តិល កូនជុះកកិលលាងគគូថ ទឹក
សើមគគុលលើរនូត ប្រើជូតរនាបក៏សឹងបាន ។ ហៅការឡ-
កិណាំស្រីជួប្នេះ សង្ខេបឈប់ស្នេះបង្អង់ខាន ស្រីម្យ៉ាងដឹង
គុណព្រះកម្មដ្ឋាន មិនហានប្រើប្តីខ្លាចនរក ។ ធ្វើការមិនបាំ
ឲ្យប្តីជួយ ឃើញប្តីនឿយព្រួយប្រញាប់គក់ ផ្គាប់បាយបំណី
បារីជក់ រកស៊ីរីកមិនប្រហំ ។ ឃើញគេប្រជុំរៀនធម៌អាថ៌
តាំងចិត្តរក្សាកាន់សីលប្រាំ បួនបួលឧបោសថបំផុតកម្ម មិន
ទ្រាំដេកត្រាំក្នុងកងទុក្ខ ។ ហេតុនេះអស់ស្រីផងទាំងឡាយ
ឲ្យដឹងគុណម្តាយគុណអាពុក ត្រាប់រុតស្រីល្អតទៅមុខ ទំនុក
ដំណាលប្រាប់កូនចៅ ។ កើតមកជាមនុស្សបុថុជ្ជន រកប្តី
ប្រពន្ធឲ្យមើលផៅ មើលភាពខ្ពស់ទាបល្អសខ្មៅ កាចស្លូត

ល្ងង់ខ្លៅមើលសាវតារ ។ ទូន្មានទាំងអស់នោះប្រុសស្រី បើចង់បានប្ដីកុំធ្វេចធ្វា ខំឆ្លៀតរកស៊ីរៀនធ្វើការ ចាំស្ដាប់មេបាគេទុកដាក់ ។ ប្រដៅនេះមៅទាំងស្រីប្រុស ចូរចាំទុកចុះទាំងពីរនាក់ កុំឃើញគេស្មោះលោព្រមស្ម័គ្រ ស្មន់ស្មើបំបាក់មុខមេបា ។ ដណ្ដឹងតាមផ្លូវទើបត្រូវច្បាប់ រៀបតាមសណ្ដាប់ពីដូនតា បានប្ដីប្រពន្ធរួមវាសនា គិតការរកស៊ីសន្សំទ្រព្យ ។ រៀនច្បាប់សង្គ្រោះទាំងប្រុសស្រី ប្រពន្ធខ្លាចប្ដីទើបបានគាប់ប្ដីក្រែងប្រពន្ធតាមទំលាប់ បើរាប់សង្គ្រោះមានម្យ៉ាង ៤ ។ បំណែកខាងស្រីស្រួវអង្ករ សំអាតឡូល្អសូដណ្ដាំ ខអាំងអន្លក់ព្រហុកម៉ាំ បំណាំប្ដីធ្លាប់ទទួលទាន ។ មួយទៀតត្រកូលសាច់ខាងប្ដី មករកការអ្វីពេលស្រែកឃ្លាន បើខ្វះឡខ្វារទាល់តែមាន សន្និដ្ឋានជាដូចត្រកូលឯង ។ សង្គ្រោះមួយទៀតគ្រប់ជាប៉ី កុំបេញធិតប្ដីឥតកោតក្រែង សង្គ្រោះជាប្អូនផ្ទះសំបែង សំអាតកន្លែងទីដំណេក ។ ត្រូវខ្វនជាស្រីបោសជំរះ មុខផ្ទះក្រោមផ្ទះកុំខ្ជិលពេក សង្គ្រោះគ្រប់ប្រាំបិត្តត្រែក បំណែករបស់ទ្រព្យខាងប្ដី ។ សំពត់អាវខោមាន

ប៉ុន្មាន គោមកែរហែសបានសុទ្ធតែថ្មី ហូលព្រែផាម្លូងមាន ពីរបី ត្រូវខ្លួនជាស្រីបែរក្បា ។ កុំឲ្យកណ្ដុរកន្លាតកាត់ គោម កែរប្រយ័ត្នកុំឲ្យធ្លា សង្គ្រោះនេះគ្រប់ប្រើប្រការ កុំឲ្យគេហាឥត គំនិត ។ បំណែកខាងប្រុសប្ដីមប្រពន្ធ ស្រឡាញ់លើសលប់ ស្មើជីវិត សង្គ្រោះមួយទៀតជាពីរពិត ប្រពន្ធខុសចិត្តកុំវាយ ធាក់ ។ កុំជេរបញ្ចោរជៀលដល់ពូជ ប្រដូចសន្តានប៉ុន្មាននាក់ ទោសនេះធ្ងន់ណាស់ដល់បែកបាក់ បែកបង់ទាំងប្រាក់ពីព្រោះ មាត់ ។ បំណែកមួយទៀតគ្រប់ជាបី ឃើញស្រីឯទៀតកុំគិត ក្បត់ ប្រពន្ធតែមួយមិនក្រខ្សត់ ខំអត់កុំបង់បានពីរបី ។ សង្គ្រោះជាបួនគ្រឿងប្រដាប់ សម្រាប់ប្រើប្រាស់ការប្រុសស្រី ការប្រើលើផ្ទះប្រើលើដី ឲ្យមានកុំខ្ចីគេមកប្រើ ។ សង្គ្រោះ គ្រប់ប្រាំបំណាំប្រុស ទៅណោះទៅណេះខ្លួនអ្នកដើរ បាន លុយបានកាក់គាប់ប្រសើរ ត្រូវយកមកផ្ញើដល់ប្រពន្ធ ។ នេះ ទើបប្រពៃសុខសប្បាយ បើចង់យកបាយចេញធ្វើបុណ្យ ឬ ចេញទៅទិញទ្រព្យស្រាលធ្ងន់ ប្ដូបចិត្តឲ្យទន់ទើបបានសុខ ។ បានសួរស្រុះស្រួលចិត្តជាមុន ចេញប្រាក់ដើមទុនទៅជាមុខ

ធ្វើបុណ្យតបគុណម្ដាយអាពុក ចង់ចៀសទោសទុក្ខកុំទាស់ទែង ។ កាលការមេបាបានប្រដៅ រំលឹកកូនចៅពីរកន្លែង មួយខឹងមួយអត់ប្រាកដស្តែង បើស្តីឲ្យវែងៈច្រើនប្រការ ៗ កុំខឹងប្រកាន់ឈ្លោះប្រកែក ប្រកួតជជែកបែកប្រាជ្ញា នោះហៅមិនចាំពាក្យមេបា ខឹងជេរផ្ដាសាព្រួសុះសាយ ៗ ខឹងឆេះឆួលក្ដៅពីអារទោ ប្រុសអាងបញ្ចោរស្រីជេរម្ដាយ ប្រពន្ធភាយក្អមអស់អន្តរាយ ប្ដីភាយឆ្នាំងបាយឆ្នាំងសំឡ ។ ប្រពន្ធសំពងអស់អុងអាង ប្ដីតាំងភាយថ្លាងយ៉ាងល្អ ៗ ថ្ងៃក្រោយបាត់ខឹងដឹងជាក្រ ត្រដះទៅទិញមកប្រើទៀត ។ អាម្យ៉ាងមិនក្អេងក្អាងតែមាត់ ជើងដៃសើយលាត់ក្រវាត់គាត ប្រពន្ធកន្ត្រាក់កាំបិតស្មៀត ប្ដីរៀតកន្ត្រាក់បានពូថៅ ។ ប្រពន្ធអាងបាក់ប្ដីអាងកាប់ មិនស្លាប់មុខសះនៅក្រឡៅ លែងគ្នាស្រឡះសះដំបៅ អាណិតកូនចៅយកគ្នាវិញ ។ នេះឯងហៅកោងកាចខុសខ្នាត តែខឹងហើយខាតមិនចំណេញ សង្គ្រោះគ្រប់ប្រាំចាំទន្ទេញ នេះពេញជាសុខយូរអង្វែង ។ ទាំងស្រីទាំងប្រុសសង្គ្រោះជាប់ រក្សាឲ្យសព្វគ្រប់កន្លែង ប្រពន្ធ

ខ្លាបថ្មីៗត្រូវក្រែង ដូចបានសម្ដែងរៀបរៀងមក ។ ពាក្យ
ចាស់ថាបេះពីព្រោះរៀន របស់ធនធានមានពីរក ប្រពន្ធចាំ
រ៉ាប់ទទួលយក សៃលកទុកដាក់មើលនាយអាយ ។ លុយ
កាក់ទុកដាក់ទីសម្ងាត់ ប្រយ័ត្នកុំឲ្យបាត់អន្តរាយ បំណីណា
ឆ្ងាញ់កុំទុកឆ្ងាយ បើតិចកុំស្ដាយស៊ីឲ្យអស់ ។ ត្រូវរកឲ្យមាន
ច្រើនសល់ផល ទុកដាក់ដំកល់ដោយកៀនកោះ ផ្ទះមួយមិន
ត្រូវឲ្យគ្មានសោះ របស់ឲ្យមានទុកសំចៃ ។ ក្រែងយប់ព្រលប់
ភ្ញៀវមកត្រង់ ឬមានលោកសង្ឃមកដល់ថ្ងៃ បានផ្ដិលគុះ
ថាសមានយ៉ាងថ្លៃ ឲ្យទៀយតែដៃដែលសំអាត ។ មនុស្ស
រស់នឹងស៊ីៗឲ្យឆ្ងាញ់ កុំសួរកំណាញ់កាញ់ខ្លាបខាត ឬក
ថោកកុំយកជាក្បួនខ្នាត សង្ខាតឲ្យមានគ្រប់ប្រដាប់ ។ អា
មនុស្សលោភពេកនេះកុំតាម ខ្ជិលក្រឡេមឡោមនេះកុំត្រាប់ កំ-
ណាញ់តិរិយរាសីអាប់ រៀនមើលជម្រាប់អ្នកត្រឹមត្រូវ ។ បើពូជ
យើងធ្លាប់គេរាប់មុខ អាពុកធ្លាប់មានជង្រុកស្រូវ យើងខំធ្វើ
ស្រែតាមម៉ែឪ រកស៊ីតាមផ្លូវគន្លងចាស់ ។ បើម្ដាយអាពុកយើង
ធ្លាប់ក្រ យើងប្រឹងត្រដរកុំឲ្យខ្វះ កុំឲ្យអ្នកស្រុកគេជៀលត្មះ

ថាយើងខ្ជិលណាស់ពីដូនតា ។ ហើយយើងមានតោកអារក្ខ
កុំរលំទុកដាក់ថែរក្សា នាំខាតទៀនធូបបេកម្លូស្លា មិនដែលនរ
ណាគេខានស្លាប់ ។ អាយុរាល់រូបទាំងប្រុសស្រី មានវែងមាន
ខ្លីមានយូរឆាប់ ស្រេចនៅសំណាងសាងមកស្រាប់ គួរស្តាប់
ព្រះធម៌ជាប្រធាន ។ គួរជឿតែគុណរតនត្រ័យ សព្វថ្ងៃប្រព្រឹត្ត
សុំស្មាទាន ភាវនារំឭកនឹកផ្លូវឈាន ឈោងយកនិព្វានជា
ឋានសុខ ៚ ឥឡូវនៅក្នុងបច្ចុប្បន្ន ឲ្យបេះដឹងគុណម្តាយ
អាពុក ទាន់គាត់រស់នៅបានឃើញមុខ បំណីបំណុកតាម
បំណង ។ ឲ្យបែងបំណែកប្រពន្ធកូន បំណូលមាត់ខ្លួនគួរ
បង្អង់ បង្អែមបំអាបគួរផ្ចិតផ្ចង់ ជំរង់ទៅជូនអាពុកម្តាយ ។
កាលគាត់បញ្ចឹមយើងរស់មក រត់រកទូលរែកពីជិតឆ្ងាយ
បំណីណាឆ្ងាញ់បេះបែកបាយ បើតិចអ្នកម្តាយអាពុកអត់ ។
សំពត់អាវឲ្យស្លៀកពាក់ល្អ គាត់ស្លៀកតាមក្រតាមខ្សោយខ្សត់
ស្រេកឃ្លានមិនហ៊ានពិសាក្បត់ ស្ទូបេះពីមាត់ឲ្យទៅកូន ។
រាប់រៀបច្រើនណាស់មិនមែនតិច មិនគួរបំភ្លេចឲ្យឈឹងស្ងួន
រាប់រយរាប់ពាន់មិនទាន់ធួន តបស្លាប់ទាំងខ្លួនមិនទាន់ដល់ ។

បើចង់ឲ្យរួចលែងជំពាក់ គួរបួសសំណាក់សាងមគ្គផល រៀនសូត្រឲ្យសព្វកុំឲ្យសល់ នាំធម៌ទៅតបស្នងសងគុណ ។ ឲ្យគាត់រក្សាសីលដរាប ឲ្យរួចចាកបាបទៅកាន់បុណ្យ ព្រះធម៌នេះទើបមានទម្ងន់ ថ្លឹងស្មើនឹងគុណអាពុកម្ដាយ ។ កើតមកជាខ្មែរឲ្យមានខ្មាស ពូជពេញពុទ្ធសាសន៍រាល់រូបកាយ បើចង់ចៀសចាកចតុរាបាយ កុំក្លាយក្លែងចិត្តចោលសាសនា ។ គួរកាន់សីលប្រាំប្រាកដ ឲ្យស្គាល់កម្មបថដប់ប្រការ ប្រកបទាំងចិត្តជាប់មេត្តា ទើបនឹងរក្សាសីលខ្ជាប់ខ្ជួន ។ កុសលកម្មបថមានបាឡី មនោកម្មបីវចីបួន កាយកម្មបីទៀតគ្រប់ចំនួន បូកផ្សំថែមបួនបានជាដប់ ។ សង្ខេបដោយបែបបទបរិយាយ មិនបានអធិប្បាយឲ្យសាយសព្វ សាកសួរឲ្យដឹងរំពឹងរាប់ ឲ្យចេះចាំចប់ម្ល៉េះឯងហោង ។៚—

# រឿងព្រេងខ្មែរ

## រឿងបុរសកុហក ៤ នាក់

មានកាលមួយថ្ងៃបុរសកុហក ៤ នាក់មកជួបជុំជិតគ្នា រួមគំនិតគិតដើរទៅរកឆបោកបញ្ឆោតយកទ្រព្យសម្បត្តិគេ នៅគេហស្ថានឆ្ងាយពីទីលំនៅរបស់ខ្លួន ដល់ព្រមព្រៀងស្រេចហើយក៏នាំគ្នាដើរទៅបានចម្ងាយប្រហែលជា ៨ គីឡូម៉ែត្រ ស្រាប់តែជួបប្រទះនឹងតាចាស់ជួនចាស់ពីរនាក់ ធ្វើចម្ការក្របាសនៅក្បែរមាត់ទន្លេមួយដាច់ឆ្ងាយពីស្រុក-ភូមិគេ ។ បុរសកុហក ៤ នាក់នោះបានដំណឹងថា តាចាស់ជួនចាស់នេះជាអ្នកមានទ្រព្យសម្បត្តិច្រើនគ្រាន់បើ ។ ដូច្នេះយើងត្រូវនាំគ្នាឈប់នៅទីនេះ ដើម្បីនឹងភូតកុហកយកទ្រព្យសម្បត្តិតាចាស់ជួនចាស់នេះឲ្យបាន នៅបន្តិច បុរស ៤ នាក់នោះសួរទៅតាចាស់ជួនចាស់ថា ឱតា-យាយអើយ យើងខ្ញុំទាំង ៤ នាក់នេះមកពីស្រុកឆ្ងាយណាស់ ខំត្រាច់ដើររកអ្នកឯណាដែលចេះដឹងរឿងព្រេងពីបុរាណនាយមកនោះ ព្រោះយើងខ្ញុំចង់ដឹងណាស់

តែវេលានេះបានមកជួបនឹងតា-យាយប្រហែលជាចេះដឹងខ្លះមិនខានរឿងពីបុរាណមក បើដូច្នេះសូមតាយាយអាណិតមេត្តានិទានរឿងព្រេងអ្វីមួយឲ្យចៅស្តាប់បានបន្តិច តាចាស់ដូនចាស់ក៏ឆ្លើយតបទៅបុរសទាំង ៤ នាក់វិញថា ឱចៅអើយ តាយាយគ្មានចេះរឿងអ្វីទេ តាំងពីក្មេងដល់ចំណាស់តាយាយប៉ុណ្ណោះនេះ សូមចៅអញ្ជើញទៅរកអ្នកឯទៀតចុះ បុរសទាំង ៤ ក៏ជំរាបទៅតាយាយវិញថា ឱតាយាយអើយ បើប្រសិនជាមានគេចេះដឹងរឿងព្រេងនោះតាយាយចូលចិត្តចង់ស្តាប់ឬទេ ថាឱចៅអើយ តាយាយចង់ស្តាប់ណាស់ តែនឹងរកអ្នកឯណាចេះរឿងនោះគ្មាន បុរសទាំង ៤ នាក់នោះក៏ជំរាបទៅតាយាយវិញដោយគួរកិច្ចកលបំណងប៉ងនឹងបោកយកទ្រព្យសម្បត្តិតាចាស់ដូនចាស់នោះឲ្យបានដោយងាយថា យើងខ្ញុំទាំង ៤ នាក់នេះចេះខ្លះដែរ ព្រោះបានដឹងពីជីតាខ្ញុំគាត់និទានប្រាប់ តែរឿងនេះបើនិយាយទៅកាលណាតាយាយគោងតែជឿទើបខ្ញុំនឹងនិទានប្រាប់បាន តាយាយក៏ព្រមព្រៀងតាមឲ្យបុរសទាំង ៤ នាក់នោះនិយាយ

បុរសទី ១ ក៏ចាប់អធិប្បាយរឿងកុហកជាដំបូងឡើងថា កាលខ្ញុំនៅក្នុងផ្ទៃម្ដាយខ្ញុំបានចំនួន ៣ ខែ ម្ដាយខ្ញុំគាត់បង់ពិសាផ្លែធូរេនសោមុខផ្ទះខ្ញុំ ដើមវាមានកំពស់ប្រហែលជា ២០ ម៉ែត្រហើយមានផ្លែតែ.១ផង នោះគាត់មិនដឹងជានឹងគិតដូចម្ដេចនឹងបានផ្លែឈើនោះមកពិសា លុះខ្ញុំបានដឹងថាគាត់បង់ពិសាផ្លែនោះ ខ្ញុំក៏ចេញពីផ្ទៃគាត់តាមទ្វារមាសទៅឡើងបេះធូរេននោះយកមកជូនគាត់ពិសារួចស្រេច ខ្ញុំត្រឡប់ចូលទៅក្នុងផ្ទៃគាត់វិញ ។

បុរសទី ២ថា ខ្ញុំនៅក្នុងផ្ទៃម្ដាយខ្ញុំបានចំនួន ៦ ខែ ហើយឃើញគាត់លំបាកឡើយហត់នឹងធ្វើស្រែចម្ការច្បារដំណាំណាស់ពេក ខ្ញុំចេញពីផ្ទៃគាត់មកខ្ញុំទៅធ្វើស្រែចម្ការ ឃ្វាលគោក្របី, ដំណាំបាយ ដងទឹកជំនួសគាត់ពីព្រឹកព្រលប់រហូតលុះដល់ល្ងាច អស់ការធ្វើហើយ ខ្ញុំចូលទៅក្នុងផ្ទៃម្ដាយខ្ញុំវិញជារៀងៗដរាបមក ។

បុរសទី ៣ថា ឱតាយាយអើយ ខ្លួនខ្ញុំនេះជាទេវតាបុត្របុះមកចាប់បដិសន្ធិនឹងម្ដាយខ្ញុំសព្វថ្ងៃនេះ ដល់ខ្ញុំចេញពីទ្វារ

មាសវេលាណា បានមកនៅបំពេរគាត់សព្វសារពើ ដល់ខ្ញុំចាស់រៀបនឹងស្លាប់ខ្ញុំសុំចូលទៅផ្ទៃម្ដាយខ្ញុំវិញ ដើម្បីកុំឲ្យស្លាប់ទាន់ ហើយកើតមកម្ដងទៀតឲ្យបានជាក្មេងឡើងវិញ ។

បុរសទី ៤ ថា ខ្លួនខ្ញុំនេះចេញពីផ្ទៃម្ដាយមកកាលណាខ្ញុំរក្សាសីលប្រាំចាំសីលប្រាំបី តែសីលនោះឃើញប្លែកពីអ្នកទាំងឡាយ ចង់ផឹកស្រា ជក់អាភៀន សម្លាប់ជីវិតគេក៏បាន លុះដល់ខ្ញុំស្លាប់ទៅ ៗ កើតជាទេវតាសោយសម្បត្តិនៅសួគ៌ា ។

ឯបុរសទាំង ៤ នាក់នោះនិយាយភូតកុហកគ្រប់គ្នា ហើយក៏សួរទៅតាចាស់ដូនចាស់ថា រឿងខ្ញុំនិទានជំរាបទាំងប៉ុន្មាននេះ តើតាយាយជឿឬទេ តាយាយក៏ឆ្លើយតបទៅវិញថា រឿងនោះតាយាយជឿហើយ តែក្នុងគំនិតគាត់ទាំងពីរនាក់គិតឃើញថា បុរសទាំងនេះសុទ្ធតែនិយាយកុហកទាំងអស់ ។

ដល់បុរសទាំង ៤ នោះទាល់ប្រាជ្ញា ក៏ឲ្យតាចាស់នោះនិយាយរឿងប្រាប់ម្ដងវិញ ប៉ុន្តែតាចាស់នោះមុននឹងនិយាយរឿងគាត់បានសន្យាដូចបុរសទាំង ៤ នាក់នោះដែរ ទើបព្រមព្រៀងទាំងអស់គ្នា ។

ឱចៅអើយ កាលតានឹងយាយមកធ្វើចម្ការក្របាសបាន ៥-៦ ឆ្នាំហើយ មានទ្រព្យសម្បត្តិប្រាក់មាសល្មមនឹងចិញ្ចឹមចៅទាំង ៤ នាក់នេះបាន តែក្នុងឆ្នាំនេះក្របាសមិនផ្លែសោះមិនដឹងជារឿងហេតុអ្វី មាន ១ ថ្ងៃតាដើររុកក្នុងចម្ការទៅឃើញដើមក្របាស ១ ដើមទំហំប៉ុនដើមត្នោតមានផ្លែ ១ ធំ តាក៏ឡើងបេះយកមកផ្ទះ ដល់តានឹងយាយនាំគ្នាបកមើលឃើញមានគ្រាប់ ៤ ក្នុងមួយគ្រាប់មានកុមារម្នាក់គ្រប់ទាំង ៤ គ្រាប់ តាបានឲ្យយាយគាត់បំបៅហើយបីបាច់រក្សា លុះដល់បុរសទាំង ៤ នាក់ធំពេញវ័យហោណាឡើង ក៏នាំគ្នារត់ចោលតាយាយអស់ទៅ ឯចំណែកតាវិញថា ចៅបុរសទាំង ៤ នាក់នេះឯងត្រឡប់មកវិញ បុរសទាំង ៤ នាក់នោះភិតភ័យខ្លាំង ក៏នាំគ្នាឆ្លើយប្រកែកទៅនឹងតាបាស់ដូនបាស់វិញថា មិនមែនទេ ៗ តា-យាយសួរទៅវិញថាហេតុអ្វីក៏ចៅថា មិនមែន បើចៅបេះតែប្រកែកយ៉ាងនេះនោះឃើញទាស់ខុសកិច្ចសន្យាហើយ បើដូច្នេះត្រូវចៅទាំង ៤ នាក់មកនៅបម្រើតាទើបត្រូវសន្យា ។

# រឿងស្រីកណ្ដុរល្ភោច

ដើមឡើយ មានបុរសម្នាក់មានប្រពន្ធ បុរសនោះតែងទៅកាប់បំការតែសព្វវេលា លុះកាប់បំការទៅដល់ដើមជ្រៃ ១ មានស្ដេចកណ្ដុរសនៅនឹងដើមជ្រៃនោះ មានសេចក្ដីភិតភ័យ ហើយស្ដេចកណ្ដុរសទៅអង្វរបុរស ដែលកាប់ព្រៃធ្វើបំការនោះថា សុំឲ្យបុរសទុកតែដើមជ្រៃ ១ នេះកុំកាប់ ខ្ញុំនឹងឲ្យរង្វាន់ក្នុង ១ ថ្ងៃ ជាមាស ១ ដុំ បុរសនោះក៏ព្រមទុកដើមជ្រៃនោះ ស្ដេចកណ្ដុរបានយកមាសប្រគល់ឲ្យបុរសនោះគ្រប់ថ្ងៃ បុរសបានមាសហើយ យកទៅប្រគល់ឲ្យប្រពន្ធតែគ្រប់ថ្ងៃ ប្រពន្ធសួរប្ដីថា អ្នកបានមាសមកពីណា ប្ដីថានាងកុំចង់ដឹងអ្វីបេះតែទុកទៅ នាងប្រពន្ធថា បើអ្នកមិនប្រាប់ខ្ញុំ ៗ នឹងទៅប្ដឹងអ្នករាជការចៅទៃ ឬនឹងទៅទូលស្ដេចថា អ្នកលួចព្រះរាជទ្រព្យ បុរសនោះឮប្រពន្ធថាដូច្នោះក៏ភ័យ ហើយបានថ្លែងប្រាប់ទៅប្រពន្ធតាមដំណើរដែលបានមាសពីស្ដេចកណ្ដុរសនោះ នាងប្រពន្ធបានដឹងដូច្នោះហើយ បានប្រាប់ទៅប្ដីវិញថា អ្នកនេះហៅពេញជាឆោតបាញ់ប្រាជ្ញ

សត្វ បើអ្នកកាប់ដើមជ្រៃនោះឲ្យរលំ ហើយពុះបំបែកយកមាសពីក្នុងដើមជ្រៃនោះនឹងបានច្រើន ព្រោះស្តេចកណ្ដុរសវាយកមាសតែពីក្នុងដើមជ្រៃនោះ បុរសនោះបានឮសំដីប្រពន្ធហើយក៏ជឿ លុះព្រឹកឡើងបានទៅកាប់រំលំដើមជ្រៃនោះរលំទៅ ហើយក៏កាប់ពុះមើលពុំឃើញមានមាសអ្វីបន្តិចសោះ ស្តេចកណ្ដុរសក៏រត់បោលដើមជ្រៃនោះទៅ លុះវេលាយប់ស្តេចកណ្ដុរសនាំគ្នាទៅលួចយកមាសពីផ្ទះបុរសនោះអស់មកវិញ ។

រឿងនេះចប់តែប៉ុណ្ណេះ ។

# បញ្ជីរឿង


លេខទំព័រ

១ រីយកថា . . . . . . . . . . . . . . . . . . . . . . . . ២៣៥

២ ខេមាខេមសរណកថា សំដែងអំពីលក្ខណៈដែលជាប់ឬសៅហ្មងសរណគមន៍ ព្រះមហាពិទូរក្រសេម រៀបរៀង (ត) . . . . . . . . . . . . . . . . ២៥៩

៣ គាថាធម្មបទប្រែ . . . . . . . . . . . . . . . . . . . . . ២៧៥

៤ រឿងមាយាស្ត្រី . . . . . . . . . . . . . . . . . . . . . ៣២៧


# រូបក្រៅរឿង


១ ព្រះពុទ្ធរូបនៅវត្ត កីយ្យូកការតី ក្រុងមណ្ឌលេ ភូមា . . . . . . . . . . . . ២៣៣

២ លោកសង្ឃភូមា គណសទ្ធម្ម កាន់បាត្រខ្ទុកម្រាក់ត្រៀបគោចរបិណ្ឌបាត . . . ៣២៥

# TABLE DES MATIÈRES

I. Viriyakathā .......................... 235

II. Khemā-Khema Saranakathā .......................... 259

III. Gāthādhammapada traduit du Pali en Cambodgien ....... 275

IV. Conte populaire Cambodgien inédit :

La fourberie féminine .......................... 327

## HORS TEXTE :

I. Bouddha monolith en marbre blanc Pagode de Kyauk — Tawgyi — Mandalay Birmanie .......................... 233

II. Religieux de la Secte Sudhamma avec son bol à aumône en laque noire. Monastère du Taiktaw — Mandalay. .... 325



ព្រះពុទ្ធរូបនៅវត្ត កីយ្យូកការតី ក្រុងមណ្ឌាលេ (ភូមា) សាងដោយ
ថ្មកែវសទាំងដុំ ក្នុងរជ្ជកាលស្តេច មិន្តោន ព. ស. ២៤០៨ ។

វីរិយកថា

# អាចារ្យ សូរ-ហ៊ាយ

# ក្រុមជំនុំប្រែព្រះត្រៃបិដក

# រៀបរៀង

វីរិយកថា

អាចារ្យ ស្វរ-ហ៊ាយ វត្តឧណ្ណាលោម ភ្នំពេញ ក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ នៅព្រះរាជបណ្ណាល័យកម្ពុជា បានដកស្រង់ពីគម្ពីរផ្សេងៗ មានគម្ពីរសំយុត្តនិកាយជាដើមមកអធិប្បាយ ។

នមត្ថុរតនត្តយស្ស

វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្បទា
និប្បន្នសោភណោ អត្ថោ ខន្ត្យា ភិយ្យោ ន វិជ្ជតិ ។

តទ្បូវនេះនឹងសំដែងព្រះសទ្ធម្មទេសនា ពណ៌នាអំពីសេចក្ដីព្យាយាម ដែលជាសាសនធម៌របស់ព្រះបរមលោកនាថមុនី ដើម្បីជាប្រយោជន៍ដល់សាសនិកជន អ្នកប្រាថ្នាសេចក្ដីសុខ សេចក្ដីចំរើន និងកុសលសម្បត្តិតាមសមគួរ ដូចសេចក្ដីដែលនឹងអធិប្បាយពន្យល់ផ្ទុំឲ្យកើតសតិបញ្ញាតទៅនេះ:

ជនទាំងឡាយដែលកើតមកក្នុងលោកនេះ មិនរើសថាជនជាតិណាឡើយ សុទ្ធតែមានធុរៈមុខការងារសម្រាប់ខ្លួនរៀងៗ

រូបទាំងអស់ ជនជាគ្រហស្ថប្រុសស្រីមានធុរៈធ្ងន់ខាងរកទទួលទានចិញ្ចឹមជីវិត មានធ្វើស្រែ ចំការ លក់ដូរ ឬធ្វើរាជការជាដើម; ចំណែកខាងអ្នកបួសក៏ត្រូវមានធុរៈផ្ទាល់ខ្លួន ខាងផ្លូវសិក្សាប្រតិបត្តិធម៌វិន័យរបស់ព្រះសម្ពុទ្ធជាម្ចាស់ ។ មនុស្សទាំងអស់ដែលមានប្រភេទផ្សេងគ្នាក្តី ដូចគ្នាក្តី មានវ័យតិចច្រើនជាងគ្នាក្តី ជំនាន់ជំណាលគ្នាក្តី សុទ្ធតែជាអ្នកបែរឈមមុខទៅរកប្រកបការងារចិញ្ចឹមជីវិត ឬផ្លូវសិក្សាវិជ្ជាសម្មាបដិបត្តិតែរៀងៗ ខ្លួន ឥតមានទំនេរសោះឡើយ ប៉ុន្តែការងារឬផ្លូវសិក្សាទាំងនោះសោត ក្រខ្លះ ងាយខ្លះ ធ្ងន់ខ្លះ ស្រាលខ្លះ សូម្បីធុរៈដែលត្រូវធ្វើនោះប៉ុនគ្នា ក៏គង់ផ្សេងគ្នាដោយសេចក្តីព្យាយាមរបស់មនុស្សដែលខ្លាំងខ្សោយ ឬមានឧបាយអង់អាចជាងគ្នាមិនខាន ។

មនុស្សដែលជាអ្នកតាំងចិត្តព្យាយាមមាំមួន មិនបណ្តោតបណ្តោយការងារដែលខ្លួនត្រូវធ្វើត្រូវប្រកបនោះ កម្រៃផលដែលកើតអំពីការព្យាយាមនោះក៏ច្រើន ។ មនុស្សដែលមិនបានតាំងចិត្តព្យាយាម ឬក៏ព្យាយាមធ្វើទៅដោយខ្ជិលច្រអូស

មិនសូវយកចិត្តទុកដាក់ កម្រៃផលដែលកើតអំពីការព្យាយាមរបស់គេនោះក៏ស្តើងស្តួចតិចបុះតាមចំណែក ។

សេចក្តីព្យាយាម ឈ្មោះថាជាគុណធម៌នាំឲ្យសម្រេចផលប្រយោជន៍ តាមនិស្ស័យវាសនារបស់ខ្លួន ដូចយ៉ាងប្រយោជន៍បច្ចុប្បន្ន គឺលាភ យស សរសើរ សុខ ជាអារម្មណ៍ដែលអ្នកផងគួរប្រាថ្នា ដែលយើងទាំងឡាយបានប្រទះឃើញហើយក្នុងកាលសព្វថ្ងៃនេះក្តី ក្នុងកាលអនាគតដែលមិនទាន់មកដល់ តែគង់នឹងបានឃើញក្នុងកាលខាងមុខ ៗ ក្តី លាភ យស សរសើរ សុខ ទាំងនេះដែលនឹងកើតឡើងបាន សុទ្ធតែកើតមានឡើងមកអំពីអំណាចកំឡាំងសេចក្តីព្យាយាមទាំងអស់, មិនមែន លាភ យស សរសើរ សុខ កើតមានឡើងមកអំពីអំណាចសេចក្តីខ្ជិលច្រអូសឡើយ ពណ៌នាមកប៉ុណ្ណោះឃើញថា សេចក្តីព្យាយាមពិតជាធម៌បញ្ចូនឲ្យកើតប្រយោជន៍យ៉ាងច្រើន មិនមែនតិចទេ ។ សមដូចពុទ្ធភាសិតដែលបានលើកផ្តើមទុកមកខាងដើមថា "បុគ្គលជាកូនប្រុស គួរព្យាយាមឲ្យ

ណាស់ ទាល់តែសម្រេចប្រយោជន៍ ឯប្រយោជន៍យ៉ាងថ្លៃថ្លា ដែលសម្រេចមកហើយ នោះមិនមានក្រៃលែងជាងខន្តីធម៌ទេ ។

ព្រះពុទ្ធឱវាទនេះហាក់ដូចព្រះសម្ពុទ្ធជាម្ចាស់ត្រាស់ដាស់តឿនឲ្យព្យាយាមបំពោះតែបុរស មិនទួទៅដល់ស្ត្រីផងឡើយ ត្រង់នេះបើប្រសិនណាជាមានពាក្យគេឆ្ងៀតសួរមកថា ព្រោះហេតុអ្វីបានជាពោលដាស់តឿនបំពោះតែបុរស ? ឆ្លើយថា មិនមែនដូច្នោះឡើយ ខាងស្ត្រីក៏ព្រះអង្គដាស់តឿនឲ្យព្យាយាមប្រកបកិច្ចធុរៈដែលល្មមធ្វើបានតាមបំណែកដូចគ្នា ប៉ុន្តែបានជាពោលប្រដៅយ៉ាងនោះ ដោយហេតុថាបុរសនោះពេញទីជាភ្នាក់ងារនៃសេចក្ដីព្យាយាមជាងស្ត្រី ព្រោះថាធម្មតាជាតិជាបុរសជាមនុស្សមានទំរង់រាងកាយស្រឡូតស្រឡះមានរឹកពារក្លៀវក្លា ទាំងកំឡាំងក៏រឹងប៉ឹង នឹងជាអ្នកបេះអត់ធន់ទ្រាំទ្រកិច្ចការធ្ងន់ៗ គ្រាន់បើជាងស្ត្រី អាចនឹងទទួលធុរៈក្រលំបាកដែលកើតអំពីការព្យាយាមប្រកបកិច្ចទាំងពួងជាងស្ត្រី ម្យ៉ាងទៀតបុរសជាមនុស្សមុះមុតអង់អាចជាងស្ត្រី ដូចការស្វះស្វែងរក

បំណោះវិជ្ជាឬប្រយោជន៍អ្វីមួយក្នុងលោកនេះក្តី លោកខាងមុខក្តី ក៏បុរសនេះឯងជាអ្នកមានទំនងគួរនឹងធ្វើប្រយោជន៍បានច្រើនយ៉ាងជាងស្ត្រី រួមសេចក្តីថាបុរសជាប្រធានឬជាទីតាំងនៃសេចក្តីព្យាយាម ហេតុដូច្នោះទើបលើកឡើងដាស់តឿនឲ្យព្យាយាមជាមុន ។

បំណែកស្ត្រីជាមនុស្សមានរាងកាយទន់ភ្លន់ កំឡាំងខ្សោយនឹងសេចក្តីវាងវៃក៏តិច មិនសមនឹងទទួលកិច្ចការក្រលំបាកបានងាយដូចបុរស ដូចយ៉ាងពលទាហានឬនាហ្មឺនមុខមន្ត្រីធំ ៗ ក៏សុទ្ធតែប្រុស ព្រោះឃើញថាជាអ្នកឈ្លាសវៃជាងស្ត្រី បុរសឈ្មោះថាជាភ្នាក់ងារក្នុងការបង្ក្រាបសត្រូវ ឈ្មោះថាជាអ្នកមានដំណែងឥស្សរភាពច្រើនជាងស្ត្រី តែស្ត្រីក៏ត្រូវព្យាយាមចាប់ការងារតាមបំណែកដែលល្មមធ្វើបានដូចគ្នា ។

ព្រោះហេតុនោះ ជនទាំងឡាយដែលកើតមកជាកូនប្រុសត្រូវប្រឹងប្រែងប្រកបការងារក្នុងផ្លូវលោកនេះ ដូចខំសិក្សាស្វែងរកវិជ្ជាណាមួយ មានវិជ្ជាខាងរដ្ឋបាលតុលាការឬវិជ្ជាខាងហត្ថកម្ម ការជាង មានជាងមាសប្រាក់ជាដើម ដែលខ្លួនស្ម័គ្រចិត្តធ្វើ

នោះ គឺធ្វើឬប្រកបការនោះៗ ឲ្យមាំមួន កុំបីធ្វេសប្រហែស បណ្តោតបណ្តោយឡើយ ត្រូវតែក្រើនក្រតើនឡើងដើម្បីនឹងធ្វើ ដំណើរវិជ្ជាសេចក្តីឆ្លាសរបស់ខ្លួន ឲ្យត្រូវឲ្យទាន់កាលសម័យ ព្រោះសម័យ ពោលគឺរបៀបបែបផែនច្បាប់ទំលាប់នឹងបំណោះ វិជ្ជាជាដើម ក្នុងកាលឥឡូវនេះ កាន់តែស្រូតរូតជឿនលឿន ប្លែកៗទៅជាងធម្មតាហើយ លុះតែខំព្យាយាមប្រឹងកង្ហើញឲ្យ ណាស់ ទើបនឹងបានស្រួបឡើងទាន់កាលសម័យ ក៏បុគ្គល ដែលមានគំនិតភ្ញាក់ឡើងទាន់សម័យនេះ ចាត់ថាជាមនុស្ស សប្បុរសមួយ ហៅថា កាលញ្ញូ ប្រែថាអ្នកស្គាល់កាល សម័យ ។

បុគ្គលដែលមានគំនិតលង់លក់មិនដើបឡើងចាប់ព្យាយាម ឲ្យទាន់កាលសម័យ នឹងវ័យរបស់ខ្លួនទៅកំពុងចំរើន បេះតែ បង្អង់ៗទៅ មិនដឹងកាលវិនាសកាលចំរើន ដែលកម្មបណ្តាល ឲ្យកើតឡើង ហៅថា អកាលញ្ញូ ប្រែថាអ្នកមិនស្គាល់កាល ចាត់ជាអសប្បុរសម្យ៉ាង ន័យនេះមានព្រះពុទ្ធឱវាទដែលព្រះ អង្គទ្រង់ដាស់តឿនក្រើនរំលឹកទុកមកថា៖

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ
យុវា ពលី អាលសយំ ឧបេតោ
សំសន្នសង្កប្បមនោ កុសីតោ
បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

សេចក្ដីថា បុគ្គលមានវ័យគឺអាយុនៅក្មេង កំពុងមានកំឡាំង តែផ្អែកនឹងខ្ជិលច្រអូសមិនមានព្យាយាមរៀនសូត្រក្នុងកាលដែលមានទំនងគួររៀនសូត្រ មានចិត្តត្រិះរិះជាប់ជំពាក់មាំក្នុងកាមគុណ មារយាទព្រាំព្រាល(១) ច្រអូសកាយច្រអូសចិត្តមិនដែលបាន (ប្រទះ) នឹងផ្លូវបញ្ញាឡើយ ។ ឱវាទនេះបំភ្លឺឲ្យឃើញថា មនុស្សប្រុសស្រីក្នុងលោកដែលកើតមកហើយមានរាងកាយធំធាត់ ឥតមានពិការខូចអវយវៈណាមួយ មានកំបុតជើងដៃជាដើមទេ ទាំងវ័យក៏នៅក្មេង ល្មមនឹងចាប់ផ្ដើមព្យាយាមប្រកបកិច្ចការផ្លូវលោកឬផ្លូវធម៌ ឲ្យទាន់សម័យដែលខ្លួនកំពុងពេញកំឡាំងនៅឡើយ គួរតែប្រញាប់ប្រឹងប្រែងកុំឲ្យហួសសម័យនោះទាន់ មិនគួរនឹងបណ្ដោតបណ្ដោយឲ្យវ័យ

១ គំនិតឡេះឡោះ ។

អស់ទៅតាមយប់និងថ្ងៃកន្លងបាត់ទៅទទេៗសោះ គួរស្តាយវ័យរបស់ខ្លួនណាស់ មិនគួរបើនឹងដំអក់ឲ្យធ្លោយសោះឡើយ ព្រោះជាន់បឋមវ័យ រវាងអាយុពី ៦ ឬ ៧ ឆ្នាំឡើងទៅទល់នឹង ៣០ ឆ្នាំនេះជាឱកាសដ៏ធំទូលាយងាយនឹងងាករេរកកិច្ចធុរៈ ដែលខ្លួនស្ម័គ្រចិត្ត បំណែកខាងគ្រហស្ថ ទោះបីរៀនអក្សរ រៀនច្បាប់ទំលាប់ឬរៀនខាងហត្ថកម្មគឺធ្វើការជាង មានជាងមាស ឬជាងធ្វើរថយន្តជាដើម,ខាងបព្វជិត នឹងចាប់រៀនសូត្រព្រះបរិយត្តិក៏បានងាយ ព្រោះកំឡាំងកាយ ក៏ឡាំងស្មារតីនៅកំពុងបរិបូណ៌ ។ វ័យជាន់ដំបូងនេះ ពេញហៅមានទំនងនាំឲ្យកើតប្រយោជន៍តរែងទៅមុខមិនតិចឡើយ ទុកជាយ៉ាងណាក៏ងាយនឹងត្រិះរិះរកឧបាយផ្សេងៗទៀត តែបើបណ្តោយឲ្យសេចក្តីខ្ជិលច្រអូសឬសេចក្តីស្រវឹងជ្រុលជ្រប់ក្នុងតាមគុណបូលគ្របសង្កត់បានហើយ សូម្បីបំណេះវិជ្ជាឬប្រយោជន៍អ្វីមួយ ដែលមានទំនងគួរនឹងបេះ ក្លួនឹងបានមានឡើងក៏គង់តែត្រឡប់វិនាសទៅវិញពុំខាន ឯសេចក្តីខ្ជិលនេះមានអាការជាទោសធ្វើឲ្យខូចប្រយោជន៍ច្រើនយ៉ាងណាស់ បំណែកសេចក្តីព្យាយាមជាគុណ

ជួយជ្រោមជ្រែងឲ្យបានសេចក្ដីសុខទាំងលោកនេះនិងខាងមុខ ៗ សមដូចបាលីដែលសំដែងអំពីដំណើរនៃសេចក្ដីខ្ជិល និងសេចក្ដីព្យាយាមថា៖

អតិសីតំ អតិឧណ្ហំ អតិសាយមិទំ អហុ

ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា អច្ចេន្តិ មាណវេ ប៉ុណ្ណោះជាដើម

សេចក្ដីថា ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមាណពគឺមនុស្សកំឡោះ ដែលលះបង់ការងារត្រូវធ្វើនោះចោល ដោយទំរន់អាងថា ពេលនេះរងាណាស់ នៅក្ដៅណាស់ ល្ងាចជ្រុលណាស់ ។ តែបើជនឯណា កាលដែលកំពុងធ្វើការងារ ដែលបុរសត្រូវធ្វើនោះ មិនសំគាល់ត្រង់ត្រជាក់ ត្រង់ក្ដៅ (មកជាប្រមាណ) ដោយក្រៃលែងជាងស្មៅ គឺថាដាក់ខ្លួនទុកដូចជាស្មៅ ជននោះនឹងមិនសាបសូន្យអំពីសេចក្ដីសុខឡើយ ។

សេចក្ដីនេះពន្យល់ឲ្យឃើញថា បុគ្គលដែលត្រូវការប្រារព្ធព្យាយាមយកចិត្តទុកដាក់ធ្វើកិច្ចការអ្វីមួយ ត្រូវកុំស្ដាយសាច់ឈាមពណ៌សម្បុរ កុំទំរន់ កុំខ្លាច កុំរអា កុំរួញរានិងសេចក្ដីទុក្ខព្រួយហត់នឿយ ដែលកើតអំពីការព្យាយាមនោះ

ឲ្យសោះ ព្រោះថាកិច្ចការទាំងឡាយ ក្នុងលោកនេះ ដែលគេត្រូវព្យាយាមគឺថាត្រូវបុះដៃធ្វើ ទោះបីធ្វើដោយកំឡាំងកាយឬដោយកំឡាំងដំរេះគិតគូរ តែងតែនឹងមានឧបសគ្គគឺឧបទ្រពទុក្ខភ័យចង្រៃ ចូលមកប្រៀតជ្រែកប្រកួតប្រណាំងគ្នានឹងកិច្ចការនោះៗ ជាធម្មតា ការចាប់ផ្ដើមព្យាយាមកិច្ចធុរៈនិមួយ ៗ នេះដំបូងឡើយ តែងប្រទះទុក្ខព្រួយនឿយលំបាកខ្លះជាទំនៀមសូម្បីព្យាយាមក្នុងផ្លូវកុសលសុចរិត ក៏គង់បានទុក្ខលំបាកដូចគ្នា តែទុក្ខលំបាកនេះរមែងឲ្យផលមកជាសុខក្នុងកាលខាងក្រោយ ហេតុដូច្នោះ កាលបើបុគ្គលមានព្យាយាមហើយត្រូវឲ្យមានខន្តី សេចក្ដីអត់ធន់ មកជាគូគ្នានឹងវីរិយ ដើម្បីជាជំនួយវីរិយ ឲ្យតាំងនៅមាំមួន ខន្តិធម៌នេះជាធម៌សម្រាប់ដឹក ឬផ្កឹះបោលនូវទុក្ខព្រួយ ឬថាជាភារៈខាងជំនះនូវទុក្ខ ដែលកើតអំពីសេចក្ដីព្យាយាមនោះៗ ខន្តិធម៌នេះរាប់ថាជាជើងសម្រាប់ជួយជ្រោមជ្រែងទប់ទល់វីរិយទុកកុំឲ្យលើកលះបោលកិច្ចធុរៈ ដែលត្រូវធ្វើនោះបេញបាន ឯវីរិយនេះកាលបើមានខន្តីជាគូហើយ

ទុកជាប្រទះអារម្មណ៍ ដែលគួរឲ្យកើតទុក្ខភ័យចូលមករបជាន់យ៉ាងណាក៏ដោយ ក៏មិនរុះរើលះកិច្ចធុរៈនោះបោលបាន ព្រោះមានខន្តីធម៌នេះជាកំឡាំងជួយគាំពារ វីរិយ និងខន្តី ទាំងពីរនេះជាធម៌ជាន់ខ្ពស់ មានគុណាទិសង្ស្រធំទូលាយយ៉ាងក្រៃលែង សូម្បីព្រះសម្មាសម្ពុទ្ធក៏ព្រះអង្គទ្រង់បានបំពេញមកហើយដែលហៅថាវីរិយបារមី ខន្តីបារមីនោះឯង ។ មួយវិញទៀតវីរិយនិងខន្តីនេះ កាលបើមានក្នុងបុគ្គលណាហើយ តែងនឹងបបួលដឹកអន្ទងបុគ្គលនោះឲ្យក្លាហាន ប្រកបកិច្ចធុរៈគ្រប់យ៉ាងប្រមូលសេចក្តីអធិប្បាយមកថា បុគ្គលអ្នកប្រកបដោយវីរិយផ្លូវកាយនិងផ្លូវចិត្តហើយនិងខន្តីសេចក្តីអត់ធន់ ដូចថ្លែងមកនេះអាចនឹងបដិសេធទុក្ខភ័យទាំងពួងបាន លែងមានញាប់ញ័រតក់ស្លុតនឹងអារម្មណ៍ដែលប៉ះពាល់មកនោះឡើយ លុះខាងក្រោយមក ក៏ឲ្យផលយ៉ាងវិសេស ទៅជាមនុស្សខ្ពង់ខ្ពស់មានឈ្មោះល្បីល្បាញឡើង ដោយអំណាចវិជ្ជាដែលកើតអំពីការប្រឹងប្រែងអត់ធន់នោះមក កាលបើសម្បូណ៌ដោយវិជ្ជាហើយ ទោះបីជួបជាអ្នកកំព្រាគ្មានមិត្រសំឡាញ់ ឬជាអ្នកក្រទ្រព្យសម្បត្តិ

មកអំពីដើម ឬក៏ជាអ្នកហោកទាបដោយរូបសម្បត្តិយ៉ាងណា ក៏គង់ត្រឡប់ឡើងទៅជាមនុស្សថ្កុំថ្កើងរុងរឿងគ្រប់យ៉ាងទាំងអស់បាន ព្រោះហេតុដូច្នោះជនទាំងឡាយគ្រប់គ្នា ទោះអ្នកមានសម្បត្តិតុកស្ងួតក្តី ខ្សត់ក្តី គួរតែខំព្យាយាមស្វះស្វែងរកវិជ្ជាដែលជាគុណសម្បត្តិ គឺជាលំអយ៉ាងខ្ពស់សម្រាប់ខ្លួន ។ ឯបុគ្គលមានភោគសម្បត្តិ និងរូបសម្បត្តិហើយ តែបើគ្មានវិជ្ជាសម្បត្តិទៀត ក៏ទុកដូចជាមនុស្សក្រីក្រសម្បត្តិ ទុកដូចជាមនុស្សពិការ មិនរុងរឿងក្នុងត្រកូលរបស់ខ្លួននោះឡើយ សមដូចសុភាសិតថា "រូបយោព្វនសម្បន្នោ វិសាលកុលសម្ភវោ វិជ្ជាហីនោ ន សោភេតិ និគន្ធា ឥវកិំសុកា" សេចក្តីថា "បុគ្គលបានកើតក្នុងត្រកូលខ្ពស់ បរិបូណ៌ដោយរូបនិងវ័យហើយ (តែបើ) សាបសូន្យចាកវិជ្ជា រមែងមិនល្អឡើយ ដូចគ្នានឹងផ្កាបា (គ្រាន់តែមានពណ៌ក្រហមប្រាលមែន) តែរកក្លិនក្រអូបគ្មាន ។ ពុទ្ធភាសិតនេះគប្បីឃើញថាវិជ្ជានេះពិតជាគុណជាតិវិសេសមែន ដែលជាផលបណ្តាលកើតចេញមកឋ្មីៗអំពីវិរិយ

នឹងខន្តី ដូចពណ៌នាមក ឯពាក្យថា វិជ្ជា សំដៅយកវិជ្ជាទាំងផ្លូវលោកផ្លូវធម៌ ដែលប្រព្រឹត្តទៅដោយប្រពៃប្រាសចាកទោសទុច្ចរិតទាំងអស់ ។

សេចក្ដីព្យាយាមខំឃ្មាតនេះជាធម៌ទាក់ទងបែកសាខាច្រើនស្ថានណាស់ ដូចក្នុងបធានសូត្រ ព្រះលោកនាថមុនីទ្រង់សំដែងទុកមក ដោយមហាករុណា ចង់ឲ្យពួកប្រជាជនក្នុងលោកបានសេចក្ដីសុខសេចក្ដីចំរើន ព្រះអង្គទ្រង់ដាស់តឿនពន្យល់ទុកមកបាឡីថា "សំវរោ ច បហានញ្ច ភាវនា អនុរក្ខនា ឯតេ បត្តារោ បធានា ទេសិតា ទិច្ចពន្ធុនា យេហិ ភិក្ខុ ឥធាតាបី ខយំ ទុក្ខស្ស បាបុណេ" អធិប្បាយថា "បធានគឺធម៌ជាគ្រឿងតាំងផ្ដួចផ្ដើមទាំងឡាយ ៤ យ៉ាងនុ៎ះគឺ៖

១ – សំវរោ ព្យាយាមរាំងមិនឲ្យបាបអកុសលដែលនៅមិនទាន់កើត កុំឲ្យកើតឡើងបាន គឺប្រយ័ត្នឥន្ទ្រិយទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត កុំឲ្យកើតសោមនស្សឬទោមនស្ស ក្នុងវេលាដែលភ្នែកឃើញរូប ត្រចៀកឮសំឡេង ច្រមុះធុំក្លិន អណ្ដាតលិទ្ធរស កាយពាល់ត្រូវ ចិត្តស្រាវជ្រាវ

រកអារម្មណ៍តាមផ្លូវមនោទ្វារ គួរប្រយ័ត្នឥន្ទ្រិយ ៦ យ៉ាងនេះកុំឲ្យលុះអំណាចឬជាប់បញ្ចោតអារម្មណ៍ទាំងនេះបាន កាលបើទូន្មានឥន្ទ្រិយបានហើយ បាបអកុសលដែលបំរុងនឹងកើតឡើងក៏កើតមិនបាន ។

២– បហានំ ព្យាយាមលះបាបដែលកើតហើយ គឺបាបដែលកើតឡើងព្រោះខ្លួនល្ងង់ខ្លៅ ឬកើតឡើងដោយសេចក្ដីវង្វេងបេសធ្វើក្នុងកាលមុន ៗ ព្រោះមិនធ្លាប់បានស្ដាប់ មិនធ្លាប់បានសិក្សាធម៌វិន័យរបស់ព្រះអរិយជាម្ចាស់ លុះខាងក្រោយមកកាលបើគិតឃើញហើយ គួរតែលះបង់បោលអំពើបាបទាំងនោះឲ្យស្រឡះបេញ ត្រូវតាំងចិត្តថានឹងលែងប្រព្រឹត្តល្មើសធ្វើដូច្នោះទៀត ។

៣– ភាវនា ព្យាយាមញ៉ាំងកុសលឬបំពេញឲ្យមានឡើងក្នុងសន្ដាន កុសលដែលនៅមិនទាន់កើតគួរព្យាយាមធ្វើឲ្យកើតឡើង ព្រោះបាបអកុសលដែលជាចំណែកទុច្ចរិតលះបេញទៅហើយនោះ ត្រូវបំពេញកុសលដែលជាចំណែកសុចរិត

ឲ្យមានឡើងជំនួស ដើម្បីកុំឲ្យមានឱកាសឲ្យបាបមានបន្តោះកើតឡើងបានទៀត ។

៤— អនុរក្ខនា ព្យាយាមរក្សាគឺរក្សាកុសលសេចក្ដីល្អរបស់ខ្លួនទុក ដែលខ្លួនបានធ្វើមកហើយក្នុងកាលមុន មិនឲ្យសាបសូន្យទៅដោយអាការធ្វេសប្រហែស ព្រោះថារបស់ឯណាដែលបានធ្វើកើតឡើងហើយក្នុងកាលមុនៗ ខាងក្រោយមកត្រូវរក្សារាំងរឿយ ៗ ទើបរបស់នោះបំរើនឡើងបាន ឧទាហរណ៍ ដូចយ៉ាងធម៌អាថ៌ឬវិជ្ជាច្បាប់ទំលាប់អ្វីក៏ដោយ ដែលទន្ទេញចាំហើយត្រូវតែឧស្សាហ៍សូត្ររឿយ ៗ ទើបនឹងចាំជាប់នៅយូរបាន ប្រធានទាំង ៤ យ៉ាងនេះ ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គជាអាទិច្ចវង្ស(១) ទ្រង់សំដែងហើយ ភិក្ខុក្នុងសាសនានេះជាអ្នកតែងតែបានព្យាយាមធ្វើកិលេសឲ្យរីងស្ងួតដោយបធានធម៌ដែលពោលមកនេះ ទើបនឹងបានដល់នូវកិរិយាអស់ទៅនៃទុក្ខទាំងពួងបាន ។

---

១ ប្រែថាពូជពង្សនៃព្រះអាទិត្យ ព្រោះសម័យដើមពួកក្សត្រិយ៍ប្រកាន់ថាៈគេជាវង្សត្រកូលនៃព្រះអាទិត្យ ។

សេចក្តីព្យាយាមនេះ កាលបើបុរសស្ត្រីបេះប្រកបលៃលកត្រិះរិះផ្លូវដែលមានទំនងត្រង់ទៅរកសេចក្តីចំរើនហើយ តែងញ៉ាំងប្រយោជន៍ឲ្យសម្រេចគ្រប់យ៉ាង សមតាមសេចក្តីប្រាថ្នារបស់ខ្លួនជាប្រាកដ ដូចយ៉ាងបុរសអ្នកបំរើរបស់ចុល្លកសេដ្ឋី កាលដើមដំបូងរើសបានកណ្តុរងាប់មួយ យកកណ្តុរនោះទៅលក់ធ្វើដើមទុនប្រកបការលក់ដូរ សន្សំឡើងម្តងបន្តិចៗ មិនយូរប៉ុន្មានក៏បានទ្រព្យសម្បត្តិកាន់តែច្រើនឡើង ទាល់តែបានជាសេដ្ឋីធំ សមដូចពុទ្ធភាសិតគាថា ត្រាស់សរសើរបុគ្គលអ្នកមានគំនិតល្អថា៖

អប្បកេនបិ មេធាវី ពាភដេន វិចក្ខណោ
សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ

សេចក្តីថា បុរសស្ត្រី អ្នកមានប្រាជ្ញា បេះកាញ់គ្នេរទ្រព្យសម្បត្តិ ប្រកបកិច្ចការចិញ្ចឹមជីវិតសមហេតុផលល្អ រមែងដំកល់ខ្លួនឡើងទៅជាមនុស្សខ្ពង់ខ្ពស់បាន ដោយសារទ្រព្យដើមទុនតែបន្តិចប៉ុណ្ណោះ ដូចជាមនុស្សអ្នកបង្កាត់ភ្លើងរងើកតូចមួយគង់បង្កាត់ឲ្យទៅជាភ្លើងឆេះធំឡើងបាន ។ បុគ្គលអ្នក

មានព្យាយាមធ្វើតៗទៅមិនដាច់មិនស្រាកក្នុងកិច្ចការរបស់ខ្លួន តែងបានសម្រេចប្រយោជន៍ឃើញទាន់ហន់ ។

ព្រោះហេតុដូច្នោះ ជនទាំងឡាយរាល់រូប កាលបើនឹកឃើញថាអាត្មាអញជាអ្នកបៀសវាងចេញចាកការងារមិនផុតហើយ គួរតែបុះបាប់ផ្តើមព្យាយាមឲ្យមាំមួន កុំបីធ្វេសប្រហែស ត្រូវតែតាំងចិត្តឲ្យក្លាហាន ក្នុងការប្រឹងប្រែងនេះកុំទំរន់ឲ្យសោះ ត្រូវតែតាំងព្យាយាមដឹកល់ទុកក្នុងចិត្តឲ្យជាប់មាំ ប្រកបដោយអង្គ ៤ ដូចបាលីថា កាមំ តចោ ន្ហារុ ច អដ្ឋិ ច អវសិស្សតុ អវសុស្សតុ មេ សរីរេ សព្វំ មំសលោហិតំ សេចក្តីថា សាច់ឈាមទាំងអស់ក្នុងសរីរាងកាយរបស់អញ រីងស្ងួតស្ងិតស្រពោនទៅចុះ នេះជាអង្គ ១, សូមឲ្យនៅសល់តែស្បែកជាអង្គ ១, សូមឲ្យនៅសល់តែសរសៃជាអង្គ ១, សូមឲ្យនៅសល់តែឆ្អឹងជាអង្គ ១, កម្រៃផលឯណាដែលមិនទាន់កើតឡើងដោយកំឡាំប្រឹងប្រែងទេ អញនឹងមិនត្រូវឈប់លែងចោលចាកព្យាយាមឡើយ ។

បុគ្គលជាអ្នកបួសឬគ្រហស្ថប្រុសស្រីក្មេងចាស់ណាមួយ កាលបើប្រកបព្យាយាមមាំមួនដូចន័យពោលមកនេះហើយ បុគ្គលនោះឯងគង់នឹងបានសេចក្ដីសុខសេចក្ដីចំរើនក្នុងលោកនេះនឹងលោកខាងមុខពុំខាន ព្រោះសេចក្ដីព្យាយាមនេះជាគន្លងហូរមកនូវផលយ៉ាងវិសេសវិសាល ឃើញជាក់ច្បាស់ ។ ម្យ៉ាងទៀតបុគ្គលដែលជាអ្នកមានព្យាយាម ទោះបីទៅនៅក្នុងប្រទេសណា សូម្បីប្រទេសនោះខ្សត់ខ្សោយវិជ្ជាសេចក្ដីចេះដឹងពុំសូវមានមនុស្សរៀនសូត្រចេះដឹងច្រើន ឬក៏ប្រទេសនោះមានឈើព្រៃញាតស្បាត ដីជង្ហុកថ្លុកក្រហេងក្រហូង មិនជាទីសប្បាយយ៉ាងណាក៏ដោយ ក៏គង់ត្រឡប់ឡើងទៅជាមានមនុស្សចេះដឹងច្រើន ទៅជាប្រទេសស្រឡះរាបស្មើ មានទាំងផ្លូវថ្នល់ខ្វាត់ខ្វែង ថ្កើងរុងរឿងគួរជាទីរីករាយសប្បាយទៅបាន (ដូចយ៉ាងប្រទេសដីក្រុងភ្នំពេញទាំងមូល ឬសាលាបាឡី ព្រះរាជបណ្ណាល័យនឹងក្នុងទីវត្តលង្កា ឧណ្ណាលោមជាដើម) ធៀបមើលបុះក្នុងកាលពីដើម នឹងកាលឥឡូវនេះក៏គង់ឃើញបានថាសេចក្ដីចំរើនដោយវិជ្ជាការចេះដឹង នឹងថ្កើងរុងរឿងក៏កាន់តែស្ទុះ

ជឿនលឿនឡើងប្លែកជាងពីដើមណាស់ ការចេះដឹងផ្សព្វផ្សាយចេញទៅខេត្ត ខ័ណ្ឌនានា និងការរុងរឿងដែលកើតឡើងទាំងនេះ គឺកើតមកអំពីកំឡាំងស្នាដៃរបស់លោកអ្នកមានព្យាយាមម្យ៉ាង មិនមែនកើតអំពីមនុស្សខ្ជិលច្រអូសឡើយ ។ សេចក្ដីព្យាយាមនេះមានគុណានិសង្សជាអនេក អាចនឹងវាតទីដីឲ្យបានថ្កុំថ្កើងក្នុងលោកនេះផង អាចនឹងនាំបណ្ដាលឲ្យបានចំរើនកុះករដោយវិជ្ជាសេចក្ដីឈ្លាសគ្រប់យ៉ាងផង សេចក្ដីព្យាយាមឈ្មោះថាដូចជាចន្ទល់ ជួយជ្រោមជ្រែងឲ្យបានសុខក្សេមក្សាន្តដល់មនុស្សអ្នកប្រាជ្ញាល្អ និងបានកន្លងបង់នូវទុក្ខគ្រប់យ៉ាងមានទុក្ខនឹងក្រីក្រទ្រព្យសម្បត្តិនឹងល្ងង់ខ្លៅជាដើម សេចក្ដីព្យាយាមឈ្មោះថាជាទម្ពក់ថ្ពក់យកនូវសេចក្ដីសុខសេចក្ដីចំរើន ឲ្យចូលមកក្នុងកណ្ដាប់ដៃរបស់ខ្លួនបាន សេចក្ដីព្យាយាមនេះព្រះសម្ពុទ្ធលោកុត្តមាចារ្យ ព្រះអង្គទ្រង់សំដែងទុកមកឃើញក្នុងធម៌ច្រើនស្ថានណាស់ ដូចក្នុងឥន្ទ្រិយ ៥ ហៅថា វីរិយិន្ទ្រិយំ ក្នុងពល ៥ ហៅថា វីរិយពលំ ក្នុងពោជ្ឈង្គ ៧ ហៅថា វីរិយសម្ពោជ្ឈង្គោ ក្នុងអង្គមគ្គ ៨ ហៅថា សម្មាវាយាមោ ក្នុង

វេសារជ្ជករណធម៌ ហៅថា វីរិយារម្ភោ ក្នុងនាថករណធម៌ ហៅថា វីរិយំ សព្ទទាំងអស់នេះ រួមមកហៅថា ព្យាយាមតែមួយម៉ាត់ប៉ុណ្ណោះ ក៏ពាក្យថាព្យាយាម គឺជាពាក្យសំស្ក្រឹតក្លាយមកពីពាក្យថា វ្យាយាម ប្រែថា ឈានទៅមិនឈប់ ក៏ឯពាក្យថាព្យាយាមនេះ មានសព្ទសំរាប់ហៅផ្លាស់ប្ដូរតាមលក្ខណៈច្រើនយ៉ាងទៅទៀត ដូចពាក្យថា វីរិយ ព្រោះជាហេតុក្លៀវក្លាមិនរួញរា ឧដ្ឋាន ព្រោះជាហេតុក្រោកឡើងប្រកបកិច្ចធុរៈ ឧស្សាហ ព្រោះជាហេតុខំឃ្មាតឬរលះរលាំង ធិតិ ព្រោះជាហេតុតាំងនៅមាំមួន អដ្ឋិតិ ព្រោះជាហេតុខ្ជាប់ខ្ជួនមិនបង្អង់ វាយាមៈ ព្រោះជាហេតុឈានទៅមិនឈប់ បរក្កម ព្រោះជាហេតុប្រឹងប្រែងឬកកេះកកាយទៅមុខ អប្បដិវានី ព្រោះជាហេតុមិនត្រឡប់បែរក្រោយ បធានៈ ព្រោះជាហេតុតាំងដួចផ្ដើមមិនផ្អាកទុកទាំងកណ្ដាលការដែលត្រូវធ្វើ បគ្គាហៈ ព្រោះជាហេតុផ្គូផ្គងជាប់ត ៗ ទៅ សព្ទទាំងនេះសុទ្ធតែជាលក្ខណរបស់វីរិយ ជាពាក្យសំរាប់ប្រើផ្លាស់ប្ដូរកុំឲ្យសាំជដែលៗ តែក៏គង់រួមខ្លួមកហៅថា ព្យាយាម ដូចគ្នាក៏បាន ។

ព្រោះហេតុដូច្នោះ ជនទាំងឡាយគ្រប់ជំពូកគួរតែខំប្រឹងប្រែង ស្វះស្វែងរកវិជ្ជាសិរាប់ដៃរបស់ខ្លួន ឬក៏ស្វែងរកធនធានទ្រព្យសម្បត្តិឱ្យត្រូវតាមសម្មាអាជីវក្នុងផ្លូវសុចរិតទាំងអស់ មួយវិញទៀត អ្នកដែលមានកូនចៅត្រូវតែដាស់តឿននឹងជួយទំនុកបំរុងផ្ដុំផ្ដើមកូនចៅបងប្អូនរបស់ខ្លួន ឱ្យខំសិក្សារៀនសូត្រឱ្យមាំមួនទាន់ភិមានវ័យនៅក្មេង កុំបណ្ដោតបណ្ដោយតាមទំនើងអំពើចិត្តក្មេងនោះឡើយ ។

សំដែងរៀបរាប់ក្នុងវិរិយកថា ក៏សន្មតថាចប់ដោយប្រការដូច្នេះឯង ។

ខេមាខេមសរណាគាថា

ព្រះមហាពិទូរ ក្រសេម គន្ថរបទបណ្ឌិត

រៀបរៀង (គ)

## លក្ខណាដាច់ ឬ សៅហ្មងនៃសរណគមន៍

តាមទំនៀមដែលព្រះបុរាណាចារ្យ បានធ្វើរៀងរាបមកហើយ កាលនឹងឲ្យឧបាសកឧបាសិកាសមាទាននូវនិច្ចសីលក្តី នូវឧបោសថសីលក្តី រមែងឲ្យសមាទាននូវព្រះត្រៃសរណគមន៍ជាមុនសិន ហើយទើបឲ្យសីលជាក្រោយ. ក៏កិរិយាដែលសមាទានដូច្នេះក៏គ្រាន់តែជាកុសល ដែលបានពោលគោរពក្នុងព្រះត្រៃសរណគមន៍ តែនឹងបានជាប្រមាណក្នុងការសមាទានសីលក៏ទេ ព្រោះរឿងសីលដោយឡែក រឿងសរណគមន៍ដោយឡែក សរណគមន៍ដែលបុគ្គលសមាទានហើយ កាលអ្នកនោះមិនកាន់យកនូវគ្រូដទៃថា ប្រសើរជាងព្រះរតនត្រ័យដរាបណា សរណគមន៍ក៏មិនដាច់ដរាបនោះ សមាទានម្តងហើយក៏ប្រព្រឹត្តទៅដរាបអស់ជីវិត កិច្ចដែលនឹងសមាទានទៀតគ្មាន បើប្រសិនជាសៅហ្មងខ្ទះក្នុងរវាង ដោយអគារវកិរិយានឹងសង្ស័យក្នុងព្រះរតនត្រ័យ ដោយប្រាសចាកបញ្ញាសោត ក៏គប្បីជំរះទោសនោះដោយសុំខមាទោស នឹងគិតបន្ទោបង់នូវសេចក្តី

សន្និះសង្ស័យចេញ ដោយឧបាយឯណានិមួយ សរណគមន៍ក៏ត្រឡប់បរិបូណ៌ឡើងវិញដូចដើម ព្រោះសរណគមន៍នោះមិនមែនដាច់ គ្រាន់តែសៅហ្មង ទាំងព្រះអដ្ឋកថាចារ្យក៏គ្មានបង្គាប់ទុកក្នុងអដ្ឋកថា ឬដីកាឯណានិមួយឡើយថា "កាលនឹងសមាទានសីល ៥ សីល ៨ ត្រូវឲ្យសមាទានសរណគមន៍ជាមុនសិន" ហេតុដូច្នោះ បុគ្គលអ្នកមានសរណគមន៍បរិបូណ៌ហើយ នឹងសមាទានតែសីលតែម្តងក៏គួរ បើអ្នកណាមួយជាមិច្ឆាទិដ្ឋិមកអំពីដើម មិនដែលដល់ព្រះរតនត្រ័យ ទើបនឹងមកជ្រះថ្លាក្នុងវេលានេះជាដំបូងដូច្នេះ គប្បីសមាទានសរណគមន៍ជាមុន ហើយសឹមសមាទានសីលជាក្រោយ ជាការគួរដោយពិត ព្រោះសរណគមន៍ជាហេតុខាងដើមដែលនឹងញ៉ាំងបុគ្គលឲ្យយាងចុះកាន់ពុទ្ធសាសនា បណ្តាកុសលឯណានីមួយដែលបុគ្គលនឹងគប្បីធ្វើក្នុងព្រះពុទ្ធសាសនា ក៏មានសរណគមន៍ជាហេតុខាងដើមទាំងអស់ ហេតុនោះបុគ្គលអ្នកមិនធ្លាប់ដល់សរណគមន៍មកអំពីថ្ងៃមុន កាលនឹងធ្វើកុសលនីមួយគប្បីសមាទានសរណគមន៍ជាមុនជាដរាប អំពើកុសលនោះទើប

មានរស្មីរុងរឿងឡើង ។ បំណែកឯអ្នកមានសរណគមន៍ ហើយមិនបាច់សមាទានក៏បាន តែបើនឹងសមាទានទៀតក៏ ឃើញថាមិនមានទោសអ្វីដែរ គ្រាន់តែជាការដែល ៗ សឹងមិន ជាសម្លាក់សំខាន់ប៉ុន្មាន ។

សរណគមន៍ដែលបុគ្គលបានសមាទានដូចពោលមក ហើយ នឹងដាច់ទៅវិញដោយហេតុ ២ ប្រការ គឺ ១ ដោយ រាប់អានវត្ថុដទៃក្រៅអំពីព្រះរតនត្រ័យ មានចូលកាន់លទ្ធិ-គ្រន្ថតិរ្ថីយ ឬទេវតាវិសេសមានព្រះឥស្វរ ព្រះនារាយណ៍ជា ដើមថាប្រសើរជាងព្រះរតនត្រ័យ មានចិត្តដួលដេកទៅលើវត្ថុ នោះខ្លាំង ហើយគោរពរាប់អានយកជាសរណៈទីពឹងដូច្នេះ សរ-ណគមន៍របស់បុគ្គលនោះរមែងដាច់ ហើយមានទោសផង ។ ២ ដាច់ដោយអ្នកកាន់សរណគមន៍នោះធ្វើកាលកិរិយាស្លាប់ទៅ ព្រោះកាលស្លាប់ទៅហើយហួសវិស័យនឹងក្តាប់យកសរណ-គមន៍រម្លងភពទៅផងបាន កាលស្លាប់ទៅហើយ បើទៅកើត ក្នុងបំណោមមនុស្សពាលមិច្ឆាទិដ្ឋិ ក៏មានទិដ្ឋិវិប្បលាសទៅតាម ដែលបានសេពគប់ ទៅជាបុគ្គលមិច្ឆាទិដ្ឋិទៅក៏មាន កាល

បានសេពគប់នឹងកល្យាណមិត្រ ក៏សមាទានកាន់យកសរណ-គមន៍ឡើងជាថ្មីក៏មាន តែដាច់ដោយធ្វើកាលកិរិយានេះ គ្មានទោស ព្រោះហួសវិស័យនឹងរក្សាតទៅបាន ។

កទា កិលិដ្ឋមេវ ហោតិ លោកិយសរណគមន៍ប្អូនកាលក៏សៅហ្មងមិនបរិសុទ្ធផូរផង់ ដោយហេតុកើតសន្ទិះសង្ស័យឬដោយគិតប្រទុស្តក្នុងព្រះរតនត្រ័យដោយចិត្តជាអកុសល, ប្អូនកាលក៏សៅហ្មងដោយអំពើល្មើសឃ្មើសឃ្មង មិនគោរពដោយកាយវាចាដោយចិត្តជាអកុសល កាលសរណគមន៍សៅហ្មងហើយ គួរគប្បីប្រញាប់ជំរះនូវឧបក្កិលេសនៃសរណគមន៍នោះដោយយោនិសោមនសិការ គឺនឹករឭកដល់គុណព្រះរតនត្រ័យដោយប្រការផ្សេង ៗ មានចំរើនពុទ្ធានុស្សតិភាវនាជាដើមបន្ទោបង់នូវឧបក្កិលេសធម៌នោះឲ្យទាល់តែបាន បើមិនរលាយទៅទេសោត ឲ្យទៅរកអ្នកប្រាជ្ញដែលប្រកបដោយបញ្ញាធ្វើធម្មសាកច្ឆាសាកសួរលោកក្តី ញាំងលោកឲ្យឲ្យឱវាទឲ្យកើតសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យឡើងក្តី ឬមួយធម៌ឯណាដែលខ្លួនធ្លាប់ស្តាប់ ធ្លាប់រៀនមកជាបសាទនីយកថានាំ

មកនូវសេចក្ដីជ្រះថ្លាសោត ក៏គប្បីពិចារណាធម៌នោះឲ្យរងោច រម្ងាប់បង់នូវឧបក្កិលេស មានវិចិកិច្ឆាជាដើម ដោយហេតុទុក្ខបហានទឹងវិក្ខម្ភនបហានឲ្យទាល់តែបាន ។ កាលបុគ្គលមកបដិបត្តិដូច្នេះហើយ ទោះបីមិនបានខមាទោសនឹងព្រះរតនត្រ័យ បុគ្គលនោះ ក៏ឈ្មោះថា មានសរណគមន៍បរិសុទ្ធបរិបូណ៌ដូចដើម ព្រោះថាសរណគមន៍កើតសៅហ្មងឡើងដោយឧបក្កិលេសធម៌ឯណា ឧបក្កិលេសធម៌នោះបុគ្គលបានសង្កត់សង្កិនឲ្យរម្ងាប់ទៅវិញដោយប្រពៃ ហើយបដិបត្តិតមក ។

ដែលនឹងពោលតទៅនេះជាខបដិបត្តិជំរះនូវសរណគមន៍ដែលសៅហ្មងដោយហេតុប្រមាទ កាលបុគ្គលញ៉ាំងអកុសលចិត្តឲ្យប្រព្រឹត្តទៅដោយប្រារព្ធបុគ្គលឯណាជាហេតុ គប្បីញ៉ាំងបុគ្គលនោះឲ្យអត់ទោស ឃើញថាល្អគួរសមណាស់ ព្រោះថាមនោកម្មដំពូកខ្លះដែលប្រព្រឹត្តទៅក្លា អាចឲ្យផលក្នុងបច្ចុប្បន្ននេះក៏មាន ដូចយ៉ាងកម្មនៃសោវេយ្យសេដ្ឋីបុត្រ ដែលគិតប្រមាទក្នុងព្រះមហាកច្ចាយនថេរ ដោយអំណាចរាគចិត្ត ក៏ឲ្យផលឃើញទាន់ហន់ក្នុងបច្ចុប្បន្ន ធ្វើឲ្យសេដ្ឋីបុត្រនោះ

ក្លាយភេទទៅជាស្ត្រី វេលាក្រោយកាលស្ត្រីភាពនោះដឹងទោសខ្លួន ញុំាងព្រះមហាកច្ចាយនថេរឲ្យអត់ទោសហើយ ទើបត្រឡប់ភេទជាបុរសដូចដើមវិញ ហេតុដូច្នោះកិរិយាដែលសូមខមាទោសនេះជាទបដិបត្តិដ៏សមគួរពន់ពេក ។ បើឧបក្កិលេសនៃសរណគមន៍ក្លាខ្លាំងណាស់ប្រព្រឹត្តទៅក្នុងកាយទ្វារ វចីទ្វារ បណ្តាលឲ្យបុគ្គលសំដែងអគារវកិរិយាដោយកាយឬដោយវាចា មានពាក់ស្បែកជើង បាំងឆត្រ បាំងទាំងយូរ ជួតក្បាល ទទូរក្បាល ស្តោះទឹកមាត់ បន្ទោឧច្ចារ បស្សាវៈ ពោយវាយនូវរបស់ស្មោកគ្រោក នឹងលាងជំរះជើងជាដើម ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តានឹងឧបចារនៃពុទ្ធបដិមាករចេតិយស្ថាន ដ៏ជាទុច្ចរិតកម្មសឹងកើតឡើងអំពីអកុសលចិត្តក្តី គឹងធ្វើអគារវកិរិយាដល់ព្រះធម៌ដោយកាយទ្វារ នឹងធ្វើក្តីអន្តរាយក្នុងទីសំដែងធម៌ ស្តាប់ធម៌ រៀនធម៌ ជាដើមក្តី ។

៨ ទៀតសម្តេចព្រះបរមសាស្តាទ្រង់ហាមទុកដោយវិន័យបញ្ញត្តិសឹងមានមកក្នុងសេខិយវត្ត មិនឲ្យសំដែងធម៌ដល់បុគ្គល ១៦ យ៉ាងដែលមិនមែនជាបុគ្គលអាពាធ គឺមនុស្សអ្នកកាន់

បាំងឆត្រ-ទាំងឃ្សូរ ១ អ្នកកាន់ដំបង ១ អ្នកកាន់អាវុធនៅដៃ ១ អ្នកកាន់សស្ត្រាមានធនូ ស្នា កាំភ្លើង ជាដើមនៅដៃ ១ អ្នកពាក់ទ្រនាប់ជើងឈើ ១ អ្នកពាក់ទ្រនាប់ជើងស្បែកជាដើម ១ អ្នកកាលលោកអ្នកសំដែងធម៌ដើរទៅជិះយានទៅ ១ អ្នកកាលលោកអ្នកសំដែងធម៌ជិះយានទាបទៅ ជិះយានខ្ពស់ទៅ ១ អ្នកកាលលោកអ្នកសំដែងធម៌ឈរ ដេកស្តាប់ ១ អ្នកកាលលោកអ្នកសំដែងធម៌អង្គុយលើទីទទេ (គឺឥតកម្រាល) ទៀងអង្គុយលើអាសនៈ ១ អ្នកកាលលោកអ្នកសំដែងធម៌អង្គុយលើអាសនៈទាប អង្គុយលើអាសនៈខ្ពស់ ១ អ្នកកាលលោកអ្នកសំដែងធម៌ឈរនៅ អង្គុយមិនក្រោកឡើងឈរស្តាប់ ១ អ្នកកាលលោកអ្នកសំដែងធម៌ដើរទៅខាងក្រោយ ដើរទៅខាងមុខ ១ អ្នកកាលលោកអ្នកសំដែងធម៌ដើរទៅខាងផ្លូវ ដើរក្នុងផ្លូវទៅ ១ បុគ្គល ១៦ ជំពូកនេះមិនគួរជាភាជនរងព្រះធម៌ វៀរលែងតែមានជម្ងឺជាទម្ងន់ អាការដែលមិនគោរពអម្បាលនេះក្តី ឬអាការដែលមិនគោរពក្នុងភិក្ខុ ១ រូបដែលមានសីលបរិសុទ្ធប្រព្រឹត្តដើម្បីសោតាបត្តិមគ្គក្តី ចាត់ជាកាយិកអគារវ គឺឈ្មោះ

ជាមិនគោរពព្រះរតនត្រ័យដោយកាយ សរណគមន៍រមែងសៅ-
ហ្មងតាមអាការដែលមិនគោរពនោះៗ ។

១ ទៀតកិរិយាដែលបុគ្គលមិនគោរពក្នុងព្រះត្រៃបិដកនោះ ព្រះអដ្ឋកថាចារ្យមិនបានសំដែងទុកក្នុងទីឯណានិមួយទេ តែពិចារណាដោយមតិ នឹងឃើញបទ១ ក្នុងគម្ពីរសារសង្គហថា ព្រះចេតិយដែលបុគ្គលនីមួយសាងឡើងហើយ បញ្ចុះព្រះធម៌មានបដិច្ចសមុប្បាទធម៌ជាដើម បានឈ្មោះថា ធម្មចេតិយ ជាទីសក្ការបូជាស្មើដោយធាតុចេតិយនឹងបរិភោគចេតិយ ហេតុដូច្នោះ កិរិយាដែលមិនគោរពព្រះធម្មចេតិយ គម្ពីរព្រះត្រៃបិដកក្តី ឃើញថាសរណគមន៍សៅហ្មងដោយពិត ក៏ដែរថា គម្ពីរព្រះត្រៃបិដកនេះមិនចំពោះតែគម្ពីរធំៗ ដូចយ៉ាងគម្ពីរ អាទិកម្មជាដើមនោះទេ សូម្បីសេចក្តីធម៌វិន័យឯណានីមួយដែលបុគ្គលសរសេរចារចម្លង ឬបោះពុម្ពជាក់ស្លឹករឹត ឬក្រដាសតិចក្តីច្រើនក្តី មិនថា កាលបុគ្គលសំដែងកិរិយាមិនគោរពមានដើរជាន់ ដើរកន្លងជាដើម ឃើញថាសរណគមន៍គង់សៅហ្មងដូចគ្នា ។ បើចារិករឿងរ៉ាវផ្សេងៗ ក្រៅពីធម៌វិន័យរបស់ព្រះដ៏មានព្រះភាគ

ស្លាប់មិនគោរពក៏មិនមានទោស សំដែងមកទាំងនេះជាកិរិយាមិនគោរពដោយកាយ ។ សេចក្ដីគារវនឹងអគារវឯទៀតដែលមិនបាននាំមកសំដែងក្នុងទីនេះ គប្បីឲ្យវិនិច្ឆ័យដូចគ្នានេះចុះ ។

១ ទៀត បុគ្គលលុះអំណាចក្នុងឧបក្កិលេសសរណគមន៍ មានទិដ្ឋិវិប្បល្លាសឃើញខុសជាត្រូវ ពោលតិះដៀលព្រះរតនត្រ័យដោយអំណាចទោសចិត្ត ឬប្រារព្ធយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃមកពោលក្រមាប់សើចលេង ឈ្មោះវាចិកអគារវ ប្រព្រឹត្តទៅក្នុងផរុសវាចា សរណគមន៍រមែងសៅហ្មង ។ កិរិយាដែលបុគ្គលតិះដៀលព្រះចេតិយ ឬរូបព្រះបដិមាករដែលជាងធ្វើមិនល្អ ដោយបំណងនឹងឲ្យធ្វើឲ្យល្អឡើង មិនឈ្មោះថាមិនគោរពក្នុងព្រះពុទ្ធអង្គ ឬមួយគ្នាតិះដៀលព្រះធម៌ដែលបុគ្គលសរសេរជារ បោះពុម្ពខុសក្ដី សំដែងខុសក្ដី សំដែងមិនច្បាស់លាស់ស្ដាប់មិនចូលចិត្តក្ដី ដោយសំគាល់ឃើញថាជាទោសក្នុងការដែលនឹងនាំយកទៅបដិបត្តិ ហើយពោលពោទសាកសួរដើម្បីនឹងជិរះបង់នូវសេចក្ដីសង្ស័យជាដើម ឬបំណងនឹងល្បងបញ្ញាអ្នកដទៃ ទើបក្លែងពោលទោសព្រះធម៌ឡើង ដើម្បីនឹង

ឲ្យអ្នកដទៃដោះស្រាយ នឹងបានឈ្មោះថា អគារវក្នុងព្រះធម៌ក៏ទេ ឬឃើញភិក្ខុបុគ្គលអង្គឯណានីមួយប្រព្រឹត្តមិនគប្បីហើយពោលត្អះតាមទោសានុទោសដែលមាននោះក្តី ពោលហាមប្រាមដើម្បីនឹងឲ្យលះបង់នូវអំពើនោះ ៗ ដោយគិតនឹងឲ្យប្រយោជន៍ក្តី មិនឈ្មោះថា អគារវក្នុងព្រះសង្ឃ ។

១ ទៀតបុគ្គលប្រារព្ធយករឿងនោះ ៗ មកជាហេតុហើយរិតក្កទៅថា ក្នុងធម៌វិន័យឯណាដែលមានពាក្យវិប្បរិវាសប្រកបទៅដោយទោសដូច្នេះ ធម៌វិន័យនោះប្រហែលមិនមែនជានិយ្យានិក នាំសត្វឲ្យរួបចាកទុក្ខក្តី ក្នុងសាសនាឯណាមានភិក្ខុពាលប្រព្រឹត្តអាក្រក់ដូច្នេះ សាសនានោះប្រហែលជាគ្មានខ្លឹមសារក្តី ។ កាលបុគ្គលកើតសន្ទេះសង្ស័យដោយហេតុដូច្នេះជាដើមហើយ ញ៉ាំងអកុសលចិត្តឲ្យកើតឡើង សរណគមន៍នៃបុគ្គលនោះឈ្មោះថាសៅហ្មង ហេតុដូច្នោះ កាលបុគ្គលឃើញនូវទោសក្នុងពាក្យដែលសំដែងធម៌ដូចពោលមកហើយនោះ ក៏គប្បីប្រឹក្សាសាកសួរអ្នកប្រាជ្ញ បន្ទោបង់នូវសេចក្តី

សង្ស័យនោះចេញ គប្បីសន្និដ្ឋានដោយចិត្តរបស់ខ្លួនថា ព្រះសទ្ធម៌នេះរមែងបរិសុទ្ធផូរផង់ដោយប្រការទាំងពួង នឹងបានមានទោសតែបន្តិចបន្តួចក៏ទេសោះ តែហាក់អាស្រ័យហេតុស្តាប់មិនល្អ ចូលចិត្តខុសដោយខ្លួនឯងក្តី ឬដោយហេតុអ្នកសំដែងធម៌នោះមានសេចក្តីឃើញវិប្បលាសទៅ ហើយពោលចេញមកក៏វិប្បលាសទៅតាមសេចក្តីឃើញនោះក្តី ។

១ ទៀត បុគ្គលសំឡឹងឃើញនូវទុច្ចរិតធម៌របស់ភិក្ខុចំ-ពួកខ្លះ គប្បីឲ្យសន្និដ្ឋានថា សេចក្តីលាមកអាក្រក់ទាំងនោះជារបស់ភិក្ខុនោះឯង បើនឹងពោលរំឭកដាស់តឿន ឬនឹងនិន្ទាស្តីថា ក៏គប្បីពោលចំពោះតែរូបភិក្ខុនោះ កុំពោលត្មះឲ្យជិតដាបទៅដល់ព្រះអរិយសង្ឃ ព្រោះថាភិក្ខុជាបុថុជ្ជនបុគ្គលប្រកបដោយកិលេសរមែងប្រព្រឹត្តឃ្លៀងឃ្លាតទៅខ្លះ មិនបានបដិបត្តិទៅតាមសម្មាបដិបទារបស់ព្រះអរិយសង្ឃ កាលបុគ្គលរក្សានូវប្រសាទគឺសេចក្តីជ្រះថ្លានៃខ្លួនទុកបានដូច្នេះ សរណគមន៍នៃបុគ្គលនោះនឹងបានសៅហ្មងក៏ទេ ។

នៅមានបុគ្គលបំពួកខ្លះជាអ្នកដល់នូវសរណគមន៍ ហើយ តែជាបុគ្គលមានសទ្ធារារែក មិនស្មោះបំពោះក្នុងគុណព្រះរតនត្រ័យតែម្តង កាលមានទុក្ខភ័យមកដល់រមែងរកនេះរកនោះជាសរណទីពឹង សូមឲ្យរំលែករំលោះទុក្ខភ័យនោះឲ្យអស់ទៅ ដូចយ៉ាងធ្វើការលៀងលោមបន់ស្រន់ខ្មោច អារក្ខ អ្នកតាជាដើម សូម្បីមានចិត្តរារែកនៅក្នុងគុណព្រះរតនត្រ័យខ្លះ សរណគមន៍ក៏សៅហ្មងដោយពិត, បើកាលណាបុគ្គលនោះបាក់ចិត្តទៅលើពាហិរវត្ថុនោះតែមួយយ៉ាង ពុំមានរារែកហើយថា អាចនឹងជួយរម្ងាប់ទុក្ខភ័យបានដូរប្រេះដូរប្រោះហើយ សរណគមទក៏ឈ្មោះថាដាច់ក្នុងកាលនោះ នឹងដឹងបានថាសរណគមន៍សៅហ្មងឬដាច់នោះ ឲ្យគប្បីកំណត់តាមទឹកចិត្ត អាការកិរិយាខាងក្រៅនឹងយកជាប្រមាណតែម្តងពុំទាន់បាន, កុំថាឡើយតែបុគ្គលធ្វើទៅលើពាហិរវត្ថុ សូម្បីធ្វើទៅលើព្រះរតនត្រ័យ ឬវត្ថុដ៏ណាងព្រះរតនត្រ័យតាមមតិខ្ញុំយល់ថា សរណគមន៍សៅហ្មងដែរ ព្រោះប្រាសចាកកម្មសទ្ធា សេចក្តីជឿថាកម្មគឺបុណ្យបាបមាន, វិបាកសទ្ធា សេចក្តីជឿថាផលរបស់បុណ្យបាបមាន កម្មស្សកតាសទ្ធា

សេចក្តីជឿថាសត្វទាំងពួងមានកម្មជារបស់ខ្លួន ជាអ្នកទទួលសោយនូវផលរបស់បុណ្យបាប ដែលខ្លួនធ្វើទុក, កាលគ្មានសទ្ធាទាំង៣ប្រភេទនេះហើយ នឹងជាអ្នកនោះជឿជាក់ក្នុងគុណព្រះរតនត្រ័យមិនបាន កាលមិនជឿជាក់ក្នុងគុណព្រះរតនត្រ័យហើយ នឹងជាអ្នកនោះមានសរណាគមន៍បរិសុទ្ធវិរផង់មិនបាន អ្នកនោះឈ្មោះថា គ្មានញាណគឺបញ្ញាគ្រឿងឃើញនូវហេតុផល ជាអ្នកកប់នៅក្នុងសេចក្តីសង្ស័យមិនមានដាច់ស្រេច ជាអ្នកមានញាណគ្រឿងដឹងឃើញខុស ទើបទៅធ្វើការបន់ស្រន់ជួញ្ចោះ សមដោយន័យដែលព្រះអដ្ឋកថាចារ្យ សំដែងទុកក្នុងអដ្ឋកថាសុត្តនិបាតថា "អញ្ញាណសំសយមិច្ឆាញាណាទិ" ជាដើម ព្រោះព្រះពុទ្ធមានមុខក្រសួងគ្រាន់តែជាអ្នកបង្ហាញខុសត្រូវឲ្យសត្វបដិបត្តិតាម មិនមែនមានមុខក្រសួងចាំទទួលរបស់បំណន់ ។

(នៅមានត)

គាថាធម្មបទ ប្រែ

របស់អាចារ្យ ហឹម

ក្រុមជំនុំប្រែព្រះត្រៃបិដក

# ធម្មបទេ ទសមោ ទណ្ឌវគ្គោ

## កោណ្ឌធានត្ថេរវត្ថុគាថា

(៤) មា វោ ច ផរុសំ កញ្ចិ   វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា   បដិទណ្ឌា ផុសេយ្យុ តំ ។
សចេ នេរេសិ អត្តានំ   កំសោ ឧបហតោ យថា
ឯសោ បត្តោសិ និព្វានំ   សារម្ភោ តេ ន វិជ្ជតិ ។

## ឧបោសថិកឥត្ថីនំវត្ថុគាថា

(៥) យថា ទណ្ឌេន គោបាលោ   គាវោ បាជេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច   អាយុំ បាជេន្តិ បាណិនំ ។

# ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងព្រះកុណ្ឌធានត្ថេរ*

(៤) អ្នកកុំពោលពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយ (បើអ្នក) ពោលហើយឲ្យគេហើយ គេគប្បីពោលតបមកកាន់អ្នកវិញមិនខាន ព្រោះថាពាក្យពោលដណ្តើមល្អ តែងនាំយកសេចក្តីទុក្ខមកឲ្យ ដំបងតបគប្បីពាល់ត្រូវអ្នកវិញ ។ បើអ្នកអាចនឹងធ្វើខ្លួនឲ្យស្ងៀមស្ងាត់បាន ដូចជារគាំងដែលគេប្រហារ គឺថាគេកាត់កណ្តាប់ហាមមាត់ចោលបង់ហើយ អ្នកឯងនឹងបានដល់ព្រះនិព្វានពិត ពាក្យពោលដណ្តើមល្អនឹងមិនមានដល់អ្នកឯងឡើយ ។

*គាថាក្នុងរឿងឧបោសថនៃស្ត្រីទាំងឡាយ*

(៥) អ្នកគង្វាលគោ កៀងគោទាំងឡាយ ទៅកាន់ទីគោចរដោយដំបង យ៉ាងណា ជរាក្តីមច្ចុក្តី ក៏រមែងកៀងអាយុនៃសត្វទាំងឡាយ យ៉ាងនោះឯង ។

# ធម្មបទេ ទសមោ ទណ្ឌវគ្គោ

អជគរបេតវត្ថុគាថា

(៦) អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ ។

មហាមោគ្គល្លានត្ថេរវត្ថុគាថា

(៧) យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ ។
វេទនំ ផរុសំ ជានឹ សរីរស្ស បភេទនំ ។
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ ។
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ ។

## ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអជគរប្រេត*

(៦) បុគ្គលពាលកាលកំពុងធ្វើកម្មលាមកទាំងឡាយ មិនទាន់ភ្ញាក់ខ្លួនទេ លុះដល់កាលជាខាងក្រោយ បុគ្គលពាលឥតប្រាជ្ញា ទើបក្តៅក្រហាយនឹងផលនៃកម្មទាំងឡាយជារបស់ខ្លួន ដូចភ្លើងឆេះ ។

*គាថាក្នុងរឿងព្រះមោគ្គល្លានត្ថេរ*

(៧) បុគ្គលណាយកដំបងទៅប្រទុស្តនឹងបុគ្គលទាំងឡាយដែលមិនមានដំបង ជាអ្នកមិនប្រទុស្តហើយ បណ្តាហេតុនៃសេចក្តីទុក្ខទាំងឡាយ ១០ យ៉ាង បុគ្គលនោះនឹងដល់នូវហេតុនៃសេចក្តីទុក្ខឯណានិមួយជាឆាប់មិនខាន ; គឺដល់នូវវេទនាដ៏អាក្រក់ ១ ដល់នូវសេចក្តីវិនាសទ្រព្យ ១ ដល់នូវកិរិយាបែកធ្លាយនៃសរីរ ១ ដល់នូវអាពាធជាទម្ងន់ ១ ដល់នូវសេចក្តីរាយមាយនៃចិត្ត ១ ដល់នូវកិរិយារបជាន់អំពីសំណាក់នៃស្តេច ១ ដល់នូវកិរិយាពោលពាក្យបង្កាច់បង្ខិនដ៏អាក្រក់ ១ ដល់នូវកិរិយាអស់ទៅ (វិនាសទៅ) នៃញាតិទាំងឡាយ ១ ដល់នូវកិរិយាពុកផុយនៃភោគសម្បត្តិទាំងឡាយ ១ ។

## ធម្មបទេ ទសមោ ទណ្ឌវគ្គោ

អថវស្ស អគារានិ    អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ    និរយំ សោ ឧបបជ្ជតិ ។

ពហុភណ្ឌិកភិក្ខុវត្ថុ គាថា

(៨) ន នគ្គចរិយា ន ជដា ន បង្កា
នានាសកា ថណ្ឌិលសាយិកា វា
រជោជល្លំ ឧក្កុដិកប្បធានំ
សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។

សន្តតិមហាមត្តវត្ថុ គាថា

(៩) អលង្កតោ ចេបិ សមំ ចរេយ្យ

## ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមហាមោគ្គល្លាន*

ម្យ៉ាងវិញទៀត ភ្លើងរន្ទះក្តី ភ្លើងជាប្រក្រតីក្តី ឆេះផ្ទះនៃបុគ្គលនោះ ១ បុគ្គលឥតប្រាជ្ញានោះលុះទំលាយកាយទៅកាលណាហើយ នឹងទៅកើតក្នុងនរកមិនខាន ។

*គាថាក្នុងរឿងពហុភណ្ឌិកភិក្ខុ*

(៨) កិរិយាប្រព្រឹត្តអាក្រាតក្តី កិរិយាប្រព្រឹត្តទ្រទ្រង់នូវផ្នួងសក់ក្តី កិរិយាប្រព្រឹត្តដេកត្រាំក្នុងភក់ក្តី កិរិយាប្រព្រឹត្តមិនបរិភោគបាយក្តី កិរិយាប្រព្រឹត្តដេកតែលើផែនដីក្តី កិរិយាប្រព្រឹត្តសន្សំនូវធូលីគឺយកភក់លាបសរីរក្តី កិរិយាព្យាយាមអង្គុយប្រហោងក្តី ក៏មិនអាចនឹងធ្វើសត្វដែលមានសេចក្តីសង្ស័យមិនទាន់កន្លងហើយ ឲ្យស្អាតម៉ត់ចត់បានឡើយ ។

*គាថាក្នុងរឿងសន្តតិមហាមត្ត*

(៩) បុគ្គលណា បើទុកជាមានខ្លួនប្រដាប់ (ដោយសំពត់នឹងគ្រឿងអម្ពរណ៍ក្តី) តែបើប្រព្រឹត្តធម៌ស្មើ

## ធម្មបទេ ទសមោ ទណ្ឌវគ្គោ

សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

ពិលោតិកតិស្សត្ថេរវត្ថុ គាថា

(១០)ហិរិនិសេធោ បុរិសោ កោចិ លោកស្មិំ វិជ្ជតិ
យោ និទ្ទំ អប្បពោធេតិ អស្សោ ភទ្រោ កសាមិវ ។
អស្សោ យថា ភទ្រោ កសា និវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ

មានរាគាទិកិលេសរម្ងាប់បង់ហើយ មានឥន្ទ្រិយទូន្មានហើយ ជាបុគ្គលទៀងហើយ មានកិរិយាប្រព្រឹត្តធម៌ដ៏ប្រសើរជាប្រក្រតី ដាក់ចុះនូវដំបង (គឺជាមិនប្រហារ) ចំពោះសត្វទាំងឡាយទាំងពួង បុគ្គលនោះហៅថាព្រាហ្មណ៍ក៏បាន ជាសមណៈក៏បាន ជាភិក្ខុក៏បាន ។

*គាថាក្នុងរឿងបិលោតិកតិស្សត្ថេរ*

(១០) បុរសដែលឃាត់បង់អកុសលវិតក្ក ដែលកើតឡើងឰដ៏ខាងក្នុង ដោយសេចក្តីខ្មាសបាបបាន បុរស(នោះ)មានតិចក្នុងលោកពេកណាស់ បុរសណានាំចេញនូវសេចក្តីលក់ហើយភ្ញាក់រឭកបាន ដូចសេះដ៏ចំរើន (ល្អ) ឃាត់បង់នូវរំពាត់បាន (បុគ្គលនោះរកបានដោយកម្រ) ។ សេះដ៏ចំរើន (ល្អ) ដែលនាយសារថីទូន្មានដោយរំពាត់យ៉ាងណា អ្នកទាំងឡាយចូរជាអ្នកមានព្យាយាម ជាគ្រឿងញាំងកិលេសឲ្យក្តៅក្រហាយមានសង្វេគយ៉ាងនោះ ។

## ធម្មបទេ ទសមោ ទណ្ឌវគ្គោ

សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បតិស្សតា
បហស្សថ[១] ទុក្ខមិទំ អនប្បកំ ។

### សុខសាមណេរវត្ថុគាថា

(១៧) ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា ទមយន្តិ តេជនំ
ទារុំ ទមយន្តិ តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។

ទណ្ឌវគ្គោ ទសមោ សមត្តោ

---

១ ម. ជហិស្សថ ។

# ទណ្ឌវគ្គទី ១០ ក្នុងព្រះធម្មបទ

បើអ្នកទាំងឡាយប្រកបព្រមដោយសទ្ធាផង ដោយសីលផង ដោយព្យាយាមផង ដោយការដំកល់ចិត្តឲ្យខ្ជាប់ខ្ជួនផង ដោយវិនិច្ឆ័យនូវធម៌ផង បរិបូណ៌ដោយវិជ្ជានឹងចរណៈផង មានស្មារតីដំកល់នៅចំពោះផង គង់នឹងលះបង់បាននូវទុក្ខមានប្រមាណដ៏ច្រើននេះមិនខាន ។

*គាថាកន្សោមសុខសាមណេរ*

(១១) ធម្មតាអ្នកគាំទឹកទាំងឡាយ តែងបង្ហូរទឹក (ទៅកាន់ទីតាមប្រាថ្នារបស់ខ្លួន) ជនអ្នកធ្វើកូនសរទាំងឡាយតែងពត់ដម្រង់កូនសរបាន (ទាបឬញ) ជនអ្នកបាំងឈើទាំងឡាយ តែងបាំងដម្រង់ឈើបាន ឯជនអ្នកប្រដៅងាយតែងទូន្មានខ្លួនឲ្យត្រឹមត្រូវល្អ ។

ទណ្ឌវគ្គទី ១០ ចប់

# ធម្មបទេ ឯកាទសមោ ជរាវគ្គោ

វិសាខាយ សហាយកាវត្ថុគាថា

(១) កោ នុ ហាសោ កិមានន្ទោ   និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា   បទីបំ ន គវេសថ ។

សិរិមាវត្ថុគាថា

(២) បស្ស ចិត្តកតំ ពិម្ពំ   អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ   យស្ស នត្ថិ ធុវំ ឋិតិ ។

ឧត្តរាថេរីវត្ថុគាថា

(៣) បរិជិណ្ណមិទំ រូបំ   រោគនិឌ្ឌំ បភង្គុរំ
ភិជ្ជតិ បូតិ សន្ទេហោ   មរណន្តំ ហិ ជីវិតំ ។

## ជរាវគ្គទី ១១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងស្ត្រីជាសំឡាញ់នៃនាងវិសាខា*

(១) កាលបើលោកសន្និវាសដែលភ្លើងមានរាគៈជាដើម ឆេះរុងរឿងអស់កាលជានិច្ចហើយ តើនឹងសើចដូចម្តេចបាន ត្រេកអរដូចម្តេចបាន នាងទាំងឡាយដែលងងឹតរួបរឹតហើយ ម្តេចឡើយក៏មិនស្វែងរកប្រទីបជាគ្រឿងបំភ្លឺ ។

*គាថាក្នុងរឿងសិរិមា*

(២) សេចក្តីទៀងទាត់ស្ថិតស្ថេរមែងមិនមានដល់អត្តភាពឯណា អ្នកចូរមើលអត្តភាពនោះចុះគឺកម្មធ្វើឲ្យវិចិត្រហើយ ជាកាយប្រកបដោយដំបៅគឺទ្វារទាំង ៩ ជាកាយដែលសង្ខារតាក់តែងសង់ចូលគ្នាឡើងហើយ ដោយឆ្អឹង ៣០០ កំណាត់ ជាកាយក្តៅក្រហាយគឺឈឺចាប់ជានិច្ច ដែលមហាជនត្រូវការដោយច្រើន ។

*គាថាក្នុងរឿងឧត្តរាថេរី*

(៣) រូបនេះគ្រាំគ្រាអស់ហើយជាទីសំណាក់នៃរោគ ជារបស់ពុកផុយរលួយ រាងកាយនៃខ្លួនជារបស់ស្អុយតែងតែបែកធ្លាយទៅ ព្រោះថាជីវិត (របស់សត្វ) មានសេចក្តីស្លាប់ជាទីបំផុត ។

# ធម្មបទេ ឯកាទសមោ ជរាវគ្គោ

សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

### លាឡុទាយិត្ថេរវត្ថុគាថា

(៧) អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ[១]
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍន្តិ ។

### បឋមពោធិវត្ថុគាថា

(៨) អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

១ ម. ជិរតិ ។

ជរាវគ្គទី ១១ ក្នុងព្រះធម្មបទ

មានតែធម៌របស់សប្បុរសទាំងឡាយ ទើបមិនចូលទៅជិតដល់នូវសេចក្ដីចាស់គ្រាំគ្រាបាន ឯលោកសប្បុរសទាំងឡាយ តែងពោលនូវពាក្យដោយសប្បុរសទាំងឡាយ តែប៉ុណ្ណោះ ។

*គាថាក្នុងរឿងលោឡុទាយិត្ថេរ*

(៧) បុរសអ្នកមានពុទ្ធវិបនតិចតួច (បេះដឹងពុទ្ធវិបនតិច) តែងចំរើនរស់នៅដូចគោបំរើ សាច់តែងចំរើនឡើងដល់បុរសនោះ ឯប្រាជ្ញាមិនចំរើនដល់បុរសនោះឡើយ ។

*គាថាក្នុងរឿងបឋមពោធិ*

(៨) តថាគតកាលស្វែងរកជាងឈើគឺតណ្ហាជាអ្នកធ្វើផ្ទះពោលគឺអត្តភាព កាលមិនបានប្រទះឃើញ (ពោធិញាណ) ទើបអន្ទោលទៅកាន់សង្សារមានជាតិមិនតែមួយ ឯសេចក្ដីកើតតែងនាំយកនូវទុក្ខមកឲ្យជារឿយ ៗ ។ នែជាងឈើគឺតណ្ហាជាអ្នកធ្វើផ្ទះពោលគឺអត្តភាព អ្នកឯងតថាគតឃើញមុខហើយ អ្នកឯងនឹងធ្វើផ្ទះពោលគឺអត្តភាព (របស់តថាគត) ទៀតមិនបានឡើយ ។

## ធម្មបទេ ឯកាទសមោ ជរាវគ្គោ

សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ ។

វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

មហាធនសេដ្ឋីបុត្តវត្ថុគាថា

(៩) អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ

ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។

អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ

សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

ជរាវគ្គោ ឯកាទសមោ សមត្តោ

## ជរាវគ្គទី ១១ ក្នុងព្រះធម្មបទ

ឆ្អឹងជំនីរទាំងអស់របស់អ្នកឯង តថាគតកាច់បំបាក់ចោលបង់អស់ហើយ ឯកំពូលផ្ទះសោតក៏តថាគតកំចាត់កំចាយចោលអស់ហើយ ចិត្តរបស់តថាគតដល់ហើយនូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ តថាគតបានដល់នូវធម៌ជាគ្រឿងក្ស័យនៃតណ្ហាទាំងឡាយ ។

*គាថាក្នុងរឿងមហាធនសេដ្ឋីបុត្ត*

(៩) ជនពាលមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យធនក្នុងកាលនៃខ្លួននៅក្មេង រមែងជ្រប់នៅដូចសត្វក្រៀលចាស់ទាំងឡាយ កាលសុបសៅ (សំកុកនៅ) ក្នុងស្រះដែលមានត្រីអស់ហើយ ។ ជនពាលទាំងឡាយមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលនៃខ្លួននៅក្មេង កាលសោកស្តាយអំពើដែលខ្លួនធ្វើក្នុងកាលអំពីមុនទាំងឡាយ រមែងដេកនៅដូចកូនសរទាំងឡាយដែលអស់ស្រឡះហើយ គឺជារបូតស្រឡះហើយអំពីធនូ ។

ជរាវគ្គ ទី ១១ ចប់

# ធម្មបទេ ទ្វាទសមោ អត្តវគ្គោ

ពោធិរាជកុមារវត្ថុគាថា

(១) អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

ឧបនន្ទសក្យបុត្តត្ថេរវត្ថុគាថា

(២) អត្តានមេវ បឋមំ បដិរូបេ និវេសយេ
អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។

បធានិកតិស្សត្ថេរវត្ថុគាថា

(៣) អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ
សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។

## អត្តវគ្គទី ១២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពោធិរាជកុមារ*

(១) បើបណ្ឌិតដឹងថាខ្លួនជាទីស្រឡាញ់ហើយ គួររក្សាខ្លួននោះឲ្យល្អ គួរសំអាតខ្លួនក្នុងវ័យទាំង ៣ វ័យណាមួយកុំខានឡើយ ។

*គាថាក្នុងរឿងឧបនន្ទសក្យបុត្តត្ថេរ*

(២) បណ្ឌិតគួរញុំាងខ្លួនឲ្យដំកល់នៅក្នុងគុណសម្បត្តិដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) ទើបនឹងមិនសៅហ្មងឡើយ ។

*គាថាក្នុងរឿងបធានិកតិស្សត្ថេរ*

(៣) បើបុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ ក៏អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរនឹងទូន្មានអ្នកដទៃបាន ព្រោះថាខ្លួនបុគ្គលទូន្មានបានដោយកម្រក្រៃពេកណាស់ ។

# ធម្មបទេ ទ្វាទសមោ អត្តវគ្គោ

កុមារកស្សបមាតាវត្ថុគាថា

(៤) អត្តា ហិ អត្តនោ នាថោ  កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន  នាថំ លភតិ ទុល្លភំ ។

មហាកាលឧបាសកវត្ថុគាថា

(៥) អត្តនា ហិ កតំ បាបំ  អត្តជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ  វជិរំ វម្ហយំ មណឹ ។

ទេវទត្តវត្ថុគាថា

(៦) យស្ស អច្ចន្តទុស្សីល្យំ  មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ  យថា នំ ឥច្ឆតី ទិសោ ។

## អត្ថវគ្គទី ១២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកុមារកស្សបមាតា*

(៤) ខ្លួនជាទីពឹងរបស់ខ្លួន ឯអ្នកដទៃដូចម្ដេចឡើយនឹងជាទីពឹងខ្លួនបាន ព្រោះបុគ្គលដែលមានខ្លួនទូន្មានល្អហើយ តែងបាន(អរហត្តផល)ជាទីពឹងដែលបុគ្គលរកបានដោយកម្រ ។

*គាថាក្នុងរឿងមហាកាលឧបាសក*

(៥) ក៏ឯបាបដែលខ្លួនធ្វើហើយ តែងកើតអាស្រ័យនៅក្នុងខ្លួន មានខ្លួនជាដែនជាទីកើតឡើងនៃបាប ក៏រមែងញាំញីបុគ្គលឥតប្រាជ្ញា ដូចគ្នានឹងពេជ្រដែលកើតអំពីថ្មភ្នំ រមែងស៊ីនូវកែវមណីគឺថ្មភ្នំដែលជាទីកើតនៃខ្លួនដូច្នោះដែរ ។

*គាថាក្នុងរឿងទេវទត្ត*

(៦) ភាវៈទ្រុស្តសីលដោយបំណែកកមួយគឺតណ្ហា របស់បុគ្គលណា តែងរួបរឹតគ្របសង្កត់នូវអត្តភាពឲ្យធ្លាក់ចុះ ដូចគ្នានឹងវល្លិ៍ជ្រៃកាលរួបរឹតគ្របសង្កត់ដើមឈើ ហោរតែងមានប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាសអន្តរាយយ៉ាងណា បុគ្គលនោះឈ្មោះថាធ្វើខ្លួនឲ្យវិនាសអន្តរាយយ៉ាងនោះដែរ ។

# ធម្មបទេ ទ្វាទសមោ អត្តវគ្គោ

សង្ឃភេទបរិសក្កនវត្ថុគាថា

(៧) សុករានិ អសាធូនិ   អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច   តំ វេ បរមទុក្ករំ ។

កាឡត្ថេរវត្ថុគាថា

(៨) យោ សាសនំ អរហត្តំ   អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ   ទិដ្ឋឹ និស្សាយ បាបិកំ ។
ផលានិ កណ្ដកស្សេវ   អត្តឃញ្ញាយ[១] ផល្លតិ ។

---

១ ម. អត្តឃាតាយ ។

## អត្ថវគ្គទី ១២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសង្ឃភេទបរិសក្កនៈ*

(៧) កម្មទាំងឡាយឯណា ដែលមិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះគឺជនពាលធ្វើបានដោយងាយ បំណែកខាងកម្មណាដែលជាប្រយោជន៍ផង ល្អផង កម្មនោះឯងគឺជនពាលធ្វើបានដោយកម្រក្រៃពេក ។

*គាថាក្នុងរឿងកាលត្ថេរ*

(៨) បុគ្គលណាឥតប្រាជ្ញាអាស្រ័យនូវទិដ្ឋិដ៏លាមកហើយ ហាមឃាត់សាសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ តែងរស់នៅប្រកបដោយធម៌ជាប្រក្រតី បុគ្គលនោះឯងឈ្មោះថាប្រព្រឹត្តទៅដើម្បីសម្លាប់ខ្លួនឯង ដូចផ្លែឫស្សី ផ្លែឡើងកាលណាសម្លាប់ដើមវាចោល ។

# ធម្មបទេ ទ្វាទសមោ អត្តវគ្គោ

ចូឡកាលឧបាសកវត្ថុគាថា

(៩) អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អត្តទត្ថត្ថេរវត្ថុគាថា

(១០) អត្តទត្ថំ បរត្ថេន ពហុណាបិ[1] ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថំ[2] បសុតោ សិយា ។

អត្តវគ្គោ ទ្វាទសមោ សមត្តោ

---

១ ពហុនាបិ ។ ២ សកត្ថ ។

# អត្តវគ្គទី ១២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចូឡកាលឧបាសក*

(៩) អ្នកធ្វើបាបដោយខ្លួនឯង នឹងសៅហ្មងដោយខ្លួនឯងវិញ អ្នកមិនធ្វើបាបដោយខ្លួនឯង តែងនឹងបរិសុទ្ធស្អាតដោយខ្លួនឯងវិញដែរ សេចក្តីបរិសុទ្ធិនឹងមិនបរិសុទ្ធិ អាស្រ័យបំពោះអំពីខ្លួនឯង ឯអ្នកដទៃញុំាងអ្នកដទៃឲ្យបរិសុទ្ធស្អាតមិនបានទេ ។

*គាថាក្នុងរឿងអត្តទត្ថត្ថេរ*

(១០) បុគ្គលមិនត្រូវញុំាងប្រយោជន៍របស់ខ្លួនឲ្យវិនាសទៅ ព្រោះតែប្រយោជន៍របស់អ្នកដទៃដែលច្រើនឡើយ បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គួរខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) កុំខាន ។

អត្តវគ្គ ទី ១២ ចប់

# ធម្មបទេ តេរសមោ លោកវគ្គោ

## ទហរភិក្ខុវត្ថុគាថា

(១) ហីនំ ធម្មំ ន សេវេយ្យ   បមាទេន ន សំវសេ
មិច្ឆាទិដ្ឋឹ ន សេវេយ្យ   ន សិយា លោកវឌ្ឍនោ ។

## សុទ្ធោទនវត្ថុគាថា

(២) ឧត្តិដ្ឋេ នប្បមជ្ជេយ្យ   ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។
ធម្មំ ចរេ សុចរិតំ   ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។

## លោកវគ្គ ទី ១៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទហរភិក្ខុ*

(១) បុគ្គលមិនត្រូវសេពគប់ធម៌ដ៏ថោកទាប គឺបញ្ចពិធកាមគុណ មិនត្រូវប្រព្រឹត្តនៅដោយសេចក្ដីប្រមាទ មិនត្រូវសេពគប់ គឺមិនត្រូវកាន់យកមិច្ឆាទិដ្ឋិ មិនត្រូវញុំាងលោកឲ្យបំរើនទេ ។

*គាថាក្នុងរឿងសុទ្ធោទន*

(២) បុគ្គលមិនគួរប្រមាទ (ធ្វេសប្រហែស) អាហារបិណ្ឌបាតទេ គួរតែប្រព្រឹត្តធម៌ដែលសុចរិតល្អ ព្រោះថាអ្នកប្រព្រឹត្តធម៌តែងដេកនៅជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គលត្រូវប្រព្រឹត្តធម៌ដែលសុចរិតល្អ មិនត្រូវប្រព្រឹត្តធម៌ទុច្ចរិតទេ ព្រោះថាអ្នកប្រព្រឹត្តធម៌តែងដេកនៅជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

# ធម្មបទេ តេរសមោ អត្តវគ្គោ

បញ្ចសតវិបស្សកវត្ថុ គាថា

(៣) យថា ពុព្វុឡកំ បស្សេ  យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ  មច្ចុរាជា ន បស្សតិ ។

អភយរាជកុមារវត្ថុ គាថា

(៤) ឯថ បស្សថិមំ លោកំ  ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ  នត្ថិ សង្គោ វិជានតំ ។

សម្មជ្ជនត្ថេរវត្ថុ គាថា

(៥) យោ ច បុព្វេ បមជ្ជិត្វា  បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។

# លោកវគ្គទី ១៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបញ្ចសតវិបស្សកភិក្ខុ*

(៣) បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញថ្ងៃបណ្តើរកូនយ៉ាងណា ឯស្តេចមច្ចុមិនឃើញអ្នកណាមួយ កាលបេរ-មិលមើលនូវលោក មានខន្ធលោកជាដើមយ៉ាងនោះដែរ ។

*គាថាក្នុងរឿងអភយរាជកុមារ*

(៤) ជនពាលទាំងឡាយរមែងលិចចុះក្នុងអត្តភាពឯណា អ្នកទាំងឡាយចូរមកមើលអត្តភាពគឺលោកនេះ ឧបមាដូចរាជរថដ៏វិចិត្រ ឯសេចក្តីជាប់ជំពាក់ រមែងមិនមានដល់បណ្ឌិតទាំងឡាយកាលដឹងច្បាស់ឡើយ ។

*គាថាក្នុងរឿងសម្មជ្ជនត្ថេរ*

(៥) បុគ្គលណាកាលពីមុនប្រមាទហើយ លុះដល់កាលជាខាងក្រោយគេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររួចផុតអំពីពពក ។

## ធម្មបទេ តេរសមោ លោកវគ្គោ

### អង្គុលិមាលត្ថេរវត្ថុគាថា

(៦) យស្ស បាបំ កតំ កម្មំ  កុសលេន បិធី[១] យតិ
សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។

### បេសការធីតាវត្ថុគាថា

(៧) អន្ធភូតោ អយំ លោកោ  តនុកេត្ថ វិបស្សតិ
សកុណោ[២] ជាលមុត្តោវ  អប្បោ សគ្គាយ គច្ឆតិ ។

### តឹសភិក្ខុវត្ថុគាថា

(៨) ហង្សា អាទិច្ចបថេ យន្តិ  អាកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា  ជេត្វា មារំ សវាហនំ ។

---

១ ម. បិហិយតិ ។ ២ សកុន្តោតិបិ បាឋោ ។

## លោកវគ្គទី ១៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអង្គុលិមាលត្ថេរ*

(៦) បុគ្គលណាធ្វើអំពើបាបហើយលះបង់ដោយកុសលបាន បុគ្គលនោះឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររួចផុតអំពីពពក ។

*គាថាក្នុងរឿងបេសការធីតា*

(៧) លោកិយមហាជននេះមានងងឹតកើតហើយ បណ្ដាជនទាំងនេះ ជនតិចណាស់រមែងឃើញច្បាស់ដោយអំណាចលក្ខណា មានអនិច្ចលក្ខណាជាដើម (ព្រោះហេតុនោះបានជា) ជនតិចគ្នា (ណាស់) ដែលទៅកាន់ស្ថានសួគ៌ ដូចគ្នានឹងសត្វស្លាប (តិចណាស់) ដែលរួចអំពីសំណាញ់ (ឬ) អន្ទាក់ ។

*គាថាក្នុងរឿងតឹសភិក្ខុ*

(៨) សត្វហង្សទាំងឡាយតែងហើរទៅក្នុងគន្លងព្រះអាទិត្យគឺអាកាស បុគ្គលអ្នកចំរើនឥទ្ធិបាទទាំងឡាយ តែងហោះទៅក្នុងអាកាសដោយឫទ្ធិ ឯអ្នកប្រាជ្ញទាំងឡាយលុះផ្ចាញ់កិលេសមារព្រមទាំងវាហនៈគឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបានដោយងាយ ។

ធម្មបទេ តេរសមោ អត្ថវគ្គោ

ចិញ្ចមាណវិកាវត្ថុគាថា

(៩) ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។

អសទិសទានវត្ថុគាថា

(១០) ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

អនាថបិណ្ឌិកស្សបុត្តកាលវត្ថុគាថា

(១១) បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

លោកវគ្គោ តេរសមោ សមត្តោ

# លោកវគ្គទី ១៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចិញ្ចមាណវិកា*

(៩) បុគ្គលប្រព្រឹត្តកន្លងពាក្យសច្ចៈ ដែលជាធម៌ឯកហោលបង់ ពោលតែពាក្យកុហកជាប្រក្រតី បរលោកក៏លះបោលស្រឡះហើយ ឈ្មោះថាមិនធ្វើអំពើបាបគ្មានឡើយ (គឺធ្វើ) ។

*គាថាក្នុងរឿងអសទិសទាន*

(១០) បុគ្គលកំណាញ់ស្អិតស្អាញមិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយរមែងមិនសរសើរទាន (របស់បុគ្គលដទៃ) សោះឡើយ ចំណែកឯលោកអ្នកប្រាជ្ញត្រេកអរនឹងទាន (របស់បុគ្គលដទៃ) លោកតែងបានសេចក្តីសុខ ក្នុងលោកខាងមុខព្រោះសេចក្តីត្រេកអរនឹងទានរបស់បុគ្គលដទៃ ។

*គាថាក្នុងរឿងបុត្តកាលនៃអនាថបិណ្ឌិក*

(១១) សោតាបត្តិផលជាគុណជាតិដ៏ប្រសើរជាងភាវៈនៃខនជាស្តេចឯករាជលើផែនដីផង ជាងទៅកាន់ស្ថានសួគ៌ផង ជាងភាវៈនៃបុគ្គលជាធំក្នុងលោកទាំងអស់ផង ។

លោកវគ្គ ទី ១៣ ចប់

## ធម្មបទេ ចុទ្ទសមោ ពុទ្ធវគ្គោ

មារធីតរវត្ថុគាថា

(១) យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោ យាតិ កោចិ លោកេ
តំ ពុទ្ធមនន្តគោចរំ
អបទំ កេន បទេន នេស្សថ
យស្ស ជាលិនី វិសត្តិកា
តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធមនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

យមកបាដិហារវត្ថុគាថា

(២) យេ ឈានប្បសុតា ធីរា នេក្ខម្មូបសមេ រតា

## ពុទ្ធវគ្គទី ១៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមារធីតា*

(១) កិលេសជាតិដែលព្រះសម្មាសម្ពុទ្ធឯណា ឈ្នះហើយ (ដោយមគ្គនោះៗ) មិនត្រឡប់ឈ្នះវិញបាន កិលេសជាតិដែលព្រះសម្មាសម្ពុទ្ធនោះឈ្នះហើយ (ដោយមគ្គនោះ) កិលេសណាមួយតែងមិនត្រឡប់មកក្នុងលោកនេះទៀតឡើយ ព្រះសម្មាសម្ពុទ្ធនោះ មានអារម្មណ៍រកទីបំផុតគ្មាន មិនមានស្នាមជើងគឺកិលេស នាងទាំងឡាយនាំទៅដោយស្នាមជើងគឺកិលេសដូចម្តេច ។ តណ្ហាមានឧបមាដូចសំណាញ់ ប្រកបដោយកិរិយាជាប់នៅក្នុងអារម្មណ៍ផ្សេងៗរមែងប្រព្រឹត្តទៅដើម្បីនាំទៅក្នុងភពណា ១ មិនមានដល់ព្រះសម្មាសម្ពុទ្ធឯណា ព្រះសម្មាសម្ពុទ្ធនោះមានអារម្មណ៍រកទីបំផុតគ្មាន មិនមានស្នាមជើងគឺកិលេស នាងទាំងឡាយនាំទៅដោយស្នាមជើងគឺកិលេសដូចម្តេច ។

*គាថាក្នុងរឿងយមកបាដិហារ្យ*

(២) អ្នកប្រាជ្ញទាំងឡាយឯណា មានសេចក្តីខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងព្រះនិព្វានជាទីរម្ងាប់បង់នូវកិលេស

# ធម្មបទេ ចុទ្ទសមោ ពុទ្ធវគ្គោ

ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។

ឯរកបត្តនាគរាជវត្ថុគាថា

(៣) កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចានជីវិតំ

កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

អានន្ទត្ថេរវត្ថុគាថា

(៤) សព្វបាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ ។

ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា

ទេវតានឹងមនុស្សទាំងឡាយ តែងស្រឡាញ់អ្នកប្រាជ្ញទាំងនោះ ជាព្រះសម្ពុទ្ធដែលមានសតិ ។

*គាថាក្នុងរឿងឯរកបត្តនាគរាជ*

(៣) ការបានបំពោះនូវអត្តភាពជាមនុស្ស សត្វគប្បីបានដោយកម្រ ជីវិតរបស់សត្វទាំងឡាយ សត្វគប្បីចិញ្ចឹមបានដោយកម្រ ការស្តាប់នូវព្រះសទ្ធម្មសត្វគប្បីបានស្តាប់ដោយកម្រ កាលជាទីកើតឡើងនៃព្រះពុទ្ធទាំងឡាយ សត្វគប្បីបានដោយកម្រ ។

*គាថាក្នុងរឿងអានន្ទត្ថេរ*

(៤) ការមិនធ្វើនូវបាបទាំងពួង ១ ការញ៉ាំងកុសលធម៌ឲ្យបរិបូណ៌ ១ ការញ៉ាំងចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ ១ ទាំង ៣ នេះឈ្មោះថាសាសនារបស់ព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ។

ខន្តីពោលគឺសេចក្តីអំណត់ជាតបៈធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងពោលនូវព្រះនិព្វានថាជារបស់ដ៏ឧត្តម

ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។
អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ ។
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធានសាសនំ ។

អនភិរតភិក្ខុវត្ថុគាថា

(៤) ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ ។
អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

## ពុទ្ធវគ្គទី ១៤ ក្នុងព្រះធម្មបទ

អ្នកបួសបៀតបៀនបុគ្គលដទៃ មិនឈ្មោះថាអ្នកបួសឡើយ សមណកាលបៀតបៀនបុគ្គលដទៃ ក៏មិនឈ្មោះថាសមណដូចគ្នា ។ ការមិនតិះដៀល ១ មិនបៀតបៀនគេ ១ សង្រួមក្នុងព្រះបាតិមោក្ខ ១ ភាវជាអ្នកដឹងប្រមាណក្នុងភត្ត ១ ទីដេកទីអង្គុយនៅដ៏ស្ងាត់ ១ ព្យាយាមជាគ្រឿងប្រកបទូទៅក្នុងអធិចិត្ត ១ ទាំង ៦ នេះឈ្មោះថាសាសនារបស់ព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ។

*គាថាក្នុងរឿងអនភិរតភិក្ខុ*

(៥) សេចក្ដីឆ្អែតក្នុងកាមទាំងឡាយ ដោយភ្លៀងជាវិការនៃកហាបណក៏មិនមានឡើយ កាមទាំងឡាយតែងមានសេចក្ដីសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ដូច្នេះហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយដ៏ជាទិព្វសម្បត្តិបបន្តួចឡើយ ឯសាវករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ តែងត្រេកអរក្នុងធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ។

# ធម្មបទេ ចុទ្ទសមោ ពុទ្ធវគ្គោ

## អគ្គិទត្តព្រាហ្មណវត្ថុគាថា

(៦) ពហុំ[១] វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា ។
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ ។
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។

---

១ ម. ពហូ ។

## ពុទ្ធវគ្គទី ១៤ ក្នុងព្រះធម្មបទ

*គាថាកូនរៀនអគ្គិទត្តព្រាហ្មណ៍*

(៦) មនុស្សទាំងឡាយជាច្រើនរូប បើមានភ័យមកគម្រាមហើយ តែងដល់នូវភ្នំទាំងឡាយផង នូវព្រៃទាំងឡាយផង នូវអារាមនឹងរុក្ខចេតិយទាំងឡាយផង ថាជាទីពឹងទីរឭក ។

ក៏ឯទីពឹងបែបនេះឯង ឈ្មោះថាទីពឹងដ៏ក្សេមក៏មិនមែន ឬឈ្មោះថាទីពឹងដ៏ឧត្តមក៏មិនមែនដែរ បុគ្គលអាស្រ័យនូវទីពឹងទាំងនេះហើយ ឈ្មោះថារួចស្រឡះចាក (ទុក្ខ) ភ័យទាំងពួងគ្មានឡើយ ។ លុះតែបុគ្គលណាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាទីពឹងទីរឭកហើយឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយជាហេតុញ៉ាំងទុក្ខឲ្យកើតឡើងព្រម ១ និរោធសច្ចជាទីប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ប្រការ ជាផ្លូវរបស់ព្រះអរិយបុគ្គលមានកិរិយាទៅកាន់ព្រះនិព្វានជាស្ថានរម្ងាប់បង់នូវទុក្ខ ១ ដោយប្រាជ្ញាដ៏ល្អបាន ។

## ធម្មបទេ ចុទ្ទសមោ ពុទ្ធវគ្គោ

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

អានន្ទត្ថេរស្សបញ្ហាវត្ថុគាថា

(៧) ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតី ។

សម្ពហុលភិក្ខុវត្ថុ

(៨) សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។

ពុទ្ធវគ្គោ ចុទ្ទសមោ សមត្តោ

## ពុទ្ធវគ្គទី ១៤ ក្នុងព្រះធម្មបទ

ឯទីពឹងបែបនេះទើបឈ្មោះថាជាទីពឹងដ៏ក្សេម ទើបឈ្មោះថាជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យនូវទីពឹងទាំងនេះឯង ទើបឈ្មោះថារួចស្រឡះចាក (ទុក្ខ) ភ័យទាំងពួងបាន ។

*គាថាក្នុងរឿងបញ្ហារបស់ព្រះអានន្ទត្ថេរ*

(៧) បុរសអាជានេយ្យរកបានដោយកម្រណាស់ លោកមិនកើតសព្វទីស្ថានឡើយ លោកមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ បើកើតក្នុងត្រកូលណា ត្រកូលនោះតែងដល់នូវសេចក្ដីសុខពិត ។

*គាថាក្នុងរឿងសម្ពហុលភិក្ខុ*

(៨) ព្រះពុទ្ធកើតឡើងជាហេតុឲ្យកើតសេចក្ដីសុខ ការសំដែងនូវព្រះសទ្ធម្មជាហេតុឲ្យកើតសេចក្ដីសុខ ការសាមគ្គីព្រមព្រៀងគ្នារបស់សង្ឃ ជាហេតុនាំមកនូវសេចក្ដីសុខ តបៈធម៌របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាហេតុឲ្យកើតសេចក្ដីសុខ ។

ពុទ្ធវគ្គ ទី ១៤ ចប់ ។

# ធម្មបទេ បន្នរសមោ សុខវគ្គោ

ញាតិកលហវូបសមនវត្ថុគាថា

(១) សុ សុខំវត ជីវាម វេរិនេសុ អវេរិនោ
វេរិនេសុ មនុស្សេសុ វិហរាម អវេរិនោ ។
សុ សុខំវត ជីវាម អាតុរេសុ អនាតុរា
អាតុរេសុ មនុស្សេសុ វិហរាម អនាតុរា ។
សុ សុខំវត ជីវាម ឧស្សុកេសុ អនុស្សុកា
ឧស្សុកេសុ មនុស្សេសុ វិហរាម អនុស្សុកោ ។

មារវត្ថុគាថា

(២) សុ សុខំវត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា

## សុខវគ្គទី ១៥ ក្នុងព្រះធម្មបទ

*គាថាកន្សែរឿងរម្ងាប់ជម្លោះរបស់ញាតិ*

(១) យើងទាំងឡាយជាអ្នកមិនមានពៀរក្នុងពៀរទាំង ៥ តែងរស់នៅជាសុខស្រួលពិត កាលបើមនុស្សទាំងឡាយមានពៀរ យើងទាំងឡាយតាំងនៅជាមនុស្សមិនមានពៀរ ។ យើងទាំងឡាយជាអ្នកមិនក្តៅក្រហាយហើយ ក្នុងសេចក្តីក្តៅក្រហាយទាំងឡាយ តែងរស់នៅជាសុខស្រួលពិត កាលបើមនុស្សទាំងឡាយក្តៅក្រហាយ យើងទាំងឡាយនៅជាអ្នកមិនក្តៅក្រហាយ ។ យើងទាំងឡាយជាអ្នកមិនខ្វល់ខ្វាយក្នុងការខ្វល់ខ្វាយទាំងឡាយ តែងរស់នៅជាសុខស្រួលពិត កាលបើមនុស្សទាំងឡាយខ្វល់ខ្វាយហើយ យើងទាំងឡាយតាំងនៅជាអ្នកមិនខ្វល់ខ្វាយ ។

*គាថាកន្សែរឿងមារ*

(២) សេចក្តីកង្វល់របស់យើងគ្មាន យើងរស់នៅជាសុខស្រួលពិត យើងមានបីតិជាអាហារ ដូចទេវតាទាំងឡាយក្នុងទេវលោកឈ្មោះអាភស្សរៈ ។

# ធម្មបទេ បន្នរសមោ សុខវគ្គោ

កោសលរញ្ញោ បរាជយវត្ថុគាថា

(៣) ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

អញ្ញតរកុលទារិកាវត្ថុគាថា

(៤) នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ
នត្ថិ ខន្ធសមា(១) ទុក្ខា នត្ថិ សន្តិ បរំ សុខំ ។

ឯកឧបាសកវត្ថុគាថា

(៥) ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា
ឯតំ ញត្វា យថា ភូតំ និព្វានំ បរមំ សុខំ ។

បសេនទិកោសលវត្ថុគាថា

(៦) អរោគ្យបរមា លាភា សន្តុដ្ឋីបរមំ ធនំ
វិស្សាសបរមា ញាតិ និព្វានំ បរមំ សុខំ ។

---

១ ទិសា ទុក្ខាតិបិ បាឋោ ។

## សុខវគ្គទី ១៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបរាជ័យនៃស្តេចកោសល*

(៣) បុគ្គលឈ្នះគេតែងសោយពៀរ បុគ្គលចាញ់គេតែងដេកសោយទុក្ខ បុគ្គលមានកិលេសស្ងប់រម្ងាប់បង់ហើយ លះបង់នូវការឈ្នះនិងចាញ់បានហើយ តែងដេកសោយសុខ ។

*គាថាក្នុងរឿងអញ្ញតរកុលទារិកា*

(៤) រកភ្លើងអ្វីស្មើដោយរាគៈគ្មាន សេចក្តីខុសអ្វីស្មើដោយទោសៈគ្មាន រកទុក្ខអ្វីស្មើដោយបញ្ចក្ខន្ធគ្មាន រកសុខអ្វីក្រៃលែងជាងព្រះនិព្វានគ្មាន ។

*គាថាក្នុងរឿងឯកឧបាសក*

(៥) សេចក្តីឃ្លានជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយជារបស់នាំឲ្យកើតទុក្ខយ៉ាងក្រៃលែង អ្នកប្រាជ្ញដឹងច្បាស់នូវសេចក្តីនេះដោយពិតហើយ តែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

*គាថាក្នុងរឿងបសេនទិកោសល*

(៦) ភាវៈនៃបុគ្គលមិនមានរោគជាលាភយ៉ាងក្រៃលែង សេចក្តីសន្តោសជាទ្រព្យយ៉ាងក្រៃលែង សេចក្តីស្និទ្ធស្នាលជាញាតិយ៉ាងក្រៃលែង ព្រះនិព្វានជាសុខ (ដ៏ឧត្តម) ក្រៃលែង ។



លោកសង្ឃភូមា គណៈសុធម្ម

(បែបយ៉ាងគណៈមហានិកាយនៅស្រុកខ្មែរ)

កាន់បាត្រខ្ទុកម្រាក់គោចរបិណ្ឌបាត ។

[illegible]

## រឿងមាយាស្រី

នេះយើងនិយាយពីរឿងព្រេងពីដើម

ថាមានបុរសម្នាក់មានប្រពន្ធនៅជាមួយគ្នា តែពុំមានកូនចៅ ដល់យូរទៅប្រពន្ធនោះមានពុតកំណាចមានសហាយ ហើយនាំសហាយមកដេកក្នុងផ្ទះតែសព្វថ្ងៃ ។

សម័យថ្ងៃ ១ ប្តីនោះពុំនៅ ទៅរកជីកដំឡូងក្នុងព្រៃ ដល់ថ្ងៃក្តៅចូលទៅអាស្រ័យនៅខ្ទមអ្នកតា ប្រពន្ធក៏រៀបតវ៉ាន់ទៅបន់អ្នកតាឲ្យទៅធ្វើប្តីឲ្យស្លាប់ និងយកសហាយធ្វើប្តី លុះរៀបស្រេចហើយ ក៏យកតវ៉ាន់នោះដើរចូលទៅក្នុងខ្ទមអ្នកតា ឯប្តីនោះឃើញ ប្រពន្ធដើរចូលទៅក្នុងខ្ទមអ្នកតាហើយគិតឆ្ងល់ថា ប្រពន្ធអញវាមករកអ្វីក្នុងខ្ទមអ្នកតានេះ គិតហើយចូលពួនក្រោយខ្នងរូបអ្នកតាលបស្តាប់ប្រពន្ធ ។

ឯប្រពន្ធចូលទៅហើយអុជទៀនធូបហើយនិយាយបន់អ្នកតាថា ខ្ញុំមិនចង់យកប្តីខ្ញុំទេ ខ្ញុំយកប្តីទៀត សូមអ្នកតាកាប់ប្តីខ្ញុំឲ្យស្លាប់ទៅ ខ្ញុំថ្វាយជ្រូក ១ ។

ប្ដីនោះឮដូច្នោះហើយឆ្លើយឡើងពីក្រោយអ្នកតាថា អើ បើនាងមានសហាយ ហើយចង់ឲ្យអញកាប់ប្ដីឲ្យស្លាប់នោះ ងាយទេ វិលទៅវិញហើយរកមាន់ក្រាបទាំងមេទាំងពង ១ សំ-បុកស្ងោរឲ្យប្ដីនាងឯងស៊ីទៅវាស្លាប់ហើយ ។

នាងនោះឮដូច្នោះហើយក៏ក្រែងតែអ្នកតាបង្គាប់ ប្រញាប់វិលមកផ្ទះវិញ រកទិញបានមាន់ក្រាប ១ សំបុក ស្ងោរទុកឲ្យប្ដីស៊ីឲ្យស្លាប់នឹងយកសហាយ ។

លុះដល់ពេលប្ដីនោះមកពីជីកដំឡូងដល់ហើយសួរថាគេអើយ បានអីស៊ីបាយរឺយ មេនោះឆ្លើយថា ខ្ញុំបានពងមាន់ក្រាប ១ សំបុកស្ងោរទុកឲ្យអ្នកប្ដី ។ ចាំរៀបបាយមកនឹងស៊ី ។

ប្រពន្ធលើកបាយទាំងពងមាន់ក្រាបមកឲ្យប្ដីស៊ី ប្ដីនោះស៊ីអស់ពងមាន់ហើយធ្វើជាលបដេកបន្តិច ៗ មេនោះគិតស្មានជាប្ដីត្រូវនឹងពាក្យអ្នកតាបង្គាប់ហើយ ផ្ទៀតឬប្ដូរវាអរណាស់ ប្ដីនោះធ្វើជាដេកទៅ ឯមេនោះបើកទ្វារនាំយកសហាយចូលទៅដេកផងគិតស្មានថាជាប្ដីស្លាប់ ។

កំពុងតែនិយាយគ្នាប្ដីឡើងអង្គុយហៅប្រពន្ធថារងាណាស់ ឲ្យដងទឹកមកដាំនឹងងូតបន្តិច ។

ឯសបាយនោះលុះឃើញប្ដីនាងនោះឡើងអង្គុយដូច្នោះ ក៏ស្ទុះរត់ពុំទាន់ ចូលទៅពួនក្នុងពាងធំ១នៅខាងជំណោកសំងំចាំប្ដីនោះដេកនឹងចេញពីពាងទៅដេកនឹងមេនោះវិញ ។

ឯប្ដីនោះឃើញហើយក៏ពុំស្រដី ធ្វើជាមិនឃើញមិនដឹងហៅប្រពន្ធថារងាណាស់ ឲ្យដាំទឹកឲ្យងូតបន្តិចនឹងអាលស្លាប់មេនោះឮថាចង់ស្លាប់ដូច្នោះអរណាស់ ដ្បិតត្រូវនឹងពាក្យដែលទៅបន់អ្នកតា ។

លុះដាំទឹកពុះហើយប្ដីថាទៅដងទឹកត្រជាក់បាន១ក្អមយកមកលាយនឹងទឹកក្ដៅនោះ ប្រពន្ធឮប្ដីប្រើដូច្នោះក៏យកក្អមចេញទៅដងទឹក ឯប្ដីនោះឃើញប្រពន្ធទៅបាត់ហើយ ក៏ឡើងដើរទៅលើកទឹកពុះ១ ខ្ទះនោះយកទៅស្រោចលើសហាយនៅក្នុងពាងស្លាប់ទៅ ហើយចូលទៅដេកវិញធ្វើជាឈឺថ្ងូរហ៊ឺៗទៀត ។

ឯមេនោះដងទឹកយកមកដល់ហើយមើលទៅឃើញសហាយត្រូវទឹកក្ដៅរួញសរសៃដូចគេដកកចេញពីពាង ក៏

ឱនខ្សឹបថាប្ដីក៏មិនឱនទៅវាមិនទាន់ដេកទេ អានោះនៅធ្វក់ដដែល មេនោះយកដៃទៅចាប់ជ្រិមុជទៅត្រូវស្លឹកត្រចៀករហែកជ្រុះទាំងសក់ ក៏ដឹងជាប្ដីស្រោចទឹកក្ដៅស្លាប់ហើយ ក៏ពុំស្រដីយកគ្របពាងមកគ្របហើយយកទឹកឲ្យប្ដីងូត ឯប្ដីក៏មិនស្រដីទឹកក៏មិនងូត ប្រាប់ប្រពន្ធថាអញត្រាន់បើហើយ ៗ ហៅប្រពន្ធចូលទៅដេក ។

លុះព្រឹកព្រហាមឡើងមេនោះពុំដឹងបើនឹងគិតធ្វើដូចម្ដេចនឹងយកខ្មោចចេញឲ្យរួចពីផ្ទះ ក៏គិតក្នុងចិត្តថាក្នុងស្រុកនេះមានចោរ ៤ នាក់ តែងលបលួចអ្នកផងតែសព្វថ្ងៃ សព្វយប់គ្រប់ភូមិ ។ ដូច្នេះអញនឹងគិតឲ្យចោរទាំងបួននាក់នោះយកខ្មោចចេញពីផ្ទះអញទៅចោលក្នុងព្រៃឲ្យបាន គិតហើយដើរទិញសំពត់ហូលអារព្រៃគេយកមកហាលជុំផ្ទះ ឯចោរទាំង ៤ នាក់នោះឃើញហើយគិតគ្នាថា ដើ! មេនេះមានណាស់តើយប់នេះយើងទៅលបលួចវាឲ្យបានកុំខាន សព្វថ្ងៃយើងក្រែងតែវាក្រ ។

ឯមេនោះហាលអាវព្រៃសំពត់ហូលនោះ លុះដល់ពេលល្ងាចក៏យកទៅជូនគេវិញអស់ ហើយក៏យកខ្សែបង់រឹតរូតពាងខ្មោចនោះឲ្យជាប់ទុកឲ្យចោរចូលមកសែង ។

ឯចោរទាំងបួននាក់ លុះយប់ក៏ចបបួលគ្នាទៅលួច ចូលទៅរករបស់ទាំងនោះពុំឃើញ ៗ តែពាង ១ បង្ខាប់មាត់បើកពុំរួច ចោរទាំងបួននិយាយគ្នាថា របស់អស់នោះវាដាក់ក្នុងពាងនេះហើយ បើដូច្នោះយើងសែងពាងនេះទៅ គិតហើយក៏នាំគ្នាសែងពាងនោះទៅ ដល់ព្រៃឆ្ងាយហើយក៏ស្រាយលូកមើល ។ អា ១ លូកដៃទៅត្រូវសក់ ថារុំយស្លូត្រូវដកដៃចេញវិញ ។ អា ១ លូកដៃទៅទៀតត្រូវស្លឹកត្រចៀក ត្រូវភ្នែក ច្រមុះ ហើយស្រែកថារុំយខ្មោចទេ ។ អា ១ ទៀតមិនជឿ លូកដៃទៅទៀតត្រូវដើមទ្រូង ក៏ដឹងជាខ្មោច ស្អុះរត់ចោលហើយខឹងណាស់ថា ដ្បិតមេនោះបញ្ឆោតឲ្យសែងខ្មោចទៅចោលបាន ចោរទាំងបួនគិតគ្នាថា យើងឃ្លាំមើលមេនោះ បើឃើញវាដើរទៅណាតែម្នាក់វា គ្នាយើងចោមចាប់វាវាយឲ្យវាវាង កុំឲ្យវាបញ្ឆោតយើងទៀត ។

ជួន ១ ថ្ងៃ មេនោះចុះទៅកំពង់រកទិញឥវ៉ាន់ ដ្បិតមានសំពៅចិនទើបនឹងដល់មកពីស្រុកចិន ៗ មេនោះដើរដល់កណ្ដាលផ្លូវ ក៏ជួបនឹងចោរទាំងបួននាក់នោះ ចោរឃើញហើយក៏នាំគ្នាប្រុតចាប់នឹងវាយ ហើយជេរពីរឿងដែលវាបញ្ឆោតនោះ មេនោះឆ្លើយថា ណ្ហើយអ្នក បើអ្នកវាយខ្ញុំក៏ឥតប្រយោជន៍ដែរ ដ្បិតខ្ញុំទៅទារប្រាក់ពីចិន ដូច្នេះមកអញ្ជើញទៅនឹងខ្ញុំ ៗ ទារបានបែកគ្នាចាយលេង ។ល

ចោរទាំងបួនឮវាថាឲ្យទៅយកប្រាក់ដូច្នោះ ក៏ចូលចិត្តនាំគ្នាទៅ មេនោះផ្ដាំចោរទាំងបួននោះថា អស់អ្នកឈរចាំនៅលើច្រាំង បើកាលណាឃើញខ្ញុំបោយដៃនោះអ្នកចុះទៅចុះ បានប្រាក់ហើយ ៗ

មេនោះនិយាយផ្ដាំចោរទាំង ៤ ហើយក៏ចុះទៅសំពៅនិយាយនឹងនាយសំពៅលក់ចោរទាំង ៤ វាថាចោរនោះជាខ្ញុំវា ហើយវាបង្អុលបង្ហាញនាយសំពៅ ប្រាប់នាយសំពៅថា បើវាចុះមកខ្ញុំឡើងទៅលើគោក អ្នកចាប់វាដាក់ច្រវាក់ឲ្យជាប់កុំឲ្យវារត់បាន នាយសំពៅព្រមហើយសួរថាខ្ញុំរបស់នាងឯងទាំង

៤ នាក់លក់ថ្លៃប៉ុន្មាន វាថាម្នាក់ថ្លៃ ២ ណែននាយសំពៅឲ្យ ១ ណែន ១ កំណាត់ វាក៏ព្រមលក់ ហើយចេញមកក្រៅបោយដៃហៅចោរទាំង ៤ នាក់នោះ ឯចោរទាំង ៤ គិតស្មានថាជាហៅឲ្យទៅយកប្រាក់ក៏នាំគ្នាចុះទៅ ដល់ហើយស្រាប់តែនាយសំពៅប្រើមនុស្សឲ្យចាប់ ដាក់ច្រវាក់នៅបាតសំពៅទាំងអស់គ្នា ឯមេនោះក៏យកប្រាក់ឡើងមកបាត់ ។

មេនោះបានប្រាក់ហើយដើរវិលមកផ្ទះវិញដល់កណ្ដាលផ្លូវ ក៏ប្លួតជាយប់ពុំហានដើរទៅទៀត ក៏ឡើងទៅដេកលើដើមឈើធំ ១ នៅប្របផ្លូវនោះ ។

ឯចោរទាំងបួននោះលុះបិនដាក់ច្រវាក់ជាប់ហើយក៏និយាយគ្នាថា ដើ! មេនេះហៅប្រាជ្ញាធំ វាបញ្ឆោតឲ្យយើងសែងខ្មោចទៅបោលក្នុងព្រៃហើយ តទ្បូវវាលក់យើងបានទៀត ។ ចោរទាំង ៤ ខឹងណាស់ កាច់ច្រវាក់បាក់រត់បុះចេញពីសំពៅដើរឡើងរត់មកទាំងយប់នោះ ក៏ជួនយប់យូរណាស់នាំគ្នាឡើងទៅដេកលើដើមឈើធំដែលមេនោះដេក ចោរបីនាក់ឡើងទៅដេកលើមែកដោយខ្លួន ឯចោរម្នាក់ឡើងៗទៅក៏ប្អូបនឹងមេនោះនៅលើចុង

ឈើនោះ អាហោរនោះថា អើហង់ឯងស្លាប់ហើយម្ដងនេះ ហង់ឯងធ្លាប់តែបញ្ឆោតយើង ឥឡូវហង់ឯងរត់ចុះឲ្យរួច ។

មេនោះលើកប្រាក់បង្ហាញហើយឱនខ្សឹបថា ណ្ហើយអ្នកកុំស្រដី កុំឲ្យអ្នកទាំងបីនោះដឹង យើងយកគ្នាជាប្ដីប្រពន្ធ យកប្រាក់នេះទៅបាយរកស៊ីកុំអ្នកធ្វើបាបខ្ញុំប្ដី ។

អាហោរឮដូច្នោះក៏មិនស្រដីទៀត ទិតបួលទៅជិតលូកដៃឱបកៀកហើយថា អើប្អូនឯងហៅប្រាជ្ញាធំ បញ្ឆោតបងពីរបីដងហើយ ឥឡូវបងបានគាត់ជាប្រពន្ធដោយសារព្រេងយើងនិយាយហើយឱបបើប ។ មេនោះពុំមានប្រកែកអ្វីហើយស្រដីថាខ្ញុំក្រែងអ្នកស្រឡាញ់ខ្ញុំមិនស្មោះ ឯខ្ញុំស្រឡាញ់អ្នកស្មោះចិត្ត ១ ហើយ ។ អានោះថាបងស្រឡាញ់ស្មោះហើយ នាងពុំដឹងចិត្តបងនឹងឲ្យបងស្បថឬឲ្យបងធ្វើដូចម្ដេច ។ មេនោះថាបើស្រឡាញ់គ្នាចិត្ត ១ នឹងគ្នា មានតែលិទ្ធអណ្ដាតគ្នា នោះមេនោះលៀនអណ្ដាត ហើយឱនទៅរកអាហោរនោះ អាហោរនោះ លិទ្ធអណ្ដាតមេនោះ ហើយលៀនអណ្ដាតឲ្យមេនោះ

លិទ្ធវិញ មេនោះស្រាប់តែខាំជាប់អណ្ដាតអានោះអស់ ១ កំណាត់ ហើយប្រានទំលាក់ពីលើចុងឈើ ធ្លាក់ដល់ដីស្រែកឮតែឡុល ៗ ។

ឯចោរទាំងបីគិតស្មានជាបិនសំពៅតាមមកចាប់ ក៏លោតពីមែកឈើរត់ទៅ ហើយស្រែកហៅគ្នាថារ៉ុយគ្នាយើងរត់ អាបិកដេញហើយ ៗ អាចោរដែលជាប់អណ្ដាតនោះស្រែកហៅគ្នាថា មេនោះវានៅលើចុងឈើនោះឲ្យមកចាប់ ប៉ុន្តែវាជាប់អណ្ដាតនិយាយមិនច្បាស់ឮតែឡុល ៗ គ្នាវាគិតស្មានជាបិនបេះតែប្រឹងរត់យកព្រះអាយុដោយខ្លួន ។

ឯមេនោះចុះពីលើចុងឈើយកប្រាក់ទៅផ្ទះ ឲ្យប្ដីនៅរកស៊ីនឹងប្ដីទៅ ។

ចប់រឿងនេះតែប៉ុណ្ណោះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHEA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់. ៩

ខ្សែ ១០, ១១, ១២, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

COMMISSION DES MŒURS & COUTUMES

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨០

គ. ស. ១៩៣៧

# បញ្ជីរឿង


លេខទំព័រ

១ សារទេសនា ព្រះវិសុទ្ធិវង្ស ហ-តាត រៀបរៀង . . . . . . . . . . . . . ៣

២ ខេមរខេមសរណកថា (សំដែងអំពីវិធីសុំខមាទោស) ព្រះមហាពិទូរ ក្រសេម រៀបរៀង (តចប់) . . . . . . . . . . . . . . . . . . . . . ២៨

៣ គាថាធម្មបទ ប្រែ . . . . . . . . . . . . . . . . . . . . . . ៤៦

៤ រឿងព្រេងខ្មែរ រឿងអាកុហកស៊ី (ចប់) . . . . . . . . . . . . . . . ៩៣


# រូបក្រៅរឿង


១ លោកសង្ឃភូមានៅវត្ត តែកតារ ក្រុងមណ្ឌលេ កំពុងមើលក្រាំងធម៌ . . . . ១

២ ក្មេងប្រុសភូមា វេលារៀបបួសជាសាមណេរ តែងខ្លួនយ៉ាងរាជកុមារ ។ និង ក្មេងស្រីពីរនាក់ តែងខ្លួនយ៉ាងកិណ្ណរី សម្រាប់ក្នុងពិធីបោះត្រចៀក . . . . ២៣

# TABLE DES MATIÈRES

I. Sāradesanā — Abrégé de la doctrine bouddhique par le Vénérable Tath ........................................ 3

II. Khemā - Khema Saranakathā ou Religions refuges des hommes ........................................ 25

III. Gāthādhammapada traduit du Pali en Cambodgien ....... 41

IIII. Contes populaires cambodgiens inédits :

Le menteur pour manger ........................... 93

## HORS TEXTE :

I. Bonze birman lisant le livre sacré fait de vieux vêtements des bonzes laqués noir et dorés. Pagode de Tekataw Mandalay ........................................ 1

II. Enfants birmans au moment de prendre le froc s'habillent de costumes princiers et des anges ailés .............. 23



លោកសង្ឃភូមានៅវត្ត តែកតាវ ក្រុងមណ្ឌលេ កំពុងមើលក្រាំង
ដែលធ្វើអំពីចីពរខ្មុកម្រាក់លាបមាស សរសេរអក្សរទឹកមាស ។
ក្រាំងបែបនេះប្រើឧសរសេររឿងកម្មវាចា ។

សារទេសនា

# ចំពោះទាហានជាតិខ្មែរ

គឺ


ព្រះវិសុទ្ធិវង្ស ហ. តាត

អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ


បានអធិប្បាយហើយរៀបរៀងឡើង

ព. ស. ២៤៧០

សូមអស់លោកអ្នកទាំងឡាយប្រុងចាំស្តាប់!

អាត្មានឹងអធិប្បាយពីសេចក្តីដែលមានប្រយោជន៍ដល់លោកអ្នកទាំងឡាយ តាមសមគួរដល់ភាសិតរបស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង នឹងតាមមតិរបស់អាត្មាដែលជាអ្នកអធិប្បាយនេះខ្លះ ដើម្បីនឹងឲ្យអស់លោកអ្នកទាំងឡាយស្តាប់ងាយយល់ងាយចូលចិត្ត ព្រោះការស្តាប់នេះ កាលបើស្តាប់ពុំបានមិនដឹងជាហេតុដូចម្តេច នោះទោះបីស្តាប់អស់ប៉ុន្មានឆ្នាំ ក៏ជាការឥតប្រយោជន៍ប្រហែលគ្នានឹងមិនស្តាប់; កាលបើស្តាប់បានយល់សេចក្តី សូម្បីស្តាប់តែ ១ រំពេច ក៏ឈ្មោះថាបានស្តាប់ដោយប្រពៃ ។ អស់អ្នកទាំងឡាយសុទ្ធតែជាខេមរជាតិ គេដឹងសព្វប្រទេសថាជាជាតិអ្នកកាន់ព្រះពុទ្ធសាសនា គួរតែឲ្យមានសេចក្តីរីករាយក្នុងចិត្តថាមានភ័ពមានសំណាង បានមកជួបប្រទះព្រះពុទ្ធសាសនាដែលជាពាក្យប្រដៅដ៏ថ្លៃថ្លាវិសេស ព្រោះព្រះពុទ្ធសាសនាជាគុណជាតិដ៏ឧត្តម អាចធ្វើអ្នកដែលប្រតិបត្តិ

តាមឲ្យបានចំរើនដោយការចេះដឹងនឹងសេចក្ដីថ្លៃថ្លា ។ តែអ្នកដែលមានឈ្មោះថាកាន់ព្រះពុទ្ធសាសនាបំពួកខ្លះ ដែលបានសិក្សាឲ្យស្គាល់ជាក់នូវរសជាតិព្រះពុទ្ធសាសនា នៅមានគំនិតផងដោងដោយសេចក្ដីជឿងឆ្ងល់ ដូចជាអ្នកខ្លះដែលបានឃើញអ្នកកាន់ព្រះពុទ្ធសាសនាខ្លះដែលពុំសូវចេះដឹង ជាអ្នកទាបថោក, ជាអ្នកក្រីក្រលំបាក ក៏ប្ដូលចិត្តថាព្រះពុទ្ធសាសនាទាបថោកណាស់ ធ្វើអ្នកដែលប្រតិបត្តិតាមឲ្យល្ងង់ ឲ្យទាបថោក ឲ្យក្រីក្រលំបាក ម្ល៉ោះហើយក៏មិនយកចិត្តទុកដាក់នឹងព្រះពុទ្ធសាសនា ឲ្យជាការមាំមួនឡើយ នេះមកពីអ្នកគិតនោះឯង មិនបានសិក្សា មិនបានពិនិត្យឲ្យឃើញតាមការពិតមែន ។ សព្វថ្ងៃនេះមានអ្នកកាន់ព្រះពុទ្ធសាសនា ជាអ្នកចេះដឹង, ជាអ្នកខ្ពង់ខ្ពស់, ជាអ្នកមានទ្រព្យសម្បត្តិ ក៏មានជាច្រើនរូបណាស់ដែរ តែមិនទាញយកមកជាគ្រឿងដឹកនាំគំនិត ។ ម្យ៉ាងទៀត មានអ្នកដែលមិនកាន់ព្រះពុទ្ធសាសនា ជាអ្នកឥតមានចេះដឹងអ្វីសោះ ជាអ្នកទាបថោក ជាអ្នកក្រីក្រ

លំបាក ក៏សឹងមានជាច្រើនរាប់មិនអស់ អ្នកមានគំនិត ហេតុដូចម្ដេចក៏មិនគិតឲ្យឃើញដល់ហេតុនេះផង ?

ម្យ៉ាងទៀត មានមនុស្សបំពួកខ្លះបានចូលមកសិក្សាបំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនាមានបំណេះអក្សរជាដើម នៅទីវត្តអារាមដែលជាទីបណ្ដុះនៃពូជបំណេះខាងព្រះពុទ្ធសាសនាតាំងពីក្មេងមក អ្នកខ្លះបានទាំងបួសថែមទៀត តែមិនខំប្រឹងរៀនសូត្រឲ្យចេះដឹងប្រាកដមែនទែន លុះដល់វេលាដែលចេញពីវត្តអារាមទៅ បានទៅសិក្សាបំណេះវិជ្ជាឯទៀតក្រៅពីលទ្ធិព្រះពុទ្ធសាសនា ក៏ត្រឡប់ឃើញថាព្រះពុទ្ធសាសនាមិនរៀបរយ មិនថ្លៃថ្លាប្រពៃដូចជាបំណេះវិជ្ជាឯទៀត ម្ល៉ោះហើយក៏នាំគ្នានិយាយបង្អាប់បំណេះដែលចេះពីវត្តអារាមទៅ គឺថាបើឃើញបំណេះណាមួយដែលមិនប្រាកដ ឬឃើញអក្សរដែលអ្នកណាមួយគេសរសេរមិនល្អ ក៏នាំគ្នានិយាយថាបំណេះវត្តអក្សរវត្តប្រើការមិនកើត ដូចជាទីវត្តរមែងតែធ្វើមនុស្សអ្នករៀនមិនឲ្យចេះប្រាកដ ត្រង់ខ្លួនឯងដែលខ្ជិលរៀននោះគិតមិន

យើញដល់ នេះមកពីគំនិតដែលគិតឃើញខុស ព្រោះលុះក្នុងអំណាចនៃសេចក្ដីភាន់ច្រឡំ ។ អស់លោកទាំងឡាយប្រយ័ត្នកុំឲ្យភាន់ច្រឡំគំនិតដូចមនុស្សបំពួកខ្លះដែលគិតឃើញខុសដូចខាងលើនេះឡើយ ត្រូវបូលចិត្តឲ្យមាំថា ព្រះពុទ្ធសាសនានេះជាច្បាប់ប្រដៅមនុស្សដែលជឿប្រតិបត្តិតាម ឲ្យមានប្រាជ្ញា ឲ្យមានបំណេះវិជ្ជា ឲ្យបានថ្លៃថ្លា ឲ្យមានរបៀបរៀបរយល្អ ឲ្យបានសេចក្ដីសុខ ដូចសេចក្ដីអធិប្បាយតទៅនេះ:

## កិរិយាកើតឡើងនៃព្រះពុទ្ធសាសនា

ពាក្យថា "ពុទ្ធសាសនា" ដែលយើងកាន់សព្វថ្ងៃនេះ បែកចេញជាពីរបទ គឺពុទ្ធ ជាបទ១ សាសនា ជាបទ១; ពុទ្ធនេះជាឈ្មោះនៃមនុស្សអស្ចារ្យ ១ នាក់ ដែលកើតក្នុងសក្យត្រកូល ជាតិជាក្សត្រិយ៍នៅក្នុងមជ្ឈិមប្រទេស គឺប្រទេសដែលគេហៅសព្វថ្ងៃនេះថាស្រុកឥណ្ឌៀរឬស្រុកអាំងប៉ែកខាងជើង បើគិតបំនួនឆ្នាំថយក្រោយពីឥឡូវនេះទៅទល់នឹងកាលសម័យ

ដែលមនុស្សអស្ចារ្យនោះកើតឡើង នោះយូរចំនួនជាង ២.៥៥០ ឆ្នាំមកហើយ ។

មនុស្សអស្ចារ្យនោះមានឈ្មោះថាសិទ្ធត្ថ បានសោយរាជ្យតាំងពីព្រះជន្ម ១៦ ឆ្នាំ ដល់មកព្រះជន្ម ២៩ ឆ្នាំបានពិចារណាឃើញច្បាស់នូវសេចក្ដីទុក្ខព្រួយដែលកើតឡើងអំពីជាតិគឺខន្ធ ៥ អំពីជរាគឺចាស់គ្រាំគ្រា អំពីព្យាធិគឺសេចក្ដីឈឺចាប់ អំពីមរណៈគឺសេចក្ដីស្លាប់ ដោយប្រាជ្ញដ៏ក្លាហានហើយមិនអាចនឹងទ្រាំនៅក្នុងនិវេសនដ្ឋាន ដែលជាទីជោកជាំដោយកាមគុណទាំង ៥ បានឡើយ ក៏ចេញបួសខំប្រឹងស្វែងរកធម៌ដើម្បីនឹងរំលត់បង់នូវសេចក្ដីទុក្ខព្រួយទាំងនោះ ដរាបដល់បានសំរេចនូវប្រាជ្ញដ៏ថ្លៃថ្លាវិសេសឈ្មោះថា "សម្ពោធិញាណ" ដែលយើងធ្លាប់ហៅមកធ្លាប់ឮមកថាព្រះអង្គបានត្រាស់ ។ មនុស្សអស្ចារ្យនេះហើយដែលមាននាមថា "ពុទ្ធ" ប្រែថាព្រះអង្គបេះគ្មានសល់ ឬថាព្រះអង្គជ្រាបច្បាស់នូវសេចក្ដីពិតមែន ឬថាព្រះអង្គភ្ញាក់ហើយអំពីដេកលក់គឺសេចក្ដីល្ងង់ ។ ព្រះពុទ្ធជាម្ចាស់នេះ កាលដែលព្រះអង្គបានត្រាស់ហើយ ទ្រង់បានពិចារណាឃើញសត្វ-

និករគឺពពួកមនុស្សនឹងទេវតា ដែលកើតឡើងក្នុងលោកមានសន្តានក្រាស់ដោយមោហគឺសេចក្ដីល្ងង់ មិនដឹងថាខ្លួនធ្លាក់លិចនៅក្នុងសមុទ្រដ៏ធំពោលគឺសង្សារវដ្ដ ដែលជាទីប្រកបដោយទុក្ខភ័យមិនដឹងៗថាខ្លួនប្រឡូកនៅលើគំនរភ្លើងទាំង ៥ ពោលគឺកាមគុណ ៥ ដែលជាគ្រឿងនាំបណ្ដាលឲ្យបានសេចក្ដីទុក្ខលំបាកសេចក្ដីពាលពាលជានិច្ច មានតែសេចក្ដីធ្វេសប្រហែស ឥតមានគំនិតគិតស្វែងរកឧបាយនឹងរលាស់ខ្លួនឲ្យរួចផុតពីក្នុងមហាសមុទ្រ ឬពីក្នុងគំនរភ្លើងនោះឡើយ ដោយសញ្ញាវិបល្លាស គឺសេចក្ដីសំគាល់ខុសថាជាទីប្រកបដោយសេចក្ដីសុខស្រួលវិញ ។

ព្រះអង្គទ្រង់ឃើញថា សត្តនិករទាំងអស់ច្រើនមានគំនិតគិតឆ្លោយយ៉ាងនេះ មកពីមោហធម៌ដែលស្រោបគំនិតសត្វបិទបាំងជិត ហើយដឹកនាំសត្វឲ្យធ្វើទុរអំពើខុសផ្សេងៗ; មោហដែលបិទគំនិតមនុស្សសត្វ ហើយដឹកនាំមនុស្សសត្វទៅនោះឧបមាដូចជាសេចក្ដីល្ងង់របស់ពពួកសត្វមមាច, សត្វកណ្ដោបជាដើម បិទបាំងមិនឲ្យស្គាល់ភ្លើងថាជាគ្រឿងក្ដៅឡើយ ហើយ

បណ្ដាលឲ្យអាចហានចូលទៅក្នុងភ្លើង ដរាបដល់បានសេចក្ដីវិនាស ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ពិចារណាឃើញដូច្នោះហើយ ក៏កើតមានព្រះទ័យប្រកបដោយមហាករុណា គឺសេចក្ដីអាណិតធំដល់ពពួកមនុស្សសត្វទាំងនោះ ប្រាថ្នានឹងជួយដោះឲ្យរួចចេញពីសេចក្ដីងងឹតល្ងង់ ដើម្បីនឹងឲ្យកើតមានប្រាជ្ញាភ្លឺស្វាងឡើង នឹងបានស្គាល់ ទុក្ខ-សុខ, អាក្រក់-ល្អ នឹងគុណ-ទោស ហើយនឹងស្វែងរកឧបាយដោះខ្លួនឲ្យរួចចេញចាកគ្រឿងទុក្ខ ។ ទើបព្រះអង្គទ្រង់សំដែងធម៌ទេសនាប្រដៅសត្វនិករ រាប់ចំនួនឆ្នាំតាំងពីព្រះអង្គបានត្រាស់ហើយ ដរាបដល់ថ្ងៃដែលព្រះអង្គចូលបរិនិព្វាន បានចំនួន ៤៥ ឆ្នាំគត់ ។ ធម៌ទេសនាជាពាក្យប្រដៅទាំងអស់ របស់ព្រះសម្មាសម្ពុទ្ធនោះឈ្មោះថា "សាសន" គឺដែលយើងធ្លាប់ហៅថា "សាសនា ឬសាស្នា" ប្រែថា "ពាក្យឬធម៌ជាច្បាប់សម្រាប់រៀនប្រដៅ" បើរួមពាក្យថា "ពុទ្ធ" ភ្ជាប់មកនឹងពាក្យថា "សាសនា" ជាពាក្យ ១ ម៉ាត់ ហៅថា "ពុទ្ធសាសនា" ប្រែថា "ពាក្យរៀនប្រដៅរបស់ព្រះពុទ្ធ" គឺច្បាប់សម្រាប់ប្រដៅមនុស្សសត្វមិនឲ្យ

ល្ងង់ ឲ្យកើតមានប្រាជ្ញាស្គាល់គ្រឿងពិតមែន ឬឲ្យកើតឲ្យមានបំណេះវិជ្ជា ឬហិច្បាប់សម្រាប់ប្រដៅសត្វ ឲ្យចេះគិតស្វែងរកឧបាយនឹងដោះខ្លួនឲ្យរួចពីគ្រឿងទុក្ខ ឲ្យបានដល់នូវសេចក្ដីសុខ ។

## ដម្លៃនៃព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនានេះ គួរអស់លោកអ្នកទាំងឡាយជ្រាបថាជាពាក្យប្រដៅមានដម្លៃដោយក្រៃលែង ។ ពាក្យប្រដៅទាំងនោះមានពាក្យខ្លះ ត្រូវគ្នានឹងពាក្យសុភាសិតរបស់អ្នកប្រាជ្ញទាំងឡាយអំពីបុរាណ ដែលមនុស្សក្នុងលោកគេបានចេះរៀងៗមកតាំងអំពីមុនព្រះសម្មាសម្ពុទ្ធបានត្រាស់មកក៏មាន ពាក្យខ្លះជាពាក្យប្រដៅផុតវិស័យគំនិតមនុស្សនឹងទេវតាទាំងអស់ ក្រៅតែអំពីព្រះសម្មាសម្ពុទ្ធ ឥតមានអ្នកណាមួយនឹងមានគំនិតគិតបង្កើតឡើងបានដូចនោះក៏មានជាច្រើនអន្លើ ដូចសេចក្ដីដែលសម្ដែងដោយសង្ខេបតទៅនេះ:

១ ព្រះពុទ្ធសាសនាដែលមានឡើងដំបូង ក្នុងស្រុកមជ្ឈិមប្រទេសៗនោះ កាលមុនដែលមិនទាន់មានព្រះពុទ្ធសាសនា

មនុស្សក្នុងប្រទេសទាំងនោះនាំគ្នាប្រព្រឹត្តប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍ដោយច្រើន ជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន ដូចយ៉ាងប្រតិបត្តិបង្អត់អាហារខ្លួនឲ្យលំបាករូបកាយ, ដេកលើបន្លា នឹងអាំងភ្លើងក្នុងវេលាថ្ងៃក្នុងរដូវក្តៅជាដើម ជាសេចក្តីប្រតិបត្តិឥតប្រយោជន៍ទាំងអស់ ក៏ឥតមានមនុស្សណាមួយគិតឃើញថាឥតប្រយោជន៍ ហើយនឹងរិះគិតរកផ្លូវប្រតិបត្តិថ្មីទៀតនោះឡើយ ។

ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ឡើង ទ្រង់បានសម្តែងធម៌ទេសនាជាដំបូង កែប្រែសេចក្តីប្រតិបត្តិទាំងនោះ គឺពន្យល់មិនឲ្យប្រតិបត្តិតាម ហើយឲ្យប្រតិបត្តិតាមបែបយ៉ាងដែលព្រះអង្គទ្រង់ជ្រាបថាមានប្រយោជន៍ពិតវិញ ធម៌ទេសនាជាដំបូងនោះ ព្រះអង្គសម្តែងថា៖

"ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា" ម្នាលភិក្ខុទាំងឡាយ, សេចក្តីប្រតិបត្តិដ៏លាមកអាក្រក់ទាំងពីរយ៉ាងនេះ បព្វជិតមិនគួរសេព គឺថាមិនត្រូវប្រតិបត្តិឡើយ; សេចក្តីប្រតិបត្តិអាក្រក់ពីរយ៉ាងនោះ គឺកាមសុខល្លិកានុយោគ ការ

ប្រកបខ្លួនឲ្យជាប់ជំពាក់ដោយសេចក្ដីសុខក្នុងកាមទាំងឡាយ ១ អត្តកិលមថានុយោគ ការប្រកបសេចក្ដីលំបាកដល់ខ្លួនឲ្យនឿយហត់ឥតប្រយោជន៍ ១ ។

សេចក្ដីប្រតិបត្តិទាំង ២ យ៉ាងនេះ ជាការនាំឲ្យសាវស្ដែស្ង មិនជាសេចក្ដីចំរើនទេ មិនតែប៉ុណ្ណោះឡើយថែមទាំងបណ្ដាលឲ្យបាននូវសេចក្ដីទុក្ខព្រួយទៀត ។

ឯតេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិ-បទា, ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិជាកណ្ដាលដែលមិនលាយប្រឡំនឹងសេចក្ដីប្រតិបត្តិអាក្រក់ទាំង ២ យ៉ាងនោះ តថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតប្រាជ្ញា ឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងក្រៃពេក ដើម្បីសេចក្ដីដឹងល្អ ដើម្បីព្រះនិព្វាន ។

ក៏សេចក្ដីប្រតិបត្តិជាកណ្ដាលនោះដូចម្ដេច ? សេចក្ដីប្រតិបត្តិជាកណ្ដាលនោះ គឺធម៌ដែលគួរស្វែងរកមានអង្គ ៨

ហៅថា "អដ្ឋង្គិកមគ្គ" ជាគ្រឿងចេញផុតចាកសត្រូវគឺកិលេស ៗ

អដ្ឋង្គិកមគ្គទាំង ៨ នោះគឺ សម្មាទិដ្ឋិ ប្រាជ្ញាយល់ត្រូវ ១ សម្មាសង្កប្បោ សេចក្ដីត្រិះរិះត្រូវ ១ សម្មាវាចា សំដីនិយាយត្រូវ ១ សម្មាកម្មន្តោ ការងារត្រូវ ១ សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមោ ព្យាយាមត្រូវ ១ សម្មាសតិ សេចក្ដីរឭកត្រូវ ១ សម្មាសមាធិ កិរិយាដំកល់ចិត្តត្រូវ ១ ៗ

២ មានធម៌ជាពុទ្ធសាសនាម្យ៉ាងទៀត ហៅថា "សច្ចធម្ម" ជាធម៌ប្រកាសនូវសេចក្ដីពិតមែន ជាសេចក្ដីកំបាំងនឹងគំនិតប្រាជ្ញារបស់មនុស្សទេវតាទាំងអស់ កាលមុនដែលពុំទាន់មានព្រះពុទ្ធសាសនា នោះគ្មានអ្នកណាមួយបេះប្រដៅគ្នាឲ្យគិតឃើញត្រូវដូចសច្ចធម៌នេះឡើយ បើទុកជាមានអ្នកឃើញខ្លះ ក៏គ្រាន់តែឃើញព្រឹលៗមិនច្បាស់លាស់ លុះដល់ព្រះអង្គបានត្រាស់ឡើង ទើបព្រះអង្គសម្ដែងអំពីធម៌ពិតមែននោះឲ្យអស់មនុស្សទេវតាទាំងឡាយបានស្គាល់ច្បាស់ច្រើនគ្នាឡើង ហៅថា "អរិយសច្ច" ៗ នេះមាន ៤ យ៉ាងគឺ:

១ – ទុក្ខំ កិរិយាកើតនៃខន្ធ ៥, កិរិយាចាស់គ្រាំគ្រានៃខន្ធ ៥, កិរិយាឈឺចាប់នៃខន្ធ ៥, កិរិយាបែកធ្លាយនៃខន្ធ ៥, គឺសេចក្តីស្លាប់ប៉ុណ្ណោះជាដើម ជាគ្រឿងទុក្ខ ។

២ – ទុក្ខសមុទយោ តណ្ហាជាមេបណ្តាលឲ្យកើតទុក្ខ ។

៣ – ទុក្ខនិរោធោ ធម៌ជាគ្រឿងរលត់មិនសល់នៃគ្រឿងទុក្ខគឺព្រះនិព្វាន ។

៤ – ទុក្ខនិរោធគាមិនីបដិបទា សេចក្តីប្រតិបត្តិធ្វើអ្នកដែលប្រតិបត្តិតាមឲ្យដល់នូវទុក្ខនិរោធ (សេចក្តីប្រតិបត្តិត្រង់នេះបានដល់មជ្ឈិមបដិបទាទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត ដូចសម្តែងខាងដើមហើយ) ។

អរិយសច្ចធម៌ទាំង ៤ នេះ បណ្តាមនុស្សមានប្រាជ្ញាទាំងប៉ុន្មាន តែបានឮបានស្តាប់ ហើយគិតតាមទំនងលំអានធម៌នេះទៅ ក៏នឹងជឿប្រាកដថាត្រូវពិតមែន ដូចក្នុងសម័យសព្វថ្ងៃនេះ បានដំណឹងថាពួកអ្នកប្រាជ្ញក្នុងប្រទេសធំៗ ដូចក្នុងប្រទេសឱរុប គេបានគិតពិនិត្យដល់ព្រះពុទ្ធសាសនាត្រង់

ណោះក៏មានសេចក្ដីស្ងើបអស្ចារ្យសរសើរថា ព្រះពុទ្ធបេះសម្ដែងធម៌ត្រូវពិតមែនណាស់ ។

៣ មានធម៌ជាពុទ្ធសាសនាម្យ៉ាងទៀតសម្រាប់ប្រដៅមនុស្ស ឲ្យបេះគិតពិចារណាដល់រូបកាយ ឲ្យឃើញថាមិនទៀង ថាជាទុក្ខ នឹងឲ្យឃើញថាមិនមែនជារបស់ខ្លួន ហៅថា "ព្រះត្រៃលក្ខណ" ជាប្រយោជន៍នឹងកុំឲ្យសត្វទាំងឡាយមានសេចក្ដីស្រវឹងទៅក្នុងរូបកាយ ។

ធម៌ជារបៀបនៃព្រះពុទ្ធសាសនា ដែលនាំយកមកពន្យល់ក្នុងទីនេះបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីឲ្យឃើញជាតួយ៉ាងនៃព្រះពុទ្ធសាសនាដែលមានដម្លៃវិសេស ព្រោះជាពាក្យប្រដៅផុតវិស័យមនុស្សនឹងទេវតាគិតប្រដៅឲ្យដូចពុំបានឡើយ ។

ដែលនៅមានតទៅទៀតនោះច្រើនណាស់ មិនមានពេលល្មមនឹងនាំយកមកអធិប្បាយឲ្យសព្វគ្រប់បាន ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឡើង បានសម្ដែងធម៌ជាពាក្យប្រដៅអស់ ៤៥ ឆ្នាំ ទើបព្រះអង្គបរិនិព្វានទៅ ព្រះសង្គីតិកាចារ្យគឺពួកសិស្សរបស់ព្រះអង្គតមក លោកបានសង្គាយនារួបរួម

ពាក្យប្រដៅរបស់ព្រះអង្គទុកជា ៣ ផ្នែក ហៅថា “ព្រះត្រៃ-បិដក” គឺវិន័យបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ បិដកទាំង ៣ នេះដូចជាទូសំរាប់ដាក់នូវរបស់មានដម្លៃ គឺព្រះពុទ្ធសាសនានេះឯង ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនាដែលជាពាក្យប្រដៅមនុស្សសត្វឲ្យមានប្រយោជន៍ឲ្យបានសេចក្ដីសុខនោះ មិនមែនប្រដៅឲ្យតែបានប្រយោជន៍នឹងសុខក្នុងបរលោកឯមុខ ដែលយើងមើលទៅមិនឃើញនោះទេ ជាពាក្យប្រដៅឲ្យបានទាំងប្រ-យោជន៍នឹងសេចក្ដីសុខក្នុងលោកនេះផង ដូចសេចក្ដីរៀបរាប់ដោយសង្ខេបតទៅនេះ :

១ ព្រះអង្គប្រដៅមនុស្សមិនឲ្យប្រព្រឹត្តតាមអបាយមុខ ៦ យ៉ាង គឺមិនឲ្យផឹកសុរា ១ មិនឲ្យដើរលេងតាមច្រកល្ហកក្នុងវេលាយប់ ១ មិនឲ្យដើរមើលល្បែងមហោស្រព ១ មិនឲ្យលេងល្បែងភ្នាល់ មានបៀប៉ោជាដើម ១ មិនឲ្យសមគំនិតនឹងមនុស្សខូចយកធ្វើជាមិត្តសម្លាញ់ ១ មិនឲ្យខ្ជិលធ្វើការងាររកស៊ី ១ (បើអស់លោកអ្នកទាំងឡាយចង់ដឹងសេចក្ដីពិស្ដារ

អញ្ជើញមើលសៀវភៅសិង្គាលោវាទសូត្រ ដែលបោះពុម្ពផ្សាយចេញពីព្រះរាជបណ្ណាល័យកម្ពុជា ) ។

២ ព្រះអង្គប្រដៅមនុស្សឲ្យចេះសង្គ្រោះគ្នាទៅវិញទៅមក តាមជាន់ គឺមាតាបិតានឹងកូន, គ្រូអាចារ្យនឹងសិស្ស, ភរិយានឹងស្វាមី មិត្តសម្លាញ់នឹងមិត្តសម្លាញ់ផងគ្នា ចៅហ្វាយនាយនឹងទាសកម្មករគឺកូនឈ្នួលឬបាវព្រាវ, សមណគឺអ្នកបួសនឹងគ្រហស្ថ (មើលសៀវភៅសិង្គាលោវាទសូត្រ) ។

៣ ព្រះអង្គប្រដៅឲ្យមានព្យាយាមក្នុងការរករបរចិញ្ចឹមជីវិត ឲ្យចេះរក្សាទ្រព្យសម្បត្តិដែលកើតដោយព្យាយាមនោះ, ឲ្យរកមនុស្សល្អធ្វើជាមិត្តសម្លាញ់, ឲ្យចេះចាយវាយទ្រព្យរបស់តាមសមគួរដល់របរដែលរកបានមក ។

៤ ព្រះអង្គប្រដៅមនុស្សមិនឲ្យដេកទ្រមក់, មិនឲ្យប្រួលចិត្តប្រជុំនិយាយគ្នាលេង បើខ្លួនចាស់កុំឲ្យស្វែងរកប្រពន្ធក្រមុំ បើប្រុសកុំឲ្យយកស្រីអ្នកលេងជាអ្នកកញ្ជះកញ្ជាយធ្វើជាមេផ្ទះ បើស្រីកុំឲ្យយកប្រុសអ្នកលេងជាអ្នកកញ្ជះកញ្ជាយធ្វើជាម្ចាស់ផ្ទះ (មើលសៀវភៅបរាភវសូត្រ) ។

ព្រះពុទ្ធសាសនាដែលនាំយកមកពន្យល់បន្តិចបន្តួចប៉ុណ្ណោះ នេះ ឲ្យឃើញថាជាពាក្យប្រដៅមនុស្សសត្វឲ្យមានប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ។

សូមអស់លោកទាំងឡាយជ្រាបថា ព្រះពុទ្ធសាសនានេះ បើអ្នកណាមួយបានកាន់ បានសិក្សា បានសង្កេតពិនិត្យមើលឲ្យសព្វគ្រប់ទៅគង់នឹងបានដឹងជាប្រាកដ ថាមានរសជាតិដ៏ថ្លៃថ្លា អាចឲ្យសំរេចប្រយោជន៍ដល់ខ្លួនអ្នកប្រតិបត្តិក្នុងបច្ចុប្បន្ននេះផង ក្នុងបរលោកខាងមុខផង ។

ឯសាសនាឯទៀតដែលមានក្នុងស្រុកយើងក៏សុទ្ធតែមានពាក្យប្រដៅឲ្យមនុស្សប្រតិបត្តិល្អដោយឡែកដែរ យើងមិនបន្ទះបង្អាប់សាសនារបស់គេនោះទេ ព្រោះចូលចិត្តថា ធម្មតាពាក្យប្រដៅដែលហៅថាសាសនានីមួយៗ បើប្រសិនជាប្រដៅឲ្យមនុស្សប្រព្រឹត្តធ្វើនូវអំពើសុទ្ធតែអាក្រក់នោះ តើអ្នកណាគេនឹងទំប្រតិបត្តិតាម គឺមានពាក្យប្រដៅឲ្យធ្វើល្អដែរ បើមិនមានច្រើនក៏គង់មានខ្លះ ល្មមតែអ្នកដែលចូលចិត្តជឿយកមកប្រតិបត្តិតាមបាន តែទោះបីមានដូច្នោះក្តីក៏គង់មិនមានលើស

លុបជាងព្រះពុទ្ធសាសនាឡើយ ក្នុងសាសនាឯទៀតបើមានសេចក្តីប្រតិបត្តិត្រូវល្អប៉ុន្មាន សេចក្តីប្រតិបត្តិនោះក៏សឹងមានបរិបូណ៌គ្រប់គ្រាន់ខាងព្រះពុទ្ធសាសនាឯណោះឥតមានខ្វះ ព្រោះព្រះពុទ្ធសាសនានេះកើតមានឡើងមុនសាសនាឯទៀត ៗ ជាច្រើន ។

ហេតុដូច្នោះ អស់លោកអ្នកទាំងឡាយដែលបានចូលមកកាន់ព្រះពុទ្ធសាសនាហើយ គួរតាំងចិត្តប្រតិបត្តិឲ្យស៊ប់សួន បើមានកិច្ចធុរៈរវល់បំពោះខ្លួនច្រើន មិនអាចនឹងប្រតិបត្តិឲ្យពេញបន្ទុកបាន ក៏គប្បីប្រតិបត្តិយ៉ាងតិចល្មមសមគួរដល់កម្លាំងដែលអាចនឹងប្រតិបត្តិបាន ព្រោះព្រះពុទ្ធសាសនានេះមានសេចក្តីប្រតិបត្តិច្រើនយ៉ាង តាមជាន់នៃអ្នកប្រតិបត្តិ ដូចសេចក្តីអធិប្បាយតទៅក្នុងខាងមុខ ។

ម្យ៉ាងទៀត ការប្រតិបត្តិតាមព្រះពុទ្ធសាសនានេះ ដូចក្នុងសម័យឥឡូវនេះមិនជាការលំបាកនឹងបេះដឹងពេកទេ ពិតមែនជាព្រះពុទ្ធសាសនាប្រៀបដូចជារបស់មានដម្លៃដ៏កល់គៅ

ក្នុងទូដ៏មាំមួនគោលគឺព្រះត្រៃបិដក ហើយពាក់ដោយសោ គឺជាភាសាបាឡី អ្នកដែលមិនចេះភាសាបាឡីដូចគេឥតមានកូនសោនៅដៃ មិនអាចនឹងហាក់បើកទូយករបស់មានដំឡៃគឺព្រះពុទ្ធសាសនាមកបាន ឯសព្វថ្ងៃនេះក្នុងស្រុកយើងកូនសោកាន់តែមានក្រៃលដែរហើយ កូនសោនោះគឺគម្ពីរសាត្រា ឬសៀវភៅដែលគេប្រែពីភាសាបាឡីមកជាភាសាយើងហើយបោះពុម្ពឡើង កាលបើបានសៀវភៅប្រែធម៌អាថ៌ទាំងនោះមកក៏ដូចគេមានកូនសោនៅដៃ អាចនឹងបាក់ទូគឺព្រះត្រៃបិដកបើកយករបស់មានដំឡៃគឺព្រះពុទ្ធសាសនា មកប្រដាប់តាក់តែងខ្លួនគឺប្រតិបត្តិតាមដូចប្រាថ្នាបាន ។



កូនក្មេងភូមា វេលារៀបនឹងបួសជាសាមណេរ បានតែងខ្លួនយ៉ាងរាជកុមារ
និងកុមារីពីរនាក់តែងខ្លួនយ៉ាងកិណ្ណរី សម្រាប់ក្នុងឱកាសពិធីបោះត្រចៀក
ក្រុងបាគន ភូមា ។

ទេសនាទេវសរលោកគាថា

# ព្រះមហាពិទូរ ក្រសេម គន្ធរបនបណ្ឌិត

រៀបរៀង (តបប់)

សេចក្ដីកោទ្ធន

ប្រសិនជាប្ដូសព្លោយធ្វើអគារវក្នុងព្រះរតនត្រ័យដោយ កាយក្ដី ដោយវាចាក្ដី គប្បីខមាទោសខ្លួនចេញ ព្រះអង្គកបា បារ្យសោកដែលនាំទុកសម្រាប់ក្នុងកិច្ចនេះថា អគារវកិរិយាដែល បុគ្គលបានល្មើសឃ្លើសឃ្លងក្នុងព្រះពុទ្ធអង្គហើយ . គប្បីពោល ខមាទោសក្នុងទីបំពោះព្រះភក្ត្រព្រះអង្គក្ដី ឬទីមហាចេតិយក្ដី ដោយគោរពក៏ឈ្មោះថាបានញុំាងទោសឲ្យត្រឡប់ឲ្យស្រាលចុះ មានឧទាហរណ៍ដូចយ៉ាងជដិលសេដ្ឋី កាលកើតជាជាងមាស ក្នុងសាសនកាលនៃព្រះពុទ្ធកស្សប បានប្រមាទព្រះពុទ្ធកស្សប ក្នុងកាលដែលព្រះអង្គបរិនិព្វានហើយ ដោយពាក្យអាសូរោះ លាមក វេលាក្រោយដឹងទោសខ្លួនហើយ បាននាំយកផ្កាមាស ៣ ទងមកកាន់លានព្រះចេតិយធ្វើ ក្ការបូជា ខ្លួនក៏ស្លៀក ដណ្ដប់សំពត់ទទឹក នឹងជ្រលក់សក់ក្បាលឲ្យទទឹកអាបឡាប ជាទណ្ឌកម្ម ហើយចូលទៅក្រាបទូលសូមខមាទោសដោយ បូជាប្រយោគជាកុសល ដោយហេតុប៉ុណ្ណោះទោសនោះក៏

ស្រាលចុះ ជាងមាសនោះមិនបានទៅកើតក្នុងនរកដោយសារកម្មនោះ លុះមកដល់សាសនានៃព្រះសាក្យមុនីនេះ បានមកកើតជាជដិលសេដ្ឋីមានសម្បត្តិគឺភ្នំមាសកំពស់ ៨០ ហត្ថ ផុលផុសឡើងសម្រាប់ប្រើជាប់បុណ្យ បែបបទសម្រាប់ខមាទោសនិងមានសំដែងទៅខាងចុង ។

បើប្រសិនជាភ្លេសប្រហែសបានធ្វើអគារវក្នុងព្រះធម៌សោតកាលដឹងទោសខ្លួនហើយ គប្បីទៅសុំខមាទោសក្នុងទីជាទីសំដែងនូវធម៌ចំពោះមុខព្រះធម្មកថិកក្តី ព្រះមហាថេរអ្នកទ្រទ្រង់នូវព្រះធម៌ក្តី ដូចយ៉ាងព្រះសុមនថេរ ដែលនៅក្នុងទីបរិហារក្នុងកោះលង្កា បានជជែកគ្នានឹងព្រះបុលនាគថេរដ៏ជាសិស្សរបស់ខ្លួន ដែលពោលធម៌ត្រឹមត្រូវហើយ ថាពោលខុស ដោយសំគាល់វិប្បលាស វេលាក្រោយយល់ថាខ្លួនពោលខុស ព្រះបុលនាគថេរពោលត្រឹមត្រូវតាមគន្លងធម៌ លុះដល់ថ្ងៃឧបោសថជាថ្ងៃប្រជុំធំ មានព្រះមហាថេរដែលជាពហុស្សូតជួបជុំនៅទីនោះជាច្រើន វេលាដែលព្រះបុលនាគថេរកំពុងសំដែងធម៌ព្រះសុមនថេរក៏ចូលទៅគោះធម្មាសនពីខាងក្រោយឲ្យសញ្ញា

កាលព្រះពុទ្ធសាសនាគលោះយាកមក ទើបសំដែងនូវទោសដែលខ្លួនពោលខុសនោះឲ្យប្រាកដក្នុងទីប្រជុំសង្ឃបរិសទ្យ រឿងនេះជាតួយ៉ាងក្នុងការដែលសុំខមាទោសព្រះធម៌ ។

បើប្រសិនជាភ្លាំងភ្លាត់ធ្វើអគារវក្នុងព្រះសង្ឃសោត ក៏គប្បីឲ្យប្រជុំសង្ឃក្នុងមណ្ឌលសីមាឯណានីមួយហើយ គប្បីសំដែងនូវទោសនឹងសូមខមាទោសចុះ, បើបានប្រមាទព្រះអរិយ ឬបុថុជ្ជនភិក្ខុអង្គឯណានីមួយ ដែលមានសីលបរិសុទ្ធដោយកាយឬដោយវាចាសោត ក៏គប្បីចូលទៅរកលោកដែលខ្លួនប្រមាទនោះ ធ្វើអភិវាទនកម្មហើយសំដែងនូវទោសនោះថា ខ្ញុំព្រះករុណាបានធ្វើខុសឆ្គាំឆ្គងយ៉ាងនេះៗ នឹងលោកដ៏មានអាយុជាកម្មដ៏លាមក សូមលោកដ៏មានអាយុប្រោសអត់ទោសនោះៗដល់ខ្ញុំព្រះករុណាចុះ, កាលបុគ្គលបានធ្វើនូវប្រយោគសម្បត្តិប្រព្រឹត្តប្រតែដូចពោលមកនេះ ឈ្មោះថាបានញុំាងទោសឲ្យត្រឡប់ បើភិក្ខុដែលខ្លួនប្រមាទនោះទៅនៅឆ្ងាយ មិនអាចនឹងទៅដល់សោត គប្បីបញ្ជូនពណ៌ដ៏មានទៅសូមខមាទោសចុះ, បើលោកដែលខ្លួនប្រមាទនោះជាព្រះអរិយ លោកបរិនិព្វាន

បាត់បង់ទៅហើយ គប្បីទៅសូមខមាទោសនៅទីដែលលោកបរិនិព្វាន ឬទីដែលធ្វើឈាបនកិច្ចសពលោក ឬចេតិយដ្ឋានដែលបញ្ចុះអដ្ឋិធាតុរបស់លោក ធ្វើសក្ការបូជាដោយគោរពហាក់ដូចជាកាលលោករស់នៅ ហើយសិមសុំខមាទោសចុះ, បំណែកឯព្រះសេខបុគ្គលនឹងភិក្ខុបុថុជ្ជនដែលមានសីលបរិសុទ្ធិលោកធ្វើកាលកិរិយាទៅហើយ ឲ្យគប្បីបដិបត្តិដូចន័យដែលពោលមកហើយនេះ, សរីរងណាដែលជាទីរងរ៉ាប់ព្រះលោកុត្តរធម៌ នឹងបដិបត្តិជាបុព្វភាគ គឺចតុបារិសុទ្ធិសីល សរីរនោះទោះបីគ្មានជីវិតគ្រងនៅហើយ ក៏គួរនឹងបូជាដោយពិត ព្រះអដ្ឋកថាចារ្យលោកសរសើរទុក ទោះបីនឹងធ្វើសក្ការបូជាឲ្យដូចសរីរព្រះខីណាស្រពក៏គួរ សូម្បីព្រះពុទ្ធអង្គមិនបានអនុញ្ញាតឲ្យធ្វើព្រះចេតិយបញ្ចុះអដ្ឋិធាតុទុកបូជា ក៏ព្រោះហាមានច្រើនណាស់មិនជារបស់អស្ចារ្យ នឹងបានទ្រង់ហាមមិនឲ្យបូជានោះក៏ទេ ហេតុនោះបុគ្គលកុំគប្បីរង្កៀសសង្ស័យឡើយ គប្បីបូជាហើយខមាទោសដោយគោរព ដូចកាលដែលលោករស់នៅចុះ បើភិក្ខុដែលខ្លួនប្រមាទនោះជាអ្នកដំណើរគ្មានទីលំនៅ ៗ នឹងក្តី

ឬធ្វើកាលកិរិយាបាត់បង់ទៅក្តី អ្នកប្រមាទនោះគប្បីទៅកាន់សំណាក់សង្ឃក្តី ឬទៅកាន់សំណាក់ភិក្ខុដែលជាបណ្ឌិតអង្គឯណានីមួយក្តី ហើយប្រកាសនូវទោសដែលខ្លួនធ្វើខុសនោះថា ខ្ញុំករុណាបានធ្វើខុសយ៉ាងនេះៗទៅលើលោកដ៏មានអាយុឈ្មោះនោះ សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំករុណាផង តែគប្បីកំណត់ប្រមាណមើលថា ភិក្ខុនោះលោកទៅកាន់ទិសណា លោកនៅក្នុងទីណា គប្បីបែរមុខទៅកាន់ទិសនោះ ហើយនមស្ការទៅរកលោកពោលថា សោ ខមតុ សូមលោកម្ចាស់នោះអត់ទោសដល់ខ្ញុំករុណាផងៗ បើភិក្ខុដែលខ្លួនប្រមាទនោះជាបុថុជ្ជន ឬជាសោតាបន្នបុគ្គល ជាសកិទាគាមីបុគ្គល ហើយខ្លួនខ្លាចក្រែងក្រែពេកណាស់ មិនហ៊ានប្ញលទៅជិតសុំខមាទោសនឹងលោកសោត ក៏គប្បីឲ្យធ្វើដូចពោលមកហើយខាងលើនោះផងៗ ន័យ ១ ទៀត លក្ខណៈដែលសុំខមាទោសក្នុងទីកំបាំងមុខ ដូចបរិយាយដែលពោលហើយនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គ និងគម្ពីរអដ្ឋកថា ឈ្មោះថាបរមត្ថសមន្តបាសាទិកា គម្ពីរសារសង្គហលោកណែនាំទុកថា

បើភិក្ខុដែលខ្លួនប្រមាទនោះធ្វើកាលកិរិយាក្តី ទៅកាន់ទីដទៃជាដើមក្តី គប្បីទៅសុំខមាទោ ក្នុងសំណាក់សង្ឃនឹងបណ្ឌិតអ្នកនោះឈ្មោះថាបានញ៉ាំងទោសឲ្យត្រឡប់ដោយប្រពៃ កុំគប្បីសង្ស័យឡើយ ព្រោះថាកិរិយាដែលធ្វើដូច្នេះជាការបដិបត្តិត្រឹមត្រូវតាមព្រះពុទ្ធដីកា ដែលអង្គសម្តេចព្រះបរមសាស្តាទ្រង់ប្រទានដល់ព្រះរាហុលថេរ ក្នុងអម្ពដ្ឋករាហុលោវាទសូត្រថា "សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតព្វំ ឧត្តានី កាតព្វំ បកាសិតព្វំ" ម្នាលរាហុល អ្នកប្បូរពិចារណាមើល កាយកម្មវចីកម្មនឹងមនោកម្ម ដែលអ្នកបានធ្វើហើយ បើឃើញថាកម្មឯណាជាកម្មមិនគាប់មិនប្រពៃ អ្នកបានភ្លាំងភ្លាត់ធ្វើទៅដោយសេចក្តីប្រមាទហើយ កុំគប្បីស្ងៀមបិទបាំងទុក គប្បីសំដែងបើកប្រកាសឲ្យប្រាកដឡើងក្នុងសំណាក់ព្រះសាស្តាក្តី ក្នុងសំណាក់អ្នករួមព្រហ្មចរិយជាមួយគ្នាដែលជាវិញ្ញូជនក្តី ឲ្យទាល់តែបាន កាលអ្នកធ្វើដូច្នេះហើយ វុឌ្ឍិ ហេសា អរិយស្ស វិនយេ សេចក្តីចំរើនក្នុងវិន័យនៃព្រះអរិយក៏នឹងមានដល់អ្នកដោយប្រការដូច្នេះ ។

វិធីដែលព្រះអដ្ឋកថាចារ្យ ឲ្យសំដែងទោសក្នុងសំណាក់បណ្ឌិតភិក្ខុនោះ ឃើញសមគ្នានឹងព្រះពុទ្ធដីកាដែលថា ឲ្យសំដែងទោសក្នុងសំណាក់អ្នករួមព្រហ្មចរិយដែលជាវិញ្ញូជន ហេតុដូច្នោះ ទើបឃើញដោយប្រៀបធៀបនឹងអនុមានថា ឧបាសកធ្វើខុស ដឹងទោសខ្លួនហើយ បើស្វែងរកសង្ឃឬបណ្ឌិតភិក្ខុដើម្បីនឹងសំដែងទោសមិនបាន នឹងសំដែងក្នុងសំណាក់នៃឧបាសកដែលជាអ្នកឆ្លាសក្នុងធម៌ មានសីលស្មើគ្នា ធ្វើនមស្សការដល់ព្រះរតនត្រ័យ ហើយទើបសុំខមាទោសក៏គួរ ។

១ ទៀត បុគ្គលបានធ្វើអគារវប្រមាទក្នុងព្រះរតនត្រ័យដោយកាយ ឬតិះដៀលដោយវាចា ឬប្រមាទបំពោះរតនវត្ថុណានីមួយកាលព្រះអង្គគង់ព្រះជន្មនៅ គេតែងតែសុំខមាទោសក្នុងសំណាក់ព្រះអង្គតែមួយអង្គប៉ុណ្ណោះ ដូចយ៉ាងបុគ្គលមានវក្កលិប្ដីជាដើម ដែលចោទព្រះទព្វមល្លបុត្រដោយបារាជិកឥតមូលគ្មាន ត្រូវទទួលទណ្ឌកម្មសូត្រផ្កាប់បាត្រ ហើយ

ត្រូវប៉ដឹងទោសខ្លួន ក៏សុំខមាទោសក្នុងសំណាក់ព្រះពុទ្ធអង្គ ព្រោះព្រះអង្គជាធម្មសាមិស្សរាធិបតី ជាម្ចាស់ធម៌ ជាធំក្នុងបរិសទ្យទាំង ៤ កាលព្រះអង្គបរិនិព្វានហើយ ដូចយ៉ាងក្នុងកាលឥឡូវនេះ ព្រះអដ្ឋកថាចារ្យទាំងឡាយពណ៌នាទុកក្នុងអដ្ឋកថាវិន័យថា ឲ្យបុគ្គលអ្នកធ្វើខុសនោះសំដែងនឹងខមា-ទោសក្នុងសំណាក់សង្ឃ គឺពួកភិក្ខុតាំងតែ ៤ អង្គឡើងទៅ ព្រោះថាសាធនកិច្ចមានបត្តនិក្កុជ្ជនកម្មជាដើម ដែលទាក់ទងដោយសង្ឃ រមែងជាអធិបតីក្នុងកម្មដែលគប្បីធ្វើដល់គ្រហស្ថ ពាក្យដែលសុំខមានោះនឹងយកភាសាបាលី ដែលវិញ្ញូលិច្ចវីសុំខមានោះក៏បាន នឹងយកតែទំនងមកពោលដោយភាសារបស់ខ្លួនក៏បាន ឲ្យអ្នកធ្វើខុសនោះទៅកាន់សំណាក់សង្ឃក្នុងសីមាឯណានិមួយ ក្រាបបាទព្រះសង្ឃដោយគោរព ហើយសុំខមាទោសដោយបាលីថា :

អច្ចយោ មំ ភន្តេ អច្ចគ្គមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ

តស្ស មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាឯណាបាន ធ្វើហើយ នូវសេចក្ដីមិនគោរពដល់ព្រះពុទ្ធ ឬព្រះធម៌ ឬហាព្រះ សង្ឃ ដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ, បពិត្រ ព្រះសង្ឃដ៏ចំរើន វីទោសខុសបានកន្លងហើយនូវខ្ញុំព្រះករុណា នោះ តាមដែលខ្លួនជាបុគ្គលពាល តាមដែលខ្លួនជាបុគ្គល វង្វេង តាមដែលខ្លួនជាបុគ្គលមិនឆ្លាស បពិត្រព្រះសង្ឃដ៏ ចំរើន សូមព្រះសង្ឃប្ដូរទទួលគឺអត់នូវសេចក្ដីខុស នៃខ្ញុំព្រះ ករុណានោះ ដោយភាវនៃកម្មនោះជាសេចក្ដីខុស ដើម្បីនឹង សង្រួមតទៅខាងមុខ ។ បាឡីបែបនេះជាឯកវចន សម្រាប់ បុគ្គលតែម្នាក់ស្ត្រ បើគ្នាច្រើនឲ្យផ្លាស់ជាពហុវចនតាមសម គួរ ហើយបែបនេះសម្រាប់បុគ្គលធ្វើខុសដោយទ្វារទាំង ៣ ជា មួយគ្នា បើធ្វើខុសតែទ្វារឯណានិមួយ គប្បីដាក់តែទ្វារនោះ ឬធ្វើខុសទៅលើវត្ថុឯណា គប្បីបេញឈ្មោះវត្ថុនោះកុំឲ្យសាំ សន ។ កាលមិនឃើញទោសដោយខ្លួនឯង បើប្រសិនជា

អានអ្នកដទៃដែលជាពហុស្សូតប្រកបដោយគុណមកដាស់តឿនក្តី ទើបសង្ស័យក្រែងមានទោសដោយមិនដឹងខ្លួនក្តី នឹងសុំខមាទោសក៏គួរ ដែលពោលមកនេះដោយអាស្រ័យជឿអ្នកដាស់តឿនជាប្រមាណ បើមិនឃើញទោសខ្លួនសោះហើយ សុំខមាចាត់ជាមុសា មិនគួរ, បើសង្ស័យគប្បីពោលជាពាក្យបរិកប្បថា "ទោសនេះបើប្រសិនជាខ្ញុំព្រះករុណាបានធ្វើហើយ សូមលោកម្ចាស់អត់ទោសនោះឲ្យខ្ញុំព្រះករុណាចុះ ខ្ញុំព្រះករុណានឹងបានសង្រួមតទៅ" ដូច្នេះទើបគួរ ការបដិបត្តិដូច្នេះដូចព្រះរាហុលថេរកាលនៅជាសាមណេរ កាលមានសេចក្តីប្រមាទធ្លាំធ្លងហើយ លោកតែងតែសុំខមាទោសជានិរាប ហេតុដូច្នេះ យើងទាំងឡាយគួរគប្បីកាន់យកតាមយ៉ាងព្រះរាហុលថេរ ដូចមានប្រាកដក្នុងអម្ពដ្ឋករាហុលោវាទសូត្រ ខាងដើមនោះ ។

ការសុំខមាទោសនេះក៏មានអានិសង្សគួរប្រាថ្នា សម្តេចព្រះបរមសាស្តាទ្រង់សំដែងទុកក្នុងសូត្រដូចមានតទៅនេះ "វុឌ្ឍិ ហេសា ភិក្ខវេ អរិយស្ស វិនយេ យទិទំ អច្ចយំ អច្ចយតោ ទិស្វា យថាកម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ "អធិប្បាយ

ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីបំរើនក្នុងអរិយវិន័យនេះ បាន
ដល់កិរិយាដែលបុគ្គលធ្វើខុសឃើញទោសខ្លួនហើយ ប្រញាប់
សំដែងទោសនោះដើម្បីនឹងសង្រួមតទៅ ឈ្មោះថាធ្វើប្រពៃ
ជាហេតុឱ្យបាននូវសព្វគុណទាំងពួង ។ មួយទៀតព្រះអង្គ
ប្រៀបដោយសេចក្តីឧបមាថា ម្នាលភិក្ខុទាំងឡាយ តថាគត
នឹងឧបមាឱ្យអ្នកទាំងឡាយស្តាប់ ដូចយ៉ាងបុរសមានសក់វែង
ជណ្តាប់សំពត់អង្គុយអាំងភ្លើងក្នុងរដូវរងា កាលបុរសនោះធ្វេស
ប្រហែស សក់ឬសំពត់ធ្លាក់ទៅលើភ្លើង ភ្លើងក៏ឆាបឆេះឡើង
បើបុរសនោះដឹងខ្លួនហើយប្រញាប់លត់មួយរំពេច របស់នោះ
ក៏មិនខូចខាតទៅទាំងអស់ កាយបុរសនោះក៏មិនឆេះរលាក
សក់បុរសនោះយូរទៅក៏លូតលាស់ឡើងវិញដូចដើម សំពត់
នោះកាលបុរសដេរប៉ះទៅ ក៏ប្រើបានដូចដើម កាយបុរស
នោះក៏ធ្វើការរកស៊ីជាប្រយោជន៍តទៅទៀតបាន ព្រោះភ្លើងមិន
បានរោលរាលមកឆេះ នេះមានឧបមាដូចម្តេចមិញ ឧបម័យ
ដូចបុថុជ្ជនបុគ្គលជាអ្នកអង្គុយជិតភ្លើងគឺកិលេស រមែងក្តៅ
ក្រហាយទៅដោយកាយទុច្ចរិត វចីទុច្ចរិតជានិច្ចនិរន្តរដូច្នេះ

កាលបើភ្ញាំងភ្លាត់ធ្វើបាបកម្មដោយកាយ វាចាហើយ កុំគប្បីសម្ងំស្ងៀម គប្បីរួសរាន់រក្សាឲ្យប្រក្រតីឡើងវិញ ដោយសំដែងនូវទោសដែលខ្លួនធ្វើខុសនោះក្នុងសំណាក់លោកអ្នកប្រាជ្ញ ហើយប្តេជ្ញាថា នឹងសង្រួមតទៅ ដូចយ៉ាងបុគ្គលប្រញាប់លត់ភ្លើងដែលឆេះសក់និងសំពត់នោះ កាលបុគ្គលមកបដិបត្តិដូច្នេះ ទោសនោះមិនអាចនឹងកំចាត់បង់នូវគុណវិសេស មានមគ្គផលជាដើមក្នុងបច្ចុប្បន្ន កាលបុគ្គលបំពេញសម្មាបដិបត្តិឲ្យក្រាស់ក្រែលឡើង អាចសម្រេចគុណវិសេសក្នុងជាតិនោះបាន នេះជាអានិសង្សនៃខមាទោស ។

## អានិសង្សនៃការដល់សរណគមន៍

“វិវដ្តគាមិកុសលំ ហិ ឥទំ សរណំ” សរណគមនកិរិយានេះជាវិវដ្តគាមីកុសល ញុំាំងបុគ្គលឲ្យដល់ព្រះនិព្វាន ជាកុសលដ៏ឧត្តមខ្ពង់ខ្ពស់ រមែងឲ្យសម្រេចនូវសម្បត្តិទាំង ៣ ប្រការ ចំពោះមានតែក្នុងសាសនាព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ក្នុងកូដទន្តសូត្រនិងទក្ខិណាវិភង្គសូត្រ សម្តេចព្រះមហាករុណាទ្រង់

សំដែងថាជាបុញ្ញកម្មដ៏ធំក្រៃលែង មានអានិសង្សជាងអាមិសទានទាំងពួង មានអន្នទានជាដើមរហូតដល់វិហារទានជាទីបំផុត ដែលបុគ្គលធ្វើដល់សង្ឃក្នុងចតុទិស អាមិសទាននោះទោះបើបុគ្គលបរិច្ចាគប្រាក់មាសអស់ទាំងលានទាំងកោដិក៏ស៊ូនឹងផលដល់នូវសរណាគមន៍មិនបាន ផលដែលខ្ពស់បំផុតក៏គឺដល់នូវព្រះនិព្វានជាទីក្សេមផុតចាកទុក្ខភ័យទាំងពួង សមដូចពុទ្ធភាសិតដែលទ្រង់សំដែងទុកក្នុងខេមាខេមសរណាបទីបិកាគាថា ដែលបានលើកឡើងសំដែងខាងដើមម្តងហើយថា៖

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ

សរណ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃនេះជាសរណដ៏ក្សេមជាសរណដ៏ឧត្តម អ្នកដែលដល់នូវត្រៃសរណនេះហើយ រមែងរួចចាកទុក្ខទាំងពួង ដោយប្រការដូច្នេះ ។

ខេមាខេមសរណកថា ចប់

គាថាធម្មបទ ប្រែ

របស់អាចារ្យ ហឹម

ក្រុមជំនុំប្រែព្រះត្រៃបិដក

## ធម្មបទេ បន្នរសមោ សុខវគ្គោ

តិស្សត្ថេរវត្ថុគាថា

(៧) បវិវេករសំ បិត្វា  រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ  ធម្មបីតិរសំ បិវំ ។

សក្កវត្ថុគាថា

(៨) សាហុ ទស្សនមរិយានំ  សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ  និច្ចមេវ សុខី សិយា ។
ពាលសង្គតចារី ហិ  ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ  អមិត្តេនេវ សព្វទា ។
ធីរោ ច សុខសំវាសោ  ញាតីនំវ សមាគមោ

## សុខវគ្គទី ១៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងតិស្សត្ថេរ*

(៧) ភិក្ខុកាលផឹកនូវរសដ៏កើតអំពីទីស្ងាត់ផង នូវរសនៃព្រះនិព្វានជាទីរម្ងាប់បង់នូវកិលេសផង នូវរសនៃបីតិដែលកើតអំពីលោកុត្តរធម៌ផង តែងមិនមានក្រវល់ក្រវាយនឹងមិនមានបាបឡើយ ។

*គាថាក្នុងរឿងសក្ក*

(៨) ការឃើញនូវព្រះអរិយបុគ្គលទាំងឡាយជាការល្អ ការនៅរួមជាមួយនឹងព្រះអរិយបុគ្គលទាំងឡាយនោះជាហេតុឱ្យកើតសុខសព្វកាល ។ បុគ្គលគប្បីមានសេចក្ដីសុខអស់កាលជានិច្ចដោយហេតុមិនបានឃើញបុគ្គលពាលទាំងឡាយមែនពិត ព្រោះថាបុគ្គលណាសេពគប់ប្រែសព្វនឹងបុគ្គលពាល បុគ្គលនោះតែងសោយសោកអស់កាលជាយូរអង្វែង ។ ការនៅរួបរួមជាមួយនឹងបុគ្គលពាលទាំងឡាយជាហេតុឱ្យកើតទុក្ខសព្វកាល ដូចនៅរួមជាមួយនឹងសឹកសត្រូវ ការនៅរួបរួមជាមួយនឹងលោកអ្នកប្រាជ្ញតែងនាំមកនូវសេចក្ដីសុខ ដូចការនៅជួបជុំនៃញាតិទាំងឡាយ ។

ធម្មបទេ សោឡសមោ បិយវគ្គោ

តស្មា ហិ ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច ធោរយ្ហសីលំ ។
វតវន្តមរិយំ តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

សុខវគ្គោ បន្នរសមោ សមត្តោ

តយោបព្វជិតវត្ថុគាថា:

(១) អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ
អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។

បិយវគ្គទី ១៦ ក្នុងព្រះធម្មបទ

ព្រោះហេតុដូច្នោះ បុគ្គលគួរសេពគប់បុគ្គលមានចិត្តខ្ជាប់ខ្ជួនផង មានបញ្ញាផង ជាពហូស្សូតផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្តនឹងធុតង្គវត្តផង ជាព្រះអរិយផង ដែលជាសប្បុរសមានប្រាជ្ញាប្រាកដដូច្នោះ ឲ្យដូចជាព្រះចន្ទ្រកាលសេពគប់ គឺជាកាលត្រេចទៅតាមផ្លូវនក្ខត្តឫក្ស ។

សុខវគ្គ ទី ១៨ ចប់

*គាថាក្នុងរឿងគយោបព្វជិត*

(១) បុគ្គលឯណាប្រកបនូវខ្លួន ក្នុងអំពើដែលគេមិនត្រូវប្រកបផង មិនប្រកបនូវខ្លួនក្នុងអំពើដែលគេត្រូវប្រកបផង បោះបង់នូវប្រយោជន៍ចោលចេញហើយ កាន់យកនូវអារម្មណ៍ជាទីស្រឡាញ់ផង បុគ្គលនោះតែងប្រាថ្នានូវបុគ្គលប្រកបរឿយ ៗ នូវខ្លួនទាំងឡាយ ។

## ធម្មបទេ សោឡសមោ បិយវគ្គោ

មា បិយេហិ សមាគញ្ឆិ    អបិយេហិ កុទាចនំ
បិយានំ អទស្សនំ ទុក្ខំ    អបិយានញ្ច ទស្សនំ ។
តស្មា បិយំ ន កយិរាថ    បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ    យេសំ នត្ថិ បិយាបិយំ ។

អញ្ញតរកុដុម្ពិកវត្ថុគាថា

(២) បិយតោ ជាយតេ[១] សោកោ    បិយតោ ជាយតេ ភយំ
បិយតោ វិប្បមុត្តស្ស    នត្ថិ សោកោ កុតោ ភយំ ។

---

១ ម. ជាយតិ ។

## បិយវគ្គទី ១៦ ក្នុងព្រះធម្មបទ

ក្នុងកាលណា ៗ ក៏កុំគប្បីសេពគប់ដោយពួកសត្វនឹងសង្ខារជាទីស្រឡាញ់ កុំសេពគប់ពួកសត្វនឹងសង្ខារមិនជាទីស្រឡាញ់ឡើយ ព្រោះថាការមិនឃើញនូវសត្វនឹងសង្ខារជាទីស្រឡាញ់ទាំងឡាយផង ការឃើញនូវសត្វនឹងសង្ខារមិនជាទីស្រឡាញ់ផង ជាហេតុនាំឲ្យកើតទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគប្បីធ្វើនូវសត្វនឹងសង្ខារថាជាទីស្រឡាញ់ឡើយ ការព្រាត់ប្រាសចាកសត្វនឹងសង្ខារដែលជាទីស្រឡាញ់ ជារបស់លាមកអាក្រក់ណាស់ សេចក្ដីស្រឡាញ់នឹងមិនស្រឡាញ់ បើមិនមានដល់ជនទាំងឡាយឯណាហើយ កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយក៏មិនមានដល់ជនទាំងនោះឡើយ ។

### គាថាក្នុងរឿងអញ្ញតរកុដុម្ពិក

(២) សោកកើតមកអំពីសេចក្ដីស្រឡាញ់ ភ័យកើតមកអំពីសេចក្ដីស្រឡាញ់ កាលបើបុគ្គលរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សោកនឹងភ័យមានមកពីណាបាន ។

## ធម្មបទេ សោឡសមោ បិយវគ្គោ

វិសាខាឧបាសិកាវត្ថុគាថា

(៣) បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

លិច្ឆវីវត្ថុគាថា

(៤) រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

អនិត្ថិគន្ធកុមារវត្ថុគាថា

(៥) កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

អញ្ញតរព្រាហ្មណវត្ថុគាថា

(៦) តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

## បិយវគ្គទី ១៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងវិសាខាឧបាសិកា*

(៣) សោកកើតមកអំពីសេចក្តីស្រឡាញ់ ភ័យកើតមកអំពីសេចក្តីស្រឡាញ់ កាលបើបុគ្គលរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សោកនឹងភ័យមានមកពីណាបាន ។

*គាថាក្នុងរឿងលិច្ឆវី*

(៤) សោកកើតមកអំពីសេចក្តីជម្រេក ភ័យកើតមកអំពីសេចក្តីជម្រេក កាលបើបុគ្គលរួចស្រឡះចាកសេចក្តីជម្រេកហើយ សោកនឹងភ័យមានមកពីណាបាន ។

*គាថាក្នុងរឿងអនិត្ថិគន្ធកុមារ*

(៥) សោកកើតមកអំពីកាម ភ័យកើតមកអំពីកាម កាលបើបុគ្គលរួចស្រឡះចាកកាមហើយ សោកនឹងភ័យមានមកពីណាបាន ។

*គាថាក្នុងរឿងអញ្ញតរព្រាហ្មណ៍*

(៦) សោកកើតមកអំពីតណ្ហា ភ័យកើតមកអំពីតណ្ហា កាលបើបុគ្គលរួចស្រឡះចាកតណ្ហាហើយ សោកនឹងភ័យមានមកពីណាបាន ។

## ធម្មបទេ សោឡសមោ បិយវគ្គោ

បញ្ចសតទារកវត្ថុ គាថា

(៧) សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវេទិនំ
អត្តនោ កម្មកុព្វានំ តំ ជនោ កុរុតេ បិយំ ។

អនាគាមិត្ថេរវត្ថុ គាថា

(៨) ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដ្ឋោ សិយា
កាមេសុ[១] អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។

នន្ទិយវត្ថុ គាថា

(៩) ចិរប្បវាសិំ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតិមិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ ។

---

១ ម. កាមេសុ ច ។

# បិយវគ្គទី ១៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបញ្ចសតទារក*

(៧) មហាជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីលនិងសមាទស្សនៈ ស្ថិតនៅក្នុងធម៌ ពោលពាក្យទៀងត្រង់ជាប្រក្រតីធ្វើកម្មជារបស់ខ្លួននោះឯងឲ្យជាទីស្រឡាញ់ ។

*គាថាក្នុងរឿងអនាគាមិត្ថេរ*

(៨) បុគ្គលឯណាប្រាថ្នាចំពោះព្រះនិព្វាន ដែលគេមិនគប្បីពោលបាន មានមគ្គចិត្តនឹងផលចិត្តពាល់ត្រូវហើយ ឥតមានចិត្តជាប់ចំពោះក្នុងកាមទាំងឡាយឡើយ បុគ្គលនោះព្រះដ៏មានព្រះភាគឲ្យឈ្មោះថា មានខ្សែនៃមគ្គប្រព្រឹត្តទៅក្នុងខាងលើ ។

*គាថាក្នុងរឿងនន្ទិយ*

(៩) ញាតិទាំងឡាយក្តី មិត្តទាំងឡាយក្តី សំឡាញ់ទាំងឡាយក្តី ឃើញបុរសដែលព្រាត់ប្រាសគ្នាអស់កាលជាយូរ ហើយមានសិរីសួស្តីមកអំពីចម្ងាយ តែងត្រេកអរក្រៃពេកនឹងបុរសដែលទើបមកដល់នោះ យ៉ាងណាមិញ ។

ធម្មបទេ សត្តរសមោ កោធវគ្គោ

តត្ថេវ កតបុញ្ញំបិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ ។

បិយវគ្គោ សោឡសមោ សមត្តោ

រោហិណីខត្តិយកញ្ញាវត្ថុ [illegible]

(១) កោធំ ជហេ វិប្បជហេយ្យ មានំ
សំយោជនំ សព្វមតិក្កមេយ្យ
តំ នាមរូបស្មិមសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ ទុក្ខា ។

## កោធវគ្គទី ១៧ ក្នុងព្រះធម្មបទ

បំណែកឯបុណ្យទាំងឡាយក៏តែងទទួលនូវបុគ្គល ដែលមានបុណ្យធ្វើហើយច្យុតអំពីមនុស្សលោកនេះហើយទៅកាន់លោកខាងមុខ ក៏ដូចញាតិទាំងឡាយកាលនេះត្រេកអរទទួលបុរសជាទីស្រឡាញ់ទើបមកដល់ យ៉ាងដូច្នោះឯង ។

បិយវគ្គទី ១៦ ចប់

*គាថាក្នុងរឿងរោហិណីខត្តិយកញ្ញា*

(១) បុគ្គលត្រូវលះបង់សេចក្ដីក្រោធ ត្រូវលះបង់មានៈ ត្រូវប្រព្រឹត្តកន្លងសំយោជនធម៌ទាំងអស់ចោលចេញ សេចក្ដីទុក្ខទាំងឡាយមិនបានអន្ទោលតាមបុគ្គលនោះ ដែលមិនជាប់នៅក្នុងនាមនឹងរូប មិនមានសេចក្ដីកង្វល់ព្រោះកិលេសនោះបានឡើយ ។

## ធម្មបទេ សត្តរសមោ កោធវគ្គោ

អញ្ញតរភិក្ខុវត្ថុគាថា

(២) យោ វេ ឧប្បតិតំ កោធំ  រថំ ភន្តំ វ វារយេ
តមហំ សារថឹ ព្រូមិ  រស្មិគ្គាហោ ឥតរោ ជនោ ។

ឧត្តរាឧបាសិកាវត្ថុគាថា

(៣) អក្កោធេន ជិនេ កោធំ  អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន  សច្ចេនាលិកវាទិនំ ។

មហាមោគ្គល្លានត្ថេរវត្ថុគាថា

(៤) សច្ចំ ភណេ ន កុជ្ឈេយ្យ  ទជ្ជា អប្បម្បិ យាចិតោ
ឯតេហិ តីហិ ឋានេហិ  គច្ឆេ ទេវាន សន្តិកេ ។

## ក្រោធវគ្គទី ១៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអញ្ញតរភិក្ខុ*

(២) បុគ្គលណាអាចអត់សង្កត់សេចក្ដីក្រោធ ដែលកើតឡើងហើយបាន ដូចនាយសារថីកាលឃាត់នូវរាជរថដែលស្ទុះលឿនទៅ តថាគតពោលថាបុគ្គលនោះឈ្មោះថា ជានាយសារថីពិត ឯជនដទៃជានាយសារថីក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរប៉ុណ្ណោះ ។

*គាថាក្នុងរឿងឧត្តរាឧបាសិកា*

(៣) បុគ្គលគប្បីឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្ដីអំណត់មិនក្រោធ គប្បីឈ្នះបុគ្គលអសប្បុរស ដោយសេចក្ដីសប្បុរស គប្បីឈ្នះបុគ្គលអ្នកកំណាញ់ស្វិត ដោយការឲ្យទាន គប្បីឈ្នះបុគ្គលអ្នកពោលពាក្យខ្មោះខ្មាះ ដោយពោលពាក្យទៀងត្រង់ ។

*គាថាក្នុងរឿងមហាមោគ្គល្លានត្ថេរ*

(៤) បុគ្គលគប្បីពោលពាក្យទៀងត្រង់ ១ មិនគប្បីក្រោធខឹង ១ បើអ្នកមានសីលមកសូមហើយគប្បីឲ្យវត្ថុសូម្បីមានប្រមាណតិចតួច ១ បុគ្គលនឹងគប្បីទៅកាន់ទេវលោកបាន ដោយហេតុទាំង ៣ យ៉ាងនេះឯង ។

## ធម្មបទេ សត្តរសមោ កោធវគ្គោ

ពុទ្ធបិតុព្រាហ្មណវត្ថុគាថា

(៥) អហឹសកា យេ មុនយោ  និច្ចំ កាយេន សំវុតា

តេ យន្តិ អច្ចុតំ ឋានំ  យត្ថ គន្ត្វា ន សោចរេ ។

បុណ្ណទាសីវត្ថុគាថា

(៦) សទា ជាគរមានានំ  អហោរត្តានុសិក្ខិនំ

និព្វានំ អធិមុត្តានំ  អត្ថំ គច្ឆន្តិ អាសវា ។

អតុលឧបាសកវត្ថុគាថា

(៧) បោរាណមេតំ អតុល  នេតំ អជ្ជតនាមិវ

## កោធវគ្គទី ១៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងភិក្ខុទាំងឡាយសួរបញ្ហា*

(៥) អ្នកប្រាជ្ញទាំងឡាយឯណា លោកមិនបៀតបៀនសត្វដទៃ សង្រួមហើយដោយទ្វារទាំង ៣ មានកាយទ្វារជាដើមអស់កាលជានិច្ច ក៏សត្វទាំងឡាយទៅក្នុងទីណាហើយដែលមិនគប្បីសោកស្រណោះបាន ឯអ្នកប្រាជ្ញទាំងឡាយនោះលោកតែងទៅកាន់ទីដ៏ទៀង ពោលគឺព្រះនិព្វាននោះដូច្នោះដែរ ។

*គាថាក្នុងរឿងបុណ្ណទាសី*

(៦) អាសវៈទាំងឡាយរបស់បុគ្គលទាំងឡាយ ដែលភ្ញាក់រឭករឿយ ៗ សព្វកាល ដែលមានកិរិយាសិក្សានូវសិក្ខាទាំង៣អស់យប់នឹងថ្ងៃជាប្រក្រតី ដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន តែងដល់នូវហេតុជាទីតាំងនៅមិនបានឡើយ ។

*គាថាក្នុងរឿងអតុលឧបាសក*

(៧) ម្នាលអតុល ក៏សេចក្ដីនិន្ទា (តិះដៀល) នឹងសេចក្ដីសរសើរនេះ ជាពាក្យមានមកហើយក្នុងកាលមុន ឯពាក្យទាំងពីរនេះមិនមែនដូចជាទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ

ធម្មបទេ សត្តរសមោ កោធវគ្គោ

និន្ទន្តិ តុណ្ហិមាសីនំ    និន្ទន្តិ ពហុភាណិនំ ។
មិតភាណិម្បិ និន្ទន្តិ    នត្ថិ លោកេ អនិន្ទិតោ
ន ចាហុ ន ច ភវិស្សតិ    ន ចេតរហិ វិជ្ជតិ ។
ឯកន្តំ និន្ទិតោ បោសោ    ឯកន្តំ វា បសំសិតោ
យញ្ចេ វិញ្ញូ បសំសន្តិ    អនុវិច្ច សុវេ សុវេ ។
អច្ឆិទ្ទវុត្តឹ មេធាវឹ    បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ    កោ តំ និន្ទិតុមរហតិ ។
ទេវាបិ នំ បសំសន្តិ    ព្រហ្មុនាបិ បសំសិតោ ។

# ក្រោធវគ្គទី ១៧ ក្នុងព្រះធម្មបទ

ជនទាំងឡាយតិះដៀលបុគ្គលអ្នកអង្គុយស្ងៀមមិននិយាយខ្លះ តិះដៀលបុគ្គលអ្នកនិយាយច្រើនខ្លះ ។ តិះដៀលបុគ្គលអ្នកនិយាយតិចខ្លះ បុគ្គលណាមួយក្នុងលោកឈ្មោះថាដែលគេមិនតិះដៀលនោះគ្មានឡើយ ក៏ឯបុរសដែលគេតិះដៀលតែម៉្យាង ឬថាដែលគេសរសើរតែម៉្យាងប៉ុណ្ណោះនោះ ក្នុងកាលដែលកន្លងទៅហើយក៏មិនមាន ក្នុងកាលទៅខាងមុខទៀតក៏មិនមាន ក្នុងកាលឥឡូវនេះក៏មិនមានសោះឡើយ ។ តែបើអ្នកប្រាជ្ញទាំងឡាយដែលពិចារណាឃើញរាល់ៗថ្ងៃ លោកសរសើរនូវបុគ្គលណាថាជាអ្នកមានប្រាជ្ញា ជាអ្នកមានកិរិយាប្រព្រឹត្តមិនធ្លុះធ្លាយជាប្រក្រតី ជាអ្នកមានចិត្តដំកល់ខ្ជាប់ក្នុងបញ្ញានឹងសីលហើយ ។

អ្នកណាគួរនឹងទៅតិះដៀលនូវបុគ្គលនោះ ដូចគ្រឿងប្រដាប់ធ្វើពីមាសជម្ពូនទបាន ទេវតាទាំងឡាយក្តី ក៏តែងសរសើរបុគ្គលនោះ មហាព្រហ្មក្តី ក៏តែងសរសើរបុគ្គលនោះដែរ ។

# ធម្មបទេ សត្តរសមោ កោធវគ្គោ

ឆព្ពគ្គិយវត្ថុគាថា

(៨) កាយប្បកោបំ រក្ខេយ្យ　　កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា　　កាយេន សុចរិតំ ចរេ ។
វចីបកោបំ រក្ខេយ្យ　　វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា　　វាចាយ សុចរិតំ ចរេ ។
មនោបកោបំ រក្ខេយ្យ　　មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា　　មនសា សុចរិតំ ចរេ ។
កាយេន សំវុតា ធីរា　　អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា　　តេ វេ សុបរិសំវុតា ។

កោធវគ្គោ សត្តរសមោ សមត្តោ

## កោធវគ្គទី ១៧ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឆព្វគ្គិយ*

(៨) បុគ្គលត្រូវរក្សាសេចក្ដីកម្រើកនៃកាយ ត្រូវសង្រួមដោយកាយ ត្រូវលះបង់កាយទុច្ចរិតចេញហើយ ត្រូវប្រព្រឹត្តសុចរិតដោយកាយឡើង ។ ត្រូវរក្សាសេចក្ដីកម្រើកដោយវាចា ត្រូវសង្រួមដោយវាចា ត្រូវលះបង់វចីទុច្ចរិតចេញហើយ ត្រូវប្រព្រឹត្តសុចរិតដោយវាចាឡើង ។ ត្រូវរក្សាសេចក្ដីកម្រើកនៃចិត្ត ត្រូវសង្រួមដោយចិត្ត ត្រូវលះបង់មនោទុច្ចរិតចេញ ត្រូវប្រព្រឹត្តសុចរិតដោយចិត្តឡើង ។ អ្នកប្រាជ្ញទាំងឡាយ(ឯណា)បានសង្រួមកាយសង្រួមវាចាសង្រួមចិត្តហើយ អ្នកប្រាជ្ញទាំងឡាយនោះឯងឈ្មោះថាសង្រួមហើយដោយប្រពៃពិត ។

កោធវគ្គទី ១៧ ចប់

# ធម្មបទេ អដ្ឋទសមោ មលវគ្គោ

## គោឃាតកវត្ថុគាថា

(១) បណ្ឌុបលាសោវទានិសិ  យមបុរិសាបិច តេ[១] ឧបដ្ឋិតា

ឧយ្យោគមុខេ បតិដ្ឋសិ  បាថេយ្យំបិ ច តេ ន វិជ្ជតិ ។

សោ ករោហិ ទីបមត្តនោ  ខិប្បំ វាយាម បណ្ឌិតោ ភវ

និទ្ធន្តមលោ អនង្គណោ  ទិព្វំ អរិយភូមិមេហិសិ ។

ឧបនីតវយោវទានិសិ  សម្បយាតោសិ យមស្ស សន្តិកំ

វាសោបិ ច តេ នត្ថិ អន្តរា  បាថេយ្យំបិ ច តេ ន វិជ្ជតិ ។

---

១ ភន្តីតិបិ បាឋោ ។

# មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងគោឃាតក*

(១) ឥឡូវខ្លួនអ្នកដូចស្លឹកឈើទុំហើយ មួយទៀតឯយមបុរសទាំងឡាយ ក៏មានប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅហើយក្នុងមាត់នៃសេចក្ដីស្លាប់ ស្បៀងអាហារគឺកុសលសោត ក៏មិនមានដល់អ្នកឡើយ ។ អ្នកឯងចូរធ្វើទីពឹងនៃខ្លួន ចូរព្យាយាមឲ្យឆាប់ ចូរធ្វើជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ អ្នកនឹងកំចាត់បង់មន្ទិលបានមិនមានទីទួលគឺកិលេសហើយគង់នឹងដល់នូវទីជាអរិយបុគ្គលដ៏ជាទិព្វមិនខានឡើយ ។ ឥឡូវខ្លួនអ្នកមានវ័យកន្លងហើយ ខ្លួនអ្នករៀបដំណើរដើម្បីទៅកាន់សំណាក់នៃយមរាជ[១] ការរំកិលនៅក្នុងបន្លោះរបស់អ្នកគ្មានឡើយ ស្បៀងគឺកុសលរបស់អ្នកក៏គ្មានដែរ ។

---

១ យមរាជនេះគឺសេចក្ដីស្លាប់មិនមែនព្រះយមរាជដែលត្រួតត្រាសត្វនរកទេ ។

# ធម្មបទេ អដ្ឋារសមោ មលវគ្គោ

គោឃាតកបុត្តវត្ថុគាថា

សោ ករោហិ ទីបមត្តនោ ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ ន បុន ជាតិ ជរំ ឧបេហិសិ ។

អញ្ញតរព្រាហ្មណវត្ថុគាថា

(២) អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

តិស្សត្ថេរវត្ថុគាថា

(៣) អយសាវ មលំ សមុដ្ឋាយ(១) តទុដ្ឋាយ តមេវ(២) ខាទតិ
ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

---

១ សមុដ្ឋិតន្តិបិ បាឋោ ។ ២ ម. តំយេវ ។

# មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿង គោឃាតកបុត្ត*

អ្នកឯងត្រូវធ្វើទីពឹងដល់ខ្លួន ចូរព្យាយាមឲ្យឆាប់ ចូរធ្វើជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ អ្នកនឹងកំចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស ទើបនឹងមិនមកកាន់ជាតិនឹងជរាទៀតឡើយ ។

*គាថាក្នុងរឿងអញ្ញតរព្រាហ្មណ៍*

(២) អ្នកប្រាជ្ញធ្វើកុសលកំចាត់បង់នូវមន្ទិលរបស់ខ្លួន បន្តិចម្តងៗ ក្នុងមួយខណៈៗ ដោយលំដាប់ ដូចជាងមាស ដែលកំចាត់បង់នូវមន្ទិលរបស់ប្រាក់មាស ។

*គាថាក្នុងរឿងតិស្សត្ថេរ*

(៣) ច្រែះកើតឡើងអំពីដែក លុះកើតឡើងអំពីដែកនោះហើយ ក៏ត្រឡប់ស៊ីដែកនោះវិញ យ៉ាងណា ឯកម្មទាំងឡាយជារបស់នៃខ្លួន ក៏តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងពិចារណានូវបច្ច័យ ៤ ហើយបរិភោគ ឲ្យទៅកាន់ទុគ្គតិយ៉ាងដូច្នោះឯង ។

## ធម្មបទេ អដ្ឋារសមោ មលវគ្គោ

លោឡុទាយីវត្ថុគាថា

(៤) អសជ្ឈាយមលា មន្តា  អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

អញ្ញតរកុលបុត្តវត្ថុគាថា

(៥) មលិត្ថិយា ទុច្ចរិតំ  មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា  អស្មិំ លោកេ បរម្ហិ ច
តតោ មលា មលតរំ  អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន  និម្មលា ហោថ ភិក្ខវោ ។

## មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងលោឡុទាយី*

(៤) មន្តទាំងឡាយមានមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយមានការមិនផ្ទួសផ្ទុលបោសច្រាសជាមន្ទិល សេចក្ដីខ្ជិលជាមន្ទិលដល់ពណ៌សម្បុរ សេចក្ដីប្រមាទជាមន្ទិលដល់បុគ្គលជាអ្នករក្សា ។

*គាថាក្នុងរឿងអញ្ញតរកុលបុត្ត*

(៥) អំពើទុច្ចរិតគឺការប្រព្រឹត្តកន្លងជាមន្ទិលរបស់ស្រី សេចក្ដីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ឯធម៌ដ៏លាមកទាំងឡាយជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ ឯធម្មជាតិជាមន្ទិលដោយវិសេសជាងមន្ទិលទាំងអស់នោះ គឺអវិជ្ជាជាមន្ទិលដ៏ក្រៃលែង, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះបង់មន្ទិលនេះចោលចេញហើយ ចូរជាអ្នកកុំមានមន្ទិលឡើយ ។

# ធម្មបទេ អដ្ឋារសមោ មលវគ្គោ

### ចូឡសារីភិក្ខុវត្ថុគាថា

(៦) សុជីវំ អហិរិកេន    កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន    សង្កិលិដ្ឋេន ជីវិតំ ។
ហិរិមតា ច ទុជ្ជីវំ    និច្ចំ សុចិគវេសិនា
អលីនេនាប្បគព្ភេន    សុទ្ធាជីវេន បស្សតា ។

### បញ្ចឧបាសកវត្ថុគាថា

(៧) យោ បាណមតិបាតេតិ[១]    មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ    បរទារញ្ច គច្ឆតិ ។

១ បាណមតិមាបេតីតិបិ បាឋោ ។

## មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចូឡសារី*

(៦) ការចិញ្ចឹមជីវិត របស់បុគ្គលអ្នកមិនមានអៀនខ្មាស អ្នកក្លៀវក្លាដូចសត្វក្អែក អ្នកមានកិរិយាកំចាត់បង់នូវគុណនៃបុគ្គលដទៃជាប្រក្រតី អ្នកប្រព្រឹត្តយកមុខ អ្នកឃ្នើសឃ្នង អ្នកមានធម៌ជាគ្រឿងសៅហ្មងហើយ តែងរស់នៅដោយងាយ ។ ឯការចិញ្ចឹមជីវិត របស់បុគ្គលអ្នកមានសេចក្ដីអៀនខ្មាស អ្នកមានកិរិយាស្វែងរកអំពើដ៏ស្អាតជានិច្ចជាប្រក្រតី អ្នកមិនឡេះឡោះ អ្នកមិនឃ្នើសឃ្នង មានព្យាយាមជាគ្រឿងរស់នៅ ដោយកម្មដ៏ម៉ត់ចត់ឃើញថាជាធម៌មានខ្លឹមហើយ តែងរស់នៅដោយកម្រ ។

*គាថាក្នុងរឿងបញ្ចឧបាសក*

(៧) ជនឯណាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វផង ពោលពាក្យកុហកផង កាន់យកនូវវត្ថុដែលគេមិនបានឲ្យហើយក្នុងលោកផង សេពនូវប្រពន្ធរបស់បុគ្គលដទៃផង

## ធម្មបទេ អដ្ឋារសមោ មលវគ្គោ

សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា
មា តំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។

### តិស្សទហរវត្ថុគាថា

(៨) ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ ។
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។

## មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

មួយទៀតជនឯណាផឹកទឹកស្រវឹងគឺសុរានិងមេរ័យផង ជននោះឯងឈ្មោះថាគាស់រម្លើងឫសគល់របស់ខ្លួនក្នុងលោកនេះដោយពិត ។

ម្នាលបុរសដ៏បំរើន អ្នកឯងចូរដឹងយ៉ាងនេះចុះថា ធម៌ដ៏លាមកទាំងឡាយដែលគេមិនសង្រួមហើយគឺលោភ ១ អធម្មគឺទោស ១ ចូរកុំបៀតបៀនអ្នកដើម្បីសេចក្ដីទុក្ខអស់កាលជាយូរឡើយ ។

*គាថាក្នុងរឿងតិស្សទហរ*

(៨) មហាជនគេឲ្យទានតាមសមគួរដល់សទ្ធា តាមសមគួរដល់សេចក្ដីជ្រះថ្លារបស់គេ បើបុគ្គលឯណាជាអ្នកអៀន[១] ខ្មាសក្នុងទឹកនឹងភោជនរបស់ជនទាំងឡាយដទៃនោះហើយ បុគ្គលនោះឯងតែងនឹងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃឬក្នុងវេលាយប់ឡើយ ។

---

១ ឬត្មះតិះដៀលឲ្យគេអៀនអន់ ។

## ធម្មបទេ អដ្ឋារសមោ មលវគ្គោ

យស្សេតំ សមុច្ឆិន្នំ   មូលឃច្ចំ សមូហតំ
ស វេ ទិវា វា រត្តឹ វា   សមាធឹ អធិគច្ឆតិ ។

### បញ្ចឧបាសកវត្ថុគាថា

(៩) នត្ថិ រាគសមោ អគ្គិ   នត្ថិ ទោសសមោ គហោ
នត្ថិ មោហសមំ ជាលំ   នត្ថិ តណ្ហាសមា នទី ។

### មេណ្ឌកសេដ្ឋីវត្ថុគាថា

(១០) សុទស្សំ វជ្ជមញ្ញេសំ   អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ   ឱបុនាតិ យថាភុសំ
អត្តនោ បន ឆាទេតិ   កលឹវ កិតវា សឋោ ។

## មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

លុះតែបុគ្គលឯណាផ្តាច់បង់នូវសេចក្តីអៀនខ្មាសនោះចោលចេញ ដកឡើងឲ្យទៅជារបស់មានឫសគល់គឺខ្លួនរមើងឡើងបានហើយ ទើបបុគ្គលនោះឯងតែងនឹងបានសមាធិចិត្តក្នុងវេលាថ្ងៃឬក្នុងវេលាយប់នោះបាន ។

*គាថាក្នុងរឿងបញ្ចឧបាសក*

(៩) រកភ្លើងអ្វី (ក្តៅ) ស្មើដោយរាគៈគ្មាន រកការចាប់យកអ្វីស្មើដោយទោសគ្មាន រកបណ្តាញអ្វីស្មើដោយមោហគ្មាន រកស្ទឹងអ្វីស្មើដោយតណ្ហាគ្មាន ។

*គាថាក្នុងរឿងមេណ្ឌកសេដ្ឋី*

(១០) ទោសរបស់ជនទាំងឡាយដទៃ បុគ្គលតែងឃើញដោយងាយបាន ឯទោសរបស់ខ្លួនវិញ បុគ្គលតែងឃើញបានដោយកម្រ ព្រោះថាបុគ្គលនោះតែងរោយរាយទោសទាំងឡាយរបស់ជនទាំងឡាយដទៃ ដូចបុគ្គលរោយរាយផេះហើយ បិទបាំងទោសរបស់ខ្លួនទុក ដូចព្រានសត្វស្លាបបិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំងមានមែកឈើជាដើម ។

# ធម្មបទេ អដ្ឋារសមោ មលវគ្គោ

ឧជ្ឈានសញ្ញិត្ថេរវត្ថុគាថា

(១១) បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ
អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។

សុភទ្ទបរិព្វាជកវត្ថុគាថា

(១២) អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។
អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធា ន មិញ្ជិតំ ។

មលវគ្គោ អដ្ឋារសមោ សមត្តោ

## មលវគ្គទី ១៨ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឧជ្ឈានសញ្ញិត្ថេរ*

(១១) បុគ្គលឯណាមានកិរិយារិះគន់រឿយ ៗ នូវទោសរបស់បុគ្គលដទៃជាប្រក្រតី មានកិរិយាសំគាល់ក្នុងការពោលទោសជានិច្ចជាប្រក្រតីហើយ អាសវទាំងឡាយតែងចំរើនដល់បុគ្គលនោះ បុគ្គលនោះឈ្មោះថាស្ថិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់ទៅនៃអាសវ ។

*គាថាក្នុងរឿងសុភទ្ទបរិព្វាជក*

(១២) ស្នាមជើងនៅលើអាកាសគ្មានទេ សមណខាងក្រៅក៏គ្មានដែរ ពពួកសត្វត្រេកអរចំពោះតែក្នុងកិលេសជាគ្រឿងធ្វើឲ្យយឺតយូរ ឯព្រះតថាគតមិនមានកិលេសធ្វើឲ្យយឺតយូរឡើយ ។

ស្នាមជើងនៅលើអាកាសគ្មានទេ សមណខាងក្រៅក៏គ្មានដែរ សង្ខារទាំងឡាយឈ្មោះថាជារបស់ទៀងទាត់គ្មានទេ ឯកិលេសជាគ្រឿងញាប់ញ័រ មិនមានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយឡើយ ។

មលវគ្គទី ១៨ ចប់

# ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

### វិនិច្ឆយមហាមត្តវត្ថុគាថា

(១) ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ
អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

### ឆព្វគ្គិយវត្ថុគាថា

(២) ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ
ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។

## ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងវិនិច្ឆយមហាមត្ត*

(១) បុគ្គលឯណាគប្បីនាំទៅគឺថាគប្បីកាត់សេចក្ដីដោយអាការដ៏រហ័សរួសរាន់ដោយហេតុឯណាមួយហើយ បុគ្គលនោះឈ្មោះថាជាអ្នកស្ថិតនៅក្នុងធម៌ដោយហេតុនោះក៏មិនបាន ។

លុះតែបណ្ឌិតឯណាវិនិច្ឆ័យជំរះនូវហេតុទាំងឡាយ ២ គឺហេតុដ៏ពិត ១ ហេតុមិនពិត ១ នាំទៅនូវជនទាំងឡាយដទៃដោយអាការមិនរហ័សរួសរាន់ត្រឹមត្រូវតាមធម៌ហើយ គប្បីគេគពោលហៅបុគ្គលនោះថា ជាអ្នកប្រាជ្ញរក្សានូវធម៌គប្បីគេគឈ្មោះថាជាអ្នកស្ថិតនៅក្នុងធម៌ដោយពិត ។

*គាថាក្នុងរឿងឆព្វគ្គិយ*

(២) បុគ្គលណាពោលពាក្យច្រើនដោយហេតុត្រឹមណាហើយ បុគ្គលនោះឲ្យឈ្មោះថាបណ្ឌិតដោយហេតុត្រឹមណោះក៏មិនមែន លុះតែបុគ្គលណាមានធម៌ក្សេមមិនមានពៀរមិនមានធម៌ដែលគេគប្បីខ្លាច បុគ្គលនោះ ទើបគប្បីគេគឲ្យឈ្មោះថាបណ្ឌិតបាន ។

# ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

៣ ឯកុទានត្ថេរវត្ថុ គាថា

(៣) ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ
យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ
ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។

៤ លកុណ្ឌកភទ្ទិយត្ថេរវត្ថុ គាថា

(៤) ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ
បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។

## ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឯកុទានត្ថេរ*

(៣) បុគ្គលណាពោលពាក្យច្រើនដោយហេតុត្រឹមណា ហើយ បុគ្គលនោះឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ដោយហេតុត្រឹមណោះក៏មិនមែន លុះតែបុគ្គលណាស្ដាប់នូវបទសូម្បីមានប្រមាណតិចហើយឃើញធម៌នាម[១]កាយ បុគ្គលនោះទើបថាជាអ្នកទ្រទ្រង់ធម៌ ពុំនោះសោតបុគ្គលណាមិនប្រមាទនូវធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់នូវធម៌ដែរ ។

*គាថាក្នុងរឿងលកុណ្ឌកភទ្ទិយត្ថេរ*

(៤) បុគ្គលណាមានសក់ស្កូវលើក្បាលដោយហេតុឯណា ហើយ បុគ្គលនោះឲ្យឈ្មោះថាព្រះថេរដោយហេតុនោះក៏ទេ ឯវ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ បុគ្គលនោះតថាគតឲ្យឈ្មោះថាជាបុគ្គលចាស់ទទេឥតអំពើ ។

---

១ នាមគឺ វេទនា សញ្ញា សង្ខារខន្ធ កាយគឺ រូបក្ខន្ធ ។

## ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

យម្ហិ សច្ចញ្ច ធម្មោ ច    អហឹសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ    សោ ថេរោតិ បវុច្ចតិ ។

សម្ពហុលភិក្ខុវត្ថុគាថា

(៥) ន វាក្ករណមត្តេន    វណ្ណបោក្ខរតាយ វា
សាធុរូបោ នរោ ហោតិ    ឥស្សុកី មច្ឆរី សឋោ ។
យស្ស ចេតំ សមុច្ឆិន្នំ    មូលឃច្ចំ សមូហតំ
ស វន្តទោសោ មេធាវី    សាធុរូបោតិ វុច្ចតិ ។

## ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

លុះតែមានសច្ចៈផង លោកុត្តរធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានផង មាននៅក្នុងបុគ្គលណាហើយ តថាគតឲ្យឈ្មោះបុគ្គលនោះថាជាអ្នក ប្រាជ្ញមានមន្ទិលខ្ជាក់ចោលដោយពិត ឬនឹងឲ្យឈ្មោះថាថេរក៏បាន ។

*គាថាក្នុងរឿងសម្ពហុលភិក្ខុ*

(៥) បុគ្គលណាជាអ្នកមានឫស្យា អ្នកមានសេចក្តីកំណាញ់ជាអ្នកអួតអាងហើយ ជននោះឲ្យឈ្មោះថាជាអ្នកមានសភាពប្រពៃ ដោយហេតុត្រឹមតែធ្វើពាក្យគឺពោលពាក្យល្អ ឬថាដោយភាវៈនៃខ្លួនជាអ្នកមានពណ៌ ដល់ទីគាប់ចិត្តក៏មិនបាន ។

លុះតែបុគ្គលណាកាត់ចោលទោសមានឫស្យាជាដើមនេះ រម្លើងឲ្យអស់ឫសគល់ចេញ ទើបតថាគតឲ្យឈ្មោះបុគ្គលនោះថាជាអ្នកប្រាជ្ញមានទោសខ្ជាក់ចោល ឬនឹងឲ្យឈ្មោះថាជាអ្នកមានសភាពប្រពៃវិញក៏បាន ។

# ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

ហត្ថកភិក្ខុគាថា

(៦) ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។
យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។

អញ្ញតរព្រាហ្មណភិក្ខុគាថា

(៧) ន តេន ភិក្ខុ សោ ហោតិ យាវតា ភិក្ខតេ បរេ
វិស្សំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។

## ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងហត្ថក*

(៦) បុគ្គលឈ្មោះថាជាសមណៈ ដោយហេតុគ្រាន់តែមានក្បាលកោរត្រងោលប៉ុណ្ណោះក៏មិនបាន ព្រោះបុគ្គលនោះគ្មានសីលវត្តនិងធុតង្គវត្ត មានតែពោលពាក្យឡេះឡោះប្រកបដោយសេចក្ដីប្រាថ្នានិងលោភ នឹងឈ្មោះថាជាសមណៈដូចម្ដេចបាន។

លុះតែបុគ្គលណារម្ងាប់បង់បាបទាំងឡាយតូចនឹងធំដោយប្រការទាំងពួងបាន បុគ្គលនោះទើបតថាគតឲ្យឈ្មោះថាជាសមណៈបាន ព្រោះភាវៈនៃបាបទាំងឡាយគឺបុគ្គលនោះលះបង់អស់ហើយ ។

*គាថាក្នុងរឿងអញ្ញតរព្រាហ្មណ៍*

(៧) បុគ្គលណាសូមជនទាំងឡាយដទៃដោយហេតុត្រឹមណាហើយ បុគ្គលនោះឲ្យឈ្មោះថាជាភិក្ខុដោយហេតុគ្រាន់តែសូមប៉ុណ្ណោះក៏មិនបាន ឬថាបុគ្គលណាកាន់យកព្រមនូវធម៌មានពិសដោយហេតុត្រឹមណាហើយ បុគ្គលនោះឲ្យឈ្មោះថាភិក្ខុដោយហេតុត្រឹមប៉ុណ្ណោះក៏មិនបានដែរ ។

ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

យោធ បុញ្ញញ្ច បាបញ្ច វាហេត្វា ព្រហ្មចរិយវា

សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតិ ។

តិត្ថិយវត្ថុគាថា

(៨) ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ

យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ ។

បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ

យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

## ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

លុះតែបុគ្គលណាក្នុងសាសនានេះបន្សាត់ចោលបង់ នូវបុណ្យផង នូវបាបផង ហើយជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ហើយដឹងនូវលោកដោយញាណ បុគ្គលនោះឯងទើបតថាគតឲ្យឈ្មោះថាជាភិក្ខុបាន ។

*គាថាក្នុងរឿងទិត្ថិយ*

(៨) បុគ្គលណាមានតែរូបទទេមិនដឹងអ្វីសោះ បុគ្គលនោះឲ្យឈ្មោះថាមុនី (អ្នកប្រាជ្ញ) ដោយសភាពជាអ្នកស្ងៀម (ប៉ុណ្ណោះ) ក៏មិនបាន លុះតែបុគ្គលណាជាបណ្ឌិតកាន់យកនូវធម៌ដ៏ប្រសើរហើយវៀរបង់នូវបាបទាំងឡាយ ដូចបុគ្គលថ្លឹងនូវជញ្ជីង ។

បុគ្គលនោះឲ្យឈ្មោះថាមុនីដោយហេតុឯណា បុគ្គលនោះឲ្យឈ្មោះថាមុនីដោយហេតុដូចពោលមកនោះ មួយទៀតបុគ្គលណាដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះទើបតថាគតឲ្យឈ្មោះថាមុនីដោយហេតុនោះ ។

# ធម្មបទេ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

ពាឡិសិកវត្ថុគាថា

(៩) ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ

អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។

សម្ពហុលភិក្ខុវត្ថុគាថា

(១០) ន សីលព្វតមត្តេន ពាហុសច្ចេន វា បន

អថ វា សមាធិលាភេន វិវិត្តសយនេន វា ។

ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ

ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

ធម្មដ្ឋវគ្គោ ឯកូនវីសតិមោ សមត្តោ

# ធម្មដ្ឋវគ្គទី ១៩ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពាលិសិក*

(៩) បុគ្គលណាបៀតបៀនសត្វទាំងឡាយ ដោយហេតុឯណាហើយ បុគ្គលនោះឲ្យឈ្មោះថាអរិយដោយហេតុនោះក៏មិនបាន បំណែកឯបុគ្គលដែលតថាគតឲ្យឈ្មោះថាអរិយ ព្រោះមិនបៀតបៀនសត្វទាំងអស់ ។

*គាថាក្នុងរឿងសម្ពហុលភិក្ខុ*

(១០) ម្នាលភិក្ខុ ឈ្មោះថាភិក្ខុបើមិនទាន់ដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវនៅឡើយទេ មិនត្រូវដល់នូវសេចក្ដីទុកចិត្តដោយគុណគ្រាន់តែសីលនិងវត្ត ឬថាដោយភាវនៃខ្លួនជាអ្នកមានពហុស្សូតស្ដាប់ច្រើន ម្យ៉ាងទៀតដោយបានសមាធិ ឬថាដោយការដេកនៅក្នុងទីស្ងាត់ ៗ ឬថាដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញបាននូវសេចក្ដីសុខដ៏កើតអំពីនេក្ខម្មដែលបុថុជ្ជនមិនសេពហើយ ។

ធម្មដ្ឋវគ្គទី ១៩ ចប់

# ធម្មបទេ វីសតិមោ មគ្គវគ្គោ

បញ្ចសតភិក្ខុវត្ថុ គាថា

(១) មគ្គានដ្ឋង្គិកោ សេដ្ឋោ　　សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ　　ទិបទានញ្ច ចក្ខុមា ។
ឯសេវ មគ្គោ នត្ថញ្ញោ　　ទស្សនស្ស វិសុទ្ធិយា
ឯតញ្ហិ តុម្ហេ បដិបជ្ជថ　　មារសេនប្បមោហនំ ។
ឯតំ ហិ តុម្ហេ បដិបន្នា　　ទុក្ខស្សន្តំ ករិស្សថ
អក្ខាតោ វោ មយា មគ្គោ　　អញ្ញាយ សល្លសត្ថនំ ។
តុម្ហេហិ កិច្ចំ អាតប្បំ　　អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ　　ឈាយិនោ មារពន្ធនា ។

## មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបញ្ចសតភិក្ខុ*

(១) ផ្លូវប្រកបដោយអង្គ ៨ ប្រសើរបំផុតជាងផ្លូវទាំងឡាយ បទទាំងឡាយ ៤ ប្រសើរបំផុតជាងសច្ចទាំងឡាយ ធម៌មានរាគទៅប្រាសហើយប្រសើរបំផុតជាងធម៌ទាំងឡាយ ឯតថាគតមានចក្ខុ (ភ្នែក) ប្រសើរបំផុតជាងសត្វជើងពីរទាំងឡាយ ។ ផ្លូវនេះឯងជាផ្លូវប្រព្រឹត្តទៅដើម្បីញុំាងកិរិយាឃើញឲ្យម៉ត់ចត់ ឯផ្លូវដទៃទៀតគ្មានទេ ព្រោះហេតុនោះអ្នកទាំងឡាយចូរដើរទៅតាមផ្លូវនេះចុះ ជាផ្លូវញុំាងមារនឹងសេនារបស់មារឲ្យវង្វេង ។ ព្រោះថាបើអ្នកទាំងឡាយដើរទៅតាមផ្លូវនេះហើយ នឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខមិនខាន ផ្លូវនេះហើយដែលតថាគតដឹងថាជាផ្លូវកំចាត់បង់នូវកូនសរ ទើបប្រាប់ហើយដល់អ្នកទាំងឡាយ ។ ព្យាយាមជាគ្រឿងញុំាងកិលេសឲ្យក្តៅទូទៅ គឺអ្នកទាំងឡាយគប្បីធ្វើ ឯតថាគតជាអ្នកប្រាប់តែប៉ុណ្ណោះ ជនទាំងឡាយបានឈានដើរទៅតាមផ្លូវនេះហើយ មុខជានឹងរួចស្រឡះចាកចំណងរបស់មារមិនខាន ។

# ធម្មបទេ វីសតិមោ មគ្គវគ្គោ

[illegible]

(២) សព្វេ សង្ខារា អនិច្ចាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា
សព្វេ សង្ខារា ទុក្ខាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា
សព្វេ ធម្មា អនត្តាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា ។

# មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

*គាថាកូនរៀនអបរបញ្ញសក*

(២) បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងទាំងឡាយមិនទៀងជួប្រេះក្នុងកាលណាហើយ គង់នឿយណាយបំពោះសេចក្ដីទុក្ខក្នុងកាលនោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីម៉ត់បត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងទាំងឡាយ នាំមកនូវសេចក្ដីទុក្ខជួប្រេះក្នុងកាលណាហើយ គង់នឿយណាយបំពោះសេចក្ដីទុក្ខក្នុងកាលនោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីម៉ត់បត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារធម៌ទាំងពួងទាំងឡាយ មិនមែនជារបស់ខ្លួនជួប្រេះ ក្នុងកាលណាហើយ គង់នឿយណាយបំពោះសេចក្ដីទុក្ខក្នុងកាលនោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីម៉ត់បត់ ។

# រឿងអាកុហកស៊ី

# រឿងអាកុហកស៊ី

មានក្មេងម្នាក់នៅនឹងម្ដាយ ចិញ្ចឹមជ្រូកកំរៀរ ១ ដល់ជ្រូកនោះធំឡើងក្មេងនោះចង់ស៊ីសាច់ជ្រូក ហើយនិយាយនឹងម្ដាយថា ម៉ែខ្ញុំចង់ស៊ីសាច់ជ្រូក ម៉ែឯងឲ្យខ្ញុំកាប់ជ្រូកយើងនេះស៊ីផឹកស្រាទៅ ម្ដាយឃាត់ថា កុំ ឯងស៊ីអីក៏ច្រើនម្ល៉េះ ទុកវានឹងលក់ឲ្យបានយកកាសប្រាក់ចាយ ឯកូននោះឮម្ដាយឃាត់ដូច្នោះហើយ ក៏នឹកតែក្នុងចិត្តចង់ស៊ីសាច់ជ្រូកពុំមានភ្លេចតែសព្វថ្ងៃលុះដល់មួយថ្ងៃកូននោះភ្ញាក់ឡើងពីដេកហើយនិយាយប្រាប់ថាឆ្និតទេពតាប្រាប់ខ្ញុំថាមានមាសប្រាក់ច្រើនណាស់ ម៉ែឯងជូនខ្ញុំទៅយក ម្ដាយនោះឮកូននិយាយប្រាប់ដូច្នោះហើយ សួរថាមាសប្រាក់នៅឯណា កូននោះឆ្លើយថា ម៉ែឯងទៅនឹងខ្ញុំចុះហើយបើខ្ញុំបង្គាប់ដូចម្ដេចម៉ែឯងធ្វើតាមខ្ញុំ ឯកូននោះយកកញ្ជើហើយនាំម្ដាយដើរទៅក្នុងព្រៃឆ្ងាយអំពីស្រុក ហើយកូននោះយកកញ្ជើស្ទុះទៅគ្របលើដីប្រឹងសង្កត់ ហើយស្រែកទៅម្ដាយថា ម៉ែជួយសង្កត់មាសប្រាក់នៅក្នុងដីនេះច្រើនណាស់ ម៉ែ

សង្កត់ឲ្យជាប់កុំលែង ខ្ញុំនឹងទៅយកបបជីកមកជីកមាស ម៉ែឯង នៅសង្កត់ឲ្យជាប់កុំលែង បើម៉ែឯងលែងមាសប្រាក់នឹងបាត់អស់ទៅ ។ ឯម្ដាយឮកូនថាដូច្នោះក៏ខំសង្កត់ល្អីនោះចាំកូនៗ នោះក៏រត់ត្រឡប់ទៅផ្ទះវិញ លុះដល់ផ្ទះហើយចាប់ជ្រូកនោះយកមកកាប់ ហើយបបួលអស់បងប្អូនផ្ទះជិតខាងមកផឹកស្រាលេងសប្បាយ ឯម្ដាយនៅចាំកូនឯក្នុងព្រៃទន្ទឹងពុំឃើញមក ឃ្លានបាយអស់កំឡាំងរោយដៃរោយជើងរបូតចេញពីលើល្អី ហើយមើលក្នុងល្អីពុំមានឃើញអ្វីសោះ ឯម្ដាយនោះក៏ដឹងថាកូនបញ្ឆោត ហើយក៏ត្រឡប់ទៅផ្ទះវិញ លុះទៅដល់ផ្ទះហើយឃើញកូនកំពុងតែស៊ីសាច់ជ្រូកផឹកស្រាលេងសប្បាយ ដូច្នោះខឹងនឹងកូនណាស់ ហើយក៏និយាយនឹងប្អូនថា ដ្បិតកូននេះខូចណាស់ ទុកចិញ្ចឹមមិនបានទេ បើដូច្នេះឯងច្រកការុងយកទៅចោលក្នុងទឹកសម្លាប់ទៅ ឯប្អូននោះឮដូច្នោះហើយសួរទៅបងថា ដំណើរដូចម្ដេចបានជាឲ្យយកកូនទៅច្រកការុងចោលទៅក្នុងទឹកសម្លាប់ដូច្នោះ ឯបងនោះនិយាយប្រាប់ទៅប្អូនតាមដំណើរសព្វគ្រប់ថា វាចេះបញ្ឆោតឲ្យអញទៅក្នុងព្រៃ

ទៅយកមាសប្រាក់ ហើយវាឲ្យអញនៅចាំក្នុងព្រៃ លុះត្រាតែដល់ថ្ងៃឃ្លានបាយស្ទើរតែនឹងដាច់ពោះ ឯវាមកកាប់ជ្រូកស៊ីផឹកស្រាលេងសប្បាយ ជ្រូកអញតែមួយទុកលក់ឲ្យបានយកប្រាក់កាសចាយ ឯប្អូននោះក៏ទៅចាប់អាកុហកស៊ីប្រកក្នុងការុងធំចងមាត់ការុងជាប់ល្អ លើកលីយកទៅនឹងបោះលក្នុងទឹកទន្លេលុះទៅដល់មាត់ទន្លេហើយ អាកុហកស៊ីនិយាយនឹងមាវាថាលោកមាអាណិតខ្ញុំៗនឹងស្លាប់ហើយ បើដូច្នេះលោកមាអាណិតទៅយកក្បួនកុហកឲ្យខ្ញុំបន្តិច ដ្បិតខ្ញុំស្លាប់ទៅនៅស្ថានខ្មោច បើគ្មានក្បួនកុហកនឹងកុហកខ្មោចស៊ី នោះនឹងដាច់ពោះស្លាប់ ឯមានោះឮក្មួយអង្វរដូច្នោះហើយក៏សួរទៅវិញ អាពុកមាក៏សួរទៅក្មួយថា ក្បួនកុហកឯងដាក់នៅឯណា នោះក្មួយប្រាប់ទៅថា ខ្ញុំដាក់នៅលើធ្នឹម ឯមានោះដាក់អាកុហកស៊ី នៅមាត់កំពង់ទឹកហើយក៏ត្រឡប់ទៅយកក្បួនឲ្យអាកុហកស៊ីវិញ ។ កាលណោះមានមនុស្សកើតឃ្លង់មួយនាក់ដើរមកជិតអាកុហកស៊ី ឯអាកុហកស៊ីមើលទៅឃើញមនុស្សឃ្លង់ដើរមកជិតដូច្នោះហើយ ធ្វើជានិយាយថា អញមកតមឃ្លង់ក្នុងការុងនេះយូរ

ថ្ងៃហើយ  មិនដឹងជា ៗ ហើយឬនៅ  ប៉ុន្តែស្តាប់មើលទៅ ឃើញហាក់ដូចសះជាអស់ហើយ  មនុស្សឃ្លង់ឮអាកុហកសុី ថាតមឃ្លង់ក្នុងការុងដូច្នោះ  ពីព្រោះខ្លួនកើតឃ្លង់  ហើយ សួរថាតមឃ្លង់ក្នុងការុងនោះនឹងជាឬ ៗ អាកុហកសុីប្រាប់ថា ដ្បិតខ្ញុំកើតឃ្លង់  គេយកមកឲ្យតមក្នុងការុងជាយូរថ្ងៃហើយមិន ដឹងជាហើយឬនៅ  បើដូច្នេះអាណិតស្រាយឲ្យខ្ញុំបន្តិច  ឯ មនុស្សឃ្លង់ក៏ស្រាយមាត់ការុងឲ្យអាកុហកសុីចេញមក  ឯអា កុហកសុីចេញអំពីក្នុងការុង  ពោសខ្លួនមើលហើយថាអញជា. ឃ្លង់ហើយ  ឯអាគិលង់ឮអាកុហកសុីថាតមឃ្លង់ក្នុងការុងជា ដូច្នោះហើយ  ក៏និយាយនឹងអាកុហកសុីថា  ឲ្យគ្នាតមឃ្លង់ផង ឯអាកុហកសុីឮដូច្នោះអរណាស់  គិតក្នុងចិត្តថាអញអស់ស្លាប់ ហើយ  បានអាគិលង់ស្លាប់ជួស  អាកុហកសុីប្រាប់អាគិលង់ ថា  បើឯងចង់ជាឃ្លង់ឆាប់ឯងកាន់ត្រណមឲ្យជាប់  កុំនិយាយ ស្រដីនឹងអ្នកណាសោះ  បើនរណាមកសួរក្តី  មកជេរមកវាយ ដូចម្តេច ៗ ក្តី  ឯងកុំនិយាយកុំស្រដី  ខំកាន់ត្រណមឲ្យខ្ជាប់ ទើបបានជាឆាប់  ឯអាគិលង់ឮអាកុហកសុីថាដូច្នោះហើយ  ក៏

ទទួលបាំហើយចូលទៅក្នុងការុង ឯអាកុហកស៊ីចងមាត់ការុងខ្ជាប់ហើយរត់បាត់ទៅ ។ ឯមានោះរកដំរាឡែអាកុហកស៊ីពុំឃើញ ដឹងថាអាកុហកស៊ីបញ្ឆោត ខឹកខឹងណាស់ គុំថាបើអញទៅដល់អញនឹងទំលាក់ក្នុងទឹកឲ្យស្លាប់ទៅ ហើយខំដើរទៅដល់ស្ទះទៅដាល់វាយអាគំលង់ ឯអាគំលង់ខំអត់បង់ជាឃ្លង់ ឯមាស្មានថាជាអាកុហកស៊ី លុះវាយធាក់អស់ពិត្តហើយលើកបោះទៅក្នុងទឹកស្លាប់ទៅ ។

ឯអាកុហកស៊ីរត់រួចអំពីនោះទៅ ៗ ជួបនឹងមនុស្សកុហកម្នាក់ បេះកុហកជួបគ្នា កំពុងតែងូតទឹក ឯអាកុហកនោះឃើញអាកុហកស៊ីដើរទៅពីចម្ងាយ ហើយធ្វើជាមុជទឹកយូរបន្តិចងើបឡើង ហើយលើកកាសឡើងថា អញមុជទឹកទៅឃើនក្រោមមានគេលេងបៀរច្រើនណាស់ អញលេងឈ្នះកាសប្រាក់ជាច្រើន ប៉ុន្តែយកមកមិនរួច បានតែមួយត្រណោតមក អាកុហកស៊ីឮដូច្នោះហើយក៏ជឿគិតស្មានជាមែន ហើយផ្លាស់សំពត់លោតចុះទៅក្នុងទឹក ហើយខំមុជទៅទង្គិចក្បាលនឹងគល់បែកឈាម ហើយដឹងខ្លួនថាជាមនុស្សកុហក ក៏ខឹកក្នុងចិត្តឃើញ

ប្រាជ្ញានឹងកុហកវិញ ហើយដើបឡើងនិយាយទៅនឹងអាដែលបញ្ឆោតនោះ អ្នកអើយខ្ញុំមុជទឹកអំបាញ់មិញទៅតាមពាក្យអ្នកឯង ហើយឃើញគេលេងបៀរបោ៉រធ្លរកំតាត់ច្រើនណាស់ ហើយខ្ញុំលេងឈ្នះប្រាក់កាសជាច្រើន ខ្ញុំទារពីគេ ៗ ឋាឲ្យមកយកអំពីអ្នកឯង នោះខ្ញុំមិនព្រមខ្ញុំបេះតែទារ គេខឹងគេៗវាយខ្ញុំបែកក្បាល ហើយគេឋាឲ្យខ្ញុំមកយកអំពីអ្នកឯង បើអ្នកមិនជឿអ្នកមើលក្បាលខ្ញុំដែលបែកនេះចុះ ឯអាដែលកុហកនោះក៏ដឹងជាអាកុហកសុីមានប្រាជ្ញាកុហកទល់មិនបានបាញ់ អាកុ-ហកសុីស្រាយកាសបែកឲ្យពាក់កណ្តាលម្នាក់ ហើយសុំគ្នាជាបងប្អូនដើររកសុីកុហកគេអំពីថ្ងៃនោះទៅ ។

និយាយរឿងអាកុហកសុីអស់តែប៉ុណ្ណេះឯង

COMMISSION DES MOEURS & COUTUMES

# បញ្ជីរឿង


លេខទំព័រ

១ សារទេសនា របស់ព្រះវិសុទ្ធិវង្ស ហ. តាត រៀបរៀង (ត) . . . . . . ១០៧

២ គាថាធម្មបទ ប្រែ . . . . . . . . . . . . . . . . . . . . . . ១២១

៣ លោកន័យ ពាក្យកាព្យ (ត) . . . . . . . . . . . . . . . . . ១៧៩

៤ រឿងព្រេងខ្មែរ រឿងបុរសបេះថ្នាំពិសពស់ . . . . . . . . . . . . . ២០១


## រូបក្រៅរឿង


១ ព្រះចេតិយធំបំផុត នៅវត្តស្វេតដោង ក្រុងព្រោម (ភូមា) . . . . . . . . ១០៥

២ លោកសង្ឃភូមា គណសទ្ធម្ម នៅវត្តតែកតាវ ក្រុងបណ្ឌាលេ . . . . . . ១៩៩



ក្រុមជំនុំទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# TABLE DES MATIÈRES


Page

I. Sāradesanā ou Abrégé de la doctrine bouddhique par le Vénérable Tath.................................. 107

II. Gāthā Dhammapada traduit du Pali en cambodgien..... 121

III. Lokanaya.................................................. 179

IV. Contes populaires cambodgiens inédits :

Histoire de l'homme connaissant le remède contre le venin des serpents.................................. 201


## HORS TEXTE


I. Le chedi central Pagode de Shwedaung Prôme Birmanie........................................ 105

II. Bonze birman de la Secte Suddhamma — Pagode de Taik-Taw -- Mandalay........................... 199



ព្រះចេតិយធំបំផុត នៅវត្តស្វេតដោង ក្រុងប្រោម (ភូមា) នៅកំពូល
ប្រដាប់ដោយមាសដាំត្បូងពេជ្រ ជាទីគោរពរបស់ភូមាយ៉ាងបំផុត

# សារទេសនា

## ពុទ្ធសាសនបដិបត្តិ

សេចក្ដីប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ដែលអ្នកកាន់សាសនាត្រូវប្រព្រឹត្តប្រតិបត្តិតាមនោះ បើចែកដោយសង្ខេបមាន ៣ ជាន់គឺ:

១ ជាន់ខាងក្រោមគឺលោកិយធម៌ សម្រាប់ពុទ្ធសាសនិកជនគឺជនអ្នកកាន់ព្រះពុទ្ធសាសនាជាន់ក្រោម គឺអ្នកដែលជាបុថុជ្ជន ប្រតិបត្តិធ្វើតាមដើម្បីនឹងឈានឡើងទៅកាន់ជាន់កណ្ដាល ។

២ ជាន់កណ្ដាលគឺលោកុត្តរធម៌ សម្រាប់ពុទ្ធសាសនិកជនជាន់កណ្ដាល គឺអ្នកដែលបានដល់នៅក្នុងមគ្គផល តាំងពីទី ១ គឺសោតាបត្តិមគ្គ ដល់ទី ៧ គឺអរហត្តមគ្គ ប្រតិបត្តិធ្វើតាម ដើម្បីនឹងឈានឡើងទៅកាន់ជាន់ខ្ពស់បំផុត ។

៣ ជាន់ខ្ពស់បំផុតគឺលោកុត្តរធម៌ សម្រាប់ពុទ្ធសាសនិកជនជាន់ខ្ពស់បំផុត គឺអ្នកដែលបានដល់នៅក្នុងអរហត្តផល ប្រព្រឹត្តប្រតិបត្តិតាម ។

ក្នុងឱកាសនេះ នឹងអធិប្បាយតែត្រង់សេចក្ដីប្រតិបត្តិក្នុងព្រះពុទ្ធសាសនាជាន់ខាងក្រោម សម្រាប់មនុស្សជាបុថុជ្ជន សេចក្ដីប្រតិបត្តិនោះមានបែបផ្សេងគ្នាជាពីរយ៉ាង គឺសេចក្ដីប្រតិបត្តិសម្រាប់អ្នកបួស ១ សម្រាប់គ្រហស្ថ ១ ។

នឹងសំដែងតែត្រង់សេចក្ដីប្រតិបត្តិសម្រាប់គ្រហស្ថ ដោយសង្ខេបដូចមានតទៅនេះ:

ផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ដែលគ្រហស្ថត្រូវប្រតិបត្តិនោះមានច្រើនប្រការ មានតាំងពីកិច្ចដែលដឹកល់ខ្លួនទៅក្នុងព្រះត្រៃសរណគមន៍ ដរាបដល់សេចក្ដីប្រតិបត្តិថ្លើខ្លួនឡើងដឹកល់ទៅក្នុងអរិយភូមិ មានសោតាបត្តិមគ្គជាដើម ។

អ្នកដែលប្រតិបត្តិក្នុងព្រះពុទ្ធសាសនា កាលជាន់ដើមពីក្នុងពុទ្ធសម័យ ឬក៏ក្នុងកាលខាងក្រោយតពីព្រះជាបរមគ្រូទ្រង់ចូលបរិនិព្វានរៀងមក ក៏រមែងប្រតិបត្តិទៅតាមសមគួរដល់សទ្ធាចិត្តរបស់ខ្លួនរៀងៗ អ្នកខ្លះបានដឹកល់ខ្លួនទៅក្នុងព្រះត្រៃសរណគមន៍ អ្នកខ្លះដឹកល់ខ្លួនទៅក្នុងនិច្ចសីល នឹងឧបោសថសីល នឹងសុចរិតទាំង ៣ ប្រការ អ្នកខ្លះក៏បានប្រតិបត្តិតាម

គន្លងនៃសមថភាវនានឹងវិបស្សនាភាវនា ជំរាបដល់ផ្លូវនឡើង ផុតជាតិជាបុថុជ្ជន ឡើងដល់នៅក្នុងទីអរិយភូមិបាន ។

អស់លោកអ្នកទាំងឡាយ ក៏សុទ្ធតែជាអ្នកប្រកបដោយកិច្ចកង្វល់ ក្នុងការងារដែលត្រូវធ្វើ បើមិនអាចនឹងប្រតិបត្តិឡើងសព្វគ្រប់បាន ក៏គប្បីប្រតិបត្តិឡើងសមគួរដល់ស្ថានដែលត្រូវបានឈ្មោះថាជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រឹមតែសេចក្ដីខាងក្រោយនេះគឺ :

១ ដឹកល់ខ្លួននៅក្នុងព្រះត្រៃសរណគមន៍ គឺតាំងចិត្តជឿជាក់ហើយបញ្ចេញវាចាប្រកាសយក ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃថាជាទីពឹង ទីរឭក ព្រមទាំងសេចក្ដីដឹងក្នុងគុណនៃព្រះរតនត្រ័យនោះផង មានដឹងថា ព្រះពុទ្ធព្រះអង្គមាននាមថា "អរហំ" ព្រោះព្រះអង្គកំចាត់បង់ហើយនូវសត្រូវគឺធម៌ជាគ្រឿងសៅហ្មងដូច្នេះជាដើម ដឹងថា "ស្វាក្ខាតោ ភគវតា ធម្មោ" ព្រះបរិយត្តិធម៌និងនវលោកុត្តរធម៌ ដែលព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងហើយដោយល្អ ដូច្នេះជាដើម ដឹងថា "សុ-បដិបន្នោ ភគវតោ សាវកសង្ឃោ" ព្រះសង្ឃជាសាវករបស់

ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយល្អ ដូច្នេះជាដើម ។

២ សមាទានរក្សាសីល ៥ គឺវៀរមិនសម្លាប់បំបាត់ជីវិតសត្វតូចធំ ១ មិនលួចទ្រព្យរបស់អ្នកដទៃ ដែលគេមិនឲ្យ ១ មិនប្រព្រឹត្តខុសក្នុងផ្លូវកាម ១ មិននិយាយកុហក ១ មិនផឹកសុរា ១ ។

( សីល ៥ នេះត្រូវរក្សាឲ្យបានជាប់ជានិច្ច បើប្រសិនជាមានដាច់ត្រង់សីលណាមួយនៅពេលណាដោយសេចក្ដីភ្លាំងភ្លាត់នោះ ត្រូវសុំសមាទានអំពីអ្នកដទៃ ឬគ្រាន់តែអធិដ្ឋានដោយខ្លួនឯង ឲ្យបានជាប់ឡើងវិញក៏បាន ) ។

៣ រក្សានូវសុចរិត ៣ ប្រការគឺ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។

កាយសុចរិត ប្រព្រឹត្តល្អដោយកាយ មាន ៣ យ៉ាងគឺ វៀរមិនសម្លាប់បំបាត់ជីវិតសត្វតូចធំ ១ វៀរមិនលួចយកទ្រព្យរបស់អ្នកដទៃ ១ វៀរមិនប្រព្រឹត្តខុសក្នុងផ្លូវកាមគឺការកន្លងប្រវេណី ១ ។

វចីសុចរិត ប្រព្រឹត្តល្អដោយវាចា មាន ៣ យ៉ាងគឺ វៀរមិននិយាយកុហក ១ វៀរមិននិយាយពាក្យញុះញង់ ១ វៀរមិននិយាយពាក្យអាក្រក់គឺពាក្យចាក់ដោតដោយការប្រទេចផ្តាសា ១ វៀរមិននិយាយពាក្យឥតប្រយោជន៍ ១ ។

មនោសុចរិត ប្រព្រឹត្តល្អដោយចិត្ត មាន ៣ យ៉ាងគឺ មិនមានប្រាថ្នាលោភលន់បង់បានទ្រព្យរបស់អ្នកដទៃ ១ មិនមានគិតគំនុំគុំកួនអ្នកដទៃឲ្យវិនាស ១ មានគំនិតគិតត្រូវតាមហេតុពិត ១ ( តាំងពីត្រៃសរណគមន៍ដល់សុចរិត ៣ ប្រការ មានពិស្តារក្នុងសៀវភៅគិហិបដិបត្តិ ) ។

សេចក្តីប្រតិបត្តិក្នុងព្រះពុទ្ធសាសនាដូចរៀបរាប់ខាងលើនេះ សូម្បីបន្តិចប៉ុណ្ណោះ ក៏គង់តែនឹងមានប្រយោជន៍ដល់អ្នកដែលប្រតិបត្តិតាមដូចសេចក្តីខាងក្រោយនេះ:

១ នឹងបានទូវអំណរពេញចិត្តខ្លួនឯងថា "ខ្លួនអញបានដាក់ខ្លួនក្នុងទីដ៏ត្រូវល្អហើយ, អញបានត្រូវហើយ អញឥតមានខុសទេ" ។

២ នឹងបានជាទីទុកចិត្ត, ជាមនុស្សជំនឿពេញចិត្តនៃអ្នកឯទៀត គឺថាបើខ្លួននៅក្នុងបន្ទុកអ្នកឯទៀតដែលយសសក្តិធំជាងខ្លួន គេនឹងទុកចិត្តជឿស្រឡាញ់រាប់អាន ដោយគេដឹងថាខ្លួនជាអ្នកសុចរិតល្អហើយ គេនឹងលើកសរសើរទំនុកបំរុងឡើងបាននូវសេចក្តីចំរើងនិងសេចក្តីសុខស្រួល ព្រោះហេតុដែលខ្លួនកាន់សុចរិតគួរឲ្យគេទុកចិត្តបាន ។

៣ នឹងមានកិត្តិសព្ទកេរ្តិ៍ឈ្មោះថាជាអ្នកប្រព្រឹត្តសុចរិតត្រឹមត្រូវ ។

៤ វេលាដែលនឹងដល់នូវមរណកាល ក៏ឥតមានសេចក្តីវង្វេងឡើយ ។

៥ លុះធ្វើមរណកាលទៅហើយ ក៏រមែងបានទៅកើតក្នុងសុគតិភព ។

ម្យ៉ាងទៀត សូមអស់លោកអ្នកទាំងឡាយជ្រាបថាផលប្រយោជន៍ដែលកើតឡើងអំពីសេចក្តីប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ដូចសេចក្តីអធិប្បាយក្នុងខាងលើនេះ ក៏សឹងមានប្រយោជន៍ប្លែកអំពីគ្នា ដោយរូបអ្នកដែលប្រតិបត្តិខ្លះល្អង់ ខ្លះមាន

ប្រាជ្ញាចេះដឹង បើល្ងង់ក៏បានផលប្រយោជន៍តិចបុះទៅ បើមានប្រាជ្ញាចេះដឹងក៏បានផលប្រយោជន៍ច្រើនឡើង ដូចសេចក្ដីអធិប្បាយតទៅក្នុងខាងមុខនេះៈ

## ទោសនៃសេចក្ដីល្ងង់

សេចក្ដីមិនចេះមិនដឹង ហៅថាសេចក្ដីល្ងង់ បើមិនចេះអក្សរនឹងលេខហៅថាល្ងង់ក្នុងអក្សរនឹងលេខ បើមិនចេះធ្វើការអ្វីហៅថាល្ងង់ក្នុងការនោះ បើមិនចេះគិតហៅថាល្ងង់ក្នុងការគិត អ្នកណាមានសេចក្ដីល្ងង់ អ្នកនោះឈ្មោះថាមនុស្សឥតបំណេះវិជ្ជា អ្នកណាឥតមានបំណេះវិជ្ជា អ្នកនោះឈ្មោះថាមនុស្សល្ងង់ ៗ នោះបើនឹងធ្វើការអ្វី ការនោះច្រើនមិនកើត បើទុកជាកើតច្រើនមិនល្អ បើនឹងនិយាយពាក្យណា ពាក្យនោះច្រើនមិនប្រាកដ បើនឹងគិតហេតុអ្វី ហេតុនោះមិនចេញមកសម្ដែងឲ្យប្រាកដជាខុសឬត្រូវបាន .។

មនុស្សល្ងង់ឧបមាដូចមនុស្សខ្វាក់ ធម្មតាមនុស្សខ្វាក់ កម្រនឹងដើរតាមផ្លូវឲ្យត្រង់នឹងរហ័សបានឡើយ ព្រោះមាន

សេចក្តីញញើតញញើមរួញរាស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម៉្លោះហើយសេចក្តីមិនប្រាកដក្នុងចិត្តនោះ ធ្វើដំណើរក៏មិនឲ្យប្រាកដជាទៅមុខឬទៅខាង ច្រើនទីសទាស ដូចគ្នានឹងមនុស្សល្ងង់ បើនឹងធ្វើឬនិយាយឬគិត ក៏ឥតមានប្រាកដក្នុងចិត្ត សេចក្តីមិនប្រាកដនេះឯង មិនអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសំរេចបាន ។

មានពុទ្ធភាសិត ១ កន្លែងសម្តែងថា មោហគឺសេចក្តីល្ងង់ តែមានច្រើនក្នុងសន្តានអ្នកណាមួយហើយ នឹងអាចធ្វើអ្នកនោះមិនឲ្យស្គាល់សេចក្តីអាក្រក់ល្អ នឹងខុស-ត្រូវ-បានឡើយ ។

មានសុភាសិតពីបុរាណ ក្នុងគម្ពីរហិតោបទេសជាភាសាសំស្ក្រឹត សេចក្តីដើមថា មានស្តេច ១ អង្គព្រះនាមសុទសិននៅក្នុងក្រុងបាដលិបុត្រ ទ្រង់នឹកប្រារព្ធដល់ព្រះរាជឱរសរបស់ព្រះអង្គ ដែលមិនយកចិត្តទុកដាក់ក្នុងការសិក្សាសាស្ត្រវិទ្យាប្រព្រឹត្តតែក្នុងផ្លូវខុស ទើបព្រះអង្គទ្រង់ព្រះរាជដំរិះថា : "កូនដែលគ្មានបំណេះវិជ្ជា ជាមនុស្សល្ងង់ មិនប្រព្រឹត្តតាមធម៌ នឹងមានប្រយោជន៍អ្វីដោយកូនដូច្នោះ ប្រៀបឧបមាដូចភ្នែកខ្វាក់

នឹងមានប្រយោជន៍អ្វីដោយភ្នែកខ្វាក់នោះ មានតែសេចក្ដីអផ្សុកព្រួយចិត្តតែម្យ៉ាង" ។

"កូនមាន ៣ យ៉ាង គឺកូនដែលមិនទាន់កើត ១ កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១ កូនដែលកើតហើយនៅរស់តែល្ងង់ខ្លៅ ១ បណ្ដាកូនទាំង ៣ យ៉ាងនេះ គួរយកកូន ២ យ៉ាងខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែ ១ គ្រា ១ លើកហើយក៏បាត់ទៅ ឯកូន ១ ទីបំផុតនោះមិនគួរយកឡើយ ព្រោះកូននោះនឹងនាំបណ្ដាលឲ្យបានសេចក្ដីទុក្ខព្រួយជានិច្ច" ។

អ្នកណាមួយ ទោះបីមានរូបឆោមលោមពណ៌ល្អតាំងនៅក្នុងតរុណវ័យគឺនៅក្មេងនៅឡើយ, កើតនៅក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ក្ដី តែប្រាសចាកចំណេះវិជ្ជាគឺឥតមានចេះដឹងអ្វីហើយ អ្នកនោះឯងជាមនុស្សឥតរាសីមានដម្លៃ ដូចគ្នានឹងផ្កាចារ (មានតែពណ៌ល្អស្រស់) តែឥតមានក្លិនក្រអូប ។

មានសុភាសិតម្យ៉ាងទៀតថា "មនុស្សនឹងសត្វគោមានការនឹងបរិភោគអាហារ សេពមេថុន នឹងដេក ដូចគ្នា តែ

មនុស្សមានបំណេះវិជ្ជាសំរាប់ធ្វើឲ្យប្លែកអំពីគោ មនុស្សណាឥតមានបំណេះវិជ្ជា មនុស្សនោះឈ្មោះថាស្មើគ្នានឹងសត្វគោ" ។

ដែលនាំរឿងសុភាសិតខ្លះមកអធិប្បាយក្នុងទីនេះ ដើម្បីឲ្យឃើញថា សេចក្តីល្ងង់នេះធ្វើអ្នកនោះឲ្យបានដល់នូវសេចក្តីមិនចំរើន នឹងទន់ទាបថយថោក តាំងពីក្នុងបច្ចុប្បន្ននេះដរាបដល់លោកខាងមុខ ។

ឯទោសនៃសេចក្តីល្ងង់ដែលនឹងឃើញច្បាស់ក្នុងបច្ចុប្បន្ននេះដូច្នេះ

១ បើល្ងង់ក្នុងវិធីអក្សរ គឺមិនចេះសរសេរ មិនចេះមើល នឹងនាំឲ្យខាតបង់នូវប្រយោជន៍ដូច្នេះ :

ក) មិនអាចមើលសាស្ត្រាឬសៀវភៅដែលមានច្បាប់ប្រ-ដៅល្អ ក្នុងព្រះពុទ្ធសាសនាឬក្រៅពីព្រះពុទ្ធសាសនាជាគ្រឿងនាំឲ្យកើតគំនិតប្រាជ្ញា ។

ខ) មិនអាចសរសេរសំបុត្រដោយខ្លួនឯងឲ្យដំណឹងដល់ញាតិមិត្តដែលខ្លួនត្រូវការ ។

គ) សេចក្ដីកំបាំងឬការក្រដែលញាតិមិត្តផ្ញើសំបុត្រឲ្យដំ-ណឹងមកចំពោះខ្លួននោះនឹងមិនសំរេចប្រយោជន៍ ។

២ អ្នកដែលឥតមានបំណេះវិជ្ជាអ្វី បើនៅអាស្រ័យជ្រកកោនក្នុងសំណាក់អ្នកធំ ហើយចេះគោរពប្រតិបត្តិឲ្យអ្នកធំលោកស្រឡាញ់អាណិតមេត្តាជួបមេត្តា អ្នកធំនោះក៏មិនអាចនឹងលើកដំកើងអ្នកនោះឲ្យមានកេរ្ដិ៍ឈ្មោះយសសក្ដិបានឡើយព្រោះលោកយល់ថាខ្លួនល្ងង់ បើគ្រាន់បើណាស់បានត្រឹមតែសេចក្ដីសុខ ព្រោះអាស្រ័យនឹងឥស្សរភាពរបស់អ្នកធំនោះប៉ុណ្ណោះ តែក៏គង់មិនរួចអំពីទីដែលជាអ្នកបំរើគេ ។

៣ មនុស្សល្ងង់ ទោះបីមានយសសក្ដិដោយអំណាចព្រេងសំណាងជួយឧបថម្ភមក បើក្ដីថ្លើងគ្រាន់បើបានតែក្នុងទីឯទៀត តែដល់ក្នុងទីប្រជុំក៏នឹងត្រឡប់ទៅជាមនុស្សឥតរាសីឥតមានដម្លៃទៅវិញ ព្រោះមិនចេះរៀបចំធ្វើអាការឫកពារឲ្យសមគួរដល់ស្ថានរបស់ខ្លួន ឬនឹងហានិយាយឡើងក៏មិនត្រូវតាមទំនងធម៌នឹងទំនងច្បាប់ ជាហេតុឲ្យអ្នកឯទៀតគេញញឹម

ក្នុងចិត្តរាល់គ្នាដោយការមើលងាយ ម្ល៉ោះហើយគេពុំជឿស្ដាប់ពុំកោតខ្លាច ដោយគេដឹងថាខ្លួនជាមនុស្សល្ងង់ ។

៤ មនុស្សល្ងង់ ជាមនុស្សខ្សត់មិត្តសម្លាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសម្លាញ់ឡើយ ។

ព្រោះហេតុអ្វី? ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងរកយកទៅឲ្យជួយធ្វើអ្វី ឬជួយពីគ្រោះប្រឹក្សាការអ្វីក៏មិនកើតទាំងអស់ ។

# គាថាធម្មបទ ប្រែ

## របស់អាចារ្យ ហឹម

## ក្រុមជំនុំប្រែព្រះត្រៃបិដក

# ធម្មបទេ វីសតិមោ មគ្គវគ្គោ

បធានកម្មិកតិស្សត្ថេរវត្ថុគាថា

(៣) ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ
យុវា ពលី អលសិយំ ឧបេតោ
អសម្បន្នសង្កប្បមនោ[១] កុសីតោ
បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

សូករបេតវត្ថុគាថា

(៤) វាចានុរក្ខី មនសា សុសំវុតោ
កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ
អារាធយេ មគ្គមិសិប្បវេទិតំ ។

---

១ សំសន្នសំកប្បមនោតិបិ បាឋោ ។

## មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបងានទកម្មិកតិស្សត្ថេរ*

(៣) បុគ្គលឯណានូវកំឡោះមានកំឡាំង តែប្រកបដោយសេចក្ដីខ្ជិលច្រអូស មានចិត្តញាប់ញ័រដោយមិច្ឆាវិតក្ក (ជម្រិះខុស) ស្ពឹកទំរន់មិនក្រោកឡើង គឺមិនប្រឹងប្រែងក្នុងកាលដែលខ្លួនមានការគួរខ្នះខ្នែងបាន បុគ្គលខ្ជិលនោះដុខជានឹងមិនបានអរិយមគ្គ ដែលខ្លួនគប្បីឃើញដោយបញ្ញាឡើយ ។

*គាថាក្នុងរឿងសូករបេត*

(៤) បុគ្គលឯណារក្សាវាចារឿយ ៗ ផង សង្រួមចិត្តឲ្យល្អផង មិនធ្វើអកុសលដោយកាយផង បើញ៉ាំងកម្មបថទាំង ៣ នេះឲ្យស្អាតវិសេសបានហើយ បុគ្គលនោះនឹងគប្បីត្រេកអរនូវមគ្គដែលបុគ្គលអ្នកស្វែងរក (នូវគុណដ៏ប្រសើរមានព្រះពុទ្ធជាដើម) ទ្រង់សំដែងហើយមិនខាន ។

# ធម្មបទេ វីសតិមោ មគ្គវគ្គោ

ពោដ្ឋិលត្ថេរវត្ថុគាថា

(៥) យោគា វេ ជាយតេ ភូរិ   អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា   ភវាយ វិភវាយ ច ។
តថត្តានំ និវេសេយ្យ   យថា ភូរិ បវឌ្ឍតិ ។

មហល្លកត្ថេរវត្ថុគាថា

(៦) វនំ ឆិន្ទថ មា រុក្ខំ   វនតោ ជាយតេ ភយំ
ឆេត្វា វនំ វនថញ្ច   និព្វនា ហោថ ភិក្ខវោ ។

# មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពោដ្ឋិលត្ថេរ*

(៥) បញ្ញាកើតមកអំពីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ឯសេចក្ដីវិនាសនៃបញ្ញា កើតមកអំពីគ្មានព្យាយាមជាគ្រឿងប្រកប អ្នកមានប្រាជ្ញាបើដឹងថាព្យាយាមជាគ្រឿងប្រកបនិងមិនប្រកបទាំងពីរនេះ ជាគន្លងប្រព្រឹត្តទៅដើម្បីសេចក្ដីចំរើននឹងសេចក្ដីវិនាសហើយ បញ្ញាចំរើនឡើងដោយប្រការឯណា គួរញ៉ាំងខ្លួនឲ្យដំកល់នៅដោយប្រការដូច្នោះឯង ។

*គាថាក្នុងរឿងមហល្លកត្ថេរ*

(៦) អ្នកទាំងឡាយចូរកាត់នូវព្រៃគឺកិលេសចោលចេញ កុំកាប់នូវដើមឈើឡើយ ភ័យកើតមកអំពីព្រៃគឺកិលេស ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកាត់នូវកិលេសដូចព្រៃធំផង នូវកិលេសដូចព្រៃតូចផង ហើយចូរជាអ្នកកុំមានព្រៃគឺកិលេសឡើយ ។

ធម្មបទេ វីសតិមោ មគ្គវគ្គោ

យាវញ្ហិ វនថោ ន ឆិជ្ជតិ អនុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោវ តាវ សោ វច្ឆោ ខីរបកោវ[១] មាតរិ ។

សារីបុត្តត្ថេរស្ស សទ្ធិវិហារិកភិក្ខុវត្ថុគាថា

(៧) ឧច្ឆិន្ទ សិនេហមត្តនោ កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ និព្វានំ សុគតេន ទេសិតំ ។

មហាធនវាណិជវត្ថុគាថា

(៨) ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហិសុ
ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

---

១ ម ខីរូបកោ ។

## មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

ព្រោះថាកិលេសដូចព្រៃតូចធំរបស់ជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ដរាបណាហើយ ជននោះឯងតែងមានចិត្តជាប់ចំពោះក្នុងស្ត្រីទាំងឡាយដរាបនោះ ដូចកូនគោនៅកំពុងបៅដោះមានចិត្តជាប់នៅក្នុងមាតា (មេ) ដូច្នោះឯង ។

*គាថាក្នុងរឿងភិក្ខុជាសទ្ធិវិហារិករបស់ព្រះសារីបុត្ត*

(៧) អ្នកចូរកាត់សេចក្ដីស្រឡាញ់ចោលចេញ ឲ្យដូចជាបុគ្គលដែលកាត់ទងផ្កាក្រមុទដែលដុះក្នុងរដូវសរទកាល ចូរចំរើននូវអដ្ឋង្គិកមគ្គ ដែលជាផ្លូវទៅកាន់ព្រះនិព្វានជាទីរម្ងាប់តែម្យ៉ាង ដ្បិតព្រះនិព្វានព្រះសុគតទ្រង់សំដែងទុកមកហើយ ។

*គាថាក្នុងរឿងមហាធនពាណិជ*

(៨) អាត្មាអញនឹងនៅក្នុងទីនេះឲ្យអស់វស្សានរដូវ អាត្មាអញនឹងនៅក្នុងទីនេះឲ្យអស់ហេមន្តរដូវនិងគិម្ហន្តរដូវទាំងឡាយ ជនពាលរមែងគិតខុសដូច្នេះ មិនដឹងសេចក្ដីអន្តរាយឡើយ ។

## ធម្មបទេ វីសតិមោ មគ្គវគ្គោ

កិសាគោតមីវត្ថុគាថា

(៩) តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ[១]
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

បដាចារាវត្ថុគាថា

(១០) ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

មគ្គវគ្គោ វីសតិមោ សមត្តោ

---

១ ម. ព្យាសត្តមានសំនរំ ។

# មគ្គវគ្គទី ២០ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកិសាគោតមី*

(៩) មច្ចុគឺសេចក្ដីស្លាប់រមែងកាន់យកនូវនរជាតិមានចិត្តជាប់នៅក្នុងអារម្មណ៍ផ្សេង ៗ ដែលលោកសន្មតថាកូននឹងសត្វចិញ្ចឹមនោះហើយត្រេចទៅ ដូចជាអន្លង់ទឹកដ៏ធំហោរជន់មកកាន់យកនូវអ្នកស្រុកដេកលក់ហើយទៅ ។

*គាថាក្នុងរឿងបដាចារា*

(១០) កូនទាំងឡាយមិនមានដើម្បីជាទីជ្រកកោន បិតាក៏មិនមានជាទីជ្រកកោន ឯពៅពង្សទាំងឡាយក៏មិនមានជាទីជ្រកកោនជាទីពឹងពួនដែរ ភាវៈជាទីជ្រកកោនក្នុងជនជាញាតិទាំងឡាយ (មានកូនជាដើម) នៃបុគ្គលដែលសេចក្ដីស្លាប់គ្របសង្កត់ហើយមិនមានឡើយ ។

អ្នកមានប្រាជ្ញាដែលបានសង្រួមក្នុងសីលល្អហើយ បើដឹងនូវអំណាចនៃប្រយោជន៍នេះហើយ គួរជំរះផ្លូវទៅកាន់ព្រះនិព្វានឲ្យឆាប់ ៗ ។

មគ្គវគ្គទី ២០ ចប់

# ធម្មបទេ ឯកវីសតិមោ បកិណ្ណកវគ្គោ

អត្តនោ បុព្វកម្មវត្ថុ គាថា

(១) មត្តាសុខបរិច្ចាគា  បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ  សម្បស្សំ វិបុលំ សុខំ ។

កុក្កុដណ្ឌខាទិកាវត្ថុ គាថា

(២) បរទុក្ខូបធានេន  យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ  វេរា សោ ន បរិមុច្ចតិ ។

ភទ្ទិយភិក្ខុវត្ថុ គាថា

(៣) យញ្ហិ កិច្ចំ តទបវិទ្ធំ  អកិច្ចំ បន កយិរតិ[១]
ឧន្នឡានំ[២] បមត្តានំ  តេសំ វឌ្ឍន្តិ អាសវា ។

---

១ ម. ករីយតិ ។ ២ ម. ឧន្នឡ្ហានំ ។

# បកិណ្ណកវគ្គទី ២១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអត្តនោបុព្វកម្ម*

(១) បុគ្គលគប្បីឃើញនូវសេចក្ដីសុខដ៏ធំទូលាយបាន ព្រោះលះបង់នូវសេចក្ដីសុខមានប្រមាណតិច អ្នកមានប្រាជ្ញា កាលបើឃើញច្បាស់ នូវសេចក្ដីសុខដ៏ធំទូលាយហើយ គួរគប្បីលះបង់នូវសេចក្ដីសុខមានប្រមាណតិចកុំខាន ។

*គាថាក្នុងរឿងកុក្កុដណ្ឌខាទិកា*

(២) ជនឯណាប្រាថ្នាសេចក្ដីសុខដល់ខ្លួន ដោយដាក់សេចក្ដីទុក្ខដល់បុគ្គលដទៃ ជននោះឈ្មោះថានៅប្រឡូកប្រឡំដោយពៀរ មិនរួចស្រឡះចាកពៀរឡើយ ។

*គាថាក្នុងរឿងភទ្ទិយភិក្ខុ*

(៣) ពិតណាស់ កិច្ចណាដែលខ្លួនត្រូវធ្វើ កិច្ចនោះភិក្ខុទាំងឡាយលះបង់ចោល ក៏ឯអំពើដែលមិនមែនជាកិច្ច (របស់ខ្លួន) បើភិក្ខុទាំងឡាយឯណាធ្វើហើយ អាសវៈទាំងឡាយតែងចំរើនដល់ភិក្ខុទាំងឡាយនោះ ជាអ្នកមានមានះដូចជាដើមបបុះដើបឡើងហើយ ដែលប្រមាទហើយ ។

## ធម្មបទេ ឯកវីសតិមោ បកិណ្ណកវគ្គោ

យេសញ្ច សុសមារទ្ធា និច្ចំ កាយគតាសតិ
អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ ។
សត្តានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។

លកុណ្ឋកភទ្ទិយត្ថេរគាថា

(៤) មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ
រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។
មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ
វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

## បកិណ្ណកវគ្គទី ២១ ក្នុងព្រះធម្មបទ

លុះតែសតិជាគ្រឿងរឭកតាំងនៅក្នុងកាយ បើភិក្ខុទាំងឡាយឯណាបានប្រារព្ធដោយប្រពៃហើយ ភិក្ខុទាំងឡាយនោះមិនសេពនូវកម្មដែលមិនមែនជាកិច្ច ជាអ្នកមានកិរិយាធ្វើរឿយ ៗ មិនដាច់ក្នុងកិច្ចជាប្រក្រតី ទើបអាសវៈទាំងឡាយរបស់ភិក្ខុទាំងឡាយដែលមានសតិសម្បជញ្ញៈនោះ តែងដល់នូវកិរិយាវិនាសអស់ទៅមិនខានឡើយ ។

*គាថាក្នុងរឿងលកុណ្ឌកភទ្ទិយ*

(៤) ព្រាហ្មណ៍គឺព្រះខីណាសវ លោកសម្លាប់បង់នូវតណ្ហាដូចជាមាតាផង នូវអស្មិមានៈដូចជាបិតាផង នូវសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិដូច (ជាស្តេច) ជាក្សត្រិយ៍ពីរព្រះអង្គផង នូវអាយតន ១២ ដូចជាដែនប្រព្រឹត្តទៅមួយអន្លើដោយនាយស្មៀនជាអ្នកញ៉ាំងសួយឲ្យសម្រេចផង ទើបជាបុគ្គលគ្មានទុក្ខឡើយ ។ ព្រាហ្មណ៍គឺព្រះខីណាសវលោកសម្លាប់បង់នូវតណ្ហា ដូចជាមាតាផង នូវអស្មិមានៈដូចបិតាផង នូវសស្សតទិដ្ឋិនិងឧច្ឆេទ-ទិដ្ឋិ ដូច (ជាព្រាហ្មណ៍) និងស្តេចទាំងពីរផង នូវវិចិកិច្ឆានីវរណ ជាគំរប់ ៥ ដូចជាខ្លាធំផង ទើបជាបុគ្គលគ្មានទុក្ខឡើយ ។

# ធម្មបទេ ឯកវីសតិមោ បកិណ្ណកវគ្គោ

ទារុសាកដិកបុត្តវត្ថុ ៥

(៥) សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។

## បកិណ្ណកវគ្គទី ២១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទារុសាកដិកបុត្ត*

(៥) សតិរបស់ជនទាំងឡាយឯណា បានដឹកល់នៅហើយក្នុងគុណព្រះពុទ្ធ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះឈ្មោះថាជាសាវករបស់ព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកដោយប្រពៃ ។ សតិរបស់ជនទាំងឡាយឯណា បានដឹកល់ហើយក្នុងគុណព្រះធម៌ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថាជាសាវករបស់ព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកដោយប្រពៃ ។ សតិរបស់ជនទាំងឡាយឯណា បានដឹកល់ហើយក្នុងគុណព្រះសង្ឃ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថាជាសាវកនៃព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកហើយដោយប្រពៃ ។ សតិរបស់ជនទាំងឡាយឯណា បានដឹកល់ហើយក្នុងកាយ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថាជាសាវករបស់ព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកដោយប្រពៃ ។

## ធម្មបទេ ឯកវីសតិមោ បកិណ្ណកវគ្គោ

សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច    អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច    ភាវនាយ រតោ មនោ ។

វជ្ជីបុត្តកភិក្ខុវត្ថុ ៦

(៦) ទុប្បព្វជ្ជំ ទុរភិរមំ    ទុរាវាសា ឃរា ទុខា
ទុក្ខោ សមានសំវាសោ    ទុក្ខានុបតិតទ្ធគូ ។
តស្មា ន ចទ្ធគូ[១] សិយា    ន ច ទុក្ខានុបតិតោ សិយា ។

---

១ ម. តស្មា នចទ្ធគូ ន ច ។

បកិណ្ណកវគ្គទី ២១ ក្នុងព្រះធម្មបទ

ចិត្តរបស់ជនទាំងឡាយឯណា ត្រេកអរហើយក្នុងកិរិយាមិនបៀតបៀនគេទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថាជាសាវករបស់ព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកដោយប្រពៃ ។ ចិត្តរបស់ជនទាំងឡាយឯណា ត្រេកអរហើយក្នុងមេត្តាភាវនា ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះឈ្មោះថាជាសាវករបស់ព្រះពុទ្ធព្រះនាមគោតម ជាអ្នកភ្ញាក់រឭក ភ្ញាក់រឭកដោយប្រពៃ ។

*គាថាក្នុងរឿងវជ្ជីបុត្តកភិក្ខុ*

(៦) កិរិយាដែលបុគ្គលចេញបួសបានដោយកម្រ ការដែលជាអ្នកបួសត្រេកអរបានដោយកម្រ ផ្ទះទាំងឡាយបុគ្គលនៅគ្រប់គ្រងបានដោយកម្រ តែងនាំមកនូវទុក្ខ ការនៅរួបរួមនឹងជនស្មើគ្នាតែងនាំមកនូវទុក្ខ ជនអ្នកដើរផ្សងព្រាយទាំងឡាយសេចក្តីទុក្ខតែងអន្ទោលតាម ព្រោះហេតុនោះបុគ្គលកុំគប្បីដើរផ្សងព្រាយផង កុំគប្បីជាអ្នកគឺសេចក្តីទុក្ខអន្ទោលតាមផង ។

# ធម្មបទេ ឯកវីសតិមោ បកិណ្ណកវគ្គោ

## ចិត្តគហបតិវត្ថុគាថា

(៧) សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ
យំយំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

## ចូឡសុភទ្ទាវត្ថុគាថា

(៨) ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តិំ ខិត្តា[១] យថា សរា ។

## ឯកវិហារិត្ថេរវត្ថុគាថា

(៩) ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ
ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។

បកិណ្ណកវគ្គោ ឯកវីសតិមោ សមត្តោ

---

១ ម. រត្តិំ ខិតា យថា សរា ។

# បកិណ្ណកវគ្គទី ២១ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចិត្តគហបតី*

(៧) បុគ្គលអ្នកមានសទ្ធាបរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយសនឹងភោគ បើទៅគប់រកប្រទេសណាៗមនុស្សទាំងឡាយតែងបូជា (ដោយលាភសក្ការ) ក្នុងប្រទេសនោះ ៗ មិនខាន ។

*គាថាក្នុងរឿងចូឡសុភទ្ទា*

(៨) មនុស្សស្របប្បុរសទាំងឡាយទុកជាស្ថិតនៅក្នុងទីឆ្ងាយ ក៏គង់តែប្រាកដដូចជាភ្នំហិមពាន្តដែរ ឯមនុស្សអសប្បុរសទាំងឡាយទុកជាស្ថិតនៅក្នុងទីជិតព្រះពុទ្ធនេះ ក៏គង់តែមិនប្រាកដហាក់ដូចជាកូនសរ ដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

*គាថាក្នុងរឿងឯកវិហារិត្ថេរ*

(៩) បុគ្គលគួរគប់រកទីអង្គុយឯកឯង ទីដេកឯកឯង កាលដែលត្រេចទៅកុំឡើខ្ជិលច្រអូស បុគ្គលតែឯកឯងកាលបើទូន្មានខ្លួន គួរតែត្រេកអរក្នុងដងនៃព្រៃ ។

បកិណ្ណកវគ្គ ទី ២១ ចប់

# ធម្មបទេ ពាវីសតិមោ និរយវគ្គោ

សុន្ទរីបរិព្វាជិកាវត្ថុគាថា

(១) អភូតវាទី និរយំ ឧបេតិ
យោ វាបិ[១] កត្វា ន ករោមីតិ[២] ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថ ។

ទុក្ខបីឡិតវត្ថុគាថា

(២) កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា
បាបា បាបេហិ កម្មេហិ និរយំ តេ ឧបបជ្ជរេ ។

វគ្គុមុទាតីរិយភិក្ខុវត្ថុគាថា

(៣) សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។

---

១ ម. យោ ចាបិ ។ ២ ម. ករោមិ ចាហ ។

## និរយវគ្គទី ២២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសុន្ទរីបរិព្វាជិកា*

(១) បុគ្គលណាពោលពាក្យមិនពិតរមែងទៅកាន់នរក ១ ម្យ៉ាងទៀតបុគ្គលណាធ្វើបាបកម្មហើយពោលថា អាត្មាអញមិនធ្វើទេដូច្នេះ ១ បុគ្គលទាំងពីរពួកនេះឯងលុះទៅកាន់លោកខាងមុខ ទៅជាកំណើតមនុស្សមានធម៌ថោកទាប ស្មើគ្នាក្នុងលោកខាងមុខទៀត ។

*គាថាក្នុងរឿងទុក្ខបីឡិត*

(២) ជនទាំងឡាយឯណាមានកព៌ន្ធព៌ទ្ធហើយដោយសំពត់កាសាវច្រើន តែមានធម៌លាមកមិនបានសង្រួម ជនទាំងឡាយនោះឈ្មោះថាមានបាប ព្រោះកម្មដ៏លាមកទាំងឡាយរមែងចូលទៅកើតក្នុងនរកមិនខាន ។

*គាថាក្នុងរឿងវគ្គុមុទាតីរិយភិក្ខុ*

(៣) ភិក្ខុទ្រុស្តសីល បរិភោគដុំដែកដែលភ្លើងឆេះក្តៅឧបមាដូចជាអណ្តាតភ្លើងប្រសើរជាង ឯភិក្ខុទ្រុស្តសីលមិនមានសេចក្តីសង្រួម បរិភោគដុំបាយនៃជនអ្នកនៅក្នុងដែនមិនប្រសើរឡើយ ។

## ធម្មបទេ ពាវីសតិមោ និរយវគ្គោ

ខេមកសេដ្ឋិបុត្តវត្ថុគាថា

(៤) ចត្តារិ ឋានានិ នរោ បមត្តោ
អាបជ្ជតី បរទារូបសេវី
អបុញ្ញលាភំ ន និកាមសេយ្យំ
និន្ទំ តតិយំ និរយំ ចតុត្ថំ ។
អបុញ្ញលាភោ ច គតី ច បាបិកា
ភីតស្ស ភីតាយ រតី ច ថោកិកា
រាជា ច ទណ្ឌំ គរុកំ បណេតិ
តស្មា នរោ បរទារំ ន សេវេ ។

ទុព្វចភិក្ខុវត្ថុគាថា

(៥) កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។

## និរយវគ្គ ទី ២២ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងខេមកសេដ្ឋីបុត្ត*

(៤) ជនដែលមានសេចក្តីប្រមាទទៅសេពប្រពន្ធរបស់បុគ្គលដទៃជាប្រក្រតី រមែងដល់នូវហេតុនៃសេចក្តីទុក្ខ៤យ៉ាងគឺ បានបំណែកមិនមែនជាបុណ្យទី ១ មិនបានដេកលក់តាមសេចក្តីប្រាថ្នាទី២ សេចក្តីនិន្ទាទី ៣ ធ្លាក់នរកទី៤ (មិនតែប៉ុណ្ណោះសោតនឹងបាន) នូវហេតុនៃសេចក្តីទុក្ខ៤យ៉ាងដទៃទៀត គឺបានបំណែកមិនមែនជាបុណ្យ ១ មានគតិដ៏លាមក ១ ខ្លួនជាអ្នកខ្លាចទៅត្រេកត្រអាលនឹងស្ត្រីដែលខ្លាចដែរ ជាសេចក្តីត្រេកអរមានប្រមាណតិច១ ព្រះរាជានឹងដាក់ពិន័យយ៉ាងធ្ងន់១ ព្រោះហេតុនោះជនកុំគប្បីសេពនូវប្រពន្ធរបស់បុគ្គលដទៃឡើយ ។

*គាថាក្នុងរឿងទុព្វចភិក្ខុ*

(៥) ស្បូវភ្លាំងបើបុគ្គលចាប់កាន់មិនល្អហើយ រមែងលះឬមុតដៃយ៉ាងណាមិញ ឯសមណធម៌ បើបុគ្គលចាប់ពាល់គឺជាប្រតិបត្តិមិនល្អហើយ រមែងទង់ទាញបុគ្គលនោះឲ្យចូលទៅកាន់នរកយ៉ាងនោះឯង ។

យំកិញ្ចិ សិថិលំ កម្មំ សំកិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។

កយិរា[១] ចេ កយិរាថេនំ ទឡ្ហមេន បរក្កមេ
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។

៩. ឥស្សាបកតឥត្ថីវត្ថុគាថា

(៦) អកតំ ទុក្កដំ សេយ្យោ បច្ឆា តប្បតិ ទុក្កដំ
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។

---

១ កយិរញ្ចេ កយិរថេនន្តិបិ បាឋោ ។

## និរយវគ្គទី ២២ ក្នុងព្រះធម្មបទ

កម្មឯណានីមួយដែលធ្ងន់ក្តី កម្មឯណានីមួយដែលសៅហ្មងល្អក់ក្តី ព្រហ្មចរិយធម៌ឯណានីមួយ ដែលបុគ្គលរលឹកឃើញហើយដោយសេចក្តីរង្កៀសក្តី កម្ម (ទាំង ៣ យ៉ាង) នោះមិនមែនជារបស់មានផលច្រើនឡើយ បុគ្គលបើធ្វើនូវកម្មឯណា គប្បីធ្វើតែកម្មនោះ គប្បីព្យាយាមប្រឹងប្រែងនូវកម្មនោះឲ្យមាំមួន ព្រោះថាសមណធម៌ជាគ្រឿងដេញដោលកិលេសដែលធូរពេកនោះ រមែងរោយរាយនូវធូលីមានរាគៈជាដើមដោយក្រៃលែង (មកលើបុគ្គលនោះ) ។

*គាថាក្នុងរឿងឥស្សាបកតត្ថិ*

(៦) អំពើអាក្រក់ដែលបុគ្គលមិនបានធ្វើហើយ ប្រសើរវិសេសណាស់ (ព្រោះថា) អំពើអាក្រក់តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ឯអំពើល្អដែលបុគ្គលធ្វើហើយឈ្មោះថាប្រសើរវិសេស (ព្រោះថា) បុគ្គលធ្វើកម្មឯណាហើយមិនបានតាមដុតកំដៅក្នុងកាលជាខាងក្រោយ កម្មនោះឯងឈ្មោះថាប្រសើរ ។

# ធម្មបទេ ពាវីសតិមោ និរយវគ្គោ

### សម្ពហុលភិក្ខុវត្ថុគាថា

(៧) នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា ។
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

### និគណ្ឋវត្ថុគាថា

(៨) អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

# និរយវគ្គទី ២២ ក្នុងព្រះធម្មបទ

*គាថាគ្មានរឿងសម្ពហុលភិក្ខុ*

(៣) នគរដែលនៅក្នុងទីបំផុតនៃដែន គឺមនុស្សទាំងឡាយគ្រប់គ្រងរក្សាហើយទាំងខាងក្នុងខាងក្រៅយ៉ាងណា អ្នកទាំងឡាយចូរគ្រប់គ្រងរក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយតែកន្លងនូវខណៈហើយ ទៀងតែទៅសោយសោកក្នុងនរកពេញបន្ទុក ។

*គាថាគ្មានរឿងនិគន្ថ*

(៤) សត្វទាំងឡាយឯណាប្រកាន់នូវមិច្ឆាទិដ្ឋិ ខ្មាសក្នុងហេតុដែលមិនគួរខ្មាស មិនខ្មាសក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងឡាយនោះរមែងទៅកាន់ទុគ្គតិ សត្វទាំងឡាយឯណាប្រកាន់នូវមិច្ឆាទិដ្ឋិ មានកិរិយាឃើញនូវហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុត្រូវខ្លាចជាប្រក្រតីផង មានកិរិយាឃើញនូវហេតុដែលគេត្រូវខ្លាច ថាជាហេតុមិនត្រូវខ្លាចជាប្រក្រតីផង សត្វទាំងឡាយនោះតែងទៅកាន់ទុគ្គតិ ។

# ធម្មបទេ តេវីសតិមោ នាគវគ្គោ

តិត្ថិយសាវកវត្ថុគាថា

(៩) អវជ្ជេ វជ្ជមតិនោ វជ្ជេ(១) អវជ្ជទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ
សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគតឹ ។

និរយវគ្គោ ពាវីសតិមោ សមត្តោ

អត្តនោវត្ថុគាថា

(១) អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យំ តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។

---

១ ម. វជ្ជេ ចាវជ្ជទស្សិនោ ។

# នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងតិត្ថិយសាវក*

(៩) សត្វទាំងឡាយឯណាប្រកាន់នូវមិច្ឆាទិដ្ឋិ ជាអ្នកដឹងថាមានទោសក្នុងរបស់ដែលមានទោស យល់ឃើញថាគ្មានទោសក្នុងរបស់ដែលមានទោស សត្វទាំងឡាយនោះតែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយឯណាប្រកាន់នូវសម្មាទិដ្ឋិ ដឹងនូវរបស់មានទោសថាជារបស់មានទោសផង ដឹងនូវរបស់មិនមានទោសថាជារបស់មិនមានទោសផង សត្វទាំងឡាយនោះតែងទៅកាន់សុគតិ ។

**និរយវគ្គទី ២២ ចប់**

*គាថាក្នុងរឿងអត្តនោ*

(១) តថាគតនឹងទ្រាំអត់ពាក្យពោលកន្លង ដូចជាដំរីដ៏ប្រសើរ ដែលទ្រាំអត់នឹងកូនសរដែលធ្លាក់ចុះអំពីខ្សែបនោះក្នុងសង្គ្រាម ព្រោះជនច្រើនតែងទ្រុស្តសីល ។

## ធម្មបទេ តេវីសតិមោ នាគវគ្គោ

ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ

ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។

វរមស្សតរា ទន្តា អាជានិយា ច សិន្ធវា

កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

ហត្ថាចារិយបុព្វកត្ថេរគាថា

(២) ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ

យថត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។

## នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

ជនទាំងឡាយតែងនាំនូវពាហនៈដែលខ្លួនហ្វឹកហ្វឺនហើយ ទៅកាន់ទីប្រជុំ ឯព្រះរាជាក៏តែងឡើងគង់លើពាហនៈដែលបុគ្គលទូន្មានហើយតែម្តង ជនឯណាអត់សង្កត់នូវពាក្យពោលកន្លងក្នុងពួកនៃមនុស្សទាំងឡាយបាន ជននោះឈ្មោះថាមានខ្លួនទូន្មានហើយតែងប្រសើរបំផុត ។

សេះអស្សតរទាំងឡាយក្តី សេះអាជន័យទាំងឡាយក្តី សេះសន្ធពទាំងឡាយក្តី ដំរីដ៏ប្រសើរទាំងឡាយដែលឈ្មោះថាកុញ្ជរក្តី ដែលបុគ្គលប្រៀនប្រដៅបានហើយក៏ឈ្មោះថាប្រសើរដែរ តែថាបុគ្គលដែលមានខ្លួនទូន្មានហើយ ប្រសើរបំផុតជាងពាហនៈទាំងឡាយមានសេះអស្សតរជាដើមនោះឯង ។

*គាថាក្នុងរឿងហត្ថាចារិយបុព្វកៈ*

(២) បុគ្គលមានខ្លួនទូន្មានឈ្មោះថាមានខ្លួនទូន្មានដោយល្អហើយ គប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះនិព្វានយ៉ាងណា បុគ្គលគប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះនិព្វាន ដោយយានទាំងឡាយមានយានដំរីជាដើមនេះ យ៉ាងនោះគ្មានឡើយ ។

## ធម្មបទេ តេវីសតិមោ នាគវគ្គោ

បរិជិណ្ណព្រាហ្មណបុត្តវត្ថុគាថា

(៣) ធនបាលកោ នាម កុញ្ជរោ
កដុកប្បភេទនោ ទុន្និវារយោ
ពទ្ធោ កពឡំ ន ភុញ្ជតិ
សុមរតិ នាគវនស្ស កុញ្ជរោ ។

បសេនទិកោសលវត្ថុគាថា

(៤) មិទ្ធី យទា ហោតិ មហគ្ឃសោ ច
និទ្ទាយិតា សម្បរិវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

## នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបរិជិណ្ណព្រាហ្មណ៍*

(៣) ដំរីឈ្មោះធនបាលបើបុះប្រេងក្លៀវក្លាហើយ នាយហត្ថាចារ្យក្រមិនឹងឃាត់បានឡើយ បើនាយហត្ថាចារ្យចងហើយ ក៏មិនបរិភោគនូវចាប់ស្មៅឡើយ ព្រោះរឭកដល់ព្រៃនាគវន (ព្រៃដំរី) ។

*គាថាក្នុងរឿងបសេនទិកោសល*

(៤) ជនណាជាអ្នកមានសេចក្ដីងោកងុយផង ជាអ្នកបរិភោគភោជនមានប្រមាណច្រើនផង ជាអ្នកដេកហើយបំរះនទៀលផង ដូចជាជ្រូកស្រុកដែលបុគ្គលចិញ្ចឹមដោយស្លូករភត្តក្នុងកាលឯណា ជននោះឈ្មោះថាមានបញ្ញាខ្លៅ តែងចូលទៅកាន់បន្ទប់រឿយ ៗ ក្នុងកាលនោះ ។

# ធម្មបទេ តេវីសតិមោ នាគវគ្គោ

សានុសាមណេរវត្ថុ គាថា

(៥) ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ
ហត្ថឹ បភិន្នមិវ អង្កុសគ្គហោ ។

បាវេយ្យកហត្ថិវត្ថុ គាថា

(៦) អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

# នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសានុសាមណេរ*

(៥) (បុគ្គលគួរសង្កត់សង្កិនចិត្តដោយគិតថា) ក្នុងកាលមុន ចិត្តនេះត្រេចទៅកាន់ចារិកតាមអាការៈដែលខ្លួនប្រាថ្នាគួរដល់សេចក្ដីសប្បាយ ក៏ក្នុងថ្ងៃនេះអាត្មាអញនឹងសង្កត់សង្កិនចិត្តនោះដោយឧបាយប្រាជ្ញា ឲ្យដូចជាហ្មដំរីកាន់យកកង្វេរសង្កត់សង្កិនដំរីបុះប្រេង ។

*គាថាក្នុងរឿងបាវេយកហត្ថិ*

(៦) អ្នកទាំងឡាយចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួនឲ្យល្អ ចូរស្រង់ខ្លួនចេញចាកផ្លុក ដែលឆ្លងបានដោយកម្រគឺកិលេស ឲ្យដូចជាដំរីដែលជាប់នៅក្នុងផ្លុក ហើយស្រង់ខ្លួនឡើងបាន ។

# ធម្មបទេ តេវីសតិមោ នាគវគ្គោ

សម្ពហុលភិក្ខុវត្ថុគាថា

(៧) សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

## នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសម្ពហុលភិក្ខុ*

(៧) បុគ្គលបើបានសំឡាញ់ឯណាដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានចិត្តខ្ជាប់ខ្ជួនជាអ្នកនៅដោយគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចត្រេចទៅជាមួយផងបានគ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួង មានចិត្តរីករាយមានស្មារតីដ៏មាំមួន គួរត្រេចទៅជាមួយនឹងសំឡាញ់នោះឯង ។

ថាបើបុគ្គលមិនបានសំឡាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានចិត្តខ្ជាប់ខ្ជួន ជាអ្នកនៅដោយគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចត្រេចទៅជាមួយផងទេ គួរត្រេចទៅតែឯកឯងវិញ ដូចជាព្រះរាជាដែលលះបង់នូវដែនដែលព្រះអង្គឈ្នះហើយ ហើយព្រះអង្គត្រេចទៅតែឯកឯង ពុំនោះសោតដូចជាដំរីដ៏ប្រសើរបោះបង់នូវហ្វូង ហើយត្រេចទៅតែឯកឯងក្នុងព្រៃ ។

ធម្មបទេ តេវីសតិមោ នាគវគ្គោ

ឯកស្ស ចរិតំ សេយ្យោ
នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

មារវត្ថុគាថា

(៨) អត្ថម្ហិ ជាតម្ហិ សុខា សហាយា
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

## នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

ឯការត្រេចទៅរបស់បុគ្គលឯកឯងឈ្មោះថាជាគុណដ៏ប្រសើរណាស់ ព្រោះថាគុណធម៌ជាសំឡាញ់មិនមានបំពោះជនពាលឡើយ តែថាបុគ្គលដែលត្រេចទៅឯកឯងនោះ មិនត្រូវធ្វើអំពើបាបទាំងឡាយឡើយ មានសេចក្ដីខ្វល់ខ្វាយតិច ដូចជាដំរីដ៏ប្រសើរជាសត្វមានខ្វល់ខ្វាយតិច បោះបង់នូវហ្វូងហើយត្រេចទៅតែឯកឯងក្នុងព្រៃដូច្នោះ ។

### គាថាក្ទនរៀនមារ

(៨) សំឡាញ់ទាំងឡាយជាគុណនាំមកនូវសេចក្ដីសុខក្នុងខណៈដែលមានប្រយោជន៍ (កិច្ច) កើតឡើងហើយ សេចក្ដីត្រេកអរដោយវត្ថុតាមមានតាមបានជាហេតុនាំមកនូវសេចក្ដីសុខ បុណ្យជាគុណជាតនាំមកនូវសេចក្ដីសុខក្នុងកាលជាទីក្ស័យជីវិត ការលះបង់នូវសេចក្ដីទុក្ខទាំងអស់ជាហេតុនាំមកនូវសេចក្ដីសុខ ។

## ធម្មបទេ តេវីសតិមោ នាគវគ្គោ

សុខា មេត្តេយ្យតា លោកេ
អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ
អថោ ព្រហ្មញ្ញតា សុខា ។
សុខំ យាវ ជរា សីលំ
សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញា បតិលាភោ
បាបានំ អករណំ សុខំ ។

នាគវគ្គោ តេវីសតិមោ សមត្តោ

# នាគវគ្គទី ២៣ ក្នុងព្រះធម្មបទ

ភាវៈនៃបុគ្គលអ្នកប្រតិបត្តិល្អក្នុងមាតា ជាគុណនាំមកនូវសេចក្ដីសុខ ឯភាវៈនៃបុគ្គលអ្នកប្រតិបត្តិល្អក្នុងបិតា ជាគុណនាំមកនូវសេចក្ដីសុខក្នុងលោកនេះដែរ ភាវៈនៃបុគ្គលអ្នកប្រតិបត្តិល្អក្នុងសមណ ជាគុណនាំមកនូវសេចក្ដីសុខក្នុងលោក ឯភាវៈនៃបុគ្គលប្រតិបត្តិល្អក្នុងព្រហ្មគឺមនុស្សអ្នកមានបាបបន្សាត់បង់ហើយមានព្រះពុទ្ធជាដើម ជាគុណនាំមកនូវសេចក្ដីសុខក្នុងលោកនេះដែរ ។

សីលជាគុណជាតនាំមកនូវសេចក្ដីសុខដរាបដល់ចាស់ សទ្ធាដែលបុគ្គលដំកល់ខ្ជាប់ហើយ ជាគុណជាតនាំមកនូវសេចក្ដីសុខ ការបានបំពោះនូវបុណ្យ ជាគុណនាំមកនូវសេចក្ដីសុខ ការមិនធ្វើអំពើបាបទាំងឡាយ ជាគុណនាំមកនូវសេចក្ដីសុខ (គ្រប់ប្រការ) ។

នាគវគ្គទី ២៣ ចប់

# ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

## កបិលមច្ឆវត្ថុគាថា

(១) មនុជស្ស បមត្តចារិនោ  តណ្ហា វឌ្ឍតិ មាលុវាវិយ
សោ បរិប្លវតិ ហុរាហុរំ  ផលមិច្ឆំវ វនស្មិំ វានរោ ។
យំ ឯសា សហតេ ជម្មី  តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ  អភិវុឌ្ឋំវ វីរណំ[១] ។
យោ ចេ តំ សហតេ ជម្មិំ  តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ  ឧទពិន្ទុវ បោក្ខរា ។

---

១ ពីរណន្តិបិ បាឋោ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកបិលមច្ឆ*

(១) តណ្ហាតែងតែបំរើនដល់បុគ្គលអ្នកមានកិរិយាប្រព្រឹត្ត ដោយសេចក្តីប្រមាទជាប្រក្រតី ដូចជាព្ធរនៃផ្ទៃក្រាលរួបរឹតនូវដើមឈើ ឯបុគ្គលអ្នកប្រព្រឹត្តក្នុងអំណាចតណ្ហានោះឯងតែងតែស្ទុះទៅកាន់ភពតូចភពធំ ដូចគ្នានឹងសត្វស្វាកាលប្រាថ្នាផ្លែឈើ ហើយលោតទៅក្នុងព្រៃ ។ តណ្ហានេះលាមកអាក្រក់ (ណាស់) ប្រកបដោយកិរិយាជាប់ជំពាក់នៅក្នុងអារម្មណ៍ផ្សេងៗក្នុងលោក បើគ្របសង្កត់បុគ្គលណាហើយ សេចក្តីសោកស្តាយទាំងឡាយតែងបំរើនឡើងដល់បុគ្គលនោះ ដូចជាស្បូវអណ្តាតដែលត្រូវភ្លៀងធ្លាក់ចុះហើយរឿយៗ ។ លុះតែបុគ្គលឯណាគ្របសង្កត់នូវតណ្ហាដ៏លាមកអាក្រក់ ដែលគេឆ្លងបានដោយកម្រនេះបាន ទើបសេចក្តីសោកស្រណោះទាំងឡាយធ្លាក់ចេញចាកជននោះឯង ដូចគ្នានឹងដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក

ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសិរត្ថោវ វីរណំ[១] ។
មា វោ នលំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

សូករបោតិកាវត្ថុគាថា

(២) យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

១ ពីរណន្តិបិ បាឋោ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

ព្រោះហេតុនោះបានជាតថាគតប្រាប់ដល់អ្នកទាំងឡាយ ៗ មានប៉ុន្មានរូបដែលប្រជុំក្នុងទីនេះ សេចក្ដីចំរើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះរូបចុះ ។

អ្នកទាំងឡាយចូរជីករម្លើងឫសគល់នៃតណ្ហាចោលចេញឲ្យដូចជាបុគ្គលដែលត្រូវការដោយស្បូវភ្លាំងហើយ ជីកជំរះស្បូវអណ្ដាសចោលចេញ មារកុំបំបាក់បង់នូវអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹកកាលបំបាក់បង់នូវដើមបបុសដូច្នោះឡើយ ។

*គាថាក្នុងរឿងសូករបោតិកា*

(២) កាលបើឫសគល់ឈើ គ្មានសេចក្ដីអន្ដរាយចូលទៅជិតបៀតបៀននៅមាំមួននៅឡើយទេ ដើមឈើបើទុកជាគេកាប់ចោលហើយក៏គង់តែដុះឡើងវិញមិនខាន មានឧបមាដូចម្ដេចមិញ កាលបើអនុស័យគឺតណ្ហាដែលបុគ្គលមិនបានផ្ដាច់បង់ទេ សេចក្ដីទុក្ខនេះក៏តែងតែកើតឡើងរឿយ ៗ មានឧបម័យដូច្នោះឯង ។

ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

យស្ស ឆត្តឹសតិ សោតា មនាបស្សវនា ភុសា

មហោវហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។

សវន្តិ សព្វធិ សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ

តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច សោមនស្សានិ ភវន្តិ ជន្តុនោ

តេ សាតសិតា សុខេសិនោ តេ វេ ជាតិជរូបគា នរា ។

តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

បុគ្គលណាមានខ្សែតណ្ហា ៣៦ ដ៏ក្លៀវក្លា តែងតែហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្តហើយ ដម្រិះទាំងឡាយដ៏ធំដែលអាស្រ័យនូវរាគៈ តែងតែនាំបុគ្គលនោះទៅកាន់ទិដ្ឋិអាក្រក់មិនខាន ។ ខ្សែនៃតណ្ហាទាំងឡាយតែងតែហូរទៅក្នុងអារម្មណ៍ទាំងពួង តណ្ហានេះដូចជាវល្លិ៍តែងកើតឡើងហើយស្ថិតនៅក្នុងអារម្មណ៍មានរូបជាដើម ក៏អ្នកទាំងឡាយបើឃើញតណ្ហាដូចជាវល្លិ៍កើតឡើងហើយ ចូរកាត់ឬសចោលចេញដោយកាំបិតគឺបញ្ញា ។ សេចក្ដីរីករាយទាំងឡាយដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ។

ជនទាំងឡាយឯណាជាអ្នកអាស្រ័យហើយនូវសេចក្ដីរីករាយ ជាអ្នកស្វែងរកសេចក្ដីសុខ ជនទាំងឡាយនោះឯងតែងចូលទៅជិតកាន់ជាតិនិងជរា ។ ពួកសត្វទាំងឡាយឯណាដែលតណ្ហាជាគ្រឿងធ្វើនូវសេចក្ដីតក់ស្លុតព័ទ្ធព័ទ្ធហើយ តែងតក់ស្លុតញាប់ញ័រ ដូចជាសត្វទន្សាយដែលព្រានព្រៃទាក់ហើយ

សំយោជនសង្គសត្តា ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។

តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ

តស្មា តសិណំ វិនោទយេ ភិក្ខុ អាកង្ខំ វិរាគមត្តនោ ។

វិព្ភន្តកភិក្ខុវត្ថុ

(៣) យោ និព្វនថោ វនាធិមុត្តោ វនមុត្តោ វនមេវ ធាវតិ

តំ បុគ្គលមេវ បស្សថ មុត្តោ ពន្ធនមេវ ធាវតិ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

សត្វដែលជាប់នៅដោយសំយោជនទាំងឡាយ តែងដល់នូវសេចក្ដីទុក្ខជារឿយៗអស់កាលយូរ ។ ពពួកសត្វទាំងឡាយដែលតណ្ហាជាគ្រឿងធ្វើនូវសេចក្ដីតក់ស្លុតព័ទ្ធព័ទ្ធហើយ តែងតក់ស្លុតញាប់ញ័រ ដូចជាសត្វទន្សាយដែលព្រានព្រៃទាក់ហើយ ព្រោះហេតុនោះភិក្ខុកាលប្រាថ្នានូវព្រះនិព្វានទីសម្រាន់ដើម្បីខ្លួន គប្បីបន្ទោបង់នូវតណ្ហាជាគ្រឿងធ្វើសេចក្ដីតក់ស្លុតបោលបេញ ។

*គាថាក្នុងរឿងវិព្ភន្តិកភិក្ខុ*

(៣) បុគ្គលណាករព្រៃគឺសេចក្ដីអាល័យក្នុងគិហិ-ភាពគ្មាន ជាអ្នកមានចិត្តបង្អោនទៅចំពោះព្រៃគឺតបធម៌ហើយ ជាអ្នកផុតចាកព្រៃគឺសេចក្ដីបំណង់ក្នុងឃរាវាសហើយ អ្នកចូរមើលបុគ្គលនោះរួចចាកព្រៃហើយ ត្រឡប់ជាស្ទុះទៅរកបំណងរបស់ឃរាវាសវិញ ។

## ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

ពន្ធនាគារវត្ថុ ៨

(៤) ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា

យទាយសំ ទារុជបព្វជញ្ច

សារត្តរត្តា មណិកុណ្ឌលេសុ

បុត្តេសុ ទារេសុ ច យា អបេក្ខា ។

ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា

ឱហារិនំ សិថិលំ ទុប្បមុញ្ចំ

ឯតំបិ ឆេត្វាន បរិព្វជន្តិ

អនបេក្ខិនោ កាមសុខំ បហាយ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងពន្ធនាគារ*

(៤) បំណងណាដែលធ្វើកើតពីដែកក្តី ដែលធ្វើកើតពីឈើនិងស្មៅបាប្លងក្តី អ្នកប្រាជ្ញទាំងឡាយពោលថាបំណងនោះជាបំណងមាំក៏ទេ ជនទាំងឡាយឯណាប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីត្រេកអរក្រៃពេក ក្នុងកុណ្ឌលជាវិការនៃកែវមណីទាំងឡាយក្តី សេចក្តីអាលោះអាល័យឯណាក្នុងកូននិងប្រពន្ធទាំងឡាយក្តី ។ អ្នកប្រាជ្ញទាំងឡាយពោលថាសេចក្តីត្រេកអរនិងសេចក្តីអាលោះអាល័យនោះ ៗ ជាបំណងមាំ (ណាស់) ជាគ្រឿងទង់ទាញសត្វឲ្យធ្លាក់ចុះទៅក្នុងអបាយ (បំណងនេះ) ធូរ ៗ ទេ ប៉ុន្តែគឺបុគ្គលស្រាយកាត់បានដោយកម្រ (ក្រៃពេក) ។

# ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

ខេមាថេរីវត្ថុ គាថា

(៥) យេ រាគរត្តានុបតន្តិ សោតំ
សយំ កតំ មកដកោវ ជាលំ
ឯតម្បិ ឆេត្វាន វជន្តិ ធីរា
អនបេក្ខិនោ សព្វទុក្ខំ បហាយ ។

ឧគ្គសេនវត្ថុ គាថា

(៦) មុញ្ច បុរេ មុញ្ច បច្ឆតោ មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ ន បុន ជាតិជរំ ឧបេហិសិ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងខេមាថេរី*

(៥) ជនទាំងឡាយឯណាត្រេកអរហើយដោយអំណាចនៃរាគៈ តែងធ្លាក់ចុះរឿយៗ កាន់ខ្សែនៃតណ្ហាដែលខ្លួនធ្វើហើយដោយខ្លួនឯង (ជនទាំងឡាយនោះមិនអាចដើម្បីឆ្លងនូវខ្សែតណ្ហានោះឡើយ) ដូចគ្នានឹងសត្វពីងពាងដែលធ្វើសំណាញ់ គឺសម្បុកអំពីសរសៃហើយដេកចាំត្រង់ទីពាក់កណ្ដាល (ផ្ចិតសម្បុក) បំណែកឯអ្នកប្រាជ្ញទាំងឡាយ រមែងកាត់បំណងនោះចោល មិនមានអាឡោះអាល័យ លះបង់ទុក្ខទាំងពួងចោលជាស្រឡះ។

*គាថាក្នុងរឿងឧគ្គសេន*

(៦) អ្នកឯងចូរលែងអាល័យក្នុងខន្ធ ដែលកន្លងទៅហើយ ចូរលែងអាល័យក្នុងខន្ធដែលមិនទាន់មានមកក្នុងខាងក្រោយ ចូរលែងអាល័យក្នុងខន្ធដែលមានក្នុងបច្ចុប្បន្ន (នេះ) ចូរជាបុគ្គលដល់ហើយនូវត្រើយនៃភព បើអ្នកឯងមានចិត្តរួចស្រឡះចាកខន្ធទាំងពួងហើយ គង់នឹងមិនចូលទៅកាន់ជាតិនឹងជរាទៀតឡើយ ។

## ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

### ចូឡធនុគ្គហបណ្ឌិតវត្ថុគាថា

(៧) វិតក្កមថិតស្ស ជន្តុនោ តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។
វិតក្កូបសមេ ច យោ រតោ អសុភំ ភាវយតី សទា សតោ
ឯស ខោ ព្យន្តិ កាហតិ ឯស ឆេច្ឆតិ មារពន្ធនំ ។

### មារវត្ថុគាថា

(៨) និដ្ឋង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងចូឡធនុគ្គហបណ្ឌិត*

(៧) តណ្ហាគឺសេចក្ដីបំណង រមែងចំរើនដោយក្រៃលែង ដល់បុគ្គលណា ដែលមានកាមវិតក្កញាំញី មានរាគដ៏ក្រាស់ក្រៃក្លា មានកិរិយាឃើញរឿយ ៗ នូវអារម្មណ៍ថាល្អស្អាតជាប្រក្រតី បុគ្គលនោះឯងឈ្មោះថាធ្វើបំណងគឺតណ្ហាឲ្យមាំមួន ៗ លុះតែបុគ្គលណាត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់នូវកាមវិតក្កមានសតិដំកល់ខ្ជាប់សព្វកាល តែងចំរើននូវអសុភជ្ឈាននោះ បុគ្គលនោះឯងទើបឈ្មោះថាធ្វើតណ្ហាដែលជាហេតុនាំឲ្យកើតក្នុងភពទាំងបីនោះឲ្យសូន្យទៅ បុគ្គលនោះឯងទើបឈ្មោះថាកាត់នូវបំណងនៃមារបាន ។

*គាថាក្នុងរឿងមារ*

(៨) បុគ្គលឯណាដល់ហើយនូវព្រះអរហត្តជាគ្រឿងសម្រេច ជាអ្នកមិនតក់ស្លុត មានតណ្ហាទៅប្រាសហើយ រកកិលេសដូចជាទីទួលគ្មាន បានកាត់ហើយនូវព្រួញគឺកិលេសជាហេតុឲ្យកើតក្នុងភពទាំងពួង រាងកាយរបស់បុគ្គលនោះឈ្មោះថា តាំងនៅក្នុងទីបំផុត (បច្ឆិមភព) ។

## ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ

អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច ។

ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ។

ឧបកាជីវកវត្ថុគាថា

(៩) សព្វាភិភូ សព្វវិទូហមស្មិ

សព្វេសុ ធម្មេសុ អនូបលិត្តោ

សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ

សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

## តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

មួយទៀតបុគ្គលឯណាមានតណ្ហាទៅប្រាសហើយ មិនបានប្រកាន់មាំក្នុងសភាវមានខន្ធជាដើម ជាអ្នកឆ្លាសក្នុងនិរុត្តិនឹងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើមនឹងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯងជាអ្នកមានសរីរស្ថិតនៅក្នុងទីបំផុត ជាអ្នកមានបញ្ញាច្រើន តថាគតឲ្យឈ្មោះថាមហាបុរស ។

*គាថាក្នុងរឿងឧបកាជីវក*

(៩) តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ដឹងច្បាស់នូវចតុភូមិកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅក្នុងតេភូមិកធម៌ទាំងពួងឡើយ លះបង់នូវចតុភូមិកធម៌ទាំងពួងអស់ហើយ មានចិត្តផុតស្រឡះហើយក្នុងហេតុជាគ្រឿងអស់ទៅនៃតណ្ហា (បើតថាគត) ត្រាស់ដឹងធម៌ដោយព្រះអង្គឯងហើយចាំបាច់សំដែងឡើងនូវអ្នកណាថាជាគ្រូជាអាចារ្យទៀត ។

# លោកន័យ

(គ)

នេះបទព្រហ្មគិត យើងថ្លែងពិតពីទំនង ពោធិសត្វ ប្រាស់ប្រាង ស្ដេចបាទឆ្នាំប្រាំបួនណា ។ មានកាលគាប់១ថ្ងៃ មហាក្សត្រថ្លៃសោយក្រយា- ស្ងោយជួនអស់អង្គអា- ចារ្យឡើង គាល់ព្រះមហាក្សត្រ ។ ស្ដេចបើកបន្ទូលថា អ្វីពីសាពន់ពេក ក្លាត់ ប្ដូរអាចារ្យបួនកាត់ ឆ្លើយដោយគួរកុំលង់ឡើយ ។ ឯសុន្ទរាល័យ ទូលក្សត្រថ្លៃថាម្ចាស់សើយ សាប់ថ្មីនោះឯង ហើយ មានរសលើសលែងដទៃ ។ ឥន្ទារម្មណ៍ទូលថា បពិត្រ មហាក្សត្រប្រើងក្រៃ បង្អែមទាំង៤នៃ មានរសក្រៃលែងនានា ។ រីអភ័យបណ្ឌិត ថាបពិត្រមហាក្សត្រា អាហារទើបទំថា សម មានរសពន់ពេកក្រៃ ។ ទើបអាចារ្យទាំង៣ ក៏ះពោធិសត្វថា ហៃ ឯអ្នកឯងសោតនៃ ថាអ្វីមានរសពីសា ។ ឯពង្សពោធិ សត្វ បុរសរ័តន៍ថ្លៃសោភា អ្នកសើចពុំបរបា អ្នកសម្ងំស្ងៀម នៅនិត ។ ស្ដេចបន្ទូលថាហៃ ហៅធនញ្ជ័យរាជបណ្ឌិត រីក្នុង ចិត្តហៅគិត យល់ដូចម្ដេចប្រាប់បរបា ។ ទើបព្រះពង្សពោធិ ទូល ថារីសពីសា អាក្រក់ល្អក្ដីណា លោកពុំរាប់ឡើយក្សត្រថ្លៃ ។

រាប់តែកាលណាឃ្លាន ចាប់បានមកហើយនៃ បរិភោគចូល ពេកក្រៃ លោកទុកជាពិសាពិត ។ រីឯអ្នកទាំងបី គេស្រដី ដោយគំនិត ដំណឹងអ្នកពាលពិត ទើបអ្នកសូត្រជាគាថា ។ វាចាសប្បុរិ រសោស ពាក្យសត្បុរស នោះជារសពិសា មនុស្ស សត្វផងសឹងអាស្រ័យ ។ វាទិតសរោ សុរសោសំឡេងនៃ ជាតិជារសប្រពៃ បម្រៀងប៉ីខ្លុយទាំងឡាយ ។ ភិរយរសា សោត្តាលារស្សូរសាយ ស្រឡៃលេងឮឆ្ងាយ នោះជារសតូរ្យ-តន្ត្រី ។ ធនុសង្គាម សរស ធ្នូសរជ័យ ជារសពិសានៃ កាលចំបាំងដោយបំពោះ ។ កាមារយោពតិ សរសំ រីប្រុសខ្លះ នឹងស្រីក្រមុំនោះ ជារសសុខឯតណ្ហា ។ ឆាតាអាហារ សោរសរសពិសា កាលឃ្លានបានភោក្តា លោករាប់ជាពិសា ក្រៃ ។ វិនិច្ឆយរស្សូ កិរិ សោនោះនៃ ពិចារណាប្រពៃ ជារសនៃអ្នកប្រាជ្ញប្រាយ ។ ធម្មោបុរសោ គឺលោកថា ធម៌ទាំងឡាយ ព្រះទេស្នាប្រាប់ប្រាយ នោះជារសភព ៣ ណា ។ រីអ្នកមានប្រាជ្ញា គឺបារណា គួរគេប្បី ឲ្យស្គាល់ ន្សូរសពី- សាទាំងនេះយកទុកប្រាណ ។ ១ គឺព្រះឧបមា

មានព្រឹក្សពុលសាម៉ាត្ស ពីឫសដល់ត្រួយមាន ផ្លែគេស៊ី ពុំរស់ឡើយ ។ សង្សារព្រះទុកជា ដើមព្រឹក្សពិសពិត ត្រើយ រីឯពាក្យបំឡើយ រសពាក្យស័ត្យនោះទុកជា ។ ផ្លែ ផ្កានោះមគ្គផល បើបុគ្គលសទ្ធា នឹងអ្នកមានប្រាជ្ញា នោះ ប្រសើរបរលោកនាយ ។ ស្ដេចស្ដាប់ពាក្យព្រះពោ- ធិរាជទូល ប្រៀបប្រាយ ត្រាស់ថាអ្នកទាំងឡាយ ទាំង ៣ នាក់ឆ្លើយដូច ម្ដេច ។ អ្នកទាំងបីប្រណម្យ ថ្វាយបង្គំធ្មេចប៉ប្រិច ភ្នែកស្ងៀម ពុំដឹងកិច្ច ក៏នឹងទូលប្ដាទរាជា ។ រាបព្រាហ្មា និង្គតោរស ពីសា សុំអេបអស់ម៉្លេះណា យើងថ្លាថ្លែងកាល ១ ថ្ងៃ ។ ស្ដេច បើកព្រះកេរិតា អស់គេនាគាល់ក្រាស់ក្រៃ ស្ដេចបន្ទូលថាហៃ អ្នកប្រាជ្ញទាំង ៤ ហាំស្ដាប់ ។ អ្វី ១ បិត្តឱទបាទរ៍ គិតពិឃាតតែង សំឡាប់ ម្ដាយឯងប្អូនចៅប្រាប់ មកដោយគួរកុំយូរឡើយ ។ ពោធិសត្វទូលថា បពិត្រមហាក្សត្រត្រានត្រើយ សោភនុសរ នោះឯងហើយ តែងសម្លាប់ម្ដាយឯងណា ។ ឯសុន្ទរាល័យ ទូលក្សត្រថ្លៃនោះអាជា- ន័យសម្លាប់ម្ដាយវា ឯនិង្គារម្មណ៍ ក្រាបទូល ។ ជាដើមបេកទាំងឡាយ សម្លាប់ម្ដាយក្សត្រិតិស្សះ

អភ័យបណ្ឌិតទូល ឫស្សីរសម្លាប់ម្ដាយឯង ។ ស្ដេចបន្ទូល ថាហៃ ចៅអភ័យបណ្ឌិតថ្លៃង យល់ម្ដេចទៅចៅឯង ថាឫស្សី សម្លាប់ម្ដាយ ។ អភ័យបណ្ឌិតទូល ក្សត្រិតស្វរលើសទាំង ឡាយ ឫស្សីផងសម្ពាយ មានផ្លែហើយសឹងស្លាប់បង់ ។ ទោះ គុម្ពដើមស្លឹកទាំង បុងទំពាំងស្លាប់ពុំគង់ សូមក្រាបទូលព្រះ អង្គ ប្រាកដពិតមហាក្សត្រថ្លៃ ។ ឥដ្ឋារម្មណ៍ទូលថា បពិត្រម-ហាក្សត្រជេស្ឋជ័យ ចេកបើផ្លែហើយនៃ គេសម្លាប់បង់សៀត ហោង ។ ហើយគេពុំទាន់យក ផ្លែវាមកបរិភោគផង សឹង មរណ៍ឯងជាម្ដង ពុំដែលរស់ឡើយក្សត្រា ។ សុន្ទរាល័យទូល ក្សត្រិតស្វរសេះញីវា មានគភ៌គឺអាជា- ន័យកាលបើបាស់ផ្ទៃ ហើយ ។ លោកទំលាយស្បែកវា យកអាជាន័យជាត្រើយ បើពុំសម្លាប់ហើយ សឹងមរណ៍មួយនឹងកូនវា ។ ហេតុ នោះខ្ញុំក្រាបទូល ក្សត្រិតស្វរលើសិរសា សត្វសម្លាប់ម្ដាយវា មានតែសេះនោះឯងហោង ។ ទើបស្ដេចបើកបន្ទូល រសមធូរ សាន្តស្វរសង់ ឋានពោធិប្បាសប្បង ម្ដេចថាលាភសម្លាប់ ម្ដាយ ។ ពោធិសត្វទូលថា បពិត្រលាភទាំងឡាយ អ្នក

កាបផងសម្លាយ តែងបង្កើតលាភខុសនោះ ។ បង្កើតលាភបានហើយ ពុំលង់ឡើយលាភបានស្មោះ សម្លាប់អ្នកកាបនោះ ឲ្យអន្តរធានបាត់បង់ ។ ហេតុនោះខ្ញុំទូលថា អ្នកឫស្យាចិត្តពុំត្រង់ ឃើញទ្រព្យគេចិត្តចង់ បានមកប្រដាប់អាត្មា ។ គិតកាប់ប្លន់លួចយក ទ្រព្យនោះមកស្អាងអាត្មាដំណើមដោយពាលា ការបំពោតបញ្ឆោតយក ។ បង្កើតបំភិតគំ- រាមគេពុំឲ្យទ្រព្យមក លលក់ទន្និញរក កល់បំបាត់ចិត្តចង់បាន ។ ១ គឺមានយសស័ក្តិ ចិត្តអប្បលក្ខណ៍នៅពុំក្សាន្ត ចង់ស្វែងលាភបើបាន អម្បាលនេះពុំប្រពៃ ។ បើបុគ្គលឯណា ចិត្តឫស្យាកាចចង្រៃ បានទ្រព្យដូច្នោះនែហើយមានទាំងបរិពារពល ។ សោយសម្បត្តិធំក្រៃ ទ្រព្យប្រពៃច្រើនសោតសល់ ពុំចិតឡើយកម្មផ្តល់ ដោយផលកាបទុច្ចរិតកម្ម ។ វិនាសអន្តរាយ បាត់ទ្រព្យខ្ចាយហេតុបាបតាំ កើតជាសាធារណ៍៥ ប្រកបឲ្យទ្រព្យខ្ចាត់ខ្ចាយ ។ សាធារណ៍ ១ គឺសឹក ១ នឹងទឹកផ្លាញអន្តរាយ ៤ ខ្ចនដើរទៅឆ្ងាយ ភ្លើងឆេះផ្ទះវិនាសបង់ ។ សាធារណ៍ ១ រាជទណ្ឌ

១ ចោរប្លន់ហេតុពុំត្រង់ សាធារណ៍ទាំង ៥ អង្គ នឹងកើត ផ្លាញមនុស្សពាលា ។ សាធារណ៍ ១ វិញនៃ ជាបើក្សួយ នៃជន្មា វិទ្រព្យកើតជាសា- ធារណ៍បាត់បង់ឲ្យខ្ចាត់ខ្ចាយ ។ រីខ្លួននឹងធ្លាក់ទៅ ដោយទុក្ខទោសរកឆ្ងាយ អស់ទ្រព្យផង ទាំងឡាយ ពុំបានទៅផងឡើយនៃ ។ រីឯអ្នកសប្បុរស បានរបស់គាប់ប្រពៃ គេមកស្តាប់ធម៌ថ្លៃ គេបូជាទទួលយក ។ ១ ជាពេទ្យតែងផ្សំ ថ្នាំផ្សះជម្ងឺគេរក ១ យកខ្លួនបួលមក នៅបំរើគេប្រក្រតី ។ ១ ធ្វើបិត្តជាមិត្ត ស្នាលស្នេហ៍ស្និទ្ធ មូលមេត្រី ហៅទៅធ្វើស្រែក្តី កាប់បម្អោះខំខ្ទីឃ្លាត ។ ១ បម្រើ អម្ចាស់ ផ្តាច់ឲ្យណាស់កុំឲ្យឃ្លាត បម្រើដិតព្រះបាទ ទ្រង់ ករុណាឲ្យប្រទាន ។ អ្នកណាបានលាភផ្ទុះ អម្បាលនេះ សឹងក្បែមក្សាន្ត ប្រាកដិតហៅមាន មន្ទិលឡើយបរិសុទ្ធ ក្រៃ ។ រីលាភក្រៅពីនោះ អាសារសោះពុំប្រពៃ កំណាប កាបពេកក្រៃ នឹងសំឡាប់ម្ចាស់វិញណា ។ បពិត្រក្សត្រ ឧត្តម ខ្ញុំពិតពុំទូលមុសា សត្វសំឡាប់មាតា មានតែលាភ ខុសឯងនៃ ។ ពោធិសត្វទូលថា បពិត្រមហាក្សត្រជើស្លជ័យ

ស្តេចយកទុកព្រះទ័យ ទើបអ្នកសូត្រជាគាថា ។ អនត្ថោបជិរូបេន ១ គឺវា នឹងឥតប្រយោជន៍ប្រា- កដនឹងបាត់លាភសួន្យសោះ ។ វាយល់ប្រហែលបាន ហាក់ជាមានលាភវិញសោះ ហាក់បានប្រយោជន៍នោះ ហេតុបទឥតពិចារណា ។ អត្ថោបនត្ថ រូបេន ១ គឺជា លាភប្រយោជន៍ហើយណា យល់ជាឥតប្រយោជន៍វិញ ។ ក្តីទាំងពីរប្រការ ពុំពិចារណាអស់អញ ដល់វាកើតឡើងវិញ នឹងវិនាសអន្តរាយ ។ ហេតុនោះហោងខ្ញុំថា ឲ្យពិចារណាសម្វាយ បើលាភផងទាំងឡាយ គួរបើបានសមឲ្យយក ។ រីអ្នកកាចវង្វេង ពុំពិតក្រែងព្ទង់លោក បរលោកនឹងសោយសោក ទល់ទុក្ខនៅនរកនាយ ។ ស្តេចស្តាប់ពោធិសត្វ ប្រុសរ័ត់ឆ្លើយក្បោះក្បាយ បូជាទ្រព្យទាំងឡាយ ដូចពីមុននោះឯងណា ។ ជនិយយត្ថ បណ្ឌានិដ្ឋិតា សូរេចនៃប្រស្នា សម្លាប់ម្តាយបរិបូណ៌ហើយ ។

នេះបទកាកគៈ- តិកាលពុទ្ធៈ ពន្លកត្រាណត្រើយ ជរ៉ែន
ប្រឌិយក្ខ តិតអ្នកស្មើឡើយ ដល់ ១០ ឆ្នាំហើយ មានកាល
១ថ្ងៃ ។ ស្តេចបើកព្រះកោ- រិតាគង់នៅ ប្រាសាទមាសមៃ
អាហារទាំង ៣ ពោធិសត្វថ្លៃ ប៉ុនប៉ងប្រាស្រែ ឡើងគាល់
ក្សត្រា ។ ដល់ហើយបង្គំ ទើបក្សត្រឧត្តម បើកបន្ទូល
ថា អ្នកប្រាជ្ញទាំង ៤ មកប្អូនហើយណា ប្អូរស្រាយប្រស្នា
ដោយតួទីទៃ ។ រីទ្វារទាំងបួន សឹងមានតៅខ្វន គ្រប់តួ
សព្វថ្ងៃ គឺមាត់គឺភ្នែក ត្របៀកវិស័យ ប្រមុះភោគនៃ ទាំងបួន
នោះណា ។ ទ្វារណាឱ្យគុណ ឱ្យទោសលើសលន់ ក្រៃ
លែងនានា អាហារទាំងឡាយ ប្អូរស្រាយបញ្ហា ដោយតួ
ឱ្យប្រា- កដកាលតរ្យរ ។ ព្រះពោធិសត្វ ពន្លកពុទ្ធតែង
ទូលថ្វាតព្រះភូ- ធរនេនធិរ័ក្ស ចាបក្រិតគ្គ មាត់នោះឯង
ក្សរ គុណទោសកើតមាន ។ ពន្លកលំហ ទូលមហាក្សត្រ
ថ្លៃ អម្ចាស់ថ្កើងថ្កាន ប្រមុះឱ្យគុណ ពេកពន់ក្សត្រក្សាន្ត
ប្រមុះសោតមាន ឱ្យទោសប្រើនក្រៃ ។ តង្ហាររម្មណ៍ទូល
បពិត្រតស្លូរ អម្ចាស់ថ្លាថ្លៃ ត្របៀកឱ្យគុណ ពេកពន់វិស័យ

ត្របៀកសោតនៃ ឲ្យទោសច្រើនផង ។ អភ័យបណ្ឌិត ទូល
ថាបពិត្រ ក្សត្រក្សាន្តច្បាស់ច្បង ភ្នែកតែងឲ្យគុណ ពេកពន់
កន្លង ភ្នែកឯងសោតហោង ឲ្យទោសច្រើនក្តាត់ ។ ស្តេច
ស្តាប់ហ្នោះហើយ ពិតពុំលុងឡើយ បន្ទូលរឹងហ្កាត់ ដណ្តឹងថា
ហៃ អភ័យបណ្ឌិត ចូរថ្លែងដោយពិត ពីគុណទៀតផង ។
អភ័យបណ្ឌិត ទូលថាបពិត្រ ក្សត្រថ្លៃច្បាស់ច្បង មនុស្ស
ផងមានភ្នែក ក្រឡេករឹងស្នង យល់ប្រាកដហោង ពុំប្រាកដ
ក្តី ។ យល់អង្គអ្នកខ្ពត់ យល់អ្នកបរិសុទ្ធ យល់ហិន
អប្រិយ៍ ភ្នែកតែងអាស្រ័យ សព្វថ្ងៃឥតបី បានឯទៀតពីរ
ក្រៃនឹងនេត្រា ។ ឥដ្ឋារម្មណ៍ទូល បពិត្រឥស្សរ អម្ចាស់
សិរសា ទោះគេតិះដៀល ដំនៀលនិន្ទា សើចយំក្តីណា
ពាក្យសរសើរផង ។ ស្រដីពីរោះ ស្រណុកចិត្តស្មោះ បរបា
ស្នេហ៍ស្នង ត្របៀកអាស្រ័យ សព្វថ្ងៃតែងត្រង រងស្តាប់ពាក្យ
ផង គុណទោសកើតមាន ។ សុន្ទរាល័យ ទូលថាក្សត្រថ្លៃ
អម្ចាស់ថ្កើងថ្កាន ច្រមុះបើធុម ក្លិនពុំប្រៀបបាន អស្សុជោរ
ពោរពាន ទៀបជិតក្រោធក្រៃ ។ បើធុមប្រេងចន្ទន៍ ក្រស្នាទូវ

មាន៎ ហាមហើយអាល័យ បើធុមម្ទឹៗ ហេតុក្ដីអាល័យ ប្រមុះ
សព្វថ្ងៃ ក្រៃលែងនានា ។ ស្ដេចស្ដាប់ពាក្យពី អាចារ្យ
ទាំង ៣ ទូលគ្រប់អាត្មា ដោយនូវដំណើរ ផ្សេងៗ ពីគ្នា
ទើបដណ្ដឹងមហា បុរសរតន៍ថ្លៃ ។ ព្រះពោធិសត្វ ពន្លកពុទ្ធ
រតន៍ លើសលោកភពត្រៃ ក្រាបទូលព្រះមហា ក្សត្រាជេស្ឋ
ជ័យ បពិត្រក្សត្រថ្លៃ ឥស្សរត្រាណត្រើយ ។ តាអ្នកទាំងបី
នេះនឹងស្រដី ពាក្យពុំត្រូវហើយ ពុំជាអ្នកប្រាជ្ញ ឯងអាចផ្លាស់
ផ្ដើយ រឺពាក្យបំឡើយ នេះអ្នកពាលពិត ។ ត្របៀកប្រមុះ
ភ្នែកអស់ទាំងនោះ សោតសឹងតែគិត គុណទោសឡើយណា
ខ្ញុំថាពុំគិត ដោយនូវពាក្យពិត មានក្នុងគាថា ។ ភាបេនអ
បនបញ្ញ បពិត្រក្សត្រា មានលាភតិបក្ដាត់ ហេតុបរបា ខ្ញុំពុំ
មុសា ទូលក្សត្រជេស្ឋជ័យ ។ ភាបេធុនោ វិនាសិតោ បពិត្រ
ក្សត្រថ្លៃ ហេតុមាតឡលាញ ផ្លាញទ្រព្យច្រើនក្រៃ មាតឯង
នោះនៃ ឲ្យទោសក្ដាត់ណា ។ ភាបេតាសេ តិបុគ្គលេ វិនា
ក្រយា នាំកូនទាំងឡាយ អន្តរាយឃ្លាតឃ្លា ហេតុមាតពុំ
ប្រ. ដោកូនឡើយនៃ ។ ភរិយំប ដោភាចេន បពិត្រក្សត្រថ្លៃ

នាំកូនព្រាត់ខ្ចាយ ខ្ចាត់ដោយទីទៃ ភរិយាសោកនៃ លេះ
លែងខ្ចាត់ខ្ចាយ ។ ហេតុពាក្យពុំបេះ ស្លូតត្រង់ត្រេកត្រេះ
កិច្ចការសម្ចាយ ប្រដៅភរិយា បរិពារទាំងឡាយ ទើបព្រាត់
ខ្ចាត់ខ្ចាយ ហេតុពាក្យនោះណា ។ កុភបេន ភយបុត្ត
នារីក្រយា ឲ្យខ្លួនភ័យភិត ហេតុបទភាបា នឹងមាត់ពាក្យប៉ា
ប្រាកដក្សត្រថ្លៃ ។ ភបេនអ តប្បិន្ទិយំ បពិត្រជេស្នជ័យ
នាំឲ្យដាប់អង្គ បោះបង់ទីទៃ ស្ងួរលក្សិណាក្ស័យ ហេតុបទ
ភាបា ។ ភបេនប ភរិឌ្ឍិត ហេតុពាក្យបរបា បេះប្រដៅកូន
ឲ្យទូន្មានភា កូនសោតដ្បិតបា ប្រដៅនោះនៃ ។ អត្ថានបោ
តិរបន បពិត្រក្សត្រថ្លៃ ឲ្យគេពិឃាត ប្រមាទខ្លួននៃ ហេតុ
ពាក្យសំដី ពុំពីរោះឡើយ ។ ភបេនល ភិតំលាភ បានទ្រព្យ
ច្រើនហើយ ហេតុបេះបាយបែង ប្លាប្លែងជាត្រើយ បានទ្រព្យ
មកហើយ ហេតុមាត់ស្រដី ។ ភបេនភ វិយំរិឌ្ឍិ ប្រពន្ធ
សព្វថ្ងៃ បំរើនឲ្យសុខ ឥតទុក្ខទោសពៀរ ស្នេហាស្និទ្ធមូលមេ
គឺហេតុភាបា ។ ភបេបនំ ធមទោសំ កើតក្តីស្នេហា ព្រៀង
លានញាតិដៅ កូនចៅក្តីណា ថ្នាក់ថ្នមសិក្ខា មានមិនមាន

ហ្មង ។ វាបេទប តសោត្ថិយ មាត់មិនឲ្យគ្រង កើតសុខ
សួស្តី វឌ្ឍីការផង ហេតុពាក្យពេះរលង សាគស្មរមេត្រី ។
វាបេសុខំ បត្តាទាយំ ពាក្យពេះស្រដី នាំខ្លួនឲ្យបាន ធន
ធានវឌ្ឍី លុះសុខសួស្តី ហេតុពេះបរបា ។ សុគតិគ- តោ
វាបេទ បពិត្រក្សត្រា នាំសត្វឲ្យបាន ដល់ឋានសួគ៌ា ហេតុ
បទវាចា សព្វទៀងត្រៃ ។ បាបេត្តិធ - លំវាពេល មនុស្ស
ផងសព្វថ្ងៃ បានផលស្រោតា សកទាគាតៃ អរហត្តញាណ
ត្រៃយ ហេតុពាក្យភារតៅ ។ និព្វត្តិ តោវាបេទ ហេតុពាក្យ
ប្រាជ្ញា សម្បត្តិនិព្វាន រួបបានសុខសា ព្រោះបទវាចា ពុំ
ពីងទៃ ។ បពិត្រព្រះអង្គ ប្រសើរទ្រើសទ្រង់ វាចរវឌ្ឍភាពត្រៃ
បើបុរសណា ប្រាជ្ញាវាងវៃ សម្រួមពាក្យនៃ អាត្មាឧត្តម ។
បែងពេះបរបា ហើយពិចារណា ពាក្យពេចន៍សុខុម គួរគាប់
ទើបចាយ សាស្រាយសោតសម នាំលែងខ្លួនលំ - នៅបាន
សួគ៌ា ។ បពិត្រមហាក្សត្រ គុណកើតពីមាត់ ទោសទុក្ខ
ភយា សឹងកើតពីមាត់ បង់បាត់ទ្រព្យា ពានយសសក្តា
បង់បាត់ខ្ជាត់ខ្ជាយ ។ បានសុខបាត់ទុក្ខ បានទោសពុំសុខ

អំពល់រូបកាយ ហេតុមាត់ស្រីដី អព្រិយ៍និយាយ ពុំងទៃ ឆ្ងាយ ពីពាក្យឡើយណា ។ ស្តេចស្តាបវាក្យពី ទូលទើប ត្រាស់ថា បាថ្លែងពីរោះ ស្មានស្មោះសោះសា ស្តែងស្តេច បូជា ដូចមុនរោះនៃ ។ ទ្វារបណ្ណា និម្មិតោផា សូមេប ប្រពៃ វិទ្វារបណ្ណា ប្រស្នានេះនៃ ចប់បរិបូណ៌ក្រៃ ពិតពុំ ឃ្លាតឃ្លា ។ ព្រះពោធិសត្វ ពន្លកពុទ្ធង្កូរ៍ ប្តីងព្រះប្រាជ្ញា ស្រុកឥន្ទបថ, រង្គរាស្ត្រនានា ល្បីព្រះយសា ប្តីភ្លើងសត្វ សាយ ។ បីដូចព្រះចន្ទ រុងរឿងសោភ័ណ រស្មីឆាឆាយ ដូចព្រះអាទិត្យ ប្តីងរិទ្ធិពន្លាយ អ្នកផងទៀបឆ្ងាយ ទូទាំង ទិសា ។ អ្នកខ្លះបានស្តាប់ ធម៌ថាគួរគាប់ ពោធិទេស្នា សឹងតែសរសើរ ដំណើរកុមារា សឹងបបួលគ្នា មកមើលចង់ យល់ ។ ដំណើរនេះណា យើងពុំបរបា ឯងឯទសពល មានអ្នកស្រុកក្រៅ សំនៅឆ្ងាយសល់ ម្នាក់ឯងទូល បិញ្ចឹម ភ្កៅនៅ ។ នាមឈ្មោះសុន១ គោបាលតែងដឹក ភ្កៅបណ្តើរ ទៅ នឹងថ្លែងស្រដី សេដ្ឋី១នៅ ទីឋានស្រុកក្រៅ មាន ពពៃច្រើន ។ ឱ្យខ្ញុំមួយឃ្លាល ឈ្មោះអង្គុល ផាស់ទៀន

ក្រពើន តែងឃ្វាលសព្វថ្ងៃ ខាងព្រៃនោះច្រើន កាល់គៀង ក្រពើន ក្រវែបសព្វថ្ងៃ ។ ជាហេតុនាកាល សុនខគោបាល នាំឆ្កែទៅព្រៃ ប្រយោជន៍រកឧស អម្រស់នោះនៃ បរបួលក្នុង ព្រៃ កាប់ឧសហើយណា ។ ឯអម្ចាស់ឆ្កែ · ទៅងូតទឹក ស្រែ ១ មានគង្គា មានដើមឈើធំ ជង្គុំសាខា ស្រែនោះឯង ណា អជ្ឈបាលនោះនៅ ។ ឆ្កែឃើញពពែ ស៊ីស្មៅក្នុងស្រែ ក្រឡេកក្រឡៅ ដេញមេខ្ចាយខ្ចាត់ រត់បាត់ចេញទៅ កូន ១ ព្រាត់នៅ ឆ្កែស្ទាត់ខាំបាន ។ កូនពពែស្រែក យំខ្លាំង បំឡេក ដែៗនាហោន ទ្រមាក់ពពែ យល់ឆ្កែរុករាន ខាំពពែ បាន ដូច្នោះហើយណា ។ ទ្រមាក់ពពែ រត់ទៅពីស្រែ ស្រែកខ្លាំងសោះសា កូនពពែលោក ឆ្កែមកខាំវា ឆ្កែជង់ នរណា មកខាំច្នេះនែ ។ ឯម្ចាស់ឆ្កែនោះ ឮស័ព្ទដូច្នោះ រត់ចេញពីព្រៃ មកវាលបង់ដឹង ដំណឹងប្រាស្រែ ដណ្ដឹង ថាហៃ ស្រែកអ្វីច្នេះណា ។ អជបាលថាឆ្កែ ខាំកូនពពែ លោក ១ មរណា ឯអម្ចាស់ឆ្កែ ថាៈទុកវា ពុំឃើញឡើយបា

ពុំឮសព្ទផង ។ ឯម្ចាស់ពពែ ស្រដីថាឆ្កែ ចៅឯងនេះហោង
ខាំកូនពពែ ក្នុងស្រែជាម្តង ព្រោះគួរចៅសង ពពែនេះនៃ ។
បើចៅពុំដឹង ពុំឮដំណឹង ឆ្កែចៅកាចក្រៃ ខាំស្លាប់អាសារ
មរណាក្នុងព្រៃ បើដូច្នោះនៃ លែងម្តេចចៅបាន ។ ទ្រមាក់
ពពែ នាំអម្ចាស់ឆ្កែ វិលវឹងមកហោន នៃមហាសេដ្ឋី ស្រដីទៅ
ឋាន ប្រាប់ថាដ្បិតមាន ឆ្កែចៅនេះឯង ។ ខាំកូនពពែ
ស្លាប់នៅក្នុងស្រែ ខ្ញុំពុំហ៊ានលែង ខ្ញុំនាំមកឋាន ដល់ហោន
នេះឯង ទើបវាថ្លាថ្លែង ប្រាប់សព្វសេចក្តី ។ សេដ្ឋីស្តែង
ស្តាប់ អស់អាថិសាសព្ទ បង្គាប់ទៅខ្ញុំ ឲ្យម្ចាស់ឆ្កែសង
គួរស្នុងសេចក្តី ម្ចាស់ឆ្កែថាទេ ខ្ញុំពុំសងឡើយ ។ សេដ្ឋីថាបើ
ពុំព្រមបុះតើ បួរចៅឡើងឆ្លើយ ទៅឋានសាលា ដល់អាមាត្យ
ហើយ សិមចៅឆ្លាស់ឆ្លើយ ទើបរួបសេចក្តី ។ អានោះ
ឆ្លើយថា ព្រោះទៅផងគ្នា ខ្ញុំនឹងខ្លាចអ្វី សេដ្ឋីនាំស្មោះ បំពោះ
ទៅខ្ញុំ ដល់សាលាទី បញ្ជូនសិងនោះ ។ ទើបថ្លាថ្លែងប្រាប់
ដំណើររៀបរាប់ ទំនងស្មានស្មោះ អាមាត្យស្តែងស្តាប់ សាសព្ទ

ដូច្នោះ ហៅអើអាទោះ ប្ដូរឆ្លើយដោយពិត ។ ម្ចាស់ឆ្កែឆ្លាស់ ឆ្លើយ ហៅម្ចាស់ខ្ញុំអើយ ខ្ញុំឆ្លើយពិតពិត អញខ្ញុំពុំដឹង ដំណឹង ដោយពិត ពុំបាននៅជិត ខ្ញុំនៅឆ្ងាយក្រៃ ។ អាមាត្យនោះហៅ បើដូច្នោះប្ដូរអា រិះរកទ្រព្យថ្លៃ ស្នងគូពពៃ ដ្បិតឆ្កែនេះនៃ ខាំនៅក្នុងព្រៃ អាហាមិនយល់ ។ នរណាគេតែង ជឿពាក្យ ព្រះស្ដួង កុហកវិលវល់ បង់តែឲ្យឈ្នះ ស្រស់ឡូះអញយល់ អាឯងកាបសល់ ភក្ដុតមោសា ។ អានោះដដែក ឆ្លើយឈ្លោះ ប្រកែក ហៅខ្ញុំនេះណា ពុំយល់ពុំដឹង ដំណឹងនេះណា ម្ដេច ឡើយមកហៅ ឲ្យខ្ញុំសងថ្លៃ ។ បង្គាប់អាមាត្យ ឈ្មោះកាលវិ- ភាទ ពិតពុំប្រពៃ ហៅច្នោះអាហាំ ទម្រាំដល់ថ្ងៃ ស្អែកសិមវិលវិ យើងមកជំនុំ ។ ឲ្យបានជួបមហា ឧដុកសេនា- បតីជាធំ មកជួយពិគ្រោះ ដោះឲ្យគួរសម គួរយើងជំនុំ ថ្ងៃស្អែកផង គ្នា ។ អ្នកក្ដីទាំងពីរ ក្រាបលាបរបេរ ហ៊ានផ្ទះអាត្មា សេដ្ឋី កំណាប គិតកាបមោសា គិតក្នុងចិត្តថា ច្នេះគួរអញទៅ ។ អង្វរសូមមហា ឧដុកសេនា- បតីជាហៅ- ក្រមឲ្យបំភ្លាត់ ឲ្យ

គាត់ជួយទៅ បង្គាប់លក់ចៅ ម្ចាស់ផ្ទៃនោះណា ។ គិតដូច្នោះ
ហើយ ពិតពុំលង់ឡើយ យប់នោះយាត្រា យកទ្រព្យសម្បត្តិ
ទៅស្កាត់បូជា ឧដុកសេនា- បតីអរក្រៃ ។ ទទួលយកហើយ
ថាសេដ្ឋីអើយ រីក្តីនេះនែ កុំឲ្យដល់ច្បាប់ ទំលាប់បំភ្លៃ អ្នក
ឈ្មោះឆាប់ក្រៃ កុំព្រួយបិត្តឡើយ ។ ទើបសេដ្ឋីលា មកផ្ទះ
អាត្មា ដល់ដេកព្រងើយ ព្រឹកទើបយាត្រា ដល់សាលាហើយ
ម្ចាស់ផ្ទៃសោតឆ្លើយ ដូចដើមនោះនៃ ។ ឧដុកសេនា- បតី
យាត្រា ដល់ហើយថាហៃ អ្នកស្រដីក្តី ក្តីគៅគាថ្ងៃ នេះឲ្យ
សង្ស័យ មន្ទិលដូច្នេះ ។ អាមាត្យប្រាយប្រាប់ ថាអ្នកបូរស្តាប់
អស់ដំណើរនេះ អាមាត្យហ្លាថ្លែង សំដែងអស់ម៉្លេះ ដំណើរ
ដូច្នេះ ឲ្យអ្នកជំនុំ ។ សេនាបតី ប្រាប់ទៅអ្នកក្តី ថាអញមិន
សម នឹងចៅមួយឡើយ ចៅឆ្លើយដោយដំ- ណើរពិតថាកុំ
ភូតភមោសា ។ ពាក្យដូចអាថា កាលនឹងវិវាទ ឯពាក្យចៅថា
ដូចម្តេចបូរថ្លែង សំដែងបរបា ចៅទាំងពីរថា ដូច្នេះហើយ
ម្ចាស់ថ្លៃ ។ កាលនោះសេនា- បតីថាអា ម្ចាស់ផ្ទៃនេះនែ

បិត្តហោរកំណាប កាបក្រៅវិស័យ មាននៅក្នុងព្រៃ ពិតថា មិនយល់ ។ អាឆ្លើយបំពោត កុហកបញ្ឆោត ថាឲ្យយើង ឆ្ងល់ យើងមានប្រាជ្ញា ពិចារណាយល់ អាងដំកាបសល់ កុហកសោះសា ។ បើយើងទាំងឡាយ គួរតែនិយាយ ប្រាប់ពិតកូវជា អ្នកអង្គុយជុំ ជំនុំនេះណា គួរដឹងឬថា ពុំគួរ ដឹងឡើយ ។ អស់ទាំងពៅក្រម ដែលអង្គុយជុំ អ្នកខ្លះឆ្លាស់ ឆ្លើយ ថាគួរតែដឹង ដំណាំងលោកអើយ ខ្លះស្ងៀមកន្តើយ ពុំហ៊ានបរបា ។ សេនាបតី ខេរខឹងថារី ម្ចាស់ផ្ទៃនេះណា ស្មានវាប្លែងពិត ពំនិតឲ្យវា សងពពែជា ១ ដូចដើមវិញ ។

(មានតទៅទៀត)



លោកសង្ឃភូមា គណៈសុទ្ធម្ម នៅវត្តតែកការ
ក្រុងមណ្ឌលេ

# រឿងព្រេងខ្មែរ

## ១— រឿងបុរសចេះថ្នាំពិសពស់

មានសម័យថ្ងៃមួយ បុរសឈ្មោះសុខធ្វើដំណើរទៅកាប់ឧសក្នុងព្រៃ លុះទៅដល់ឃើញសត្វខ្លាមួយធំ ក្ស័យនៅជើងជម្ប្យកក្បែរប្រែកនោះ បុរសសុខពិនិត្យមើលហេតុសព្វគ្រប់ទៅឃើញថា ខ្លានេះក្ស័យនឹងពស់ចឹក ព្រោះនៅខាងក្រោមខ្លានោះមានរន្ធពស់ ១ បុរសនេះមានសេចក្ដីសប្បុរសផល់សាកសពសត្វនេះណាស់ ក៏ស្រាយចង់យាមយកថ្នាំជុសស្រលាបលាបឲ្យ លុះបាន១ស្របក់ខ្លាដឹងខ្លួនដើបឡើងឃើញប្រាណប្រឡាក់សុទ្ធតែថ្នាំដែលលាប ក៏មានសេចក្ដីទោមនស្សដល់បុ-រសដែលលាបថ្នាំហើយស្រដីថា ហេតុម្ដេចបានជាអ្នកឯងអាបហានយកអ្វីមកប្រឡាក់ខ្លួនអញយ៉ាងនេះ បុរសនោះឆ្លើយថា យើងដើរមកឃើញបងឯងក្ស័យនឹងពស់ចឹក ហើយយើងជុសថ្នាំស្រឡាបលាបឲ្យបងឯងរស់តើ សត្វខ្លាថាអញមានក្ស័យអ្វីពស់មានចឹកអញពីកាលណា អញកំពុងដេកលក់ស្រួលតើ

បើដូច្នេះអញត្រូវប្រហារជីវិតឯងធ្វើជាអាហារ បុរសឈ្មោះសុខ
មានសេចក្ដីតក់ស្លុតនឹងសេចក្ដីមរណភាពខ្លាំង ក៏អង្វរខ្លាថាបង
អើយ អាណិតកុំអាលពិឃាតយើងក្នុងគ្រានេះ ចាំយើងទៅ
រកអ្នកប្រាជ្ញណាឲ្យគេមកជំនុំជំរះឲ្យ បើរកទៅឃើញជាយើង
ខុស សឹមបងប្រហារជីវិតយើង បើឃើញត្រូវទុកជីវិតយើង
ខ្លាក៏ព្រមតាមសំណូមរបស់ចៅសុខ ៗ វិលមកវិញប្រទះសត្វ
សេះនឹងក្របីនៅក្បែរផ្លូវក៏ស្រដីថា បងទាំងពីរអាណិតទៅជួយ
យកអាយុយើងផង ព្រោះខ្លាដែលពស់ចឹកក្បួយបានរស់ឡើង
ដោយយើងដាក់ថ្នាំឲ្យវា ប្រាថ្នាប្រហារជីវិតយើង ថាយើងធ្វើគេ
ឲ្យភ្ញាក់ហើយធ្វើឲ្យប្រឡាក់ខ្លួនគេអស់ សត្វទាំងពីរដឹងសេចក្ដី
សព្វគ្រប់ក៏ពិចារណាទៅឃើញថា ត្រូវតែកុំទៅកាត់សេចក្ដីឲ្យ
បុរសនេះឈ្នះខ្លា ដោយគិតឃើញថា បើអញឲ្យបុរសនេះឈ្នះ
មុខជាសត្វខ្លាគុំគួនយកអញធ្វើជាអាហារពុំលែង ក៏ស្រដីទៅ
ចៅសុខថា បងឯងខុសមែនហើយ ត្រូវឲ្យខ្លាស៊ីទៅ ។
ចៅសុខរឹតតែភ័យខ្លាំងឡើង ក៏លាពាជីនឹងក្របីដើរយ៉ាងលឿន

ទៅទៀត លុះប្រទះនឹងសុភាទន្សាយ ចៅសុខប្ដឹងតាមដំណើរ ដល់ដឹងរឿងសព្វគ្រប់ សុភាទន្សាយប្រាប់ចៅសុខឲ្យទៅនិយាយអង្វរខ្លាទៀតទៅ សិមយើងទៅជួយ ។

ក្នុងគ្រាដែលបុរសកំពុងតែជជែកនឹងខ្លា សុភាទន្សាយទៅដល់ ក៏ធ្វើជាសួរទៅថា បងឯងទាំងពីរនាក់ទាស់គ្នាពីរឿងអ្វី សត្វខ្លានឹងចៅសុខក៏បានប្ដឹងតាមដំណើររៀងខ្លួន ។

សុភាទន្សាយកាត់សេចក្ដីថា បើដូច្នេះត្រូវបងខ្លាឯងទៅដេកនៅត្រង់កន្លែងដដែលហើយឲ្យយួរដូចពីមុន បើដល់គ្រប់កំណត់ត្រូវភ្ញាក់ហើយពុំឃើញក្បួយទេ បងឯងត្រូវពិឃាតមនុស្សនេះធ្វើជាអាហារចុះ ។

ខ្លាក៏ទៅដេកតាមបង្គាប់ សត្វពស់ចេញពីរន្ធមកចឹកខ្លានោះក្បួយទៅ លុះឃើញសត្វខ្លាក្បួយហើយ សុភាទន្សាយប្រាប់ទៅបុរសនោះថា បងឯងកុំលាបឃ្មុំឲ្យវារស់ទៀតហើយក៏លាចៅសុខទៅទីលំនៅវិញ ។

ត្រូវយើងនឹកគុណគេ កុំធ្វើដូចសត្វខ្លា ។

# បញ្ជីរឿង


លេខទំព័រ

១ បមាទាប្បមាទកថា .................... ២០៩

២ គាថាធម្មបទ ប្រែ (តចប់) .................... ២៤១

៣ សក្ករទេសនា (តចប់) .................... ៣០៩

៤ រឿងមនុស្សល្ងោត ៤ នាក់ .................... ៣២៧


# រូបក្រៅរឿង


១ រូបភាពឆ្នេរទន្លេ ឥរវតី ប្រទេសភូមា .................... ៣០៧



ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# TABLE DES MATIÈRES

Pages

I. Pamādappamādakathā........................ 209

II. Gāthā dhammapada traduit du Pali en Cambodgien... 251

III. Sāradesanā.......................................... 309

IV. Conte populaire inédit :

Histoire des quatre niais.......................... 327

## HORS TEXTE

I. Sur les bords du fleuve Iravady, (Birmanie) une des innombrables pagodes.......................... 307

ឞមានាប្បមានគេជា

របស់អាចារ្យ សេង - ឈុន ក្រុមជំនុំប្រែព្រះត្រៃបិដក

រៀបរៀង



បមាទាបមាឧបញ្ញារម្ភា

# នមត្ថុរតនត្តយស្ស

*សូមក្រាបថ្វាយបង្គំ (ដោយគោរព) ចំពោះព្រះរតនត្រ័យ*

*គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។*

សៀវភៅនេះនឹងពណ៌នាសួរប្រស្នា ទៃបមាទនិងអប្បមាទធម៌ តាមសេចក្ដីដែលមាននៅក្នុងគម្ពីរទាំងឡាយ មានគម្ពីរព្រះធម្មបទជាដើមផង តាមសេចក្ដីយល់ឃើញរបស់ខ្ញុំអ្នកតែង ដែលបានសិក្សាក្នុងគម្ពីរឯទៀតៗផង មករួបរួមគ្នាធ្វើជាសេចក្ដី មានពីរផ្នែក ៗ ផ្នែកទី ១ ជាភាសាបុច្ឆាវិសជ្ជនា គឺសួរនិងឆ្លើយ, ផ្នែកទី ២ ជាពាក្យរាយ ៕

ផ្នែកទី ១

បុ. សួរថា៖ យើងបានឮគេមកយូរណាស់មកហើយថា មានមហាឫសី បេះដប្បមនុស្សស្លាប់ឲ្យរស់ឡើងវិញមែនឬ?

វ. ឆ្លើយថា៖ បើតាមន័យក្នុងព្រះពុទ្ធសាសនា ថា មហាឫសីលោកបេះជីវមនុស្សស្លាប់ឲ្យរស់វិញមែន ប៉ុន្តែជីវបានតែមនុស្សស្លាប់ តែនៅមានដង្ហើមចេញចូល ។

បុ. មនុស្សពួកណាដែលស្លាប់ហើយ តែនៅមានដង្ហើមចេញចូល?

វ. ពួកមនុស្សដែលប្រមាទ គឺធ្វេសប្រហែស ឬភ្លេចស្មារតី ។

បុ. មហាឫសីនោះគឺអ្នកណា ព្រោះហេតុដូចម្តេចបានជាឈ្មោះថាមហាឫសី?

វ. មហាឫសីនោះគឺព្រះពុទ្ធ បានជាឈ្មោះថា មហាឫសី ព្រោះលោកស្វែងរកនូវគុណដ៏ធំ គឺ សីល, សមាធិ, បញ្ញា ដែលជាធម៌ធ្វើព្រះអង្គឲ្យរួចចេញអំពីកណ្តាប់ដៃនៃសេចក្តីទុក្ខគ្រប់យ៉ាង ។

បុ. ព្រះពុទ្ធដែលជាមហាឫសី ទ្រង់ជីវមនុស្សប្រមាទ ឬភ្លេចសតិដោយឧបាយដូចម្តេច?

វិ. ទ្រង់ផបដោយឧបាយដើរដាស់តឿនសតិ ឲ្យដឹកហ៊ុំផ្សេង ៗ ។

បុ. ហ៊ុំនោះគឺអ្វី បានជាឈ្មោះថាហ៊ុំនោះតើដោយហេតុដូចម្ដេច?

វិ. ហ៊ុំនោះគឺធម៌ បានជាឈ្មោះថាហ៊ុំនោះដោយហេតុដែលបានធ្វើរោគរបស់សត្វឲ្យជាសះស្បើយទៅបាន ។

បុ. រោគរបស់សត្វមានប៉ុន្មាន គឺអ្វីខ្លះ កើតនៅទីណា?

វិ. រោគរបស់សត្វមាន ៨ យ៉ាង គឺៈ មិច្ឆាទិដ្ឋិ គំនិតយល់ខុស ១, មិច្ឆាសង្កប្បោ ត្រិះរិះខុស ១, មិច្ឆាវាចា និយាយស័ដីខុស ១, មិច្ឆាកម្មន្តោ ធ្វើការងារខុស ១, មិច្ឆាអាជីវោ ចិញ្ចឹមជីវិតខុស ១, មិច្ឆាវាយាមោ ប្រឹងប្រែងខុស ១, មិច្ឆាសតិ រលឹកខុស ១, មិច្ឆាសមាធិ ធ្វើចិត្តឲ្យនឹងខុសពីកម្មដ្ឋានទាំង ៤០ ប្រការ ១; (ទាំង ៨ នេះ) កើតនៅក្នុងសន្ដានចិត្តសត្វ ។

បុ. សេចក្ដីខុសទាំង ៨ នេះព្រោះហេតុអ្វីបានជាហៅថារោគ ចូរអធិប្បាយប្រៀបធៀបសេចក្ដីឲ្យពិស្ដារមកមើល?

វិ. សេចក្ដីខុសទាំង ៨ នេះបានជាហៅថារោគ ព្រោះហេតុដូចគ្នានឹងរោគកើតនៅកាយខាងក្រៅ ។ ធម្មតារោគដែលកើតនៅកាយខាងក្រៅ រមែងធ្វើរូបឲ្យកើតវិបត្តិផ្សេងៗ មានវិកលវិការ បាក់ដៃ បាក់ជើង ខ្វាក់ភ្នែកជាដើមខ្លះ ជួនកាលរោគនោះខ្លាំងពេកធ្វើមនុស្សឲ្យស្លាប់ទៅខ្លះ យ៉ាងណាមិញ, ឯសេចក្ដីខុសទាំង ៨ នេះ រមែងធ្វើបដិសន្ធិវិញ្ញាណរបស់សត្វឲ្យវិកលវិការ ស្លាប់កើតក្នុងអបាយភូមិទាំង ៤ នឹងស្លាប់កើតក្នុងភពទាំង ៣ មិនចេះផុតខ្លះ ជួនកាលរោគនោះខ្លាំងពេកហៅថា និយតមិច្ឆាទិដ្ឋិ ធ្វើសត្វឲ្យស្លាប់ពូជសេចក្ដីល្អ ខានបានទៅព្រះនិព្វានខ្លះ ដូច្នោះឯង ។

បុ. ថ្នាំសម្រាប់កែរោគ ៨ យ៉ាងនោះ មានប៉ុន្មានមុខ គឺអ្វីខ្លះ? ចូររាប់ហើយអធិប្បាយមកមើល

វិ. ថ្នាំសម្រាប់កែរោគ ៨ យ៉ាងនោះ មាន ៨ មុខ គឺសម្មាទិដ្ឋិ គំនិតយល់ត្រូវ ១, សម្មាសង្កប្បោ ត្រិះរិះត្រូវ ១, សម្មាវាចា និយាយសំដីត្រូវ ១, សម្មាកម្មន្តោ ធ្វើការងារត្រូវ ១,

សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវ ១, សម្មាវាយាមោ ព្យាយាមប្រឹងប្រែងត្រូវ ១, សម្មាសតិ មានសេចក្ដីរឭកត្រូវ ១, សម្មាសមាធិ ដំកល់ចិត្តឲ្យនឹងត្រូវទៅក្នុងកម្មដ្ឋានទាំង ៤០ ប្រការ ១ ។

សេចក្ដីអធិប្បាយថាៈ ថ្នាំទាំងនេះជាថ្នាំពូកែផុតឆាប់ អាចធ្វើរោគក្នុងសន្ដានចិត្តរបស់សត្វដែលផឹក គឺប្រតិបត្តិតាម ឲ្យជាសះស្បើយបាន តែបំណែកពួកសត្វទាំងឡាយ ដែលមិនផឹកថ្នាំនេះ គឺមិនប្រតិបត្តិតាមនោះ បណ្ដាលមកអំពីសេចក្ដីប្រមាទនោះឯង ។ ហេតុនេះពួកមនុស្សដែលប្រមាទ ឬភ្លេចស្មារតីនោះ បាត់ថាជាអ្នកមានពូជសេចក្ដីល្អស្លាប់គ្រប់គ្នា សមដូចពុទ្ធភាសិតនៃព្រះអរហំសម្មាសម្ពុទ្ធ ក្នុងគម្ពីរធម្មបទ ថាៈ

អប្បមាទោ អមតំ បទំ  បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ  យេ បមត្តា យថា មតា ។
ឯតំ វិសេសតោ ញត្វា  អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ  អរិយានំ គោចរេ រតា ។
តេ ឈាយិនោ សាតតិកា  និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ  យោគក្ខេមំ អនុត្តរំ ។

ធម៌មិនប្រមាទ (នេះ) ជាឧបាយ ធ្វើមនុស្សឲ្យឆ្ងាយពីសេចក្ដីស្លាប់ ធម៌ដែលប្រមាទ (មុខតែនឹងដាច់) ធ្វើមនុស្សឲ្យស្លាប់ជាកិច្ចឧបាយ ជនមិនមានធម៌ប្រមាទទាំងឡាយ ទោះស្លាប់ទៅឆ្ងាយហាក់ដូចរស់នៅ ជនណាប្រមាទទោះបីរស់នៅក៏ព្រះទ្រង់ហៅថាជាមនុស្សស្លាប់ ។ បណ្ឌិតដែលមានប្រាជ្ញាផុតឆាប់ កាលបើដឹងអប្បមាទធម៌នេះ ដោយហេតុណាមួយដែលយ៉ាងវិសេស ហើយចិត្តលោកបេះតែមានអំណរ ទៅក្នុងអារម្មណ៍ពោលគឺព្រះធម៌ ដែលជាទីបរនៃអរិយ ។ ហើយកើតសេចក្ដីត្រេកអរផុតអាក់ លើកចិត្តទៅដាក់ក្នុងអប្បមាទ បណ្ឌិតទាំងឡាយលោកតែងសង្វាត ព្យាយាមឱហាតមាំផុតមានដាប់ បានដុតកិលេសហើយបានសម្រេចនិព្វាន ផុតដាប់ ជាកយោគធម៌ (ដែលគ្មានគ្រឿងប្រៀបដូចគ្នានឹងស្គរ) ព្រោះជាធម៌ល្អលើសធម៌ទាំងពួង ។

បុ. អ្នកមិនប្រមាទបើទុកជាស្លាប់ ក៏ហាក់ដូចជារស់នៅនោះតើដោយហេតុយ៉ាងណា ?

វិ. អ្នកមិនប្រមាទបើទុកជាស្លាប់ហើយ ក៏ហាក់ដូចជារស់នៅនោះ ដោយហេតុថា មនុស្សមិនភ្លេចខ្លួន រមែងធ្វើធម៌ដែល កើត ចាស់ ឈឺ ស្លាប់ ឲ្យអស់ទៅ ដោយអំណាចបំរើននូវវិបស្សនាញាណ ហើយចូលទៅជ្រកក្នុងអមតបុរី ។

បុ. ពួកជនដែលភ្លេចខ្លួន បើទុកជារស់នៅ ក៏ហាក់ដូចជាស្លាប់នោះតើយ៉ាងណា ?

វិ. ពួកជនដែលភ្លេចខ្លួន បើទុកជារស់នៅ ក៏ហាក់ដូចជាស្លាប់នោះ ដ្បិតថា មនុស្សទាំងនោះ បើគ្រហស្ថក្តី ក៏ឥតមានចិត្តណាមួយគិតថា អញនឹងឲ្យទាន រក្សាសីល រក្សាឧបោសថ សោះឡើយ បំណែកបព្វជិតរកគំនិតគិតថា អញនឹងបំពេញវត្តមានអាចារិយវត្តនឹងឧបជ្ឈាយវត្តជាដើម អញនឹងសមាទាននូវធុតង្គ នឹងបំរើនមេត្តាភាវនា ដូច្នេះក៏មិនមាន ពួកជនដែលរស់នៅយ៉ាងនេះ ក៏ហាក់ដូចជាស្លាប់ ព្រោះគេចមិនផុតអំពី ជាតិ ជរា ព្យាធិ មរណៈ ផង មិនមានគំនិតដូចគ្នានឹងខ្មោច ឬដើមឈើ ដែលឥតវិញ្ញាណផង ។

បុ. មនុស្សភ្លេចសតិ នាំឲ្យខូចធម៌ប៉ុន្មាន ឲ្យចំរើនធម៌ប៉ុន្មានយ៉ាង? គឺធម៌អ្វីខ្លះ

វិ. មនុស្សភ្លេចសតិ នាំឲ្យខូចធម៌ ៤ យ៉ាង គឺឲ្យខូចសំវរ (ការសង្រួមឥន្ទ្រិយទាំងប្រាំមួយ) ១ ឲ្យខូចសុចរិត ១ ឲ្យខូចសមថកម្មដ្ឋាន ១ ឲ្យខូចវិបស្សនាបញ្ញា ១ នឹងឲ្យចំរើនធម៌ ៤ យ៉ាង គឺឲ្យចំរើនអភិជ្ឈានឹងទោមនស្ស ១ ឲ្យចំរើនទុច្ចរិត ១ ឲ្យចំរើននីវរណ ១, ឲ្យចំរើនអវិជ្ជា ១ ។

បុ. អភិជ្ឈានឹងទោមនស្សកើតមកពីធម៌អ្វី? ចូរអធិប្បាយ

វិ អភិជ្ឈានឹងទោមនស្សកើតមកពីមិនសង្រួមឥន្ទ្រិយ ។ អធិប្បាយថា: ឥន្ទ្រិយទាំង ៦ មានមុខក្រសួងធំដោយបំណែក ៗ គឺភ្នែកធំខាងមើលរូប ត្រចៀកធំខាងស្តាប់សំឡេង ច្រមុះធំខាងស្រូបក្លិន អណ្តាតធំខាងដឹងរសជាតិ កាយធំខាងប៉ះពាល់នូវផោដ្ឋព្វារម្មណ៍ ចិត្តធំខាងទទួលយកអារម្មណ៍ដែលចូលមកតាមទ្វារទាំង៦ ។ ដូចភ្នែកឃើញរូបណាមួយជាទីគួរប្រាថ្នា ចិត្តដឹងច្បាស់កាលណាក៏កើតទៅជាអភិជ្ឈា គឺសេចក្តីលោភចង់បាន កាលបើឃើញរូបមិនជាទីប្រាថ្នា ក៏កើតទៅជាទោមនស្ស

គឺសេចក្ដីស្អប់ឃ្នាន់ខ្នាញ់ ។ ឯសេចក្ដីអធិប្បាយក្នុងឥន្ទ្រិយទាំង ៥ ទៀតក៏ដូចគ្នាដែរ ។ កាលបើចិត្តកើតទៅជាអភិជ្ឈានិងទោមនស្សហើយ មុខតែនឹងប្រព្រឹត្តធ្វើនូវការអាក្រក់មិនលែង បើមិនអាក្រក់ដោយកាយ ក៏អាក្រក់ដោយសំដី ឬអាក្រក់ដោយចិត្ត ។

បុ. អាក្រក់ដោយកាយមានប៉ុន្មាន អាក្រក់ដោយសំដីមានប៉ុន្មាន អាក្រក់ដោយចិត្តមានប៉ុន្មាន គឺអ្វីខ្លះ? ចូរអធិប្បាយ

វិ. អាក្រក់ដោយកាយមាន ៣ គឺសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាម ១ ។ អាក្រក់ដោយសំដីមាន ៤ គឺ កុហកគេ ១ និយាយញុះញង់គេ ១ និយាយពាក្យទ្រគោះ ១ និយាយពាក្យឥតប្រយោជន៍ ១ ។ អាក្រក់ដោយចិត្តមាន ៣ គឺ ចង់បានរបស់គេ ១ ចង់ធ្វើឲ្យគេវិនាស ១ មានគំនិតយល់ឃ្វាង ១ សេចក្ដីអធិប្បាយដូចមានក្នុងសៀវភៅគិហិបដិបត្តិស្រាប់ ។

កាលបើទុច្ចរិតទាំង ៣ ប្រការកើតបរិបូណ៌ហើយ នឹងឲ្យបំរើននីវរណធម៌ទៀត ។

បុ. នីវរណធម៌ ប្រែថាដូចម្ដេច ធម៌នោះមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ? ចូររៀបរាប់ឲ្យសព្វគ្រប់មកមើល

វិ. នីវរណធម៌ ប្រែថាធម៌សម្រាប់រាំងគំនិតសត្វលោក ឲ្យកៀងជាប់នៅក្នុងភពទាំង ៣ គឺ កាមភព ១ រូបភព ១ អរូបភព ១ ។ ធម៌នោះមាន ៥ យ៉ាង គឺ កាមច្ឆន្ទ សេចក្ដីពេញចិត្តនឹងកាម ១ ព្យាបាទ សេចក្ដីប៉ុនប៉ងឲ្យគេវិនាស ១ ថីនមិទ្ធ ងងុយដេក ១ ឧទ្ធច្ចកុក្កុច្ច សេចក្ដីអណ្ដែតអណ្ដូង នឹងរាយមាយរសាប់រសល់ចិត្ត ១ វិចិកិច្ឆា សេចក្ដីសង្ស័យក្នុងគុណរតនត្រ័យមិនបេះដាច់ ១ កាលបើធម៌ទាំង ៥ នេះមាន ហើយជាបច្ច័យដល់អវិជ្ជាទៀត ។

បុ. អវិជ្ជា ប្រែថាដូចម្ដេច ទុកជាអ្វី ដូចពុទ្ធភាសិតយ៉ាងណា បើតាមវត្ថុនឹងអត្ថនឹងទោស មានប៉ុន្មាន គឺអ្វីខ្លះ? ចូរអធិប្បាយឲ្យពិស្តារ

វិ. អវិជ្ជា ប្រែថា មិនដឹង ទុកជាក្បាលនៃអកុសលធម៌ទាំងពួង ដូចពុទ្ធភាសិតដែលឆ្លើយប្រស្នានឹងអភិធមាពពពថា

អវិជ្ជាមុទ្ធាតិ ជានាហិ អ្នកឯងចូរចាំថា អវិជ្ជាជាក្បាលអកុសល វិជ្ជាមុទ្ធាតិ បាតិធី លុះតែរកវិជ្ជាបានទើបទៅទំលាក់អវិជ្ជាបាន[១] ។ បើចាត់តាមវត្ថុមាន ៨ គឺ ១- ទុក្ខេ អញ្ញាណំ មិនដឹងកងទុក្ខ ២- ទុក្ខសមុទយេ អញ្ញាណំ មិនដឹងហេតុដែលនឹងឲ្យកើតទុក្ខ ៣- ទុក្ខនិរោធេ អញ្ញាណំ មិនដឹងឧបាយដែលរំលត់ទុក្ខ ៤- ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ មិនដឹងផ្លូវជាទីដើរទៅកាន់ឧបាយដែលរំលត់ទុក្ខ ៥- បុព្វន្តេ អញ្ញាណំ មិនដឹងទីបំផុតខាងដើមរបស់សង្សារវដ្ដ ៦- អបរន្តេ អញ្ញាណំ មិនដឹងទីបំផុតខាងចុងនៃសង្សារវដ្ដ ៧- បុព្វន្តាបរន្តេ អញ្ញាណំ មិនដឹងទីបំផុតខាងដើមនឹងទីបំផុតខាងចុងនៃសង្សារវដ្ដ ៨- បដិច្ចសមុប្បាទេ អញ្ញាណំ មិនដឹងធម៌ដែលជាបច្ច័យឲ្យកើតតៗគ្នា[២] ។ បើចាត់ដោយអត្ថមាន ២៣ យ៉ាងគឺ

---

១ ខុទ្ទកនិកាយសុត្តនិបាត ។ ២ ធម៌ទី ១ ដល់ធម៌ទី ៤ ចូរមើលក្នុងសៀវភៅអរិយសច្ច ធម៌ទី ៥ ដល់ធម៌ទី ៧ មើលក្នុងសៀវភៅអភិធម្មត្ថសង្គហ ត្រង់និបាយពីវដ្ដ ៣ ប្រការ ធម៌ទី ៨ ចូរមើលក្នុងសៀវភៅបដិច្ចសមុប្បាទធម៌ ។

១- អញ្ញាណំ មិនដឹង ២- អទស្សនំ មិនឃើញ ៣- អនភិសមយោ មិនបានត្រាស់ដឹង ៤- អននុពោធោ មិនភ្ញាក់រលឹក ៥- អសម្ពោធោ មិនត្រាស់ដឹងព្រម ៦- អប្បដិវេធោ មិនចាក់ធ្លុះនូវមគ្គនឹងផល ៧- អសង្គាហណា កំណត់មិនបាន ៨- អបរិយោគាហណា ស្ទង់ចុះមិនបាន ៩- អសមបេក្ខនា ឥតមានទំនងគយគន់មើលបាន ១០- អបច្ចវេក្ខណា ឥតមានទំនងពិចារណាឃើញបាន ១១- អបច្ចក្ខកម្មំ ជាអំពើមិនប្រាកដ ១២- ទុម្មេជ្ឈំ ឥតប្រាជ្ញ ១៣- ពាល្យំ មានសភាពល្ងង់ ១៤- អសម្បជញ្ញំ មានសភាពមិនដឹងខ្លួន ១៥- មោហោ វង្វេងភាន់ភាំង ១៦- សម្មោហោ វង្វេងជ្រប់ ១៧- អវិជ្ជោឃោ សេចក្តីល្ងង់ជាអន្លង់ឲ្យសត្វលិចលង់ ១៨- អវិជ្ជាយោគោ អវិជ្ជាជាគ្រឿងចងសត្វ ១៩- អវិជ្ជានុសយោ អវិជ្ជាជាធម្មជាតិដេកនៅក្នុងចិត្តសត្វ ២០- អវិជ្ជាសរោ សេចក្តីល្ងង់ជាគ្រឿងត្រាំសត្វ ២១- អវិជ្ជាបរិយុដ្ឋានំ សេចក្តីល្ងង់ជាគ្រឿងស្ទាក់ផ្លូវ ២២- អវិជ្ជាជាលំ សេចក្តីល្ងង់ជាសំណាញ់ ២៣- មោហោ អកុសលមូលំ សេចក្តីល្ងង់ជា

ឫសនៃអកុសលធម៌ទាំងពួង[១] ។ បើចាត់តាមទោសមាន ៥ គឺ ១- អនិច្ចត្ថេន ដោយសេចក្តីថាញុំាងសត្វឲ្យតាំងនៅមិនទៀង ២- ទុក្ខត្ថេន ដោយសេចក្តីថានាំសត្វឲ្យកើតទុក្ខ ៣- អនត្តត្ថេន ដោយសេចក្តីថាធ្វើសត្វឲ្យបានតែស្រាយៗ ៤- សន្តាបត្ថេន ដោយសេចក្តីថាញុំាងសត្វឲ្យក្តៅក្រហាយ ៥- វិបរិណាមត្ថេន ដោយសេចក្តីថាធ្វើសត្វឲ្យទ្រុតទ្រោម ប្រែប្រួលទៅតាមកាលតាមវេលា[២] ។

ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធជាម្ចាស់ត្រាស់ថា អវិជ្ជានេះហើយជាពូជនៃសេចក្តី កើត ចាស់ ឈឺ ស្លាប់ មនុស្សដែលប្រកបដោយអវិជ្ជា ឈ្មោះថាជាមនុស្សមានពូជស្លាប់ពិតប្រាកដ ។ អវិជ្ជា មានសេចក្តីប្រមាទ ឬភ្លេចសតិ ជាឫសព្រោះអវិជ្ជា កើតមកពីនីវរណៈៗ កើតមកអំពីទុច្ចរិតៗ កើតមកពីអសំវរៈៗ កើតមកពីមិនមានសតិ ។ ឯពាក្យថាមិនមាន

---

១ អត្ថរបស់អវិជ្ជា ២៣ យ៉ាងនេះ មានក្នុងគម្ពីរខុទ្ទកនិកាយចុល្លនិទ្ទេស ។ ២ មានក្នុងគម្ពីរបដិសម្ភិទាមគ្គ ។

សតិនឹងពាក្យថាប្រមាទក៏ជាសេចក្ដីជាមួយគ្នា ហេតុនេះបមាទធម៌ចាត់ជាកំពូលនៃអកុសលធម៌ទាំងពួង ដូចពុទ្ធភាសិតដែលព្រះភគវន្តមុនីទ្រង់ត្រាស់ទុកមកថា សេយ្យថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ, សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ, ហត្ថិបទំ តេសំ អគ្គមក្ខាយតិ, យទិទំ មហន្តត្តេន ឯវមេវ ខោ ភិក្ខវេ យេ កេចិ អកុសលា ធម្មា, សព្វេ តេ បមាទមូលកា បមាទសមោសរណា, បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ (ប្រែថា) ម្នាលភិក្ខុទាំងឡាយ ស្នាមជើងសត្វដែលនៅលើផែនដីទាំងប៉ុន្មាន ក៏មកប្រជុំចុះក្នុងស្នាមជើងដំរី គឺថាតូចជាងស្នាមជើងដំរីទាំងអស់ ឯស្នាមជើងដំរី តថាគតពោលថា ជាកំពូលរបស់ស្នាមជើងសត្វទាំងនោះ ព្រោះថាស្នាមជើងដំរីនោះជាស្នាមជើងធំជាងគេ, ម្នាលភិក្ខុទាំងឡាយ ធម៌ជាអកុសលទាំងពួង ក៏សឹងតែមានបមាទធម៌ជាឫស តែងមកប្រជុំក្នុងបមាទធម៌ទាំងអស់ តថាគតហៅ បមាទធម៌ (នេះ) ថាជាកំពូលរបស់អកុសល់ធម៌ទាំងនោះ ។

មានពុទ្ធភាសិត ១ ទៀតសំដែងថាៈ បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា ប្រែថាៈ ជនដែលប្រកបដោយប្រមាទ ឈ្មោះថាជាជនល្ងង់អប្បតិតប្រាជ្ញា ព្រោះមិនដឹងគួរប្រយោជន៍ ក្នុងលោកនេះនឹងលោកខាងមុខ ធ្វើកាលគីរិយ[១] ទាំង ៣ ឲ្យកន្លងទៅទទេ ៗ ព្រោះមិនឃើញទោសនៃសេចក្តីប្រមាទ ដូចបានពណ៌នាមកហើយ ។ ឯព្រះពុទ្ធជាមហេឫសី ទ្រង់ជប្បមនុស្សមានសេចក្តីប្រមាទឲ្យរស់ឡើង ដូចភាសិតថាៈ

បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

ប្រែថា អ្នកប្រាជ្ញមានព្រះពុទ្ធជាដើម បានកំចាត់បង់នូវបមាទធម៌ ដោយអប្បមាទធម៌ក្នុងកាលឯណាហើយ លោកក៏ឡើងកាន់ប្រាសាទពោលគឺបញ្ញា ជាអ្នកមិនមានសេចក្តីសោក អាចក្រឡេកមើលនូវពួកមនុស្សដែលមានសេចក្តីសោក (ព្រោះកើត ស្លាប់ គ្មានឈប់) បានក្នុងកាលនោះ, (ម្យ៉ាងទៀត)

---

១ ចូរមើលក្នុងសៀវភៅអត្ថានុសាសនី ។

លោកអ្នកប្រាជ្ញ (នោះ) តែងរមិលមើលនូវមនុស្សពាលអប្បឥតប្រាជ្ញា (កំពុងកើតស្លាប់) ដូចជាគេដែលឈរលើកំពូលភ្នំ ហើយមើលមកមនុស្សដែលឈរនៅខាងក្រោម ឃើញបានដោយសព្វគ្រប់ ។

បុ. មនុស្សដែលមិនប្រមាទ ឬប្រកបដោយសតិនោះ អាចកំចាត់បង់នូវធម៌ប៉ុន្មានយ៉ាងបាន ធម៌នោះគឺអ្វីខ្លះ? ចូរអធិប្បាយ

វិ. មនុស្សដែលប្រកបដោយសតិនោះ អាចកំចាត់បង់នូវធម៌ ៤ ប្រការបាន គឺលះអភិជ្ឈានិងទោមនស្ស ១, លះទុច្ចរិតបី ១ លះនីវរណប្រិ ១, លះអវិជ្ជា ១ ហើយធ្វើធម៌ទាំង ៤ ប្រការឲ្យចំរើនឡើងគឺ ១- សំវរ, ២- សុចរិត, ៣- សមថកម្មដ្ឋាន[1] ៤- វិបស្សនាបញ្ញា[2] ។ អធិប្បាយថា: ការដែលសង្រួមឥន្ទ្រិយទាំង ៦ បាន អាស្រ័យដោយសេចក្តីមិនធ្វេសប្រហែស គឺលើកសតិឡើងពិចារណានូវ កាយ វេទនា ចិត្ត ធម្មារម្មណ៍

១-២ ចូរមើលក្នុងសៀវភៅអភិធម្មត្ថសង្គហៈរបស់ព្រះឧត្តមមុនី និងមាននិយាយអំពីចរិត និងរបៀបចំរើនដោយសព្វគ្រប់ ។

ឲ្យឃើញថាជារបស់ មិនទៀង ជាទុក្ខ និងជាអនត្តា ។ លុះពិ-ចារណាដូច្នេះហើយ ជាហេតុឲ្យលះបង់នូវអភិជ្ឈានិងទោមនស្សបាន កាលបើអភិជ្ឈានិងទោមនស្សរលត់ហើយ ទើបបំពេញនូវសុចរិតទាំងបីបាន លុះបំពេញសុចរិតបានផូរផង់ល្អហើយ ទើបបំរើននូវសមថកម្មដ្ឋានបាន កាលបើសមថកម្មដ្ឋានដែលបុគ្គលបានបំរើនល្អហើយ ជាបច្ច័យឲ្យបំរើននូវវិបស្សនាបញ្ញាទៀត វិបស្សនាបញ្ញានេះជាគ្រឿងកំចាត់ពូជអកុសលពោលគឺអវិជ្ជាបាន ។

ហេតុនេះ សេចក្តីមិនប្រមាទបាត់ជាកំពូលនៃកុសលធម៌ទាំងពួង ដូចពុទ្ធភាសិតទ្រង់ត្រាស់សំដែងទុកមកថាៈ សេយ្យ-ថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ, សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ, ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន; ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា, សព្វេ តេ អប្បមាទមូលកា អប្បមាទ-សមោសរណា, អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ

(ប្រែថា) ម្នាលភិក្ខុទាំងឡាយ ស្នាមជើងសត្វដែលទៅលើផែនដីទាំងប៉ុន្មាន ក៏មកប្រជុំចុះក្នុងស្នាមជើងដំរី គឺថាតូចជាងស្នាមជើងដំរីទាំងអស់ ឯស្នាមជើងដំរី តថាគតពោលថាជាកំពូលរបស់ស្នាមជើងសត្វទាំងនោះ ព្រោះថាស្នាមជើងដំរីនោះជាស្នាមជើងធំជាងគេ យ៉ាងណាមិញ; ម្នាលភិក្ខុទាំងឡាយ ធម៌ជាកុសលទាំងអស់ ក៏សឹងមានសេចក្តីមិនប្រមាទជាឫសតែងមកប្រជុំក្នុងអប្បមាទទាំងអស់ តថាគតហៅអប្បមាទធម៌ (នេះ) ជាកំពូលរបស់កុសលធម៌ទាំងនោះ ។

ហេតុនេះអ្នកមានប្រាជ្ញាមិនគួរធ្វេសប្រហែសឡើយ ចូរនាំគ្នាស្វែងរកទ្រព្យសម្បត្តិក្នុងលោកនេះ នឹងបរលោកឲ្យបាន ហើយត្រូវរក្សាទ្រព្យទាំងពីរនោះកុំឲ្យខូចអន្តរាយ ហើយចូរឲ្យប្រកបដោយអប្បមាទធម៌ ព្រោះថាអប្បមាទធម៌នេះ តែងដុតកិលេសធម៌ឲ្យអស់ទៅ ហើយនឹងបានជួបប្រទះនូវសេចក្តីសុខដ៏ធំទូលាយ ពោលគឺព្រះនិព្វាន (ក្នុងលោកខាងមុខ) ។

ចប់ ផ្នែកទី ១ ។

## ផ្នែកទី ២

ក្នុងផ្នែកទី ២ នេះក៏ត្រូវនិយាយពីអប្បមាទទៀត ប៉ុន្តែមិនបានធ្វើជាពាក្យសួរឆ្លើយទេ ធ្វើជាសេចក្ដីរាយអធិប្បាយតាមអត្ថនោមតិខ្លះ នឹងដកស្រង់យកគាថាជាភាសិតយកមកទុកប្រដាប់សតិបញ្ញារបស់កុលបុត្រអ្នកសិក្សាបរិយត្តិធម៌ខ្លះប៉ុណ្ណោះ ដូចមានសេចក្ដីហូរហែតទៅនេះ៖

ក្នុងអដ្ឋកថាធម្មបទប្រាប់សេចក្ដីថា៖ សូម្បីការរៀនពុទ្ធវចនគឺព្រះត្រៃបិដកទាំងមូលបានចេះចាំនោះក៏ដោយ ព្រោះតែអាស្រ័យសេចក្ដីមិនប្រមាទទាំងអស់ ហេតុនេះសេចក្ដីមិនប្រមាទចាត់ថាជាធម៌អាចជម្រុលមនុស្សប្រុសស្រី ឲ្យរៀនសូត្របំណោះវិជ្ជាផ្សេង ៗ ឲ្យចេះចាំទៅបាន ព្រោះហេតុនោះការចេះដឹងមានមូលមកអំពីមិនប្រមាទ ឯការចេះដឹងក៏ជាមូលរបស់សេចក្ដីល្អអាក្រក់ គ្រប់យ៉ាង ឯសេចក្ដីល្អអាក្រក់គ្រប់យ៉ាងនោះទៀតសោតច្រើនមានមកតែក្នុងភាសិតទាំង ៤ យ៉ាង[១]

---

១ ពុទ្ធភាសិត ១ សាវកភាសិត ១ ឥសីភាសិត ១ ទេវតាភាសិត ១ ។

ឯភាសិតទាំង ៤ យ៉ាងនោះសឹងមានជាភាសាបាឡី ឬភាសាសំស្ក្រឹត បើមានបារិកក្នុងភាសាឯទៀត ៗ ជាភាសាសម្រាយគ្រប់ប្រទេសនោះ ក៏មានតិចតួច ហើយមិនទៀងទាត់ដូចជាភាសាបាឡីនឹងភាសាសំស្ក្រឹតឡើយ ។ ក៏ឯភាសាទាំងពីរនោះជាភាសាលំបាកពេកណាស់ បើអ្នកដែលមិនរៀនសូត្រឲ្យចេះដឹងបាឡីទេ ក៏មិនអាចនឹងដឹងសេចក្ដីបានឡើយ លុះតែអ្នកដែលខំរៀនសូត្រឲ្យចេះដឹងបាឡីទើបមើលយកសេចក្ដីបាន ។

ឯភាសិតជាភាសាបាឡីនោះ ខ្ញុំនឹងដាក់បន្តទៅខាងមុខនេះ បំណែកភាសិតជាភាសាសំស្ក្រឹត[១]នោះមិនបានដាក់មកផងទេ ។

(១) អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ
អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ និព្វានំ

១ ចូរមើលក្នុងភាសិតដែលព្រះតេជព្រះគុណព្រះវិសុទ្ធិវង្ស បានរៀបរៀងពោះពុម្ពបញ្ចុះដិជាមួយគ្នានឹងសៀវភៅនេះចុះ ។

មនុស្សខ្ជិលនឹងមានសិល្បសាស្ត្រពីណា មនុស្សមិនមានសិល្បសាស្ត្រ នឹងរកទ្រព្យពីណាបាន មនុស្សមិនមានទ្រព្យ នឹងមានមិត្តសំឡាញ់ពីណា មនុស្សមិនមានមិត្តសំឡាញ់ នឹងបានសេចក្ដីសុខពីណា មនុស្សមិនមានសេចក្ដីសុខ នឹងមានបុណ្យពីណា មនុស្សមិនមានបុណ្យ នឹងបានព្រះនិព្វានពីណា ។

(២) សិប្បសមធនំ នត្ថិ សិប្បំ ចោរា នគណ្ហន្តិ

ឥធ លោកេ សិប្បំ មិត្តំ បរលោកេ សុខាវហំ ។

ទ្រព្យទាំងអស់ (ក្នុងលោកនេះ) ស្មើដោយសិល្បសាស្ត្រមិនមានឡើយ ដ្បិតសិល្បសាស្ត្រចោរលួចយកទៅមិនបាន ក្នុងលោកនេះ បានសិល្បសាស្ត្រជាមិត្តសំឡាញ់ ដល់ទៅក្នុងបរលោក នឹងនាំសេចក្ដីសុខមកឲ្យ ។

(៣) ពោធ បុត្ត សទា វិជ្ជំ មា ខេទាបរិយំ គរុំ

សទេសេ បូជិតោ រាជា ពុធោ សព្វត្ថ បូជិតោ ។

កូនចៅអើយចូរអ្នកខំរៀនវិជ្ជា គ្រប់កាល កុំឲ្យលំបាកគ្រូអាចារ្យលោកដាស់តឿន ដ្បិតព្រះរាជា មានមនុស្សបូជា

(រាប់អាន) តែក្នុងប្រទេសរបស់ព្រះអង្គទេ ឯអ្នកប្រាជ្ញ មានគេបូជា (រាប់អាន) គ្រប់ទីកន្លែង ។

(៤) ពោធ បុត្ត កិមាលសេ អពោធោ ភារវាហកោ
ពោធកោ បូជិតោ លោកេ ពោធ បុត្ត ទិនេ ទិនេ ។

កូនចៅអើយ ចូរអ្នកខំរៀនកុំខ្ជិលច្រអូស ព្រោះមនុស្សល្ងង់ច្រើនធ្វើការធ្ងន់ៗក្នុងលោកនេះ គេរាប់អានតែអ្នកប្រាជ្ញទេ ចូរកូនចៅឯងខំឲ្យបានជាអ្នកប្រាជ្ញ ១ ថ្ងៃបន្តិចៗ ។

(៥) សព្វសុតមធិយេថ ហីនមុក្កដ្ឋមជ្ឈិមំ
សព្វស្ស អត្ថំ ជានេយ្យ ន ច សព្វំ បយោជយេ ។

គួររៀនបំណេះវិជ្ជាគ្រប់យ៉ាង ទោះបែបថោកទាប ខ្ពស់ កណ្ដាលក៏ដោយ នឹងគួរដឹងប្រយោជន៍សេចក្ដីនោះដឹងគ្រប់យ៉ាង តែមិនគួរប្រកបកិច្ចគ្រប់យ៉ាងនោះទេ ។

(៦) ន លោកេ សោភតេ មូឡ្ហោ កេវលត្តបសំសកោ
អបិសម្បិ ហិតោ កូបេ កតវិជ្ជោបកាសិតោ ។

មនុស្សល្ងង់បេះតែលើកដំកើងខ្លួនប៉ុណ្ណោះ មិនបានរុង-រឿងក្នុងលោកឡើយ មនុស្សដែលមានបំណេះវិជ្ជា ទោះធ្លាក់ទៅក្នុងរណ្ដៅក៏នៅតែ (មានមនុស្សរាប់អាន) ។

(៧) មទន្ទមទនំ សត្ថុំ ខលានំ កុរុតេ មទំ

បក្ខុសង្ខារកំ តេជំ ឧលូកានមិវន្ធកំ ។

គម្ពីរគឺក្បួនច្បាប់ អាចបង្ហាត់មនុស្សដែលស្រវឹងបាន តែមិនអាចនឹងធ្វើសេចក្ដីស្រវឹងរបស់មនុស្សពាលឲ្យអស់ទៅទេ ដូចជាភ្លើងឡេតខ្លីដល់មនុស្សដែលមានភ្នែក បំណែកសត្វមៀមទៅជាងងឹតភ្នែកវិញ ។

(៨) ភោជនំ មេថុនំ និទ្ទា គវេ បោសេ ប. វិជ្ជតិ

វិជ្ជា វិសេសោ បោសស្ស តំ ហីនោ គោណសមោ ភវេ ។

ការបរិភោគ មេថុនធម្ម ដេក មានទូទៅទាំងគោទាំងមនុស្ស តែវិជ្ជាធ្វើបុរសឲ្យវិសេស បើបុរសដែលមិនមានបំណេះវិជ្ជាទុកស្មើដូចជាគោ ។

(៩) យោ សិស្សោ សិប្បលោភេន ពហុំ ពហុំ វ គណ្ហតិ

មូគោវ សុបិនំ បស្សំ ន សក្កា កបិតុំ បរំ ។

សិស្សឯណាលោភក្នុងសិល្បសាស្ត្រ រៀនម្តងៗ ចង់ឲ្យបានច្រើនៗ កូនសិស្សនោះទុកដូចជាមនុស្សគេដេកយល់សប្តិ ព្រោះនិយាយប្រាប់គេមិនកើត ។

(១០) ឧដ្ឋាតា ឧបដ្ឋានារិ សុស្សូសា បរិចារិកា
សក្កច្ចំ សិប្បុគ្គហណំ គរុំ អារាធយេ ពុធោ ។

ការក្រោកទទួល ១ ការទំនុកបំរុង ១ ជឿស្តាប់ ១ កិច្ចបម្រើ ១ រៀនសិល្បសាស្ត្រដោយគោរព ១ (កិច្ចល្អទាំង៥នេះ) អ្នកមានប្រាជ្ញាគួរធ្វើគ្រូឲ្យលោកត្រេកប្រាណ ។

(១១) ឧបជ្ឈាចរិយានញ្ច មាតាបិតូនមេវ ច
សក្កច្ចំ យោ នុបដ្ឋាតិ សុតោបិ តស្ស តាទិសោ ។

អាចារ្យឯណាមិនទំនុកបំរុងឧបជ្ឈាចារ្យ នឹងមាតាបិតាដោយគោរពទេ សូម្បីកូនសិស្សគេក៏មិនទំនុកបំរុងអាចារ្យនោះដែរ ។

(១២) ឧបជ្ឈាចរិយានញ្ច មាតាបិតូនមេវ ច
សក្កច្ចំ យោ ឧបដ្ឋាតិ សុតោបិ តស្ស តាទិសោ ។

អាចារ្យឯណាតែងទំនុកបំរុងឧបជ្ឈាចារ្យ នឹងមាតាបិតាដោយគោរពហើយ សូម្បីកូនសិស្សក៏ទំនុកបំរុងអាចារ្យនោះដែរ ។

(១៣) សភាវសទិសំ វាក្យំ សភាវសទិសំ ប៉យំ
សភាវសទិសំ កោធំ យោ ជានាតិ ស បណ្ឌិតោ ។

អ្នកណាចេះនិយាយក៏សមគួរតាមភាពខ្លួន ចេះស្រឡាញ់ក៏សមគួរតាមភាពខ្លួន ចេះខឹងក៏សមគួរតាមភាពខ្លួន អ្នកនោះទើបហៅថា បណ្ឌិត (អ្នកចេះ) ។

(១៤) ហិរញ្ញេន មិគាគំ សុសីលេន អសីលិនោ
អធម្មិកស្ស ធម្មេន ពាលានម្បិ សុតេន កំ ។

ហ្វូងម្រឹគឥតមានត្រូវការអ្វីដោយប្រាក់ មនុស្សមិនមានសីលក៏ឥតត្រូវការអ្វីដោយសីលល្អ មនុស្សឥតធម៌ក៏មិនត្រូវការអ្វីដោយធម៌ បំណែកមនុស្សពាល ដូចម្ដេចនឹងត្រូវការដោយសេចក្ដីចេះដឹង ។

(១៥) អប្បស្សុតាយំ បុរិសោ ពលិពទ្ទោ វ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។

បុរសមិនមានសេចក្ដីចេះដឹង រមែងរេបរិលដូចជាគោទឹម រទេះ ដុំសាច់របស់វាចេះតែចំរើន តែត្រង់បញ្ញារបស់វាមិនចំរើនឡើយ ។

(១៦) អប្បស្សុតោ សុតំ អប្បំ ពហុំ មញ្ញតិ មានិកោ
សិន្ធុទកំ អប្បស្សន្តា កូបេតោយំវ មណ្ឌុកោ ។

មនុស្សចេះដឹងតិច មានមានៈសំគាល់សេចក្ដីចេះដឹងតិចថាជាច្រើន ដូចជាសត្វកង្កែបដែលមិនបានឃើញសមុទ្រ ចេះតែសំគាល់ទឹកអណ្ដូងតូចថាច្រើនជាង (ទឹកសមុទ្រ) ។

(១៧) សីហមេទា សុវណ្ណេន ន ច តិដ្ឋន្តិ វដតេ
បណ្ឌិតានំ តថា វាក្យំ ន ច តិដ្ឋន្តិ ទុជ្ជនេ ។

ខ្លាញ់សត្វសីហៈ មិនដក់នៅក្នុងផ្ដិលមាសនឹងផ្ដិលប្រាក់យ៉ាងណាមិញ ឯពាក្យរបស់បណ្ឌិតក៏មិនដក់នៅក្នុងចិត្តមនុស្សទុជ្ជនដូច្នោះឯង ។

(១៨) មហាតេជោបិ តេជោយំ មត្តិកំ ន មុទុំ ករេ
អាបោ បាចេតិ មុទុកំ សាធុ វាចា ច កក្ខឡំ ។

ភ្លើងនេះសូម្បីមានតេជៈមហិមា ក៏ធ្វើដីឲ្យទន់មិនបាន មានតែទឹកទើបធ្វើដីឲ្យទន់បាន ឯវាចារបស់សាធុជន រមែងធ្វើមនុស្សដែលរឹងរូសឲ្យទន់ទៅបាន ។

(១៩) មុទុនារ រិបុំ ជេតិ មុទុនា ជេតិ ទារុណំ
នាសិទ្ធិ មុទុនា កិញ្ចិ យតោតោ មុទុនា ជយេ ។

គេឈ្នះសត្រូវក៏ដោយពាក្យទន់ ឈ្នះសេចក្ដីអាក្រក់ក៏ដោយពាក្យទន់ អ្វីៗដែលមិនសម្រេចដោយពាក្យទន់មិនមានឡើយ ហេតុនោះគប្បីឈ្នះដោយពាក្យទន់គ្រប់យ៉ាងចុះ ។

(២០) បត្តកល្លោទិតំ អប្បំ វាក្យំ សុភាសិតំ ភវេ
ខុទ្ទិតស្ស កទន្នម្បិ ភុត្តំ សាទុរសោ ភវេ ។

ពាក្យតិចតួចដែលនិយាយត្រូវតាមកាល ក៏បាត់ជាពាក្យពីរោះបាន មើលតែអាហារដែលមិនឆ្ងាញ់ចុះ បើឃ្លានស៊ីទៅគង់តែឆ្ងាញ់ ។

(២១) សត្តកាបិ ពហុវាចា នាទរា ពហុភាណិនោ
សោបការម្បុទាសីនំ នតុ ទិដ្ឋំ នទំ ជលំ ។

មនុស្សនិយាយច្រើន (ហួសកាល) ស្ដីវាជាច្រើននោះ ប្រកបដោយប្រយោជន៍ ក៏មិនសូវមានអ្នកណាអើពើឡើយ មើលបុះទឹកក្នុងទន្លេ សូម្បីមានឧបការច្រើន ពួកទាសីអ្នកដងទឹក ក៏ដឹតឃើញឧបការ(ទឹក)ខ្លះ ។

(២២) មាតា ហីនស្ស ទុព្ភាសា បិតា ហីនស្ស ទុក្រិយា

ឧភោ មាតាបិតា ហីនា ទុព្ភាសា ច ទុក្រិយា ។

ម្ដាយនិយាយអាក្រក់ កូនក៏និយាយអាក្រក់តាម បិតាកិរិយាអាក្រក់ កូនក៏មានកិរិយាអាក្រក់តាម បើមាតាបិតាទាបថោក (អាក្រក់) ទាំងពីរនាក់ កូនក៏និយាយអាក្រក់នឹងមានកិរិយាអាក្រក់តាម ។

(២៣) មាតា សេដ្ឋស្ស សុភាសា បិតា សេដ្ឋស្ស សុក្រិយា

ឧភោ មាតាបិតា សេដ្ឋា សុភាសា ច សុក្រិយា ។

មាតានិយាយពាក្យប្រសើរសុភាព កូនក៏និយាយពាក្យប្រសើរសុភាពតាម បិតាមានកិរិយាប្រសើរសុភាព កូនក៏មានកិរិយាប្រសើរសុភាពតាម បើមាតានឹងបិតានិយាយពាក្យ

ប្រសើរនឹងកិរិយាសុភាពទាំងពីរនាក់ ក្មួនក៏និយាយពាក្យប្រ-សើរនឹងមានកិរិយាសុភាពតាម ។

(២៨) បឋវីភូសនំ មេរុ រត្តិយា ភូសនំ សសី
ជនានំ ភូសនំ រាជា សេនាយ ភូសនំ គជោ ។

ភ្នំជាគ្រឿងប្រដាប់របស់ផែនដី ក្នុងរាត្រីមានព្រះចន្ទជាគ្រឿងប្រដាប់ ស្តេចជាគ្រឿងប្រដាប់របស់ជនទាំងឡាយ ដំរីជាគ្រឿងប្រដាប់របស់សេនា ។

(២៩) សីលតា សោភតេ រូបំ ចារិតា សោភតេ កុលំ
សបុប្ផា សោភតេ វញ្ញំ សគជា សោភតេ ពលំ ។

រូបមានសីលជាគ្រឿងលំអ ត្រកូលមានការប្រព្រឹត្តល្អជាគ្រឿងលំអ ព្រៃមានផ្កាជាគ្រឿងលំអ ពលមានដំរីជាគ្រឿងលំអ (ដូចគ្នា) ។

(២៦) កោកិលានំ សទ្ទំ រូបំ នារីរូបំ បតិព្វតំ
វិជ្ជា រូបំ អរូបានំ ខមា រូបំ តបស្សិនំ ។

សំឡេងស្រណោះជារូបល្អរបស់សត្វតាវ៉ៅ សេចក្ដីពិតត្រង់នឹងស្វាមីជារូបល្អរបស់នាងនារី វិជ្ជាជារូបល្អរបស់មនុស្សអាក្រក់ សេចក្ដីអត់ធន់ជារូបល្អរបស់ព្រះយោគី ។

(២៧) ទីបកេ ទីបកោ បន្តោ នារិកេ ទីបកោ បតិ
តិលោកេ ទីបកោ ធម្មោ សុបុត្តោ កុលទីបកោ ។

ព្រះបន្ទូរជាប្រទីបក្នុងទ្វីប ប្ដីជាប្រទីបរបស់នារី ធម៌ជាប្រទីបក្នុងត្រៃលោក កូនដែលល្អជាប្រទីបរបស់ត្រកូល ។

(២៨) អបុត្តកំ ឃរំ សុញ្ញំ ទេសំ សុញ្ញំ អរាជិកំ
អបញ្ញស្ស មុខំ សុញ្ញំ សព្វសុញ្ញំ ទលិទ្ទកំ ។

ផ្ទះមិនមានកូន ហៅថាផ្ទះសូន្យទទេ ប្រទេសដែលមិនមានស្ដេច ហៅថាប្រទេសសូន្យទទេ មាត់របស់មនុស្សឥតបញ្ញា ហៅថាមាត់សូន្យទទេ សេចក្ដីក្រលំបាក ហៅថាសូន្យទទេគ្រប់យ៉ាង ។

(២៩) សោតំ សុតេនេវ ន កុណ្ឌលេន
ទានេន ន បាណកំ ន តុកង្គណេន

អាភាតិ កាយោ បុរិសុត្តមស្ស

បរោបការេន ន បន្ធនេន ។

មានត្រចៀកប្រយោជន៍តែនឹងស្តាប់ មិនមែនមានគ្រាន់តែសម្រាប់ពាក់ទំហូរទេ មានដៃប្រយោជន៍នឹងឲ្យទាន មិនមែនមានគ្រាន់តែសម្រាប់ពាក់ខ្សែដៃទេ កាយរបស់មនុស្សខ្ពង់ខ្ពស់ដែលរុងរឿងបានដោយសារធ្វើឧបការឲ្យអ្នកដទៃ មិនមែនមានគ្រាន់តែលាបខ្លឹមបន្ធន៍ទេ ។

(៣០) ទានំ អត្ថចរិយាបិយ- វាចា អត្តសមំបិ ច

សង្គហា ចតុរោ ឥមេ មុនិន្ទេន បកាសិតា ។

ការចែកវត្ថុឲ្យ ១ ប្រព្រឹត្តប្រយោជន៍ ១ មានវាចាគួរស្រឡាញ់ ១ មិនកាន់ខ្លួន ១ ទាំង ៤ នេះព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសថាជាធម៌សម្រាប់យឹតយោងលោក ។

(៣១) វនេ មិគា ន លភន្តិ មតាភយា និទ្ទសុខំ

រាជានោបិ ន លភន្តិ ឧត្តរបាមភីតតោ ។

សំសារភយភីតេន ន រមន្តិ យេ បណ្ឌិតា ។

ហ្វូងម្រឹគនៅក្នុងព្រៃ រមែងដេកមិនលក់ស្និទ្ធព្រោះខ្លាចសេចក្ដីស្លាប់ ស្ដេចទាំងឡាយក្ដីមិនលក់ស្និទ្ធព្រោះខ្លាចសត្រូវដែលមានកំឡាំង ឯបណ្ឌិតមិនសូវមានសេចក្ដីរីករាយព្រោះខ្លាចភ័យក្នុងសង្សារ ។

(៣២) ខមាជាគរិយុដ្ឋានំ សំវិភាគោ ទយិក្ខនា
នាយកស្ស គុណា ឯតេ ឥច្ឆិតព្វាហិតត្ថិនោ ។

សេចក្ដីអត់ធន់ ១ ប្រុងប្រយ័ត្ន ១ ការចែកបាយ ១ សេចក្ដីអាណិត ១ សេចក្ដីប៉ុនប៉ងល្អ ១ ទាំងនេះជាគុណរបស់មនុស្សជានាយកអ្នកដែលត្រូវការដោយប្រយោជន៍គប្បីប្រាថ្នាចុះ ។

(៣៣) បរិភូតោ មុទុ ហោតិ អតិតិក្ខញ្ច វេរវា
ឯតញ្ច ឧភយំ ញត្វា អនុមជ្ឈំ សមាចរេ ។

ទន់គឺខ្លាចពេក ក៏គេជិះជាន់ រឹងគឺកោងពេក គេក៏ចងពៀរ (ហេតុនេះអ្នកមានប្រាជ្ញា) កាលបើដឹងសេចក្ដីទាំងពីរនេះហើយ គួរប្រព្រឹត្តខ្លួនឲ្យជាកណ្ដាលៗ ។

(៣៤) នេកន្តមុទុនា សក្កា ឯកន្តតិតិក្ខេន វា
មហន្តេ ឋបិតុំ អត្តំ តស្មា ឧភយមាចរេ ។

មនុស្សដែលទន់គឺខ្លាចតែម្យ៉ាងក្តី មនុស្សដែលរឹងគឺកោងតែម្យ៉ាងក្តី មិនអាចនឹងធ្វើខ្លួនឲ្យធំបានទេ ព្រោះហេតុនោះ (អ្នកមានប្រាជ្ញា) គួរប្រព្រឹត្តទាំងពីរយ៉ាង (គឺកុំខ្លាចពេក កុំហ៊ានពេក) ។

(៣៥) មហារុក្ខស្ស ផលិនោ អាមំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស ន ជានាតិ ពីជញ្ចស្ស វិនស្សតិ ។

ឈើធំមានផ្លែគ្រប់ដើម អ្នកណាបេះយកផ្លែខ្ចីទៅ អ្នកនោះឈ្មោះថាមិនបានដឹងឬលិឍរសរបស់ផ្លែឈើនោះផង ឈ្មោះថាធ្វើពូជរបស់ឈើឲ្យវិនាសទៅផង ។

(៣៦) មហារុក្ខូបមំ រដ្ឋំ អធម្មេន បសាសតិ
រសញ្ចស្ស ន ជានាតិ រដ្ឋញ្ចាបិ វិនស្សតិ ។

ដែនប្រៀបដូចជាឈើធំ បើស្តេចណាគ្រប់គ្រងមិនត្រូវតាមធម៌ (ច្បាប់) ស្តេចនោះឈ្មោះថាមិនបានសោយនូវរសជាតិគឺការគ្រប់គ្រងផង ឈ្មោះថាធ្វើដែនទាំងមូលឲ្យវិនាសផង ។

(៣៧) ទានំ សីលំ បរិច្ចាគំ អជ្ជវំ មទ្ទវំ តបំ
អក្កោធំ អវិហឹសញ្ច ខន្តិំ ច អវិរោធនំ ។
ឥច្ចេតេ កុសលេ ធម្មេ ឋិតេ បស្សាមិ អត្តនិ ។
(ទសេតេ ធម្មេ រាជានោ អប្បមត្តេន ការយេ ។)

ទាន ១ សីល ១ ការបរិច្ចាគ ១ ចិត្តត្រង់ ១ ចិត្តទន់ ១ តបៈ១ មិនក្រោធ ១ មិនបៀតបៀន ១ អត់ធន់ ១ កាន់មិនខុសយុត្តិធម៌ ១ ធម៌ទាំង ១០ នេះ ព្រះរាជាត្រូវកាន់កុំឲ្យធ្វេសប្រហែស ។

(៣៨) មហារុក្ខស្ស ផលិនោ បក្កំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស វិជានាតិ ពីជញ្ចស្ស ន នស្សតិ ។

ឈើធំរមែងមានផ្លែគ្រប់ដើម អ្នកណាបេះយកផ្លែទុំទៅ (អ្នកនោះ) ឈ្មោះថាបានដឹងឬលិឍរសរបស់ឈើនោះផង ឈ្មោះថាធ្វើពូជរបស់ឈើនោះមិនឲ្យវិនាសទៅផង ។

(៣៩) មហារុក្ខូបមំ រដ្ឋំ ធម្មេន យោ បសាសតិ
រសញ្ចស្ស វិជានាតិ រដ្ឋញ្ចាបិ ន នស្សតិ ។

ដែនប្រៀបដូចជាឈើធំ ស្តេចណាគ្រប់គ្រងត្រឹមត្រូវតាមធម៌ (ច្បាប់) (ស្តេចនោះ) ឈ្មោះថាបានសោយនូវរសគឺការ

គ្រប់គ្រងនោះផង ឈ្មោះថាបានធ្វើដែនទាំងមូលមិនឲ្យវិនាសផង ។

(៤០) យោ ច រាជា ជនបទំ អធម្មេន បសាសតិ
សព្វោសធីហិ សោ រាជា វិរុទ្ធោ ហោតិ ខត្តិយោ ។

ស្តេចណាគ្រប់គ្រងជនបទមិនត្រឹមត្រូវតាមច្បាប់ ស្តេចនោះឈ្មោះថាជាក្សត្រខុសនឹងឱសថ (គឺពួកទេវតា) រក្សាព្រះអង្គគ្រប់ ៗ ផ្លូវ ។

(៤១) បុត្តោ បាបំ កតោ មាតា សិស្សោ បាបំ កតោ គរុ
នាគរេហិ កតោ រាជា រាជា បាបំ បុរោហិតោ ។

កូនធ្វើអាក្រក់ ក៏គេតិះដៀលដល់មាតា សិស្សធ្វើអាក្រក់ ក៏គេតិះដៀលដល់គ្រូ អ្នកនគរធ្វើអាក្រក់ ក៏គេតិះដៀលដល់ស្តេច ស្តេចធ្វើអាក្រក់ ក៏គេតិះដៀលដល់បុរោហិត (អ្នកប្រដៅស្តេច) ។

(៤២) ពាលស្ស ជីវិតំ អប្បំ បណ្ឌិតស្ស ពហុតរំ
ជនកាយស្ស រាជារំ រាជធម្មោវ រាជុនំ ។

ជីវិតរបស់មនុស្សពាលតិចពេកណាស់ ជីវិតរបស់បណ្ឌិតច្រើនជាង ស្តេចជាជីវិតរបស់ពួកជន រាជធម៌ (១០ ប្រការ) ជាជីវិតរបស់ស្តេច ។

(៤៣) កប្បិនញ្ច មប្បិនំ កក្កុជិនញ្ច ធេនុនំ
បុត្តបោសោ យថា ហោតិ តថា មច្ចេសុ រាជុនំ ។

មេអណ្តើក មេត្រី មេមាន់ និងមេគោ វាចិញ្ចឹមកូនយ៉ាងណា ព្រះរាជាគប្បីចិញ្ចឹមអាមាត្យជានុរាស្ត្រយ៉ាងនោះដែរ ។

(៤៤) កុលសេដ្ឋោ សប្បញ្ញោ ច វុឌ្ឍិ សូរោ ច សីលវា
ពហុស្សុតោ ឧដ្ឋានោ ច ធីរោ សុគតិគាមិនោ ។
នវេតេ សុជនា សេដ្ឋា បាបត្តានំ និវារយេ ។

មនុស្សមានត្រកូលខ្ពស់ ១ មនុស្សមានប្រាជ្ញា ១ មនុស្សមានសេចក្តីចំរើន ១ មានសេចក្តីក្លៀវក្លា ១ មនុស្សមានសីល ១ មនុស្សមានសេចក្តីចេះដឹងច្រើន ១ មនុស្សមានព្យាយាម ១ អ្នកប្រាជ្ញ ១ មនុស្សមានសុចរិតធម៌នាំទៅកាន់សុគតិ ១ មនុស្សល្អប្រសើរទាំង ៩ ពួកនេះ គប្បីនាំគ្នាធ្វើខ្លួនឲ្យផុតចាកបាប ។

(៤៥) ពុទ្ធោ បច្ចេកពុទ្ធោ ច អរហា អគ្គសាវកោ
មាតា បិតា គរុ សត្ថា ទាយកោ ធម្មទេសកោ ។
បណ្ឌិតេហិ ឥមេ ទស ន ទុព្ភន្តិ ជាតិយា ។

ព្រះពុទ្ធ១ ព្រះបច្ចេកពុទ្ធ១ ព្រះអរហន្ត១ ព្រះអគ្គសាវក១ មាតា១ បិតា១ គ្រូ១ សាស្ដាចារ្យ១ ទាយក១ អ្នកសំដែងធម៌១ ទាំង ១០ ពួកនេះ បណ្ឌិតទាំងឡាយត្រូវដឹងថាជាមនុស្សមិនគួរប្រទុស្ដ ។

(៤៦) សតំ ទីឃាយុកោ សព្វ- សត្តានំ សុខការណំ
អសតំ បន សព្វេសំ ទុក្ខហេតុ ន សំសយោ ។

លោកសប្បុរស បើមានអាយុវែង ជាហេតុឲ្យសេចក្ដីសុខដល់សព្វសត្វ ឯមនុស្សអសប្បុរស បើមានអាយុវែង ទៅជាហេតុនាំឲ្យកើតសេចក្ដីទុក្ខដល់សព្វសត្វវិញ កុំបាច់សង្ស័យអ្វីឡើយ ។

(៤៧) ទោសំ បរស្ស បស្សតិ   អត្តទោសំ ន បស្សតិ

តិលមត្តំ បរទោសំ   ឆាឡិកេរំ ន បស្សតិ ។

មនុស្សដែលឃើញតែទោសរបស់គេ តែងមិនបានឃើញទោសខ្លួនឯង (ជួនកាល) ទោសរបស់អ្នកដទៃប៉ុនគ្រាប់ល្ង នៅតែមើលឃើញ ទោសខ្លួនឯងប៉ុនផ្លែដូង ក៏នៅតែមើលមិនឃើញ ។

(៤៨) ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ

កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ ។

មនុស្សខូច ព្រោះជាតិក៏មិនមែន ព្រាហ្មណ៍គឺមនុស្សល្អ ព្រោះតែជាតិក៏មិនមែន ដែលជាមនុស្សខូច ក៏ព្រោះកម្ម ដែលជាព្រាហ្មណ៍គឺមនុស្សល្អ ក៏ព្រោះកម្ម (ដ្បិតមនុស្សខូច និងមនុស្សល្អ សឹងមានគ្រប់ជាតិគ្រប់សាសន៍) ។

(៤៩) ហីនជច្ចោបិ ចេ ហោតិ   ឧដ្ឋាតា ធិតិមា នរោ

សីលអាចារសម្បន្នោ   និសេ អគ្គីវ ភាសតិ ។

នរជនសូម្បីកើតក្នុងត្រកូលទាបក៏ដោយ បើមានសេចក្តីព្យាយាម (ខំរៀនសូត្រ) គង់បានទៅជាអ្នកប្រាជ្ញ បរិបូណ៌ដោយសីលនិងមារយាទរុងរឿងក្នុងទីប្រជុំ ដូចជាភ្លើងភ្លឺក្នុងទីងងឹត ។

*គាថាទាំង ៤៩ ដែលបានដកយកមកនេះ គ្រាន់ជាគ្រឿងដាស់តឿនស្មារតីរបស់សាធុជនគ្រប់គ្នា កុំឲ្យភ្លេចខ្លួន ព្រោះការភ្លេចខ្លួន (ប្រមាទ) ជាពូជសេចក្តីល្ងង់ បើមិនភ្លេចខ្លួន គឺមិនប្រមាទ ទើបមានពូជសេចក្តីចេះដឹង ហេតុនេះការចេះដឹង ក៏កើតមកពីមិនប្រមាទដែរ*

ចប់ផ្នែកទី ២ តែប៉ុណ្ណេះ ។

គាថាធម្មបទ ប្រែ

របស់ អាចារ្យ ហ៊ឹម

ក្រុមជំនុំប្រែព្រះត្រៃបិដក

ចប់

# ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

សក្កទេវរាជវត្ថុគាថា

(១០) សព្វទានំ ធម្មទានំ ជិនាតិ

សព្វរសំ ធម្មរសោ ជិនាតិ

សព្វរតឹ ធម្មរតី ជិនាតិ

តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

អបុត្តកសេដ្ឋិវត្ថុគាថា

(១១) ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ

ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។

# តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងសក្កទេវរាជ*

(១០) ឲ្យទានធម៌ឈ្មោះទានទាំងពួង រសរបស់ធម៌ឈ្មោះរសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ឈ្មោះសេចក្ដីត្រេកអរទាំងពួង ធម៌ជាគ្រឿងអស់ទៅនៃតណ្ហាឈ្មោះសេចក្ដីទុក្ខទាំងពួង ។

*គាថាក្នុងរឿងអបុត្តកសេដ្ឋី*

(១១) ភោគ (សម្បត្តិ) ទាំងឡាយរមែងសម្លាប់នូវបុគ្គលឥតប្រាជ្ញា ប៉ុន្តែមិនដែលសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានឡើយ ឯបុគ្គលឥតប្រាជ្ញារមែងសម្លាប់ខ្លួន ព្រោះសេចក្ដីបំណាច់ក្នុងភោគ (សម្បត្តិ) ដូចជាបុគ្គលសម្លាប់ជនដទៃព្រោះចង់បានទ្រព្យសម្បត្តិ ។

## ធម្មបទេ ចតុវីសតិមោ តណ្ហាវគ្គោ

អង្កុរវត្ថុ គា. ៤

(១២) តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

តណ្ហាវគ្គោ ចតុវីសតិមោ សមត្តោ

# តណ្ហាវគ្គទី ២៤ ក្នុងព្រះធម្មបទ

*គាថាគន្ថវៀនអន្តរ*

(១២) ស្រែទាំងឡាយមានស្មៅជាទោស ឯពពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះបានជាទានដែលបុគ្គលបានឲ្យ បំពោះពួកបុគ្គលដែលមានរាគៈទៅប្រាសហើយ ទើបជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ឯពពួកសត្វលោកនេះមានទោសៈជាទោស ព្រោះហេតុនោះបានជាទានដែលបុគ្គលបានឲ្យ បំពោះពួកបុគ្គលដែលមានទោសៈទៅប្រាសហើយ ទើបជាទានមានផលច្រើន។ ស្រែទាំងឡាយមានស្មៅជាទោស ឯពពួកសត្វលោកនេះមានមោហៈជាទោស ព្រោះហេតុនោះបានជាទានដែលបុគ្គលបានឲ្យបំពោះពួកបុគ្គលដែលមានមោហៈទៅប្រាសហើយ ទើបជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ឯពពួកសត្វលោកនេះមានសេចក្ដីប្រាថ្នាជាទោស ព្រោះហេតុនោះបានជាទានដែលបុគ្គលបានឲ្យ បំពោះពួកបុគ្គលដែលមានសេចក្ដីប្រាថ្នាទៅប្រាសហើយ ទើបជាទានមានផលច្រើន ។

តណ្ហាវគ្គទី ២៤ ចប់

## ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

### បញ្ចភិក្ខុវត្ថុគាថា

(១) ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ ។
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ ។
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

### ហំសឃាតកវត្ថុគាថា

(២) ហត្ថសញ្ញតោ បាទសញ្ញតោ
វាចាសញ្ញតោ សញ្ញតត្តមោ
អជ្ឈត្តរតោ សមាហិតោ ឯកោ
សន្តុសិតោ តមាហុ ភិក្ខុ ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

### គាថាក្នុងរឿងបញ្ចភិក្ខុ

(១) កិរិយាសង្រួមដោយភ្នែកជាការល្អ កិរិយាសង្រួមដោយត្រចៀកជាការល្អ កិរិយាសង្រួមដោយច្រមុះជាការល្អ កិរិយាសង្រួមដោយអណ្ដាតជាការល្អ ។

កិរិយាសង្រួមដោយកាយជាការល្អ កិរិយាសង្រួមដោយវាចាជាការល្អ កិរិយាសង្រួមដោយចិត្តជាការល្អ កិរិយាសង្រួមគ្រប់ទ្វារទាំងអស់ជាការល្អ (ដ្បិត) ភិក្ខុដែលបានសង្រួមគ្រប់ទ្វារទាំងអស់ តែងតែរួចស្រឡះចាកទុក្ខទាំងពួង ។

### គាថាក្នុងរឿងហំសឃាតក

(២) ជនឯណាមានដៃសង្រួមហើយ មានជើងសង្រួមហើយ មានវាចាសង្រួមហើយ មានអត្តភាពសង្រួមហើយ អ្នកត្រេកអរហើយក្នុងកិរិយាបំរើនូវកម្មដ្ឋានដែលមានក្នុងខ្លួន អ្នកមានចិត្តដំកល់មាំហើយ ជាអ្នកនៅឯកឯង តែងមានចិត្តសន្ដោស ដោយមគ្គនឹងផលរបស់ខ្លួន ទើបតថាគតហៅជននោះថាជាភិក្ខុបាន ។

## ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

កោកាលិកវត្ថុគាថា

(៣) យោ មុខសញ្ញតោ ភិក្ខុ   មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ   មធុរន្តស្ស ភាសិតំ ។

ធម្មារាមត្ថេរវត្ថុគាថា

(៤) ធម្មារាមោ ធម្មរតោ   ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ   សទ្ធម្មា ន បរិហាយតិ ។

វិបក្ខសេវកភិក្ខុវត្ថុគាថា

(៥) សលាភំ នាតិមញ្ញេយ្យ   នាញ្ញេសំ បិហយំ ចរេ
អញ្ញេសំ បិហយំ ភិក្ខុ   សមាធឹ នាធិគច្ឆតិ ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងកោកាលិក*

(៣) ភិក្ខុឯណាមានមាត់សង្រួមហើយ ជាអ្នកមានកិរិយាពោលដោយបញ្ញាមានឈ្មោះថាមន្តាជាប្រក្រតី ជាអ្នកមានចិត្តមិនរាយមាយហើយ អាចសំដែងនូវអត្ថផង ធម៌ផង បានភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ ។

*គាថាក្នុងរឿងធម្មារាមត្ថេរ*

(៤) ភិក្ខុមានធម៌ជាគ្រឿងត្រេកអរទូទៅ អ្នកត្រេកអរក្នុងធម៌ អ្នកពិចារណារឿយ ៗ នូវធម៌ អ្នករឭករឿយ ៗ នូវធម៌ (ភិក្ខុនោះ) រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

*គាថាក្នុងរឿងវិបក្ខសេវកភិក្ខុ*

(៥) ភិក្ខុកុំគប្បីមើលងាយនូវលាភរបស់ខ្លួន កុំគប្បីប្រព្រឹត្តប្រាថ្នានូវលាភរបស់ជនទាំងឡាយដទៃ ភិក្ខុណាប្រាថ្នាលាភពួកជនដទៃ (ភិក្ខុនោះ) មិនបាននូវសមាធិទេ ។

## ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

អប្បលាភោបិ ចេ ភិក្ខុ   សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ   សុទ្ធាជីវិមតន្ទិតំ ។

### បញ្ចគ្គទាយកព្រាហ្មណវត្ថុគាថា

(៦) សព្វសោ នាមរូបស្មឹ   យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ   ស វេ ភិក្ខូតិ វុច្ចតិ ។

### សម្ពហុលភិក្ខុវត្ថុគាថា

(៧) មេត្តាវិហារី យោ ភិក្ខុ   បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ   សង្ខារូបសមំ សុខំ ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

ភិក្ខុ (ណា) មានលាភតិចមែន តែមិនមើលងាយនូវលាភរបស់ខ្លួន ទេវតាទាំងឡាយតែងតែសរសើរភិក្ខុនោះឯងថា ជាអ្នកចិញ្ចឹមជីវិតស្អាតហើយមិនខ្ជិលច្រអូស ។

*គាថាកនរឿងបញ្ចគ្គទាយកព្រាហ្មណ៍*

(៦) បុគ្គលឯណាមិនមានសេចក្ដីប្រកាន់ថាជារបស់ខ្លួន បំពោះនាមនិងរូបទាំងអស់ផង ជាអ្នកមិនសោកស្ដាយបំពោះនាមនិងរូបដែលមិនមាន គឺថាដែលដល់នូវសេចក្ដីវិនាសជាដើមផង បុគ្គលនោះឯងតថាគតហៅថាជាភិក្ខុបាន ។

*គាថាកនរឿងសម្ពហុលភិក្ខុ*

(៧) ភិក្ខុឯណាមានកិរិយានៅ ដោយអំណាចនៃព្រហ្មវិហារមានមេត្តាជាអារម្មណ៍ជាប្រក្រតី ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះតែងបានចំណែកនៃព្រះនិព្វានជាស្ថានស្ងប់រម្ងាប់នូវសង្ខារ ជាទីនាំមកនូវសេចក្ដីសុខ ។

ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ

ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។

បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ចុត្តរិ ភាវយេ

បញ្ច សង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។

ឈាយ ភិក្ខុ មា ច បមាទោ មា តេ កាមគុណេ ភវស្សុ(១) ចិត្តំ

មា លោហគុឡំ គិលិ បមត្តោ មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

---

១ ម. រមេស្សុ ។

ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

ម្នាលភិក្ខុ អ្នកចូរស្តារនូវទូកគឺអត្តភាពនេះទៅ ទូកគឺអត្តភាពនេះបើអ្នកស្តារបានហើយ អ្នកនឹងដល់នូវត្រើយគឺព្រះនិព្វានជាឆាប់ បើអ្នកកាត់នូវរាគៈផង ទោសផងៈស្រេចហើយលំដាប់តទៅអ្នកនឹងដល់ព្រះនិព្វានមិនខាន ។

ភិក្ខុគួរកាត់ឱរម្ភសំយោជនទាំង ៥ ចោលចេញ គួរលះបង់ឧទ្ធម្ភាគិយសំយោជនទាំងប្រាំចោលចេញ រួចហើយត្រូវបំរើនឥន្ទ្រិយទាំង ៥ តទៅទៀត ភិក្ខុបានកន្លងនូវធម៌ជាគ្រឿងជំពាក់ទាំង ៥ គឺ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ បានហើយនោះ តថាគតឲ្យឈ្មោះថាអ្នកឆ្លងអន្លង់បាន ។ ម្នាលភិក្ខុ អ្នកចូរបំរើននូវឈាន ចូរអ្នកកុំប្រមាទឡើយ ចិត្តរបស់អ្នកចូរកុំវិលទៅរកកាមគុណទៀតឡើយ ចូរអ្នកកុំប្រមាទមើលងាយ ទំពាស៊ីនូវដុំដែកទង់ដែងឡើយ អ្នកកាលបើឆេះនៅក្នុងនរកក្តី កុំកន្ទក់កន្ទេញថាលំបាកណាស់ដូច្នេះឡើយ ។

## ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

នត្ថិ ឈានំ អបញ្ញស្ស　　នត្ថិ បញ្ញា អឈាយិនោ[១]
យម្ហិ ឈានញ្ច បញ្ញា ច　　ស វេ និព្វានសន្តិកេ ។

សុញ្ញាគារំ បវិដ្ឋស្ស　　សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតិ ហោតិ　　សម្មា ធម្មំ វិបស្សតោ ។

យតោ យតោ សម្មសតិ　　ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ　　អមតន្តំ វិជានតំ ។

តត្រាយមាទិ ភវតិ　　ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ　　បាដិមោក្ខេ ច សំវរោ ។

---

១ អឈាយតោតិបិ បាឋោ ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

ឈានតែងតែមិនមានដល់បុគ្គលឥតបញ្ញា បញ្ញាតែងតែមិនមានដល់បុគ្គលឥតឈាន ឈានក្ដី បញ្ញាក្ដី បើមានក្នុងបុគ្គលណាហើយ បុគ្គលនោះឯងឈ្មោះថាស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។ សេចក្ដីត្រេកអរ ដែលមិនមែនវិស័យរបស់មនុស្សតែងមានដល់ភិក្ខុ អ្នកចូលទៅនៅក្នុងទីស្ងាត់ ។ អ្នកមានចិត្តស្ងប់ស្ងាត់ហើយ កាលឃើញច្បាស់នូវធម៌ដោយប្រពៃ ។ ក្នុងកាលឯណា ៗ ភិក្ខុពិចារណានូវកិរិយាកើតឡើងនិងវិនាសទៅនៃខន្ធទាំងឡាយ ក្នុងកាលនោះៗ ភិក្ខុតែងបាននូវសេចក្ដីអំណរនិងសេចក្ដីរីករាយ ឯសេចក្ដីអំណរនិងសេចក្ដីរីករាយនោះឈ្មោះថាអមត របស់បណ្ឌិតទាំងឡាយអ្នកដឹងច្បាស់នូវធម៌ ។ ហេតុជាទីតាំងក្នុងខាងដើមនេះគឺ កិរិយារក្សានូវឥន្ទ្រិយ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាដិមោក្ខ ១ របស់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះតែងមានក្នុងព្រះនិព្វាននោះ ។

## ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ
បដិសន្ថារវុត្យស្ស អាចារកុសលោ សិយា ។
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

### បញ្ចសតភិក្ខុវត្ថុគាថា

(៨) វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ

### សន្តកាយត្ថេរវត្ថុគាថា

(៩) សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

(នែភិក្ខុ) អ្នកចូរសេពគប់នូវកល្យាណមិត្រទាំងឡាយ ដែលជាអ្នករស់នៅដោយស្អាត ហើយជាអ្នកមិនខ្ជិលច្រអូស ធ្វើជាភិក្ខុត្រូវប្រព្រឹត្តនូវបដិសណ្ឋារ ត្រូវឈ្លាសក្នុងអាចារ អ្នកមានសេចក្តីរីករាយច្រើន ព្រោះតែប្រព្រឹត្តនូវបដិសណ្ឋារនឹងឈ្លាសក្នុងអាចារនោះហើយ គង់នឹងធ្វើគឺបាននឹងដល់នូវព្រះនិព្វានជាទីបំផុតនៃវដ្តទុក្ខមិនខាន ។

*គាថាក្នុងរឿងបញ្ចសតភិក្ខុ*

(៨) ដើមម្លិះជំរុះបុះនូវផ្កាទាំងឡាយដែលស្វិតស្រពោន ចោលចេញយ៉ាងណា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះលែងនូវរាគផង ទោសផង យ៉ាងនោះ ។

*គាថាក្នុងរឿងសន្តកាយត្ថេរ*

(៩) ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ អ្នកមានចិត្តដ៏កល់មាំហើយ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ តថាគតហៅថាអ្នកស្ងប់ស្ងាត់ ។

ធម្មបទេ បញ្ចវីសតិមោ ភិក្ខុវគ្គោ

ណង្គលកុដត្ថេរវត្ថុគាថា

(១០) អត្តនា ចោទយត្តានំ បដិមំសេថ[១] មត្តនា
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ
តស្មា សំយម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។

វក្កលិត្ថេរវត្ថុគាថា

(១១) បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

សុមនសាមណេរវត្ថុគាថា

(១២) យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។

ភិក្ខុវគ្គោ បញ្ចវីសតិមោ សមត្តោ

---

១ ម. បដិមាសេថ អត្តនា ។

## ភិក្ខុវគ្គទី ២៥ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងនង្គលកុដត្ថេរ*

(១០) (ម្នាលភិក្ខុ) អ្នកចូររំឭកដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិចារណាខ្លួននេះដោយខ្លួនឯង អ្នកឯងបើមានខ្លួនគ្រប់គ្រងហើយ មានសតិខ្ជាប់ខ្ជួនហើយ នឹងនៅជាសុខមិនខាន ។

ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនជាគតិជាទីរឭករបស់ខ្លួន ព្រោះហេតុឯណា ហេតុនោះអ្នកឯងចូររក្សាខ្លួនឲ្យល្អ ដូចនាយពាណិជការរក្សាសេះដ៏បំរើន ។

*គាថាក្នុងរឿងវក្កលិត្ថេរ*

(១១) ភិក្ខុអ្នកមានសេចក្ដីរីករាយច្រើន ដែលជ្រះថ្លាហើយក្នុងព្រះពុទ្ធសាសនា រមែងបានបំណែកនៃព្រះនិព្វានជាស្ថានរម្ងាប់បង់នូវសង្ខារជាសុខមិនខាន ។

*គាថាក្នុងរឿងសុមនសាមណេរ*

(១២) ភិក្ខុណានៅកំឡោះ មានព្យាយាមប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឈ្មោះថាញុំាងលោកនេះឲ្យភ្លឺស្វាង ដូចគ្នានឹងព្រះចន្ទដែលផុតអំពីពពក ។

ភិក្ខុវគ្គ ទី ២៥ ចប់

# ធម្មបទេ ឆព្វីសតិមោ ព្រាហ្មណវគ្គោ

បសាទពហុលព្រាហ្មណវត្ថុគាថា

(១) ឆិន្ទ សោតំ បរក្កម្ម កាមេ បនុទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។

សម្ពហុលភិក្ខុវត្ថុគាថា

(២) យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វសំយោគា អត្ថំ គច្ឆន្តិ ជានតោ ។

មារវត្ថុគាថា

(៣) យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបសាទពហុលព្រាហ្មណ៍*

(១) ម្នាលព្រាហ្មណ៍ អ្នកចូរប្រឹងប្រែងកាត់ក្រសែនៃតណ្ហាឲ្យបាន អ្នកចូរបន្ទោបង់នូវវត្ថុកាមនឹងកិលេសកាមៈចាលចេញ, នែព្រាហ្មណ៍ បើអ្នកស្គាល់ច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃសង្ខារទាំងឡាយហើយ អ្នកឈ្មោះថាដឹងនូវព្រះនិព្វានដែលគេធ្វើមិនបាន ។

*គាថាក្នុងរឿងសម្ពហុលភិក្ខុ*

(២) ព្រាហ្មណ៍ដល់នូវត្រើយគឺសេចក្តីត្រាស់ដឹង ក្នុងធម៌ទាំងឡាយពីរគឺ សមថធម៌ ១ វិបស្សនាធម៌ ១ ក្នុងកាលឯណា កិលេសជាគ្រឿងប្រកបទាំងឡាយមានកាមសំយោជនជាដើមរបស់ព្រាហ្មណ៍នោះ កាលដឹងយ៉ាងនេះ រមែងដល់នូវកិរិយាតាំងនៅពុំបានឡើយ ។

*គាថាក្នុងរឿងមារ*

(៣) អាយតនខាងក្នុងក្តី អាយតនខាងក្រៅក្តី អាយតនទាំងខាងក្នុងទាំងខាងក្រៅក្តី មិនមានដល់បុគ្គលណា

## ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

វីតទ្ទរំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

### អញ្ញតរព្រាហ្មណវត្ថុគាថា

(៤) ឈាយឹ វិរជ្ជមាសីនំ កតកិច្ចំ អនាសវំ

ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

### អានន្ទត្ថេរវត្ថុគាថា

(៥) ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា

សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ ។

អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេសា ។

ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ។

តថាគតហៅបុគ្គលនោះថា អ្នកមានក្រវល់ក្រវាយទៅប្រាសហើយ . អ្នកប្រាសហើយចាកកិលេសទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

*គាថាកន្លងរឿងអញ្ញតរព្រាហ្មណ៍*

(៤) តថាគតហៅអ្នកមានឈាន មានធូលីគឺកាមទៅប្រាសហើយ អ្នកអង្គុយនៅតែឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ រកអាសវៈគ្មាន ដល់ហើយនូវព្រះអរហត្ត ជាផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះថាជាព្រាហ្មណ៍ ។

*គាថាកន្លងរឿងអានន្ទត្ថេរ*

(៥) ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ ព្រះចន្ទ្ររុងរឿងបានតែក្នុងវេលាយប់ ព្រះមហាក្សត្រិយ៍រុងរឿងបានតែក្នុងកាលទ្រង់គ្រឿងប្រដាប់ ព្រះសមណព្រាហ្មណ៍រុងរឿងបានតែក្នុងកាលបំរើឈាន ចំណែកឯព្រះសម្ពុទ្ធជាម្ចាស់តែងតែរុងរឿងអស់យប់នឹងថ្ងៃទាំងអស់ដោយតេជៈ ។

## ធម្មបទេ ឆព្វីសតិមោ ព្រាហ្មណវគ្គោ

### អញ្ញតរព្រាហ្មណបព្វជិតវត្ថុគាថា

(៦) ពាហិតបាបោ ហិ ព្រាហ្មណោ
សមចរិយាយ សមណោតិ វុច្ចតិ
បព្វាជយមត្តនោ មលំ
តស្មា បព្វជិតោតិ វុច្ចតិ ។

### សារីបុត្តត្ថេរវត្ថុគាថា

(៧) ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអញ្ញតរព្រាហ្មណបព្វជិត*

(៦) បុគ្គលដែលតថាគតហៅថាព្រាហ្មណ៍ព្រោះបន្សាត់បង់នូវបាប ដែលតថាគត ហៅថាសមណៈព្រោះប្រព្រឹត្តរម្ងាប់នូវអកុសលធម៌ ព្រោះហេតុនោះបុគ្គលឯណាកាលបណ្តេញបង់នូវមន្ទិលនៃខ្លួនបាន បុគ្គលនោះតថាគតហៅថាបព្វជិត ។

*គាថាក្នុងរឿងសារីបុត្តត្ថេរ*

(៧) ព្រះខីណាស្រវព្រាហ្មណ៍កុំគប្បីប្រហារដល់ព្រាហ្មណ៍ដទៃ ព្រះខីណាស្រវព្រាហ្មណ៍កុំគប្បីចងពៀរបំពោះព្រាហ្មណ៍ដទៃ (បើយ៉ាងនេះ) តថាគតតិះដៀលព្រាហ្មណ៍ដែលប្រហារដល់ព្រះខីណាស្រវព្រាហ្មណ៍ តែបើព្រះខីណាស្រវព្រាហ្មណ៍ឯណាចងពៀរបំពោះព្រាហ្មណ៍អ្នកប្រហារនោះ តថាគតនឹងតិះដៀលព្រះខីណាស្រវព្រាហ្មណ៍នោះជាងព្រាហ្មណ៍អ្នកប្រហារនោះទៅទៀត ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទា និសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

មហាបជាបតិគោតមីវត្ថុគាថា

(៨) យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។

សារីបុត្តត្ថេរវត្ថុគាថា

(៩) យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ
សក្កច្ចំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

ឯហេតុមានកិរិយាមិនប្រហារតបជាដើម របស់ព្រះខីណាសវព្រាហ្មណ៍នេះ មិនមែនជាគុណដ៏ប្រសើរតិចតួចឡើយ ការហាមឃាត់ចិត្តចាកអារម្មណ៍ជាទីស្រឡាញ់ឯណា (របស់ព្រះខីណាសវព្រាហ្មណ៍ ឯការហាមឃាត់នោះក៏មិនមែនជាគុណដ៏ប្រសើរតិចតួចដែរ) ក៏ឯចិត្តដែលប្រកបដោយសេចក្ដីក្រោធ បើងាកចេញចាកវត្ថុឯណាៗហើយ សេចក្ដីទុក្ខតែងរម្ងាប់អំពីវត្ថុនោះៗដោយពិត ។

*គាថាក្នុងរឿងមហាបជាបតិគោតមី*

(៨) អំពើអាក្រក់ដោយ កាយ វាចា ចិត្តមិនមានដល់បុគ្គលឯណា តថាគតហៅបុគ្គលដែលបានសង្រួមដោយស្ថានទាំងឡាយ ៣ យ៉ាងនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងសារីបុត្តត្ថេរ*

(៩) ភិក្ខុបើបេះដឹងធម៌អាថ៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ អំពីសំណាក់អាចារ្យឯណា ត្រូវនមស្ការថ្វាយបង្គំអាចារ្យនោះដោយគោរព ឲ្យដូចជាព្រាហ្មណ៍កាលថ្វាយបង្គំការបូជាភ្លើង ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

## ជដិលព្រាហ្មណវត្ថុគាថា

(១០) ន ជដាហិ ន គោត្តេន ន បច្ចា ហោតិ ព្រាហ្មណោ
យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចិ សោ ច ព្រាហ្មណោ

## កុហកព្រាហ្មណវត្ថុគាថា

(១១) កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរន្តេ គហណំ ពាហិរំ បរិមជ្ជសិ ។

## កិសាគោតមីវត្ថុគាថា

(១២) បំសុកូលធរំ ជន្តុំ កិសំ ធមនិសន្ថតំ
ឯកំ វនស្មិំ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងជដិលព្រាហ្មណ៍*

(១០) បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ព្រោះផ្នួងសក់ក៏មិនមែន ព្រោះតែកំណើតក៏មិនមែនដែរ សច្ចញ្ញាណក្តី លោកុត្តរធម៌ក្តី បើមានក្នុងបុគ្គលណាហើយ បុគ្គលនោះឈ្មោះថាអ្នកស្អាតផង ឈ្មោះថាព្រាហ្មណ៍ផង ។

*គាថាក្នុងរឿងកុហកព្រាហ្មណ៍*

(១១) នែព្រាហ្មណ៍ អ្នកមានបញ្ញាអាក្រក់ ប្រយោជន៍អ្វីដោយផ្នួងសក់របស់អ្នកឯង ប្រយោជន៍អ្វីដោយសំពតសាជកជាវិការនៃស្បែកខ្លាឃ្មុំរបស់អ្នកឯង សន្តានខាងក្នុងរបស់អ្នកឯងសឹងតែសាំញាំដោយរាគាទិកិលេស ហើយអ្នកឯងដុសខាត់តែកាយខាងក្រៅ ។

*គាថាក្នុងរឿងកិសាគោតមី*

(១២) តថាគតហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូលមានសរីរស្គម មានខ្នងដ៏ដេរដាសដោយសរសៃ តែឯកឯងកាលបំរើនឈានក្នុងព្រៃនោះឯងថាជាព្រាហ្មណ៍ ។

ឯកព្រាហ្មណវត្ថុគាថា

(១៣) ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិ[១]សម្ភវំ

ភោវាទី នាម សោ ហោតិ ស វេ ហោតិ សកិញ្ចនោ ។

អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ឧគ្គសេនសេដ្ឋីបុត្តវត្ថុគាថា

(១៤) សព្វសញ្ញោជនំ ឆេត្វា យោ វេ ន បរិតស្សតិ

សង្គាតីគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. បេត្តិសម្ភវំ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឯកព្រាហ្មណ*

(១៣) តថាគតហៅបុគ្គលអ្នកកើតដោយកំណើតនៃព្រាហ្មណ៍ អ្នកកើតដោយផ្ទៃនៃមាតាជាព្រាហ្មណ៍ថាជាព្រាហ្មណ៍ក៏ទេដែរ បុគ្គលនោះគ្រាន់តែឈ្មោះថាភោវាទី ព្រោះបុគ្គលនោះឯងជាអ្នកមានកិលេសជាគ្រឿងកង្វល់នៅឡើយ ។ តថាគតហៅតែបុគ្គលដែលគ្មានកិលេសជាគ្រឿងកង្វល់ អ្នកគ្មានសេចក្ដីប្រកាន់នោះឯងថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងឧគ្គសេនសេដ្ឋីបុត្ត*

(១៤) បុគ្គលឯណាមួយកាត់នូវសញ្ញោជនទាំងអស់បាន មិនតក់ស្លុតព្រោះតណ្ហា តថាគតហៅបុគ្គលនោះដែលបានឆ្លងនូវកិលេសជាគ្រឿងជំពាក់ អ្នកប្រាសចាកកិលេសជាគ្រឿងប្រកបថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

ទ្វេព្រាហ្មណវត្ថុគាថា

(១៥) ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហនុក្កមំ
ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

អក្កោសកភារទ្វាជវត្ថុគាថា

(១៦) អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ
ខន្តិពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។

សារីបុត្តត្ថេរវត្ថុគាថា

(១៧) អក្កោធនំ វត្តវន្តំ សីលវន្តំ អនុស្សទំ
ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាកន្សើរឿងទេវព្រាហ្មណ*

(១៥) តថាគតហៅបុគ្គលអ្នកកាត់សេចក្ដីក្រោធ ដូចជាព្រ័ត្រសម្រាប់រឹតផង នូវតណ្ហាដូចជាខ្សែសម្រាប់បងផង នូវធម៌ជាទីតាំងនៃទិដ្ឋិ ៦២ ប្រព្រឹត្តទៅដោយកិលេសជាគ្រឿងឈានតាម អ្នកមានបង្គោលគឺអវិជ្ជាដកចោលហើយផង អ្នកត្រាស់ដឹងសច្ចៈ ៤ ផងនោះឯងថាជាព្រាហ្មណ៍ ។

*គាថាកន្សើរឿងអក្កោសកភារទ្វាជ*

(១៦) បុគ្គលឯណាមិនមានចិត្តប្រទូស្ដ តែងអត់សង្កត់នូវពាក្យជេរផង នូវកិរិយាប្រទូស្ដនឹងកិរិយាចងផង តថាគតហៅអ្នកមានខន្តីជាកម្លាំង ដូចជាពួកពលប្រើជើងនោះឯងថាជាព្រាហ្មណ៍ ។

*គាថាកន្សើរឿងសារីបុត្តត្ថេរ*

(១៧) តថាគតហៅបុគ្គលដែលមិនមានសេចក្ដីក្រោធ ជាអ្នកមានធុតង្គវត្ត មានសីលវត្ត មានចិត្តមិនឃ្លានប៉ោងឡើងដោយអំណាចនៃតណ្ហា ជាអ្នកមានឥន្ទ្រិយទូន្មានល្អហើយ មានសរីរស្ថិតនៅហើយក្នុងទីបំផុតនោះថាជាព្រាហ្មណ៍ ។

## ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

ឧប្បលវណ្ណាថេរីវត្ថុគាថា

(១៨) វារិ បោក្ខរបត្តេវ អារគេរិវ សាសបោ

យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។

អញ្ញតរព្រាហ្មណវត្ថុគាថា

(១៩) យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ

បន្នភារំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ខេមាភិក្ខុនីវត្ថុគាថា

(២០) គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ

ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងឧប្បលវណ្ណាថេរី*

(១៨) បុគ្គលឯណាមិនបានជាប់នៅក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយ ដូចជាទឹកដែលមិនជាប់នៅលើស្លឹកឈូក (ពុំនោះសោត) ដូចជាគ្រាប់ស្ពៃដែលមិនទើរនៅលើចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងអញ្ញតរព្រាហ្មណ៍*

(១៩) បុគ្គលឯណាដឹងច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃសេចក្ដីទុក្ខចំពោះខន្ធរបស់ខ្លួន ក្នុងលោកនេះបាន តថាគតហៅបុគ្គលដែលមានខន្ធភារដាក់ចុះហើយ ដែលប្រាសចាកកិលេសទាំងឡាយនោះឯងថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងខេមាភិក្ខុនី*

(២០) តថាគតហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅដឹងច្បាស់ក្នុងខន្ធ មានប្រាជ្ញាដឹងច្បាស់ក្នុងធម៌ អ្នកឈ្លាសស្គាល់នូវមគ្គនិងមិនមែនមគ្គ ជាអ្នកដល់ហើយនូវអរហត្តមានអត្ថដ៏ខ្ពង់ខ្ពស់នោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

បព្ភារវាសីតិស្សត្ថេរវត្ថុគាថា

(២១) អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ
អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។

អញ្ញតរភិក្ខុវត្ថុគាថា

(២២) និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច
យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

សាមណេរានំវត្ថុគាថា

(២៣) អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ
សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងបព្ភារវាសីតិស្សត្ថេរ*

(២១) តថាគតហៅបុគ្គលដែលមិនច្រឡំហើយដោយជនទាំងពីរពួកគឺ គ្រហស្ថ១ អ្នកបួស១ ជាអ្នកប្រព្រឹត្តិដោយគ្មានអាល័យ មានសេចក្ដីប្រាថ្នាតិចនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងអញ្ញតរភិក្ខុ*

(២២) បុគ្គលឯណាដាក់ចុះនូវអាជ្ញា គឺថាប្រាសហើយចាកសេចក្ដីបៀតបៀនចំពោះសត្វទាំងឡាយ (ដែលមានសេចក្ដីតក់ស្លុតផង) ដែលមាំមួនហើយផង មិនសម្លាប់ (សត្វ) ដោយខ្លួនឯងផង នឹងមិនប្រើគេឲ្យសម្លាប់ផង តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងនៃសាមណេរទាំងឡាយ*

(២៣) តថាគតហៅបុគ្គលអ្នកមិនខឹងតបចំពោះពួកជនដែលខឹង អ្នកមានអាជ្ញារលត់ហើយ ចំពោះពួកជនដែលមានអាជ្ញាលើខ្លួន អ្នកមិនមានសេចក្ដីប្រកាន់ខ្លួន ចំពោះពួកជនដែលមានសេចក្ដីប្រកាន់ខ្លួននោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

## មហាបន្ថកត្ថេរវត្ថុគាថា

(២៤) យស្ស រាគោ ច ទោសោ ច
មានោ មក្ខោ ច បាតិតោ
សាសបោរិវ អារគ្គា
តមហំ ព្រូមិ ព្រាហ្មណំ ។

## បិលិន្ទវច្ឆត្ថេរវត្ថុគាថា

(២៥) អកក្កសំ វិញ្ញាបនឹ
គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កញ្ចិ
តមហំ ព្រូមិ ព្រាហ្មណំ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងមហាបន្ថកត្ថេរ*

(២៤) រាគៈក្តី ទោសៈក្តី មានះ (សេចក្តីប្រកាន់ខ្លួន) ក្តី ទាំងមក្ខៈ (សេចក្តីលុបគុណ) ក្តី បើបុគ្គលឯណាបានទម្លាក់បោលហើយ ដូចជាគ្រាប់ស្ពៃដែលធ្លាក់ចុះអំពីចុងនៃដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងបិលិន្ទវច្ឆត្ថេរ*

(២៥) បុគ្គលឯណាមិនដែលញុំាងបុគ្គលណាមួយឲ្យជាប់ជំពាក់ដោយអំណាចធ្វើគេឲ្យក្រោធខឹង ព្រោះពាក្យសំដីឯណា អ្នកមានអាសវអស់ហើយ រមែងពោលពាក្យសំដីនៃខ្លួនដែលជាពាក្យញុំាងអ្នកដទៃឲ្យដឹងច្បាស់សេចក្តីថាជាពាក្យពិត តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

អញ្ញតរត្ថេរវត្ថុ គាថា

(២៦) យោធ ទីឃំ វា រស្សំ វា  អណុំ ថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ  តមហំ ព្រូមិ ព្រាហ្មណំ ។

សារីបុត្តត្ថេរវត្ថុ គាថា

(២៧) អាសា យស្ស ន វិជ្ជន្តិ  អស្មិំ លោកេ បរម្ហិ ច
និរាសយំ[១] វិសំយុត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

មហាមោគ្គល្លានត្ថេរវត្ថុ គាថា

(២៨) យស្សាលយា ន វិជ្ជន្តិ  អញ្ញាយ អកថំកថី
អមតោគធំ អនុប្បត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. និស្សាសំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងអញ្ញតរត្ថេរ*

(២៦) បុគ្គលឯណាក្នុងលោកនេះ មិនហ៊ានកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ទោះវត្ថុវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អក្តី អាក្រក់ក្តី តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងសារីបុត្តត្ថេរ*

(២៧) សេចក្តីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តែងមិនមានដល់បុគ្គលឯណា តថាគតហៅបុគ្គលដែលមិនមានសេចក្តីប្រាថ្នា ដែលប្រាសចាកកិលេសនោះឯងថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងមហាមោគ្គល្លាន*

(២៨) អាល័យគឺសេចក្តីប្រាថ្នាតែងមិនមានដល់បុគ្គលណា (ឬថា) បុគ្គលណាគ្មានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះបានដឹងច្បាស់នូវធម៌ តថាគតហៅបុគ្គលដែលមានចិត្តយាងចុះហើយកាន់ព្រះនិព្វាន ដែលមានអរហត្តផលដល់ហើយដោយលំដាប់នោះថាជាព្រាហ្មណ៍ ។

## ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

រេវតត្ថេរវត្ថុគាថា

(១៩) យោធ បុញ្ញញ្ច បាបញ្ច
ឧភោ សង្គំ ឧបច្ចគា
អសោកំ វិរជំ សុទ្ធំ
តមហំ ព្រូមិ ព្រាហ្មណំ ។

ចន្ទាភត្ថេរវត្ថុគាថា

(៣០) ចន្ទំវ វិមលំ សុទ្ធំ
វិប្បសន្នមនាវិលំ
នន្ទិភវបរិក្ខីណំ
តមហំ ព្រូមិ ព្រាហ្មណំ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងរេវតត្ថេរ*

(២៩) បុគ្គលឯណាក្នុងលោកនេះ (លះបង់ហើយ) នូវសភាវទាំងពីរគឺបុណ្យ ១ បាប ១ ផុតកន្លងហើយនូវកិលេសជាគ្រឿងជាប់នៅមានរាគជាដើម តថាគតហៅបុគ្គលដែលគ្មានសេចក្ដីសោក ដែលប្រាសចាកធូលីគឺកិលេសមានរាគជាដើម ដែលជាអ្នកស្អាតនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងចន្ទាភត្ថេរ*

(៣០) តថាគតហៅអ្នកប្រាសហើយចាកមន្ទិលគឺ រាគា-ទិក្កិលេស ដូចជាព្រះចន្ទ្រប្រាសហើយចាកមន្ទិលមានពពកជាដើម ជាអ្នកស្អាត ជាអ្នកមានចិត្តជ្រះថ្លា មានចិត្តមិនល្អក់ គឺមានចិត្តប្រាសចាកមន្ទិលគឺកិលេស ជាអ្នកមានសេចក្ដីត្រេកអរក្នុងភពអស់រលីងហើយនោះថាជាព្រាហ្មណ៍ ។

## ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

### សីវលិត្ថេរវត្ថុគាថា

(៣១) យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី អនេជោ អកថំកថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

### សុន្ទរសមុទ្ទត្ថេរវត្ថុគាថា

(៣២) យោធ កាមេ បហត្វាន អនាគារោ បរិព្វជេ
កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាកួនរឿងសីវលិត្ថេរ*

(៣១) បុគ្គលឯណាឆ្លងកន្លងហើយនូវផ្លូវកោងគឺរាគៈផង នូវភក់ដែលគេឆ្លងបានដោយកម្រគឺកិលេសផង នូវសង្សារវដ្ដផង នូវមោហៈផង ជាអ្នកឆ្លងហើយនូវអន្លង់ទាំង ៤ បានដល់ត្រើយគឺព្រះនិព្វានហើយ ជាអ្នកមានឈាន ជាអ្នកមិនញាប់ញ័រដោយតណ្ហា ជាអ្នកគ្មានសេចក្ដីសង្ស័យ ។ ជាអ្នកមិនមានប្រកាន់មាំក្នុងឧបាទាន ជាអ្នកដល់និព្វានហើយ (ព្រោះរលត់នូវកិលេស) តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

*គាថាកួនរឿងសុន្ទរសមុទ្ទត្ថេរ*

(៣២) បុគ្គលឯណាលះបង់នូវកិលេសកាមនឹងវត្ថុកាមទាំងឡាយ ជាអ្នកគ្មានផ្ទះសម្បែង វៀរលែងជាស្រឡះហើយ តថាគតហៅបុគ្គលដែលមានកាមនឹងភពអស់រលីងហើយនោះថាជាព្រាហ្មណ៍ ។

## ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

ជដិលត្ថេរវត្ថុគាថា

(៣៣) យោធ តណ្ហំ បហត្វាន អនាគារោ បរិព្វជេ

តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

ជោតិកត្ថេរវត្ថុគាថា

(៣៤) យោធ តណ្ហំ បហត្វាន អនាគារោ បរិព្វជេ

តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បឋមនដបុត្តកត្ថេរវត្ថុគាថា

(៣៥) ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា

សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

## ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងជដិលត្ថេរ*

(៣៣) បុគ្គលឯណាក្នុងលោកនេះលះបង់តណ្ហា (ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦) ជាអ្នកមិនត្រូវការដោយផ្ទះសម្បែង (ចេញបួស) វៀរលែងជាស្រឡះ តថាគតហៅបុគ្គលដែលមានតណ្ហានឹងភពអស់រលីងហើយនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងជោតិកត្ថេរ*

(៣៤) បុគ្គលឯណាក្នុងលោកនេះលះបង់នូវតណ្ហា (ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦) ជាអ្នកបួសឥតផ្ទះសម្បែង តថាគតហៅបុគ្គលដែលមានតណ្ហានឹងភពអស់រលីងហើយនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងបឋមនដបុត្តកត្ថេរ*

(៣៥) បុគ្គលឯណាលះបង់ហើយនូវគ្រឿងប្រកបជារបស់មនុស្សទាំងពួង កន្លងហើយនូវគ្រឿងប្រកបដែលជាទិព្វ តថាគតហៅបុគ្គលដែលប្រាសចាកកិលេសទាំងពួងនោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

ទុតិយនដបុត្តកត្ថេរវត្ថុគាថា

(៣៦) ហិត្វា រតឹ អរតិញ្ច សីតិភូតំ និរូបធឹ
សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

វង្គីសត្ថេរវត្ថុគាថា

(៣៧) ចុតឹ យោ វេទិ សត្តានំ ឧប្បបត្តិញ្ច សព្វសោ
អសតំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

# ព្រាហ្មណវគ្គទី ១៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទុតិយទេវបុត្តកត្ថេរ*

(៣៦) បុគ្គលឯណាលះបង់ហើយនូវសេចក្ដីត្រេកអរក្នុងកាមគុណផង នូវសេចក្ដីត្រេកអរ (ក្នុងកិរិយានៅក្នុងព្រៃផង) តថាគតហៅបុគ្គលដែលមានចិត្តត្រជាក់គ្មានឧបក្កិលេស អ្នកគ្របសង្កត់ក្នុងខន្ធលោកទាំងពួង អ្នកមានព្យាយាមនោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងវង្គីសត្ថេរ*

(៣៧) បុគ្គលឯណាដឹងច្បាស់នូវកិរិយាច្យុតផង នូវកិរិយាកើតឡើងផង (នៃសត្វទាំងឡាយ) ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរគឺសេចក្ដីប្រតិបត្តិល្អ អ្នកត្រាស់ដឹង (នូវសច្ច៤) នោះថាជាព្រាហ្មណ៍ ។ ទេវតាទាំងឡាយក្តី គន្ធព្វនឹងពពួកមនុស្សទាំងឡាយក្តី មិនបានដឹងច្បាស់នូវគតិនៃបុគ្គលទាំងឡាយឯណា តថាគតហៅបុគ្គលអ្នកមានអាសវៈអស់ហើយជាព្រះអរហន្តនោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ តេវីសតិមោ ព្រាហ្មណវគ្គោ

ជម្ពុកត្ថេរវត្ថុគាថា

(៣៨) យស្ស បុរេ ច បច្ឆា ច
មជ្ឈេ ច នត្ថិ កិញ្ចនំ
អកិញ្ចនំ អនាទានំ
តមហំ ព្រូមិ ព្រាហ្មណំ ។

អង្គុលិមាលត្ថេរវត្ថុគាថា

(៣៩) ឧសភំ បវរំ វីរំ
មហេសឹ វិជិតាវិនំ
អនេជំ ន្ហាតកំ ពុទ្ធំ
តមហំ ព្រូមិ ព្រាហ្មណំ ។

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងធម្មទិន្នាត្ថេរី*

(៣៨) បុគ្គលឯណាមិនមានសេចក្ដីកង្វល់ក្នុងខន្ធដែលកន្លងទៅហើយផង ក្នុងខន្ធដែលនឹងមានមកខាងមុខផង ក្នុងខន្ធដែលមានសព្វថ្ងៃនេះផង តថាគតហៅបុគ្គលដែលមិនមានសេចក្ដីកង្វល់ មិនមានសេចក្ដីប្រកាន់នោះថាជាព្រាហ្មណ៍ ។

*គាថាក្នុងរឿងអង្គុលិមាលត្ថេរ*

(៣៩) តថាគតហៅបុគ្គលអ្នកដូចជាគោឧសភ អ្នកប្រសើរ អ្នកមានព្យាយាម អ្នកស្វែងរកនូវគុណដ៏ធំ អ្នកឈ្នះមារ អ្នកគ្មានកិលេសជាគ្រឿងញាប់ញ័រ អ្នកមានកិលេសបង្ហូរចេញហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះថាជាព្រាហ្មណ៍ ។

# ធម្មបទេ ឆវីសតិមោ ព្រាហ្មណវគ្គោ

នេះហ៊ត ព្រាហ្មណវគ្គគាថា

(៤១) បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ
តមហំ ព្រូមិ ព្រាហ្មណំ ។

ព្រាហ្មណវគ្គោ ឆវីសតិមោ សមត្តោ

ធម្មបទគាថា និដ្ឋិតា

# ព្រាហ្មណវគ្គទី ២៦ ក្នុងព្រះធម្មបទ

*គាថាក្នុងរឿងទេវហិតព្រាហ្មណ៍*

(៤០) បុគ្គលឯណាដឹងច្បាស់នូវខន្ធបញ្ចក ដែលខ្លួនអាស្រ័យនៅហើយក្នុងភពមុនផង ឃើញច្បាស់នូវស្ថានសួគ៌និងអបាយភូមិផង ម្យ៉ាងទៀតដល់ហើយនូវធម៌ជាគ្រឿងអស់ទៅនៃជាតិផង ដល់ហើយនូវធម៌សម្រេចព្រោះដឹងច្បាស់ដោយបញ្ញាផង ជាអ្នកប្រាជ្ញ (ផង) តថាគតហៅបុគ្គលដែលមានធម៌ជាទីបំផុតនៃកិលេសជាគ្រឿងសៅហ្មងទាំងពួងនៅហើយគឺប្រព្រឹត្តហើយនោះថាជាព្រាហ្មណ៍ ។

ព្រាហ្មណវគ្គ ទី ២៦ ចប់

គាថាព្រះធម្មបទ ចប់ហើយ

# ធម្មបទស្ស វគ្គស្សុទ្ទានំ

យមកំ បមាទំ ចិត្តំ    បុប្ផំ ពាលញ្ច បណ្ឌិតំ
អរហន្តំ សហស្សំ បាបំ    ទណ្ឌំ ជរា អត្ត លោកំ
ពុទ្ធំ សុខំ បិយំ កោធំ    មលំ ធម្មញ្ច មគ្គញ្ច
បកិណ្ណកំ និរយំ នាគំ    តណ្ហា ភិក្ខុ ច ព្រាហ្មណោ ។

# បញ្ជីវគ្គនៃធម្មបទ

(ក្នុងធម្មបទនេះមានវគ្គ ២៦ គឺ) យមកវគ្គ ១ បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ ។



រូបភាពផ្នែរទន្លេឥរវតី ប្រទេសភូមា មានវត្តអារាមជាច្រើន សាងតាំងពី ព.ស. ៩៥០
អ្នកស្រុកនេះបេះថែរក្សារបស់បូរាណទាំងនោះ ឲ្យគង់នៅដរាបដល់សព្វថ្ងៃនេះ ។

បើទុកជាមានមិត្រសម្លាញ់ ក៏ច្រើនបានតែមិត្រសម្លាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ។

៥ មនុស្សល្ងង់ បើជាអ្នករកស៊ីតាមធម្មតា ក៏មិនអាចនឹងធ្វើឲ្យបំរើនដូចអ្នកដែលមានប្រាជ្ញាចេះដឹងបានឡើយ ព្រោះខ្លួនមិនស្គាល់ទំនងនៃការរកស៊ី មានមិនស្គាល់កាលដែលគួរធ្វើនឹងមិនគួរធ្វើជាដើម ហើយទៅធ្វើឲ្យខុសទំនងខុសកាល ។

កាលបើដូច្នេះហើយ ធ្វើម្តេចការរកស៊ីនោះនឹងបំរើនឡើងបាន បើទុកជាធ្វើពានទៅត្រូវលើទំនងឬកាលដែលគួរធ្វើ ក៏មិនរួចពីសេចក្តីលំបាក ។

៦ មនុស្សល្ងង់ មិនដែលបានសេចក្តីសរសើរអំពីសំណាក់អ្នកប្រាជ្ញ អ្នកចេះដឹងណាមួយដល់ម្តងឡើយ បើបានសរសើរខ្លះតែអំពីសំណាក់មនុស្សដែលល្ងង់ជាងខ្លួន ។

ទោសនៃសេចក្តីល្ងង់ ដែលនាំយកមកអធិប្បាយក្នុងទីនេះជាសេចក្តីសង្ខេបខ្លី ដែលនៅមានតទៅទៀតជាសេចក្តីវែងឆ្ងាយទូលាយណាស់ ។

ទោសនៃសេចក្ដីល្ងង់នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះ នឹងមានទៅក្នុងលោកឯមុខទៀតជាអនេក តែមិនបាននាំយកមកអធិប្បាយក្នុងទីនេះទេ ។

### អានិសង្សនៃការចេះដឹង

ពាក្យថា "ចេះដឹង" នេះ ជាពាក្យជំទាស់គ្នាឬទីទៃពីគ្នានឹងពាក្យថា "ល្ងង់" កាលបើមិនល្ងង់ហៅថាចេះដឹង តែឥតចេះដឹងហៅថាល្ងង់ ។

បើមិនល្ងង់ក្នុងអក្សរក្នុងលេខឬក្នុងការអ្វី ៗ ឈ្មោះថាចេះដឹងក្នុងអក្សរក្នុងលេខឬក្នុងការនោះ ៗ សេចក្ដីចេះនេះបើនឹងហៅថា "បំណេះវិជ្ជា" ដូច្នេះវិញក៏បាន ។

មនុស្សមានបំណេះវិជ្ជា បើនឹងធ្វើការអ្វី ៗ ការនោះច្រើនកើតហើយបានល្អផង បើនឹងនិយាយពាក្យណា ពាក្យនោះច្រើនប្រាកដ បើគិតហេតុអ្វី ហេតុនោះរមែងចេញមកសម្ដែងឲ្យប្រាកដជាខុសឬត្រូវបាន ។

មនុស្សមានបំណេះវិជ្ជាឧបមាដូចមនុស្សភ្នែកភ្លឺ ធម្មតាមនុស្សភ្នែកភ្លឺ បើនឹងដើរតាមផ្លូវអាចដើរទៅបានដោយត្រង់ផងដោយរហ័សផង ព្រោះភ្នែកមើលឃើញផ្លូវប្រាកដ សេចក្ដីប្រាកដនេះឯងអាចធ្វើដំណើរឲ្យត្រង់តាមផ្លូវមិនឲ្យវិសវាសដូចគ្នានឹងមនុស្សមានបំណេះវិជ្ជា បើនឹងធ្វើឬនិយាយឬគិតក៏អាចស្រាវទាញយកគោលមកបញ្ជាក់ឲ្យប្រាកដក្នុងចិត្តបានសេចក្ដីប្រាកដនេះឯងអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសំរេចបាន ។

បំណេះវិជ្ជាគឺការចេះដឹងនេះ តែមាននៅក្នុងសន្ដានអ្នកណាហើយ រមែងធ្វើអ្នកនោះឲ្យបានដល់នូវអានិសង្ស គឺប្រយោជន៍, សេចក្ដីសុខ, សេចក្ដីចំរើន, នឹងសេចក្ដីថ្កុំថ្កើងតិចនឹងច្រើនតាមសមគួរដល់ការចេះដឹងតិចនឹងច្រើន តាំងពីក្នុងបច្ចុប្បន្ននេះដរាបដល់លោកខាងមុខ ។

ឯអានិសង្សនៃការចេះដឹង ដែលនឹងឃើញច្បាស់ក្នុងបច្ចុប្បន្ននេះដូច្នេះ :

១ បើចេះវិធីអក្សរគឺចេះសរសេរចេះមើលនឹងនាំឲ្យមានប្រយោជន៍ដូច្នេះ:

ក) អាចនឹងមើលសាស្ត្រាឬសៀវភៅដែលជាច្បាប់ប្រដៅជាហេតុនាំកើតគំនិតប្រាជ្ញា ។

ខ) អាចសរសេរសំបុត្រដោយខ្លួនឯង ឲ្យដំណឹងដល់ញាតិមិត្តដែលខ្លួនត្រូវការ ។

គ) សេចក្ដីកំបាំងឬការក្រដែលញាតិមិត្រផ្ញើសំបុត្រឲ្យដំណឹងមកបំពោះខ្លួន ក៏នឹងសំរេចប្រយោជន៍ទៅបាន ។

២ អ្នកដែលមានបំណេះវិជ្ជាផ្សេងៗ មានវិជ្ជាអក្សរជាដើម បើនៅធ្វើការក្នុងសំណាក់អ្នកធំដោយយកចិត្តទុកដាក់ អ្នកធំនោះលោកនឹងស្រឡាញ់រាប់អាន ហើយអាចនឹងទំនុកបំរុងឲ្យមានកេរ្តិ៍ឈ្មោះយសសក្ដិឡើងបាន ព្រោះលោកយល់ថាខ្លួនមានបំណេះវិជ្ជា ។

ឯចំណែកមនុស្សដែលមានបំណេះវិជ្ជានោះ ទោះបីមិនមានយសសក្ដិក្ដី ក៏គង់មិនធ្លាក់ខ្លួនទៅជាមនុស្សដុនដាបទាបថោកក្រីក្រពេកឡើយ ព្រោះបំណេះវិជ្ជាអាចនឹងប្រមូលមកនូវ

ទ្រព្យសម្បត្តិបាន សមដូចសុភាសិត ១ កន្លែងថា “ទ្រព្យសម្បត្តិមានមាសប្រាក់ជាដើម មិនប្រសើរស្មើនឹងទ្រព្យគឺបំណេះវិជ្ជាទេ ព្រោះទ្រព្យសម្បត្តិមានកាលក៏វិនាសទៅដោយអន្តរាយផ្សេងៗ មានចោរលួចជាដើម ឯបំណេះវិជ្ជាដែលមាននៅក្នុងខ្លួនហើយ ឥតមានចោរណានឹងលួចយកទៅបានឡើយ ។

ម្យ៉ាងទៀត “មិនគប្បីមើលងាយនូវបំណេះវិជ្ជាឬនូវសិល្បសាស្ត្រថាមានបន្តិចបន្តួចឡើយ បំណេះវិជ្ជានេះសូម្បីមានតែម្យ៉ាង កាលបើគេចេះស្ទាត់ប្រាកដហើយក៏ជាគ្រឿងចិញ្ចឹមជីវិតបាន” ។

៣ អ្នកមានបំណេះវិជ្ជា បើជាអ្នកមានយសសក្តិក៏នឹងមានសេចក្តីចំរើនរុងរឿង មិនតែក្នុងទីឯទៀតទេ សូម្បីក្នុងទីប្រជុំក៏ជាអ្នកមានរាសីមានដម្លៃច្រើន ព្រោះចេះរៀបចំធ្វើអាការឬកពារឲ្យសមគួរដល់ស្ថានរបស់ខ្លួន ឬនឹងពោលនិយាយឡើងក៏ត្រូវតាមទំនងច្បាប់នឹងទំនងធម៌ ម្លោះហើយអ្នកឯទៀតគេក៏ជឿស្តាប់នឹងកោតខ្លាច ដោយគេដឹងថាជាអ្នកមានបំណេះវិជ្ជា ។

វៀរលែងតែមនុស្សល្ងង់ទើបមិនជឿស្ដាប់ ព្រោះមនុស្ស ល្ងង់មិនសូវច្បាស់ការខុសត្រូវ មិនសូវស្គាល់ថាអ្នកណាជាអ្នក ចេះដឹង ជាអ្នកល្ងង់ ដឹងត្រឹមតែខ្លួនឯង សំគាល់ថាជាអ្នកចេះ ដឹងជាងគេ ។

៤ អ្នកមានចំណេះវិជ្ជា ជាមនុស្សសម្បូណ៌ដោយមិត្រ សម្លាញ់ ព្រោះអ្នកឯទៀតគេច្រើនត្រូវការអ្នកដែលមានចំណេះ វិជ្ជានោះធ្វើជាមិត្រសម្លាញ់ ។

ព្រោះហេតុអ្វី ? ព្រោះថាអ្នកមានចំណេះវិជ្ជាអាចធ្វើជាទី ពឹងដល់អ្នកដែលមានកិច្ចធុរៈ ហើយទៅពឹងរកឲ្យជួយធ្វើឬជួយ ពិគ្រោះប្រឹក្សាការអ្វីៗ បាន ។

៥ អ្នកមានចំណេះវិជ្ជា បើតាំងខ្លួនជាអ្នករកស៊ីតាម ធម្មតាវិញ ក៏មានសេចក្ដីចំរើនក្នុងការរកស៊ីនោះ ព្រោះជាអ្នក មានគំនិតចេះគិតស្គាល់ទំនងនៃការរកស៊ី មានស្គាល់កាល ដែលគួរធ្វើនឹងមិនគួរធ្វើជាដើម ហើយទៅប្រកបការរកស៊ីឲ្យ ត្រូវទំនង ត្រូវកាលដែលគួរធ្វើ ។

៦ អ្នកមានបំណេះវិជ្ជា រមែងបាននូវសេចក្ដីសរសើរអំពីសំណាក់អ្នកប្រាជ្ញអ្នកចេះដឹងរឿយ ៗ ។

អានិសង្សនៃការចេះដឹងដែលនាំយកមកអធិប្បាយក្នុងទីនេះជាសេចក្ដីសង្ខេបខ្លី ដែលនៅមានតទៅទៀតជាសេចក្ដីពិស្ដារ ។

អានិសង្សនៃការចេះដឹងនេះមិនមែនមានតែក្នុងបច្ចុប្បន្ននេះទេ នឹងមានទៅក្នុងលោកឯមុខទៀតដោយច្រើន តែមិនបាននាំយកមកអធិប្បាយក្នុងទីនេះទេ ។

ហេតុដូច្នេះ អស់លោកអ្នកទាំងឡាយគួរខ្ពើម គួរស្អប់សេចក្ដីល្ងង់ កុំបណ្ដោយចិត្តឲ្យសេចក្ដីល្ងង់ចូលមកលុកលុយពេញបន្ទុកបានឡើយ គួរតាំងសេចក្ដីព្យាយាមប្រឹងប្រែងស្វែងរកបំណេះវិជ្ជាគឺការចេះដឹងមកទុកដាក់ក្នុងខ្លួន ដើម្បីនឹងកំចាត់បង់នូវសេចក្ដីល្ងង់ចេញ ។

ឯសេចក្ដីល្ងង់ឧបមាដូចទីងងឹត បំណេះវិជ្ជាការចេះដឹងឧបមាដូចជាប្រទីបគឺចង្កៀងគោមដែលអុចមានពន្លឺភ្លឺឡើង បើប្រទីបនោះមាននៅក្នុងទីងងឹតត្រង់ណា ងងឹតត្រង់ទីនោះក៏ខ្លាត

ខ្ទាត់បាត់ទៅ បើប្រទីបនោះមានពន្លឺតិច ងងឹតដែលខ្ទាត់ចេញទៅក៏តិច បើប្រទីបមានពន្លឺច្រើន ងងឹតដែលខ្ទាត់ចេញទៅក៏ច្រើនដែរ ដូចគ្នានឹងបំណោះវិជ្ជា បើចេះដឹងតិច សេចក្ដីល្ងង់ក៏ថយចេញទៅតិច បើចេះដឹងល្មម សេចក្ដីល្ងង់ក៏ថយចេញទៅយ៉ាងល្មម បើចេះដឹងច្រើន សេចក្ដីល្ងង់ក៏ថយចេញទៅច្រើន ដូចជាព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ព្រះអង្គបានសំរេចនូវបំណោះវិជ្ជាដ៏ធំទូលាយបំផុត សេចក្ដីល្ងង់ក្នុងសន្ដានព្រះអង្គក៏ខ្ទាតខ្ទាត់ចេញឥតមានសល់ដល់តិចតួចឡើយ មានតែពន្លឺភ្លឺស្វាងដោយព្រះប្រាជ្ញា បានជាមានព្រះនាមថា "សព្វញ្ញូ" ប្រែថា ព្រះអង្គទ្រង់ជ្រាបសព្វ ។

## ការសំអាត

អស់លោកអ្នកទាំងឡាយ គួរឧស្សាហ៍សំអាតទីលំនៅ, សំអាតគ្រឿងប្រើប្រាស់, សំអាតគ្រឿងស្លៀកពាក់, សំអាតគ្រឿងផឹកនិងភោជន, សំអាតរូបកាយ ឲ្យស្អាតឲ្យផូរផង់ល្អ ។

ព្រោះហេតុកាលបើទីលំនៅជាដើមមិនស្អាតល្អហើយ នឹងជាហេតុនាំបណ្តាលឲ្យរូបកាយរបស់យើង ដែលអាស្រ័យនៅនឹងគ្រឿងមិនស្អាត មានរោគផ្សេង ៗ ។

កាលបើរូបកាយមានរោគហើយ ចិត្តដែលអាស្រ័យនៅខាងក្នុងរូបកាយ ធ្វើម្តេចនឹងប្រព្រឹត្តទៅដោយស្រួលបាន កាលបើចិត្តប្រព្រឹត្តទៅមិនស្រួលហើយ គំនិតប្រាជ្ញាដែលអាស្រ័យនៅនឹងចិត្ត ធ្វើម្តេចនឹងដុះដាលចំរើនភ្លឺស្វាងឡើងបាន កាលបើគំនិតប្រាជ្ញាមិនចំរើន មិនភ្លឺស្វាងហើយ ប្រយោជន៍ដែលយើងត្រូវការបង់បានក្នុងបច្ចុប្បន្ននេះនឹងលោកខាងមុខធ្វើម្តេចនឹងសំរេចប្រយោជន៍បាន ។

កាលបើយ៉ាងនេះ គួរតែចូលចិត្តថាបណ្តារោគទាំងអស់សុទ្ធតែជាគូសត្រូវ ឬជាមេចោរជាអ្នកបំផ្លាញនូវប្រយោជន៍នៃអស់យើងរាល់គ្នា ព្រោះសេចក្តីពិតថាអ្នកណាមួយទោះបីមានបុណ្យសក្តិក្តី មានទ្រព្យសម្បត្តិច្រើនក្តី មានប្រាជ្ញាច្រើនក្តី មានកំឡាំងច្រើនក្តី កាលបើរោគចូលមកអាស្រ័យនៅក្នុងរូបកាយបានហើយ បុណ្យសក្តិជាដើមរបស់អ្នកនោះក៏ត្រូវឡប់ទៅ

ជាឥតមានអានុភាពប្រើការមិនកើតទាំងអស់ ព្រោះបាល់ បាញ់អំណាចនៃរោគដែលចូលមកលុកលុយក្នុងរូបកាយ ។

ហេតុដូច្នេះ គួរតែយើងខំឧស្សាហ៍សំអាតទីលំនៅជាដើម ដើម្បីនឹងរារាំងបិទផ្លូវកុំឲ្យរោគកើតឡើងបាន ។

ពិតមែនជាមានពុទ្ធភាសិត ១ កន្លែងសម្ដែងថា "រូបំ រោគ-និទ្ធំ" រូបជាទីកប់នៅនៃរោគ ឬជាទីអាស្រ័យនៅនៃរោគ ។

ដែលព្រះអង្គសម្ដែងដូច្នេះចំពោះត្រង់កន្លែងដែលរោគចូលទៅអាស្រ័យនៅគឺរូបកាយ បើឥតរូបកាយក៏ឥតមានរោគ តែមានរូបកាយហើយក៏ឈ្មោះថាមានទីសំរាប់នៅនៃរោគ ។

ឯរោគសមុដ្ឋាន គឺហេតុដែលបណ្ដាលឲ្យរោគកើតឡើងនោះ ព្រះអង្គមិនបានសម្ដែងចំពោះត្រង់ពាក្យថា "រូបំ រោគ-និទ្ធំ" នេះទេ រោគសមុដ្ឋាននោះព្រះអង្គមានសម្ដែងទុកក្នុងសូត្រឯទៀតដោយប្រើនមានគិរិមានន្ទសូត្រជាដើម ។

ឯទីកន្លែងដែលលោកគ្រោកក៏រាប់ថាជាសមុដ្ឋាននៃរោគ មិនមែនមានតែក្នុងដំរានៃពេទ្យសព្វថ្ងៃនេះឡើយ ក្នុងពុទ្ធភា-សិតក៏មានសម្ដែងប្រាប់ថាឲ្យសំអាត ដើម្បីនឹងកំចាត់បង់នូវ

ោសមានពោគភ្អែកជាដើម ដូចសេចក្ដីដែលនឹងមានសម្ដែងទៅក្នុងខាងមុខ ។

ការសំអាតដែលយើងត្រូវធ្វើនោះដូច្នេះ :

១ ការសំអាតទីលំនៅ ត្រូវសំអាតទីខាងក្រោមផ្ទះឬទីខាងផ្ទះដោយជុំវិញ កុំឲ្យមានសំរាមនឹងភក់ជ្រាំ កុំឲ្យមានក្លិនស្អុយជាទីស្មោកគ្រោកឡើយ ។

ទីខាងក្នុងផ្ទះ ត្រូវបោសសំអាតកុំឲ្យមានសំរាមនឹងធូលីកុំឲ្យមានស្ដោះទឹកមាត់ឬខាកដាក់លើក្ដារក្រាល ឬក្នុងបន្ទោះក្ដារដែលបង្អៀត ឬក៏លើផ្ទៃដីឬឥដ្ឋខាងក្នុងផ្ទះ ត្រូវឲ្យស្ដោះដាក់តែក្នុងទីដែលគួរស្ដោះ ឬក្នុងប្រដាប់សំរាប់ស្ដោះមានកន្ថោរជាដើម ។

កុំឲ្យមានសំបុកពីងពាងឬមែ្រងភ្លើងព័ទ្ធព័ន្ធនៅជញ្ជាំងឬពិតានឬជម្រូលផ្ទះ ។

ទីកន្លែងសំរាប់អង្គុយឬសំរាប់អាស្រ័យដំណេក ត្រូវបោសនឹងជូតសំអាតឲ្យស្អាត ។

គ្រឿងដេកគឺគ្រែនឹងកំរាល ត្រូវឧស្សាហ៍គោះជូតសំអាត កុំឲ្យមានធង់ធូលីជាប់ប្រឡាក់ កំរាលដេកនឹងស្រោមខ្នើយ ក៏ត្រូវបោកគក់ដុសលាងឲ្យរឿយៗ កុំឲ្យជាប់ប្រឡាក់ដោយញើសក្អែល ។

២ ការសំអាតគ្រឿងប្រើប្រាស់ក្នុងផ្ទះ របស់សំរាប់ប្រើប្រាស់មានតុនឹងកៅអីជាដើម ត្រូវឧស្សាហ៍ជូតសំអាតកុំឲ្យមានធូលីរុំឡើយ ។

បើមានកន្ថោរសំរាប់ស្ដោះទឹកមាត់ ត្រូវសំអាតកុំឲ្យដក់ទឹកមាត់ឬជាប់ប្រឡាក់កាត់ទឹកក្រោះក្នុងកន្ថោរនោះ ព្រោះទឹកមាត់តែហួសវេលានឹងមានក្លិនអាក្រក់ ។

គ្រឿងប្រដាប់សំរាប់ដាក់គ្រឿងផឹក មានបានពែងនឹងផ្តិល ឬកែវទឹកជាដើម ត្រូវរកសំពត់ដែលស្អាតល្អសំរាប់ជូតកុំយកសំពត់ឬកន្សែងដែលសំរាប់ជូតមុខជូតដៃឬជូតញើសទៅជូតគ្រឿងប្រដាប់ផឹកនោះឡើយ ។

គ្រឿងប្រដាប់សំរាប់ដាក់ភោជនាហារមានបាននឹងស្លាបព្រាជាដើម ក៏ត្រូវសំអាតដូចគ្នា ។

៣ ការសំអាតគ្រឿងផឹកនឹងភោជន ទឹកដែលសំរាប់ផឹកត្រូវសំអាតគឺត្រងកុំឲ្យមានផង់ធូលី បើដាក់ទឹកផឹកនឹងអ្វីត្រូវឲ្យមានគ្របបិទឲ្យជិត ត្រូវដំកល់ទុកដោយឡែកផ្សេងអំពីទឹកសំរាប់ងូតសំរាប់លាង ។

គ្រឿងភោជនមានបាយសំឡជាដើមក៏ត្រូវសំអាតដូចគ្នា បើដាក់បាយសំឡឬម្ហូបអ្វីៗ នឹងភាជន៍ ត្រូវឲ្យមានគ្របបិទឲ្យជិតកុំឲ្យសត្វល្អិតមានរុយជាដើមចូលបានឡើយ ។

៤ ការសំអាតគ្រឿងស្លៀកពាក់ គ្រឿងស្លៀកពាក់ទាំងអស់ មានសំពត់ ខោនឹងអាវជាដើម ត្រូវឧស្សាហ៍បោកគក់ដុសលាងឲ្យរឿយៗ កុំឲ្យប្រឡាក់ដោយញើសក្អែលនឹងធូលីឬកុំឲ្យមានក្លិនស្អុះស្អាបជូរផ្អូមឡើយ ព្រោះគ្រឿងស្លៀកពាក់កាលបើមិនស្អាតហើយ ជាហេតុនាំឲ្យស្អុះស្អាប់ឲ្យស្នៀបរមាស់បណ្ដាលឲ្យកើតរោគមានកមរមាស់ជាដើម ។

៥ ការសំអាតរូបកាយ រូបកាយបើប្រឡាក់ដោយញើសក្អែលត្រូវងូតទឹកជំរះដុសលាងឲ្យស្អាត វៀរលែងតែក្នុងពេលដែលកំពុងធ្វើការងារ ។

វេលាចូលទៅក្នុងទីកន្លែងត្រូវលាងជើងជូតឲ្យស្អាតហើយសឹមចូលទៅ វៀរលែងតែជើងស្អាតស្រាប់ ។

បើសក់ដុះវែងត្រូវកាត់កោរបេញ ។

បើក្រចកដៃ - ជើងដុះវែងត្រូវកាត់ចេញឲ្យស្អាត ឲ្យស្មើត្រឹមនឹងសាច់ ។

វេលាបរិភោគរួចហើយ ត្រូវសំអាតមាត់នឹងធ្មេញឲ្យស្អាត គឺយកឈើសម្រាប់ចាក់ធ្មេញមកចាក់កកាយយកចេញនូវកំទេចបាយឬត្រីសាច់ដែលចូលទៅជាប់ជ្រៀតជ្រែកតាមចន្លោះកៀនធ្មេញកុំឲ្យសល់នៅ រួចដុសលាងដោយប្រាសឲ្យស្អាតល្អ ដើម្បីនឹងរក្សាធ្មេញកុំឲ្យមានរោគមានដង្កូវស៊ីជាដើមផង កុំឲ្យមានក្លិនស្អុយផ្សាយចេញពីមាត់ផង ឯធ្មេញនេះក្រៅពីពេលបរិភោគអាហារ មានពេលកំណត់ឲ្យដុសលាងសំអាត ពីរដង គឺពេលរៀបអាស្រ័យដំណេកក្នុងវេលាយប់ម្តង ពេលក្រោកពីដេកម្តង ។

ការសំអាតមានប៉ុណ្ណោះជាដើម កាលបើបានប្រព្រឹត្តធ្វើហើយនឹងនាំឲ្យមានអានិសង្សដូច្នេះ :

១ នឹងមានកំហាត់បង់នូវរោគផ្សេង ៗ

២ នឹងមានគំនិតប្រាជ្ញាភ្លឺថ្លាល្អ

សេចក្ដីដែលពណ៌នាអំពីការសំអាតដូចខាងលើនេះ មិនមែនមានតែក្នុងតម្រារឿងសំអាតក្នុងបច្ចុប្បន្ននេះឡើយ ច្បាប់នេះព្រះពុទ្ធសាសនាក៏មានសម្ដែងទុកមកដោយច្រើន ។

ក្នុងគម្ពីរវិន័យបិដក ប៉ែកខាងខន្ធកវិន័យ មានសេចក្ដីជាពុទ្ធបញ្ញត្តិនឹងពុទ្ធានុញ្ញាតមានដូច្នេះជាដើម ឲ្យបោសសំអាតទីសេនាសនកុំឲ្យមានសំបុកពីងពាងនឹងម្រែងភ្លើងជាដើម ។

កុំឲ្យទុកសក់វែង ។

កុំឲ្យទុកក្រចកវែង ។

កុំឲ្យស្ដោះទឹកមាត់ដាក់ក្នុងទីដែលគេសំអាត ។

ត្រូវលាងជើងជូតឲ្យស្អាតសិមជាន់លើកំរាល ។

ម្យ៉ាងទៀត ព្រះអង្គសម្ដែងថាអ្នកដែលមិនសំអាតធ្មេញនឹងត្រូវបាននូវទោស ៥ យ៉ាង គឺៈ ១- កើតរោគក្នុងភ្នែក ២- ស្អុយមាត់ ៣- សរសៃសំរាប់ទទួលរសអាហារមិនស្អាតល្អ ៤- ប្រមាត់នឹងស្លេស្មមិនឱបក្រសោបអាហារដែលបរិភោគទៅ

៥- នាំបណ្ដាលឲ្យឆ្អែមឬមិនឲ្យឃ្លានអាហារបរិភោគមិនស្ងវ បាន ។

អ្នកដែលសំអាតធ្មេញ នឹងត្រូវបាននូវអានិសង្ស ៥ យ៉ាង គឺ ១- មានភ្នែកភ្លឺស្រឡះល្អ ២- មិនស្អុយមាត់ ៣- សរសៃសំរាប់ទទួលរសអាហារស្អាតល្អ ៤- ប្រមាត់នឹងស្លេស្មទទួលឧបក្រសោហបអាហារដែលបរិភោគទៅ ៥- នាំបណ្ដាលឲ្យឃ្លានចូលចិត្តចង់បរិភោគអាហារ ។

ម្យ៉ាងទៀត ក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់សមាធិនិទ្ទេស មានសេចក្ដីសំដែងអំពីអប្បនាកោសល្ល ១០ យ៉ាង ត្រង់អប្បនាកោសល្លទី ១ ឈ្មោះ "វត្ថុវិសទកិរិយា" សេចក្ដីថា ធ្វើវត្ថុខាងក្នុងនឹងខាងក្រៅឲ្យស្អាត ។

ធ្វើវត្ថុខាងក្នុងឲ្យស្អាតគឺធ្វើរូបកាយឲ្យស្អាត មានកាត់ក្រចក កោរសក់ នឹងជំរះជុសលាងខ្លួនមិនឲ្យមានញើសនឹងក្អែលជាដើម ។

ធ្វើវត្ថុខាងក្រៅឲ្យស្អាត គឺសំអាតគ្រឿងស្លៀកពាក់នឹងទីដេកទីអង្គុយជាដើមឲ្យស្អាតបាត ។

កាលបើវត្ថុខាងក្នុងនិងខាងក្រៅស្អាតល្អហើយ ៗ ទៅ អង្គុយចំរើនព្រះកម្មដ្ឋាន ចិត្តនឹងចេតសិកក៏ប្រព្រឹត្តទៅដោយស្រួល កាលបើចិត្តនឹងចេតសិកស្រួលហើយ ញាណគឺប្រាជ្ញដែលអាស្រ័យនៅនឹងចិត្តក៏ភ្លឺស្វាងរុងរឿងល្អ ឧបមាដូចជាពន្លឺប្រទីបគឺចង្កៀងគោម កាលបើតួប្រទីបស្អាត ប្រេងក៏ល្អ ប្រឆេះក៏ល្អ លំផ្លូងក៏ស្អាតល្អ ពន្លឺប្រទីបនោះក៏ភ្លឺរុងរឿងឡើងបាន ។

កាលបើវត្ថុខាងក្នុងនឹងខាងក្រៅមិនស្អាតល្អហើយ ញាណគឺប្រាជ្ញាក៏មិនភ្លឺស្វាងរុងរឿងឡើងបាន ដូចជាពន្លឺប្រទីប កាលបើតួប្រទីបជាដើមមិនស្អាតល្អហើយ ពន្លឺនោះក៏មិនភ្លឺស្វាងរុងរឿងឡើងបាន ។

ការសំអាតដែលមានក្នុងច្បាប់ព្រះពុទ្ធសាសនាច្រើនប្រការណាស់ តែដែលនាំយកមកអធិប្បាយក្នុងទីនេះជាសេចក្ដីសង្ខេប ។

សូមអស់លោកអ្នកទាំងឡាយ ឧស្សាហ៍សំអាតដូចសេចក្ដីខាងលើនេះ នឹងបានត្រូវតាមគម្រាក្នុងបច្ចុប្បន្ននេះផង ត្រូវ

តាមច្បាប់ក្នុងព្រះពុទ្ធសាសនាផង មិនគ្រាន់តែបានត្រឹមប៉ុណ្ណោះឡើយ នឹងបានទាំងប្រយោជន៍ផ្សេងៗផង មានកំចាត់បង់នូវរោគចេញអំពីកាយជាដើម កាលបើរាងកាយឥតមានរោគហើយ ឈ្មោះថាបាននូវលាភដ៏ឧត្តមសមដូចពុទ្ធភាសិតថា (អារោគ្យបរមាលាភា) មានលាភអ្វីក៏មិនឧត្តមស្មើនឹងគ្មានរោគ ។ បានសេចក្ដីថា អ្នកដែលឥតរោគ អាចនឹងទទួលនូវលាភគ្រប់យ៉ាងបាន ឯអ្នកដែលមានរោគសូម្បីលាភឯណាមួយកើតចំពោះខ្លួន ក៏មិនអាចនឹងទទួលយកបាន បើទុកជាទទួលយកមកបាន ក៏ហៅតែនឹងបាន នឹងអាចសោយសេចក្ដីសុខព្រោះលាភនោះពុំបានឡើយ ព្រោះខ្លួនអ្នកមានរោគរកសេចក្ដីសុខគ្មាន ។

សេចក្ដីទាំងប៉ុន្មាន ដែលបាននាំយកមកអធិប្បាយក្នុងខាងលើនេះ ជាសេចក្ដីសង្ខេបគ្រប់អន្លើទាំងអស់ព្រោះមិនមានពេលល្មមនឹងអធិប្បាយឲ្យពិស្ដារទៅបាន ក៏សម្មតិថាចប់តែប៉ុណ្ណោះហោង ។ ៙—

## ២– រឿងមនុស្សឆោត ៤ នាក់

កាលនោះមានមនុស្សឆោត ៤ នាក់ ព្រមព្រៀងបបួលគ្នាដើររករៀនក្តី លុះដើរបន្តិចទៅប្រទះចាប់បានអណ្តើក ៥ បុរសទាំង ៤ នាក់នោះក៏យកអណ្តើកនោះមកចែកគ្នា ដល់ចែកទៅចែកមកនៅសល់អណ្តើក ១ មនុស្សទាំងអស់នោះមិនសុខចិត្តតែរៀងខ្លួន ក៏តាំងចែកគ្នាម្តងទៀត ចែកទៅចែកមកនៅសល់អណ្តើក ១ ដដែល មិនដឹងនឹងគិតធ្វើដូចម្តេច បុរសទាំង ៤ នាក់នោះក៏ទាល់គំនិតនៅអង្គុយមើលមុខគ្នាធ្វើភ្នែកឡឹងឡង់ ក្នុងវេលានោះមានបុរសម្នាក់ទៀតដើរទៅក៏ប្រទះនឹងមនុស្ស ៤ នាក់នោះ ក៏ឈរមើលមនុស្ស ៤ នាក់នោះចែកអណ្តើកគ្នា ហើយបុរសម្នាក់នោះឃើញឆោតយ៉ាងនេះ សើចហើយស្រដីទៅនឹងបុរស ៤ នាក់ថា មើលទៅអ្នកដូចជាមិនសូវប្រសប់សោះ បុរស ៤ នាក់គ្រាន់តែឮសំដីប៉ុណ្ណោះ ក៏និយាយថា ឱលោក បើលោកចេះ មេត្តាអាណិតមកចែកឲ្យយើងបន្តិច

បុរសម្នាក់នោះឮដូច្នោះហើយ ក៏ដើរចូលទៅអង្គុយហើយ ក៏ចាប់យកអណ្ដើក ៥ នោះមកហើយ រើសមើលអណ្ដើកណាដែលធំជាងគេយកមកទ្រាប់អង្គុយ ហើយនៅសល់អណ្ដើក ៤ ក៏បែកឲ្យទៅបុរស ៤ នាក់នោះអណ្ដើក ១ ម្នាក់ បុរស ៤ នាក់ក៏សុខចិត្តរៀងខ្លួន ហើយបុរស ៤ នាក់នោះក៏មានវាចាថា អ្នកមើលទៅប្រហែលជាចេះក្ដី បុរសនោះឆ្លើយឡើងថាខ្ញុំចេះ ថាឱអ្នកអើយ បើអ្នកចេះអ្នកមេត្តាប្រាប់យើងខ្ញុំផង បុរសម្នាក់ឆ្លើយថា បើអ្នកចូលចិត្តចង់ឲ្យខ្ញុំប្រាប់ តោងតែអ្នករៀនទន្ទេញតាមខ្ញុំ បុរស ៤ នាក់ឆ្លើយថា បាទ ហើយបុរសនោះប្រាប់ទៅអ្នក ៤ នាក់នោះឲ្យទន្ទេញរៀងខ្លួន ។

ប្រាប់ទៅបុរសទី ១ ថា ទំពក់វាទៅ ទើបញៀវជ្រុះ ។

- បុរសទី ២ ថា មានប្រឡាយ ទើបទឹកហូរ ។
- បុរសទី ៣ ថា មានសម្រាម ទើបឆ្កែវាជុះ ។
- បុរសទី ៤ ថា មែន ទើបគេថា ។

បុរស ៤ នាក់ក៏ទន្ទេញពាក្យនេះគ្រប់គ្នាទៅ ។

បុរស ៤ នាក់នាំគ្នាទៅឆ្ងាយទៅៗបានទៅដល់ភូមិ ១ នឹងរកផ្ទះសំបែងអ្វីនឹងសំណាក់ក៏គ្មាន លុះបន្តិចទៅៗ ប្រទះនឹងយាយចាស់ម្នាក់មេម៉ាយ ក៏និយាយសុំផ្ទះយាយចាស់នោះសំណាក់ គាត់ក៏ព្រមឲ្យ ហើយបុរសនោះនាំគ្នាទាំង ៤ នាក់ទៅនៅសំណាក់នៅផ្ទះយាយនោះ យប់នោះក៏តាំងទន្ទេញពាក្យក្ដីដែលបុរសម្នាក់នោះប្រាប់ ទន្ទេញមិនឈប់ឈរទាល់តែភ្លឺ យាយចាស់ខឹងណាស់ លុះព្រឹកឡើងគាត់ទៅប្ដឹងមេស្រុក ថាលោកមេស្រុក យប់មិញនេះមានមនុស្ស ៤ នាក់មកសុំផ្ទះខ្ញុំសំណាក់ បុរសទាំងនោះចេះតែនិយាយទន្ទេញទាល់តែភ្លឺ តែមិនដឹងថាជាពាក្យដូចម្ដេចរកស្ដាប់ពុំបានសោះ ខ្ញុំខានដេកព្រួនវាល់ព្រឹក ហេតុនេះខ្ញុំមកប្ដឹងលោក សូមលោកហៅមនុស្សទាំង ៤ នាក់នោះមកជំនុំជំរះឲ្យខ្ញុំ មេស្រុកបានស្ដាប់ហើយក៏ឲ្យបម្រើទៅហៅបុរសទាំង ៤ នោះមក រួចតាំងសួរទៅបុរសនោះថាហេតុដូចម្ដេចបានជាឯងទន្ទេញអ្វីទាល់តែភ្លឺ រកយាយចាស់គាត់ដេកព្រួនមិនបាន តើដែលឯងទន្ទេញនោះពាក្យដូចម្ដេច

ប្រយោជន៍អ្វី បុរសទាំង ៤ នាក់ឆ្លើយថា ខ្ញុំទន្ទេញពាក្យក្តី មេស្រុកបង្គាប់ទៅទៀតថា ឯងរាល់គ្នាស្លូតម្តងម្នាក់ទៅមើលអញនឹងស្តាប់ ។

បុរសទី ១ ថា ទំពក់វាទៅទើបញៀវាមក ។

បុរសទី ២ ថា មានសម្រាមទើបឆ្កៀវាជុះ ។

បុរសទី ៣ ថា មានប្រទ្បាយទើបទឹកវាហូរ ។

បុរសទី ៤ ថា មែនទើបគេថា ។

ថាតែប៉ុណ្ណោះហើយ មេស្រុកកាត់សេចក្តីថា ឯងទាំង ៤ នាក់ត្រូវទៅនៅធ្វើខ្ញុំបម្រើយាយចាស់នេះ បុរសអស់នោះក៏ទៅនៅជាខ្ញុំយាយចាស់នោះទៅ យាយនោះក៏គាត់ប្រើធ្វើការសព្វសារពើតែរាល់ថ្ងៃ ។

លុះនៅនឹងយាយនោះបាន ២-៣ ខែ យាយគាត់តាំងប្រើអាទាំង ៤ នាក់នោះឲ្យទៅរកកាប់ឈើធ្វើទូក អាទាំង ៤ ក៏នាំគ្នាដើរទៅចូលក្នុងព្រៃធំ ហើយដើរទៅរកឈើឯណាប្រហោងទើបកាប់ ដល់ចូលទៅក្នុងព្រៃជ្រៅទៅប្រទះឃើញឈើ ១ ដើម

ធំហើយប្រហោងផង បុរសទាំង ៤ នាក់និយាយគ្នាថា យើងបាន ប្រទះឈើប្រហោងហើយយើងនាំគ្នាកាប់ឈើនេះ បុរសទាំង ៤ មូលមាត់គ្នាក៏តាំងកាប់រំលំឈើប្រហោងនោះ លុះបន្តិចទៅឈើ បង់រលំ អាទាំង ៤ នាក់ស្រែកថា កនយើងឈើជិតរលំហើយ អាណាមករត់ទៅចាំទ្រកុំឲ្យបែកឈើយើងក្រែងធ្វើទូកមិនកើត អាម្នាក់ក៏ស្ទុះទៅចាំទ្រ ដល់ឈើនោះបាក់មកសង្កត់ស្លាប់ធ្វើ មាត់ស្រិញ អាទាំង ៣ នាក់ឃើញដូច្នោះហើយនាំគ្នាសើចថា យើអានេះខ្លាំងណាស់រ៉ុយ ឈើទំហំប៉ុណ្ណឹងវាទ្រហើយវាសើច ថែមទៀត អា ៣ នាក់នាំគ្នាចាំមើលអាម្នាក់ដែលស្លាប់ ដល់ យូរពេកក៏ស្រែកហៅថា លីមកឆាប់ឡើងនឹងអាលទៅ ឃ្លាន បាយណាស់ ដល់ឃើញនៅស្ងៀមតាំងនាំគ្នាដើរចូលទៅ មើល លុះដឹងថាអាម្នាក់នោះស្លាប់ហើយ អា ៣ នាក់ក៏ភ័យ ណាស់តាំងនិយាយគ្នាថា យើងនៅមិនបានទេ តែយើងនៅ មុខជាគេប្តឹងថាយើងវាយអានេះសម្លាប់ហើយ បើដូច្នេះយើង នាំគ្នារត់ ព្រមព្រៀងគ្នាក៏រត់ទៅ ដល់ពេលយប់វង្វេងមិន

វត់ទៅឯណា ទៅត្រង់កំពង់ផ្ទះយាយ ហើយនាំគ្នាលួចទូក យាយនោះនឹងអុមទៅត្រើយម្ខាង អាទាំង ៣ នាក់នាំគ្នាចុះទូក អាម្នាក់នៅខាងកន្សៃបែរមុខទៅខាងកន្សៃ អានៅខាងក្បាល ក៏បែរមុខទៅខាងក្បាល អាម្នាក់ទៀតនៅអង្គុយកណ្ដាលបាច ទឹកទូក តែទូកនោះមិនបានស្រាយខ្សែបំណងចេញ តាំង នាំគ្នាអុម ១ យប់ទាល់ភ្លឺនៅដដែល លុះភ្លឺស្រាងឡើង យាយ ចាស់ចុះទៅដងទឹកប្រទះអា ៣ នាក់ហើយស្រែកថា យើអា នេះវត់ទៅណា អាទាំង ៣ នាក់ក្រឡេកទៅឃើញយាយចាស់ ជាចៅហ្វាយខ្លួនក៏ទាល់មិនដឹងបើរត់ទៅណា ក៏ទៅនៅបម្រើ យាយចាស់វិញទៅ ។